Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

របាយការណ៍ប្រចាំប្រទេសរបស់ធនាគារពិភពលោក

# តើប្រជាពលរដ្ឋក្រីក្រទៅទីណាអស់ហើយ ?
# ការវាយតម្លៃភាពក្រីក្រឆ្នាំ២០១៣



ធនាគារពិភពលោក

ខែ វិច្ឆិកា ឆ្នាំ ២០១៣

**រូបិយប័ណ្ណ និងអត្រាប្តូរប្រាក់សមមូល**
រូបិយប័ណ្ណ = ប្រាក់រៀល

អត្រាប្តូរប្រាក់ជាមធ្យមឆ្នាំ២០០៤៖ ១ ដុល្លារ(អាមេរិក) = ៣.៩០៦ រៀល
អត្រាប្តូរប្រាក់ជាមធ្យមឆ្នាំ២០១១៖ ១ ដុល្លារ(អាមេរិក) = ៤.០៦៦ រៀល
អត្រាប្តូរប្រាក់ ថ្ងៃ១៩ ខែមេសា ឆ្នាំ២០១៣៖ ១ ដុល្លារ(អាមេរិក) = ៣.៩៩៥ រៀល

**ឆ្នាំសារពើពន្ធ**
ថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ


នាយកប្រចាំតំបន់អាស៊ី ៖ អាក់សែ៊ល វ៉ាន់ ត្រូសេនប៊ើក (Axel van Trotsenburg)
នាយកប្រចាំប្រទេស ៖ អាណែ្ណត ឌីសុន (Annette Dixon) ត្រឹមខែកក្កដាឆ្នាំ២០១៣ និង
អ៊ូលរិក ហ្សាចៅ (Ulrich Zachau) ចាប់ពីខែតុលាឆ្នាំ២០១៣
នាយកផ្នែកសេដ្ឋកិច្ច ៖ ស៊ូឌៀរ ស្ទិធី (Sudhir Shetty)
ប្រធានគ្រប់គ្រងប្រចាំប្រទេស ៖ អាឡាសាន សូ (Alassane Sow)
ប្រធានផ្នែកសេដ្ឋកិច្ច ៖ ម៉ាធ្យូ វើហ្គីស (Mathew Verghis)
ប្រធានក្រុមការងារ ៖ កាឡូស សូប្រាដូ (Carlos Sobrado)
សហប្រធានក្រុមការងារ ៖ នាក់ សមសែន (Neak Samsen)

# តើប្រជាពលរដ្ឋក្រីក្រទៅទីណាអស់ហើយ ?
# ការវាយតម្លៃភាពក្រីក្រឆ្នាំ២០១៣

ធនាគារពិភពលោក
វ៉ាស៊ីនតោន ឌី.ស៊ី.

# តារាងមាតិកា


**សេចក្តីថ្លែងអំណរគុណ** ........ **IX**

**អារម្ភកថា** ........ **XI**

**ខ្លឹមសារសង្ខេប** ........ **XV**

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ........ XVI

ការចំណាយលើការប្រើប្រាស់ សុខុមាលភាព វិសមភាព និងភាពក្រីក្រ ........ XVI

កត្តាសំខាន់ៗដែលជួយកាត់បន្ថយភាពក្រីក្រ ........ XX

លើកកម្ពស់ការអភិវឌ្ឍមនុស្ស ........ XXI

មេរៀននានាដែលមានកន្លងមក ........ XXIII

អនុសាសន៍គោលនយោបាយសំខាន់ៗ ........ XXV

**ជំពូកទី ១៖ តើមានរឿងអ្វីកើតឡើងចំពោះប្រជាពលរដ្ឋក្រីក្រ ?** ........ **1**

**លក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ច** ........ 1

**ភាពក្រីក្រ និងសុខុមាលភាព** ........ 5

អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា(អ.ស.ស.ក) ........ 6

ការវាស់វែងភាពក្រីក្រនៅកម្ពុជា ........ 7

កម្រិតនិងនិន្នាការនៃភាពក្រីក្រនៅកម្ពុជា ........ 9

សូចនាករវាស់វែងកម្រិតជីវភាពពលរដ្ឋផ្សេងៗទៀត ........ 11

ស្ថានភាពផ្ទះសម្បែង និងរបស់របរប្រើប្រាស់ក្នុងផ្ទះ ........ 14

វិសមភាពនៃការចំណាយរបស់ប្រជាពលរដ្ឋម្នាក់ៗ និងកំណើននៃការចំណាយ ........ 15

ភាពងាយរងគ្រោះ ........ 18

ចរិតលក្ខណៈគ្រួសារប្រជាពលរដ្ឋក្រីក្រ ........ 20

**ជំពូកទី ២៖ ប្រភពចំណូលផ្សេងៗរបស់ប្រជាពលរដ្ឋ ..... 27**
**ការវិវត្តការងារនៅតាមទីប្រជុំជន ..... 27**
ទំនោរទីផ្សារការងារនិងតួនាទីរបស់វាក្នុងការកាត់បន្ថយភាពក្រីក្រ ..... 27
សមាសភាពនៃការងារ៖ តួនាទីយេនឌ័រ ការសិក្សាអប់រំ និងការងារប្រសើរជាងមុន ..... 30
វិស័យវាយនភ័ណ្ឌ ..... 35
អនុសាសន៍ពាក់ព័ន្ធនឹងគោលនយោបាយនានា ..... 38
**តួនាទីនៃសេដ្ឋកិច្ចជនបទ ..... 39**
ប្រជាពលរដ្ឋនៅតាមទីជនបទ ..... 39
ការវិវត្តនៃភាពក្រីក្រជនបទពីឆ្នាំ២០០៤ ដល់ ឆ្នាំ២០១១ ..... 40
ចំណាយលើការប្រើប្រាស់ ..... 42
ស្ថានភាពលំនៅដ្ឋាន និងរបស់របរនៅតាមទីជនបទ ..... 42
ចំណូលរបស់ប្រជាពលរដ្ឋ ..... 43
ចំណូលដែលមានប្រភពពីកសិផល ..... 43
ចំណូលដែលមានប្រភពពីការលក់កម្លាំងពលកម្ម ..... 46
ចំណូលដែលមានប្រភពពីការប្រកបមុខរបរដោយខ្លួនឯង ..... 48
ចំណូលដែលមានប្រភពពីប្រាក់ឧបត្ថម្ភផ្សេងៗ ..... 49
ទស្សនៈផ្សេងៗរបស់ប្រជាពលរដ្ឋនៅតាមទីជនបទ ..... 49
ស្ថានភាពនៃវិស័យស្រូវអង្ករ ..... 50
គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ..... 50
បញ្ហាដែលនៅសេសសល់ ..... 51
កត្តាសំខាន់ៗនៃការកាត់បន្ថយភាពក្រីក្រ ..... 52
គ្រួសារដែលរស់នៅតាមទីប្រជុំជនក្នុងអំឡុងឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧ ..... 54
ចំណូលរបស់ក្រុមគ្រួសារពលរដ្ឋនៅតាមទីជនបទ ពីឆ្នាំ២០០៤ ទៅឆ្នាំ២០០៩ ..... 54
កត្តាចម្បងៗក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ ..... 55
អនុសាសន៍នានាពាក់ព័ន្ធនឹងគោលនយោបាយ ..... 56

**ជំពូកទី ៣៖ ផ្តោតការយកចិត្តទុកដាក់បន្ថែម ចំពោះជនក្រីក្រនិងជនងាយរងគ្រោះ ..... 59**
**វិស័យអប់រំ ..... 59**
សាវតារនៃវិស័យអប់រំ ..... 59
វិស័យអប់រំឯកជននៅកម្ពុជា ..... 61
លទ្ធផលនៃការអប់រំ ..... 61
លក្ខណៈនៃការអប់រំ ..... 69
គុណភាពនិងថវិកានៃការអប់រំ ..... 73
អនុសាសន៍គោលនយោបាយ ..... 75
**សុខភាព ..... 76**
មរណកុមារ ..... 80
សមភាពក្នុងការផ្តល់ និងការប្រើប្រាស់សេវាកម្មសុខភាព ..... 83
សមភាពនៃការចំណាយលើសុខភាព ..... 85
អាហារបំប៉នម្តាយ និងកុមារ ..... 90
សេចក្តីសន្និដ្ឋាន និងអនុសាសន៍គោលនយោបាយ ..... 92

**ឧបសម្ព័ន្ធ ១៖ សូចនាករប៉ាន់ស្មានថ្មី នៃភាពក្រីក្រនៅកម្ពុជា ក្នុងឆ្នាំ២០០៩ ..... 97**
អញ្ញាតថ្មីនៃចំណាយលើការប្រើប្រាស់សរុប ..... 97
បន្ទាត់ភាពក្រីក្រថ្មី ..... 105
លទ្ធផលនៃការវិភាគភាពក្រីក្រឆ្នាំ២០០៩ ..... 112

**ឧបសម្ព័ន្ធ ២៖ សូចនាករប៉ាន់ស្មានថ្មីនៃភាពក្រីក្រ ចេញដោយរដ្ឋាភិបាល និងធនាគារពិភពលោក សម្រាប់ឆ្នាំ ២០០៤-២០១១ ..... 123**
អាត្រាភាពក្រីក្ររួម ..... 123
ការចំណាយលើការប្រើប្រាស់ និងបន្ទាត់ភាពក្រីក្រ ..... 124
ការប្រៀបធៀបអត្រាភាពក្រីក្រថ្មី ចេញដោយរាជរដ្ឋាភិបាល និងធនាគារពិភពលោក ..... 127

**ឧបសម្ព័ន្ធ ៣៖ និម្មិតកម្មនៃកត្តាជំរុញដល់ការកាត់បន្ថយភាពក្រីក្រ ..... 129**
ឆ្នាំ២០០៧-២០០៩ ..... 129
ឆ្នាំ២០០៤-២០០៧ ..... 130
ឆ្នាំ២០០៤-២០០៩ ..... 131

**ឯកសារយោង ..... 133**

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះចងក្រងសម្រេចទៅបានដោយមានកិច្ចសហប្រតិបត្តិការពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា អង្គការអភិវឌ្ឍន៍នានា ព្រមទាំងមានការជួយជ្រោមជ្រែង និងកិច្ចខិតខំប្រឹងប្រែងពីសំណាក់សហការីជាច្រើននៃធនាគារពិភពលោក។

របាយការណ៍នេះចងក្រងដោយអ្នកនិពន្ធមួយក្រុម ក្រោមការដឹកនាំរបស់លោក កាឡូស សូប្រាដូ (Carlos Sobrado) និងលោក នាក់ សមសែន។ អ្នកនិពន្ធជំពូកទី១ នៃរបាយការណ៍នេះ រួមមានលោក អេនរីកេ អាល់ដាហ្ស ការ៉ុល (Enrique Aldaz-Carroll) និង លោក លី សូដេត ដែលបានតាក់តែងខ្លឹមសារនានាស្តីពីស្ថាន-ភាព ម៉ាក្រូសេដ្ឋកិច្ច, លោក កាឡូស សូប្រាដូ (Carlos Sobrado) បានតាក់តែងខ្លឹមសារនានាស្តីពីស្ថានភាពក្រីក្រនិងស្ថានភាពរស់នៅ។ នៅជំពូកទី២អ្នកនិពន្ធរួមមានលោកស្រី អេលីសា ហ្គាមបេរ៉ូនី (Elisa Gamberoni) និង លោក ហ្វ្រង់ស៊ីស្កូ អេរៀស វ៉ាសកេ (Francisco Arias-Vazquez) ដែលបានតាក់តែងផ្នែកខ្លឹមសារនានាស្តីពីស្ថានភាពការងារនៅតំបន់ទីប្រជុំជន, លោក នាក់ សមសែនដែលបានតាក់តែងខ្លឹមសារនានាស្តីពីតួនាទីនៃវិស័យជនបទ ព្រមទាំងលោក ស៊ូយ៉ូស៊ី ហ្វូការ (Tsuyoshi Fukao) លោក កាឡូស សូប្រាដូ (Carlos Sobrado) និង លោក ស៊ីមេត បេង (Simeth Beng) ដែលបានតាក់តែងខ្លឹមសារនានាស្តីពីវិស័យអប់រំ, លោក ធីម៉ូស៊ី ចនស្តុន (Timothy Johnston) និង លោក មីហ្គែល សាន យ៉ូគ្វីន (Miguel San Joaquin) ដែលបានតាក់តែងខ្លឹមសារនានាស្តីពីវិស័យសុខាភិបាល។ លោកស្រី លូស៊ីឡា ប្រ៊ុយនី (Lucilla Bruni) និងលោក រីឆាត ដឺហ្គ្រូត (Richard de Groot) ដែលបានតាក់តែងខ្លឹមសារនានាស្តីពីប្រព័ន្ធការពារសង្គមនិងអនុសាសន៍នានាទាក់ទងនឹងការពង្រឹងប្រព័ន្ធការពារសន្តិសុខសង្គម នៅជំពូកទី ៣។ របាយការណ៍ក៏មានការចូលរួមផ្តល់ជាអត្ថបទផ្សេងៗពីលោកស្រី ពូជ្យា ឌុត្តា (Puja Dutta) លោកស្រី ម៉ារីយ៉ាណា អាំងហ្វង់តេ (Mariana Infante) លោក ជា ហួត និង លោក អែមម៉ារេ អូហ្សាលទីន (Emre Ozaltin)។ លោក អេនរីកេ អាល់ដាហ្ស ការ៉ុល (Enrique Aldaz-Carroll) បានផ្តល់នូវយោបល់បច្ចេកទេសរួមសំរាប់ការតាក់តែងឯកសារនេះ ហើយបានគាំទ្រការប្រាស្រ័យទាក់ទងជាមួយរាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នអន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត។ លោកស្រី គង់ លីដែន កញ្ញា គីលីនណា និង កញ្ញា សាត ផល្លីន បានផ្តល់ការគាំទ្រ និង

សម្របសម្រួលខាងផ្នែកកិច្ចការរដ្ឋបាលផ្សេងៗ។ អ្នកកែសម្រួលអត្ថបទរបាយការណ៍នេះ ជាភាសាអង់គ្លេស គឺលោក ជេរ៉េមី ហ្សេរ៉ាឌី ម៉ាហ្សូ ឡា (Jeremy Gerardi Mazzola)។

សហការីនៅធនាគារពិភពលោកផ្សេងៗទៀតក៏បានផ្តល់ជាយោបល់ និងការចង្អុលបង្ហាញដល់ក្រុមអ្នកនិពន្ធផងដែរ ដែលក្នុងនោះ រួមមាន លោក ពីទើ ឡង់ចូវ (Peter Lanjouw) ដែលបានជួយពិនិត្យនូវវិធីសាស្ត្រគណនាភាពក្រីក្រ លោក អេនឌ្រូ ម៉េសុន (Andrew Mason) និងលោក ហេមី៉ុ សាវេដ្រា (Jaime Saavedra) ដែលបានជួយរៀបចំ និងដឹកនាំកិច្ចប្រជុំអង្គសិក្ខាសាលាមួយ ដើម្បីជួយត្រួតពិនិត្យលទ្ធផលជំហានដំបូងនៃការគណនាភាពក្រីក្រ។ ការចងក្រងរបាយការណ៍នេះ គឺឋិតក្រោមការដឹកនាំ និងចង្អុលបង្ហាញពីលោកស្រី អាណែ្ណត ឌីសុន (Annette Dixon) (នាយកប្រចាំប្រទេស), លោក អាឡាសាន សូ (Alassane Sow) (ប្រធានគ្រប់គ្រង ប្រចាំប្រទេស), លោក ស៊ូឌៀរ ស្ទិធី (Sudhir Shetty) (នាយកទទួល បន្ទុកផ្នែកសេដ្ឋកិច្ច), និងលោក ម៉ាធ្យូ វើហ្គីស (Mathew Verghis) (ប្រធានគ្រប់គ្រងផ្នែកសេដ្ឋកិច្ច)។ លោក កេណ្ណេត ស៊ីមលើ (Kenneth Simler) និង សាល់ម៉ែន ហ្សៃឌី (Salman Zaidi) មានតួនាទីជាអ្នកពិនិត្យឯកសារនេះ តាំងពីដើមរហូតដល់ចប់ និងបានផ្តល់មតិស្ថាបនាដ៏មានតម្លៃជាច្រើន។

នៅពេលរៀបចំឯកសារទស្សនទានសម្រាប់រៀបចំរបាយការណ៍នេះ ក្រុមអ្នកនិពន្ធបានមានឱកាសជួបពិភាក្សាជាមួយ ឯកឧត្តម ហង់ ជួនណារ៉ុន(រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ) ឯកឧត្តម ផាន់ ផល្លា (អគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ) ឯកឧត្តម ជា សុផារ៉ា (រដ្ឋមន្ត្រីក្រសួង អភិវឌ្ឍន៍ជនបទ) ឯកឧត្តម សៅ ជីវ័ន្ត (រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ) ឯកឧត្តម ថេង ច័ន្ទសង្វារ (អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ) លោក ជ្រៃ ពុំ (អនុប្រធាននាយកដ្ឋានសុខភាពជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ) ឯកឧត្តម ង៉ាន់ ចំរើន (អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប) ឯកឧត្តម ពិត ចំណាន (រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា) និង លោក វេជ្ជបណ្ឌិត ឡោ វាសនា គិរី (ប្រធាននាយកដ្ឋានផែនការ និងព័ត៌មានសុខភាព នៃក្រសួងសុខាភិបាល)។

ក្រុមអ្នកនិពន្ធក៏បានទទួលនូវយោបល់ល្អៗពីកិច្ចពិភាក្សានានា ក្នុងឱកាសនៃកិច្ចប្រជុំស្តីពីលទ្ធផលនៃការប៉ាន់ស្មានភាពក្រីក្រ ដែលបានធ្វើឡើងនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។ ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះឯកឧត្តម វង្សី វិស្សុត (អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ឯកឧត្តម ផាន់ ផល្លា (អគ្គលេខាធិការរងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ) ឯកឧត្តម ទួន ថាវរៈ (អនុរដ្ឋលេខាធិការក្រសួងផែនការ)។ ក្រុមអ្នកនិពន្ធ ក៏សូមថ្លែងអំណរគុណចំពោះក្រុមទីប្រឹក្សាស្ថិតិរបស់ស៊ុយអែតប្រចាំនៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងក្រុមការងារអន្តរក្រសួងរបស់រាជរដ្ឋាភិបាល ដើម្បីកំណត់ពីបន្ទាត់ភាពក្រីក្រឡើងវិញ ព្រមជាមួយ លោក សារធី អាចារីយ៉ា (Sarthi Acharya)។ ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងជាពិសេសចំពោះ ឯកឧត្តម សន ស៊ីថន (អនុរដ្ឋលេខាធិការក្រសួងផែនការ) ចំពោះកិច្ចខិតខំប្រឹង-ប្រែងរបស់ឯកឧត្តម ក្នុងការផ្សព្វផ្សាយ និង លើកកម្ពស់ស្ថិតិនៅកម្ពុជា រួមទាំងផ្តល់ទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា (អ.ស.ស.ក) ដើម្បីឲ្យការសិក្សានេះធ្វើទៅបាន។ ក្រុមអ្នកនិពន្ធក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងជាពិសេសចំពោះឯកឧត្តម ហង់ ជួនណារ៉ុន ដែលបានចូលរួមផ្តល់យោបល់ផ្សេងៗតាំងពីដំណាក់កាលចាប់ផ្តើមរៀបចំរបាយការណ៍នេះរហូតដល់ដំណាក់កាលឯកសារពង្រាងចុងក្រោយ។

របាយការណ៍នេះរៀបចំឡើងដោយបានទទួលការគាំទ្រផ្នែកថវិកាពីក្រសួងអភិវឌ្ឍន៍អង់គ្លេស DFID តាមរយៈគម្រោងសម្របសម្រួល និងការវិភាគភាពក្រីក្រនិងអភិបាលកិច្ចនៅកម្ពុជា ដែលហៅកាត់ថា PRAGACS។

# អារម្ភកថា

គេមិនអាចស្វែងយល់ស៊ីជម្រៅអំពីស្ថានភាពសេដ្ឋកិច្ចសង្គមកម្ពុជា នាពេលបច្ចុប្បន្នទេ ប្រសិនជាគេមិនបានស្វែងយល់ពីផលប៉ះពាល់នានាដែលបន្សល់ទុកពីសង្គ្រាមវៀតណាម ជម្លោះផ្ទៃក្នុង និង សង្គ្រាមស៊ីវិលនៅកម្ពុជាពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៩៩។ សង្គ្រាមបានចាប់ផ្តើមនៅវៀតណាមនៅឆ្នាំ១៩៥៥ ហើយទីបំផុតបានរីកសាយភាយដល់កម្ពុជា និងឡាវ ជាពិសេសនៅតាមតំបន់ព្រំដែនរបស់ប្រទេសទាំងពីរនេះជាប់នឹងវៀតណាម ដែលអាមេរិកបានទម្លាក់គ្រាប់បែកមកលើយ៉ាងធ្ងន់ធ្ងរ។ បន្ទាប់ពីមានរដ្ឋប្រហារមួយនៅឆ្នាំ១៩៧០ កម្ពុជាបានធ្លាក់ចូលទៅក្នុងទំនាស់ផ្ទៃក្នុងជាច្រើនដំណាក់កាល ជាពិសេសដំណាក់កាលបដិវត្តន៍របស់ពួកខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលបណ្តាលឲ្យទ្រព្យសម្បត្តិឯកជននានាត្រូវបានបំផ្លាញ មានការបង្ខំឲ្យធ្វើការហួសកម្លាំង និងការបណ្តេញចេញពីទីក្រុងទៅជនបទ ការចាប់ដាក់គុក និងការសម្លាប់ជាច្រើន។ ក្នុងរបបនេះ គេប៉ាន់ស្មានថាប្រជាពលរដ្ឋប្រហែលជាពីរលាននាក់បានបាត់បង់ជីវិតដោយសារការសម្លាប់ ការបង្អត់អាហារ និងជំងឺផ្សេងៗ។ បើទោះជាមានការរំដោះ និងការកាន់កាប់ពីសំណាក់ប្រទេសវៀតណាមនៅចុងឆ្នាំ១៩៧៨ក៏ដោយ ក៏សង្គ្រាមនិងការប្រយុទ្ធគ្នាពុំទាន់បានរលត់នោះទេ។ កងទ័ពវៀតណាមបានដកចេញអស់ នៅឆ្នាំ១៩៩០ ហើយគ្រប់ភាគីជម្លោះនៅកម្ពុជាបានចុះកិច្ចព្រមព្រៀងសន្តិភាពនាទីក្រុងប៉ារីសនៅខែតុលាឆ្នាំ១៩៩១។ ការប្រយុទ្ធគ្នារវាងភាគីផ្សេងៗត្រូវបានកាត់បន្ថយយ៉ាងច្រើន ប៉ុន្តែអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ កម្ពុជានៅតែប្រឈមនឹងអស្ថិរភាពនយោបាយ ដោយសារភាគីជម្លោះទាំងអស់នៅមានកម្លាំងប្រដាប់អាវុធនៅពីក្រោយរៀងៗខ្លួន។ រហូតដល់ឆ្នាំ ១៩៩៩ ដែលការប្រើកម្លាំងប្រដាប់អាវុធដើម្បីផ្តួលគូប្រជែងនយោបាយហាក់ដូចជាត្រូវបានបញ្ចប់ ដែលពេលនោះហើយ ជាវេលាដែលគេអាចកំណត់ថា ជម្លោះនិងសង្គ្រាមជាច្រើនទសវត្សរ៍នៅកម្ពុជាត្រូវបានបញ្ចប់។

គេមានការលំបាកក្នុងការវាស់វែងឲ្យបានច្បាស់លាស់ថា តើជម្លោះ និងសង្គ្រាមបានធ្វើឲ្យខូចខាតដល់ប្រទេសនិងប្រជាពលរដ្ឋកម្ពុជាកម្រិតប៉ុណ្ណា។ ឯកសាររបស់ រូម៉្មេ (Rumme) ក្នុងឆ្នាំ ១៩៩៤ បានសរសេរថា ជម្លោះនិងសង្គ្រាមនៅកម្ពុជាពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៨៧ បានធ្វើឲ្យប្រជាពលរដ្ឋចំនួនពី ២,៣ ទៅ ៣,៩លាននាក់បាត់បង់អាយុជីវិត ដែលចំនួននេះមានប្រមាណពីមួយភាគបីទៅប្រមាណពាក់កណ្តាលនៃប្រជាពលរដ្ឋកម្ពុជាសរុបចំនួន ៧,១ លាននាក់នាឆ្នាំ១៩៧០។ ប្រជា-

ពលរដ្ឋនៅតាមទីក្រុងទូទាំងប្រទេស ត្រូវបានជម្លៀសឲ្យទៅនៅតាមតំបន់ជនបទ។ ហេតុនេះហើយ គិតមកត្រឹមឆ្នាំ២០១០ កម្ពុជាជាប្រទេសដែលមានអត្រាប្រជាពលរដ្ឋរស់នៅទីប្រជុំជនទាបជាងគេទីពីរ ក្នុងចំណោមប្រទេសទាំងអស់នៅតំបន់អាស៊ី។ រូបិយប័ណ្ណត្រូវបានលុបបំបាត់ចោល។ ឯកសាររដ្ឋបាលជាច្រើនរាប់ទាំងកម្មសិទ្ធិដីធ្លី និងអត្រានុកូលដ្ឋានត្រូវបានបាត់បង់ ឬកម្ទេចចោល។ បញ្ហាចំណោទនានាទាក់ទងនឹងដីធ្លីបច្ចុប្បន្ននេះអាចដោយ-សារតែមូលហេតុនៃការបណ្តេញចេញទាំងស្រុង និងការបាត់បង់ឯកសារគតិយុត្តិផ្សេងៗ ដែលកើតមានក្នុងរបបខ្មែរក្រហម។

ក្នុងរយៈពេល ១៤ ឆ្នាំដែលកម្ពុជាមានសន្តិភាពពេញលេញ កម្ពុជាបានប្រែប្រួលមុខមាត់ស្ទើរគ្រប់វិស័យ ក៏ប៉ុន្តែផលប៉ះពាល់ដែលបានបន្សល់ទុកពីជម្លោះប្រដាប់អាវុធ និងអស្ថិរភាពនៅតែមានវត្តមាននៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ននៅឡើយ។ ឧទាហរណ៍ អ្នកកាន់តំណែងនានា ទាំងក្នុងវិស័យឯកជន និងវិស័យសាធារណៈសុទ្ធតែកើតនៅមុន ឬអំឡុងរបបខ្មែរក្រហម ហើយពួកគេភាគ-ច្រើនបានឆ្លងកាត់សង្គ្រាម និងបានរងគ្រោះពីសង្គ្រាមនេះផងដែរ។ ក្នុងសង្គមកម្ពុជាបច្ចុប្បន្ន គេមិនចម្លែកចិត្តទេប្រសិនបើបានឮថា មនុស្សជាច្រើនដែលមិនបានដឹងពីថ្ងៃ ខែ ឆ្នាំ កំណើតពិតរបស់ខ្លួន ឬឮថា ស្ទើរគ្រប់ក្រុមគ្រួសារមានសាច់ញាតិរបស់ខ្លួនបានបាត់បង់ជីវិត អំឡុងសម័យសង្គ្រាម និងជម្លោះនោះ។

ស្ថានភាពស្ថាប័ននានាក្នុងពេលបច្ចុប្បន្ននេះជាលទ្ធផលនៃដំណើរការកសាងអំឡុងទសវត្សរ៍ ឆ្នាំ១៩៩០ ដែលជាទសវត្សរ៍មានអាទិភាពខ្ពស់បំផុត ធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋមានអាហារបរិភោគបានឆ្អែត ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តឡើងវិញ និង ការធានាឲ្យមានសន្តិសុខសណ្តាប់ធ្នាប់សង្គម និងនីតិរដ្ឋឲ្យបានកម្រិតល្អមួយ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបានធ្វើឡើងក្នុងកាលៈទេសៈដ៏លំបាក ដែលប្រទេសមិនត្រឹមតែប្រឈមនឹងអស្ថិរភាពនយោបាយប៉ុណ្ណោះទេ ប៉ុន្តែសង្គ្រាមនៅតែបន្តមាន។ ក្នុងកាលៈទេសៈដ៏លំបាកលំបិននេះ វាមិនមែនជារឿងចម្លែកទេដែលប្រទេសនេះមិនបានអនុវត្តទស្សនទាននានាពាក់ព័ន្ធនឹងការចូលរួម និងតម្លាភាព បើទោះបីដឹងថា ទស្សនៈទាំងនេះនឹងផ្តល់ផលយ៉ាងច្រើនសម្រាប់ការអភិវឌ្ឍន៍នាពេលអនាគត។ នេះក៏ដោយហេតុផលថា ប្រទេសនេះមានកិច្ចការ និងបញ្ហាចំណោទដែលត្រូវដោះស្រាយបន្ទាន់ៗ មានជាអាទិ៍ ការរៀបចំរដ្ឋមួយឲ្យដំណើរការបាន និងមាននិរន្តភាព។

ប្រជាពលរដ្ឋវ័យក្មេងជំនាន់ក្រោយដែលមិនបានឆ្លងកាត់ភាពជូរចត់ពីសង្គ្រាមនាពេលអតីត កំពុងដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ។ គិតត្រឹមឆ្នាំ ២០១០ ប្រជាពលរដ្ឋកម្ពុជាប្រមាណពីរភាគបីគឺកើតក្រោយឆ្នាំ១៩៩៣។ សម្រាប់អ្នកទាំងនោះ ជម្លោះនិងសង្គ្រាមជាច្រើនឆ្នាំនាពេលអតីតកាលហាក់មិនមានអ្វីធ្វើឲ្យពួកគេនឹកនារនោះទេ ហើយពួកគេគិតថា រឿងទាំងអស់នេះជារឿងរបស់អ្នកជំនាន់មុន មិនមានអ្វីមកពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃរបស់អ្នកជំនាន់ក្រោយទេ។ ផ្ទុយទៅវិញ យុវវ័យបច្ចុប្បនេះយកចិត្តទុកដាក់ និងព្រួយ-បារម្ភអំពីអនាគតរបស់ពួកគេជាងរឿងរ៉ាវសង្គមនានាកាលពីសម័យមុន។ ពួកគេព្រួយបារម្ភពីឱកាសការងារបច្ចេក-វិទ្យាថ្មីៗ ការរៀបចំគ្រួសារថ្មី ការដាំដុះស្រូវ ការថែទាំសុខភាព ការសិក្សាអប់រំ យានជំនិះ ។ល។ ជាងព្រួយ-បារម្ភពីបញ្ហាសង្គមដែលកើតមានកាលពីអតីត។

សម្រាប់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋបានផ្តល់ជូនដល់ពលរដ្ឋនូវលក្ខខណ្ឌចាំបាច់នានាសម្រាប់ការរស់នៅ និងជួយឲ្យពួកគេលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃ។ ប៉ុន្តែនៅពេលដែលប្រជាពលរដ្ឋមានជីវភាពកាន់តែធូរធារពីមួយថ្ងៃទៅមួយថ្ងៃ ពួកគេមានការរំពឹងទុក និងទាមទារឲ្យរដ្ឋផ្តល់លក្ខណ្ឌចាំបាច់នានាឲ្យដូចបណ្តាប្រទេសជឿនលឿន។

ក្តីរំពឹងទាំងនេះនាំឲ្យកើតមានភាពប្រឈមថ្មីៗ សម្រាប់សង្គមនិងរដ្ឋ។ ម្យ៉ាងទៀត ការរំពឹងទុករបស់ប្រជាពលរដ្ឋមិនមែនត្រឹមតែចង់បានការទទួលទានគ្រប់គ្រាន់ប៉ុណ្ណោះទេ ប៉ុន្តែពួកគេកំពុងចាប់ផ្តើមចង់ឲ្យសេវាកម្មសាធារណៈកាន់តែប្រសើរ ក្នុងនោះមានជាអាទិ៍ នីតិរដ្ឋ តម្លាភាពពីមន្ត្រីសាធារណៈ និង ជាពិសេស ទាក់ទងនឹងសុវត្ថិភាព

ដីធ្លី។ ឥឡូវនេះ ប្រជាពលរដ្ឋហាក់ចង់ឃើញការលើកកម្ពស់ជីវភាពរបស់ពួកគេឲ្យប្រសើរឡើងឆាប់រហ័ស។ ម៉្យាងទៀត ការអភិវឌ្ឍកន្លងមកបានបង្កឲ្យមានបញ្ហាថ្មីៗ ដូចជា បញ្ហាបរិស្ថាន (ការបំពុលបរិស្ថាន ការធ្វើឲ្យដីខ្សោះជីជាតិ និង ការប្រើប្រាស់ធនធានធម្មជាតិ ហួសកម្រិតជាដើម) បញ្ហាកំណើនថ្លៃទំនិញ សេវារស់នៅប្រចាំថ្ងៃ ព្រមទាំងបញ្ហាសុខភាពមួយចំនួនរាប់ទាំងជំងឺហ៊ីវ/អេដស៍ ផ្តាសាយ ។ល។ និង ។ល។ បញ្ហាប្រឈមដ៏ធំរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការលើកកម្ពស់សមត្ថភាព និង លទ្ធភាពរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកថ្មីៗទាំងនេះ និងដោះស្រាយបញ្ហាថ្មីៗ ដែលមិនធ្លាប់កើតមានកាលពីទសវត្សរ៍ឆ្នាំ១៩៩០។

# ខ្លឹមសារសង្ខេប

ក្នុងរយៈពេល ៧ឆ្នាំ ចាប់ពីឆ្នាំ២០០៤ដល់ឆ្នាំ២០១១ សេដ្ឋកិច្ចកម្ពុជាមានកំណើនយ៉ាងខ្លាំងក្លា ធ្វើឲ្យកម្ពុជាជាប់ចំណាត់ថ្នាក់ក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតលើពិភពលោក។ ការចំណាយប្រចាំថ្ងៃក្នុងប្រជាពលរដ្ឋម្នាក់ៗក៏បានកើនឡើងជិត ៤០ភាគរយផងដែរ ក្នុងអំឡុងពេលដូចគ្នានេះ។ ផលនៃកំណើនសេដ្ឋកិច្ចនេះបានទៅដល់ដៃប្រជាពលរដ្ឋក្រីក្រជាច្រើនដែលកត្តានេះ មិនត្រឹមតែបានជួយកាត់បន្ថយគម្លាតនៃការចំណាយរវាងប្រជាពលរដ្ឋអ្នកមាន និងប្រជាពលរដ្ឋអ្នកក្រប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានជំរុញឲ្យកំណើនចំណាយរបស់ប្រជាពលរដ្ឋក្រីក្រខ្ពស់ជាងកំណើនចំណាយរបស់ប្រជាពលរដ្ឋអ្នកមានដែរ។ ជាលទ្ធផល ការគណនាបានបង្ហាញថា អត្រាភាពក្រីក្រនៅកម្ពុជាបានធ្លាក់ចុះពី ៥០,២ ភាគរយ ទៅ ២០,៥ ភាគរយ ដែលជាអត្រាមួយលើសពីការរំពឹងទុករបស់អ្នកវិភាគនានា។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ប្រជាពលរដ្ឋដែលបានចាកផុតពីភាពក្រីក្រមិនទាន់មានជីវភាពធូរធារជំដុំនោះទេ ពួកគេនៅតែងាយធ្លាក់ចូលក្នុងភាពក្រីក្រវិញយ៉ាងងាយ ប្រសិនបើមានគ្រោះតូចណាមួយកើតឡើង។ ក្នុងរយៈពេល ៧ឆ្នាំ នេះ មានកត្តានាំមុខចំនួនបួនដែលជំរុញឲ្យប្រជាពលរដ្ឋចាកផុតពីភាពក្រីក្រ៖ ទី១-ថ្លៃស្រូវអង្ករ ដែលបានតម្លៃខ្ពស់, ទី២-កំណើនអត្រាថ្លៃឈ្នួលពលកម្មនៅតាមទីជនបទ, ទី៣-ការកើនឡើងនូវការងារដែលមានប្រាក់បៀវត្សរ៍នៅតាមទីប្រជុំជន, និងទី៤-កំណើនប្រាក់ចំណូលពីការប្រកបរបរជំនួញតូចតាច។ ក្នុងនោះគេសង្កេតឃើញថា ការលើកកម្ពស់សុខភាព និងការអប់រំ និងការវិនិយោគរបស់រដ្ឋាភិបាលកម្ពុជាលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តបានបង្កលក្ខខណ្ឌអំណោយផលដល់ប្រជាពលរដ្ឋក្រីក្រជាច្រើន ជួយឲ្យពួកគេអាចជួយក្រុមគ្រួសារ និងខ្លួនគេផ្ទាល់ឲ្យចាកផុតពីភាពក្រីក្រ។ ប៉ុន្តែ កត្តានាំមុខទាំងបួននេះអាចនឹងគាំងនាពេលអនាគតខាងមុខ។ កម្រិតជីវភាពរបស់ប្រជាពលរដ្ឋភាគច្រើនមិនទាន់បានធូធារខ្លាំងនៅឡើយ ដូចនេះប្រសិនបើកត្តានាំមុខទាំងនេះគាំង ប្រជាពលរដ្ឋភាគច្រើនអាចងាយធ្លាក់ខ្លួនក្រីក្រម្តងទៀត។ ហេតុនេះហើយ រដ្ឋាភិបាលមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ និងមានភាពប្រឈមថ្មីៗដែលត្រូវដោះស្រាយ។ គោលនយោបាយ និងសកម្មភាពនានា តម្រូវឲ្យផ្តោតការយកចិត្តទុកដាក់ឲ្យចំទិសដៅ ដើម្បីរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្រ ដែលសម្រេចបានកន្លងមក។ ប្រជាពលរដ្ឋក្រីក្របច្ចុប្បន្ននេះភាគច្រើនកំពុងរស់នៅតាមទីជនបទ។ ប្រជាពលរដ្ឋក្រីក្រនៅតាមទីជនបទមាន ៩០ ភាគរយនៃប្រជាពលរដ្ឋក្រីក្រសរុប។ ហេតុដូចនេះហើយ ដើម្បីជួយប្រជាពលរដ្ឋក្រីក្រឲ្យបានច្រើនជាអតិបរមា គោលនយោបាយរបស់រដ្ឋាភិបាលគួរផ្តោតលើការលើក

កម្ពស់ផលិតភាពទ្រព្យសំខាន់ៗពីរ ដែលប្រជាពលរដ្ឋក្រីក្រភាគច្រើនមាន គឺកម្លាំងពលកម្ម និងដីធ្លី។

## ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

ការបញ្ចប់ជម្លោះផ្ទៃក្នុងនៅឆ្នាំ ១៩៩៩ បានជួយឲ្យកម្ពុជាអាចធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនទៅក្នុងទីផ្សារអន្តរជាតិ។ រឿងដែលគួរឲ្យកត់សម្គាល់គឺ កម្ពុជាបានពង្រីកវិស័យឧស្សាហកម្មរបស់ខ្លួន នាំមុខដោយឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង។ ដោយសារវិស័យឧស្សាហកម្មមានកំណើនខ្ពស់ដល់ ៣០ភាគរយក្នុងមួយឆ្នាំៗ ផលិតផលក្នុងស្រុកសរុបពីវិស័យឧស្សាហកម្មមានកំណើនទ្វេដង បើគិតត្រឹមឆ្នាំ ២០០៤ ហើយវិស័យនេះរួមចំណែក ២៧ភាគរយ ក្នុងផលិតផលក្នុងស្រុកសរុប (ផ.ស.ស) របស់កម្ពុជា។ ទន្ទឹមគ្នានេះដែរ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងផលិតផលក្នុងស្រុកសរុបបានធ្លាក់ចុះពីកម្រិត ៤៤ ភាគរយ នៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៩០ មកត្រឹមកម្រិត ២៩ ភាគរយ ក្នុងឆ្នាំ ២០០៤។

**ពីឆ្នាំ ២០០៤ ដល់ ឆ្នាំ ២០១១ ផ.ស.ស ក្នុងម្នាក់ៗ (គិតជាថ្លៃគោលឆ្នាំ ២០០០, ដុល្លារ) កើនឡើង ៥៤,៥ ភាគរយ។ កំណើនកម្រិតនេះធ្វើឲ្យកម្ពុជាជាប់ចំណាត់ថ្នាក់ទី១៥ ក្នុងចំណោម ១៧៤ ប្រទេស។** កំណើនដ៏គួរឲ្យកត់សម្គាល់នេះ ដោយសារកត្តារួមផ្សំមួយចំនួនក្នុងនោះ រួមមានកត្តាសន្តិភាពពេញលេញ ប្រជារាស្ត្រវ័យក្មេង គោលនយោបាយបើកទូលាយដល់ការវិនិយោគ និងពាណិជ្ជកម្មសេរី និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ កត្តាទាំងអស់នេះបានជំរុញឲ្យមានកំណើនផ្នែកទេសចរណ៍ សំណង់ ឧស្សាហកម្មកាត់ដេរ និង កសិកម្ម ប៉ុន្តែសេដ្ឋកិច្ចកម្ពុជា ក៏ដូចសេដ្ឋកិច្ចប្រទេសនានាលើសកលលោកផងដែរ ដែលមានកំណើនយឺតនៅ ឆ្នាំ២០០៨ ហើយបន្តធ្លាក់ចុះបន្ថែមទៀតនៅឆ្នាំ ២០០៩ (មានកំណើនតែ ១,៤ ភាគរយ គិតជាកំណើនផ.ស.សក្នុងពលរដ្ឋម្នាក់ៗ តាមថ្លៃគោលឆ្នាំ២០០០) ដោយសារវិបត្តិសេដ្ឋកិច្ចសកល។ ប៉ុន្តែទោះជាទទួលរងនូវវិបត្តិសេដ្ឋកិច្ចពិភពលោកក្តី ក៏សេដ្ឋកិច្ចកម្ពុជាពុំទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដូចបណ្តាប្រទេសអភិវឌ្ឍទេ ហើយសេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញយ៉ាងលឿន។

**ប្រសិនកម្ពុជាអាចរក្សាកំណើន ដែលធ្វើបានកាលពីទសវត្សរ៍កន្លងទៅនោះកម្ពុជានឹងក្លាយជាប្រទេសអ្នកមានចំណូលមធ្យមនៅឆ្នាំ ២០១៥។** ដោយសារផលិតផលជាតិសរុប (ផ.ជ.ស) ក្នុងប្រជាពលរដ្ឋម្នាក់ៗ មានកម្រិតទាបនៅឆ្នាំ ២០០៤ (៤០០ ដុល្លារអាមេរិក) កំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លាកាលពី ៧ឆ្នាំ កន្លងទៅ មិនអាចប្រែ-ក្លាយកម្ពុជាពីឋានៈប្រទេសមានប្រាក់ចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមទេ។ នៅឆ្នាំ២០១១ ផលិត-ផលជាតិសរុប (ផ.ជ.ស) ក្នុងប្រជាពលរដ្ឋម្នាក់ៗ មានត្រឹមតែ ៨២៣ ដុល្លារអាមេរិកប៉ុណ្ណោះ នៅទាបជាង ១,០២៦ ដុល្លារអាមេរិក ដែលជាកម្រិត ផ.ជ.ស ដើម្បីអាចចាត់ចូលជាប្រទេសមានប្រាក់ចំណូលមធ្យម។ ប៉ុន្តែប្រសិនបើកម្ពុជាអាចរក្សាកំណើនរបស់ខ្លួនបាន កម្ពុជានឹងក្លាយជាប្រទេសមានចំណូលមធ្យមនៅ ឆ្នាំ២០១៥។ (**ក្រាហ្វិក ក**)

## ការចំណាយលើ ការប្រើប្រាស់ សុខុមាលភាព វិសមភាព និង ភាពក្រីក្រ

**រាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក បានធ្វើបច្ចុប្បន្នកម្មលើវិធីសាស្ត្រវាស់វែងការចំណាយ និងភាពក្រីក្រពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ ដើម្បីឲ្យវិធីសាស្ត្រនេះឆ្លុះបញ្ចាំងពីស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ននេះ។** វិធីសាស្ត្រវាស់វែងការចំណាយរបស់ប្រជាពលរដ្ឋ និងភាពក្រីក្រនៅកម្ពុជា ត្រូវបានរៀបចំឡើងដំបូងបង្អស់នៅឆ្នាំ ១៩៩៧ ដោយប្រើប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា (អ.ស.ស.ក) ឆ្នាំ ១៩៩៣។ បើគិតមកដល់បច្ចុប្បន្នវិធីសាស្ត្រនេះលែងសូវឆ្លុះបញ្ចាំងពីស្ថានភាពកម្ពុជាសព្វថ្ងៃហើយ។ ដោយជ្រាបបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោកបានចាប់-ផ្តើមរៀបចំវិធីសាស្ត្រគណនាថ្មីមួយ ហើយកិច្ចការនេះត្រូវបានធ្វើឡើងដាច់ដោយឡែកពីគ្នារៀងៗខ្លួន ប៉ុន្តែមានការផ្លាស់ប្តូរយោបល់ទៅវិញទៅមក។ ក្រុមអ្នកវិភាគរបស់ធនាគារពិភពលោកទទួលបានមតិល្អៗជាច្រើនពី

**ក្រាហ្វិក ក៖** អត្រាកំណើន ផ.ស.ស ក្នុងម្នាក់ៗ (ថ្លៃគោលឆ្នាំ២០០០, ដុល្លារ)




**ប្រភព៖** គណនីជាតិនិងការព្យាករប្រជាសាស្ត្រ របស់វិទ្យាស្ថានជាតិស្ថិតិ(វ.ជ.ស)

សំណាក់ក្រុមអ្នកវិភាគរបស់រាជរដ្ឋាភិបាលពាក់ពន្ធ័នឹងស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ ដើម្បីយកទៅសម្រេចលើកត្តាមួយចំនួនទាក់ទងនឹងវិធីសាស្ត្រគណនានេះ។ ចំណែកក្រុមអ្នកវិភាគរបស់រាជរដ្ឋាភិបាលក៏ទទួលបានមតិល្អៗជាច្រើនពីបទពិសោធន៍ និងរបៀបគណនាវិធីសាស្ត្រដែលបានធ្វើកាលពីឆ្នាំ ១៩៩៧ និងវិធីសាស្ត្រនានាដែលបានអនុវត្តនៅប្រទេសដទៃទៀត ហើយក្រុមការងារនេះបានប្រើគោលការណ៍ និងលទ្ធផលមួយចំនួនដែលក្រុមការងាររបស់ធនាគារពិភពលោកបានធ្វើ។ ជាសរុប ក្រុមការងារទាំងពីរបានរៀបចំឲ្យមានវិធីសាស្ត្ររៀងៗខ្លួន ដើម្បីគណនាភាពក្រីក្រពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ ហើយលទ្ធផលស្តីពីអត្រាភាពក្រីក្រដែលគណនាពីវិធីសាស្ត្រទាំងពីរនេះមានកម្រិតស្រដៀងគ្នាជាពិសេសចាប់ពីឆ្នាំ ២០០៩មក។[1]

**ការចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋម្នាក់ៗ (ថ្លៃគោលឆ្នាំ២០០៩, រៀល) បានកើនឡើង ៣៧,៨ ភាគរយ គឺកើនឡើងពី ៦,៣៩៩ រៀលនៅឆ្នាំ ២០០៤ ដល់ ៨,៨១៥ រៀលនៅឆ្នាំ ២០១១។** កំណើននេះស្របនឹងកំណើន ផ.ស.ស។ បើគិតជាអត្រាកំណើនប្រចាំឆ្នាំវិញ អត្រាកំណើនចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋម្នាក់ៗមានល្បឿន ៤,៧ ភាគរយក្នុងមួយឆ្នាំក្នុងរយៈពេល៧ឆ្នាំ គិតចាប់ពីឆ្នាំ២០០៤ មក។ គួរបញ្ជាក់ថា កំណើនចំណាយលើការប្រើប្រាស់ដែលមានកម្រិត ៣៧,៨ ភាគរយ មានកម្រិតទាបជាងកំណើនរបស់ផលិតផលក្នុងស្រុកក្នុងម្នាក់ៗ ដែលមានកម្រិត ៥៤,៥ ភាគរយ។ ក៏ប៉ុន្តែ ភាពខុសគ្នានេះមិនមែនប្លែកអ្វីទេ នៅតាមបណ្តាប្រទេសដទៃទៀត ក៏គេឃើញភាពខុសគ្នានេះដែរ ដោយសារតែការរីកចម្រើនមួយផ្នែករបស់សេដ្ឋកិច្ចមិនបានផ្តល់ផលប្រយោជន៍ទៅដល់ប្រជាពលរដ្ឋគ្រប់ៗរូបនោះទេ។

**ការរីកចម្រើននៃការទទួលបានសេវាកម្មផ្សេងៗ និងកំណើនទ្រព្យសម្បត្តិនានារបស់ប្រជាពលរដ្ឋបានបញ្ជាក់បន្ថែមថា កំណើនចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋពិតជាត្រឹមត្រូវ។** សូចនាករនានាទាក់ទងនឹងស្ថានភាពលំនៅដ្ឋាន ទ្រព្យសម្បត្តិនៃគ្រួសារនីមួយៗបានបង្ហាញថា ជីវភាពរបស់ប្រជាពលរដ្ឋមានភាពប្រែប្រួលខ្លាំងដូចលទ្ធភាពចំណាយលើការប្រើប្រាស់របស់ពួកគាត់ដែរ។ ឧទាហរណ៍ អត្រាគ្រួសារប្រជាពលរដ្ឋមានអគ្គិសនីប្រើប្រាស់បានកើនឡើងចំនួន ៣ ដង។ អត្រាគ្រួសារប្រជាពលរដ្ឋដែលមានបង្គន់ប្រើប្រាស់បានកើនឡើង

ទ្វេដង។ អត្រាគ្រួសារប្រជាពលរដ្ឋដែលមានទឹកស្អាតប្រើប្រាស់បានកើនឡើងដល់ ២៥ ភាគរយ។ ចំពោះទ្រព្យសម្បត្តិវិញ អត្រាគ្រួសារប្រជាពលរដ្ឋដែលមានទូរទស្សន៍បានកើនឡើង ៤ ដង។ កត្តាទាំងអស់នេះហើយដែលបញ្ជាក់ឲ្យឃើញច្បាស់ថា ប្រជាពលរដ្ឋមានលទ្ធភាពបង្កើនការចំណាយរបស់ខ្លួន។

**ការចំណាយលើការប្រើប្រាស់របស់ក្រុមប្រជាពលរដ្ឋ (បញ្ចភាគទី ១) នៅឆ្នាំ ២០១១ មានកម្រិតស្មើនឹងការចំណាយលើការប្រើប្រាស់របស់ក្រុមប្រជាពលរដ្ឋដែលមានជីវភាពមធ្យមកាលពីឆ្នាំ ២០០៤។** ម៉្យាងវិញទៀត លំនៅដ្ឋាន ទ្រព្យសម្បត្តិរបស់ក្រុមប្រជាពលរដ្ឋ (បញ្ចភាគទី១) នៅ ឆ្នាំ២០១១ មានស្ថានភាពប្រហាក់ប្រហែលនឹងប្រជាពលរដ្ឋក្រុមបញ្ចភាគមធ្យមកាលពីឆ្នាំ២០០៤ ដែរ។ នេះសបញ្ជាក់ឲ្យឃើញថា ប្រជាពលរដ្ឋក្រីក្រជាងគេបំផុតនៅឆ្នាំ២០១១ មានស្ថានភាពប្រហាក់ប្រហែលនឹងប្រជា-ពលរដ្ឋដែលមានជីវភាពមធ្យម កាលពីឆ្នាំ២០០៤។

**កំណើនចំណាយលើការប្រើប្រាស់ពិតជាកើតមានច្រើន ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រមែនៈ កំណើនចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋក្រីក្រខ្ពស់ជាងកំណើនចំណាយរបស់ប្រជាពលរដ្ឋអ្នកមាន។** ឧទាហរណ៍ កំណើនចំណាយរបស់ក្រុមប្រជាពលរដ្ឋបញ្ចភាគទី ១ (២០ ភាគរយ នៃប្រជាពលរដ្ឋសរុប) មាន ៥៦,៥ ភាគរយ ចំណែកឯកំណើននៃការចំណាយរបស់ក្រុមប្រជាពលរដ្ឋផ្សេងៗទៀតមានកម្រិតទាបជាងនេះ ក្រុមប្រជាពលរដ្ឋបញ្ចភាគទី ២ មាន ៥១,៦ ភាគរយ, ក្រុមប្រជាពលរដ្ឋបញ្ចភាគទី ៣ មាន ៤៥ ភាគរយ, ក្រុមប្រជាពលរដ្ឋបញ្ចភាគ ទី ៤ មាន ៣៨,៤ ភាគរយ និងក្រុមប្រជាពលរដ្ឋបញ្ចភាគទី ៥ មាន ២៦,៨ ភាគរយ (ក្រុមប្រជាពលរដ្ឋ ២០ ភាគរយ ដែលជាពលរដ្ឋអ្នកមានបំផុតក្នុងចំណោមប្រជាពលរដ្ឋសរុប)។

**គេក៏សង្កេតឃើញមានការកែលម្អសន្ទស្សន៍វិបុល-ភាព** (prosperity index) **ផងដែរ។** កម្រិតនៃការចំណាយលើការប្រើប្រាស់របស់ក្រុមប្រជាពលរដ្ឋបញ្ចភាគទី ១ និងទី ២ នៃប្រជាពលរដ្ឋសរុបបានកើនឡើងពី ២០,៧ ភាគរយ នៅឆ្នាំ ២០០៤ ដល់ ២០,៤ ភាគរយ នៅឆ្នាំ ២០១១។

**ចាប់ពីឆ្នាំ២០០៧ មក វិសមភាពបានធ្លាក់ចុះរៀងរាល់ឆ្នាំផងដែរ។** លទ្ធផលមួយក្នុងចំណោមលទ្ធផលជាច្រើន ដែលធ្វើឲ្យក្រុមអ្នកវិភាគមានការភ្ញាក់ផ្អើល គឺការរកឃើញថា វិសមភាពត្រូវបានកាត់បន្ថយចាប់តាំងពីឆ្នាំ ២០០៧មក បន្ទាប់ពីមានការកើនឡើងប៉ុន្មានឆ្នាំមុននេះ។ ឧទាហរណ៍៖ សន្ទស្សន៍ជីនីបានធ្លាក់ចុះជាបន្តបន្ទាប់ពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០១១ បន្ទាប់ពីបានកើនឡើងពីកម្រិត ០,៣២៦ នៅឆ្នាំ ២០០៤ ទៅ ០,៣៧៤ នៅឆ្នាំ ២០០៧។ អត្រានេះបានធ្លាក់ចុះមកកម្រិត ០,២៨២ នៅឆ្នាំ ២០១១។

**ទោះជាយ៉ាងនេះក្តី គម្លាតពិតរវាងប្រជាពលរដ្ឋអ្នកមាននិងអ្នកក្រនៅតែមានកម្រិតខ្ពស់ដដែល បើគេគិតតាមន័យដាច់ខាត។** ដោយសារតែការគណនាវិសមភាពគិតតាមន័យធៀប គេសង្កេតឃើញថា វិសមភាពបានធ្លាក់ចុះ។ ការកើនឡើងនៃគម្លាតរវាងអ្នកមាននិងអ្នកក្រអាចកើតមានព្រមគ្នា ដោយសារគម្លាតរវាងអ្នកមាននិងអ្នកក្រត្រូវបានគេគិតតាមន័យដាច់ខាតផង និងតាមន័យធៀបផង។ ដើម្បីឲ្យងាយយល់ យើងសូមផ្តល់ឧទាហរណ៍មួយ៖ បើសិនជាមនុស្សម្នាក់មានចំណូល ១០ ដុល្លារ ហើយម្នាក់ទៀតមានចំណូល ២០ ដុល្លារនោះ អ្នកទី ២ មានចំណូលលើសអ្នកទី១ចំនួន២ដង ប៉ុន្តែបើគិតជាប្រាក់វិញ អ្នកទី២លើសអ្នកទី១ តែ ១០ដុល្លារ ប៉ុណ្ណោះ។ ប្រសិនបើមនុស្សម្នាក់ៗមានចំណូល ១០០ ដុល្លារ ហើយមនុស្សម្នាក់ទៀតមានចំណូល ២០០ដុល្លារនោះ អ្នកទី២មានចំណូលលើសអ្នកទី១ ចំនួន ២ ដងដែរ ប៉ុន្តែបើគិតជាប្រាក់វិញ អ្នកទី ២ លើសអ្នកទី១ ចំនួន ១០០ ដុល្លារ។ មូលហេតុនេះហើយ ដែលគេសង្កេតឃើញថា ទោះបីវិសមភាពមានការធ្លាក់ចុះក៏ដោយ គម្លាតពិតរវាងអ្នកមាននិងអ្នកក្រនៅតែមានកម្រិតខ្ពស់។

**ដោយសារចំណាយរបស់ប្រជាពលរដ្ឋទូទៅ និងប្រជាពលរដ្ឋក្រីក្របានកើនឡើង អត្រាភាពក្រីក្រនៅកម្ពុជាបានធ្លាក់ចុះ ពី ៥៣,២ ភាគរយមកត្រឹម ២០,៥**

**ភាគរយ។** ស្ថានភាពនៅប្រទេសកម្ពុជាមានលក្ខណៈខុសប្លែកពីបណ្តាប្រទេសដទៃទៀត ដែលគេសង្កេតឃើញថាកំណើនសេដ្ឋកិច្ចបណ្តាប្រទេសទាំងនោះ តែងតែជំរុញគម្លាតរវាងប្រជាពលរដ្ឋអ្នកមាននិងអ្នកក្រកាន់តែខ្ពស់ ប៉ុន្តែនៅកម្ពុជា កំណើនសេដ្ឋកិច្ចបានជួយប្រជាពលរដ្ឋទូទៅនិងប្រជាពលរដ្ឋក្រីក្រ ដែលនេះជាមូលហេតុជួយជំរុញល្បឿននៃការកាត់បន្ថយភាពក្រីក្របានកាន់តែលឿន។ អ្វីដែលកើតមានឡើងនៅកម្ពុជានេះ គឺហួសពីការរំពឹងទុករបស់អ្នកវិភាគទាំងឡាយ ហើយល្បឿននៃការកាត់បន្ថយភាពក្រីក្រនេះមានន័យថា កម្ពុជាសម្រេចបានគោលដៅអភិវឌ្ឍសហស្សវត្សរ៍ទៅហើយ។

**ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋភាគច្រើន ដែលបានចាកចេញពីភាពក្រីក្រមិនទាន់មានជីវភាពធូរធារខ្លាំងក្លានោះទេ ពួកគេអាចធ្លាក់ចូលក្នុងភាពក្រីក្រវិញបានយ៉ាងងាយ។** ឧទាហរណ៍៖ នៅឆ្នាំ២០១១ បើសិនមានហេតុការណ៍ណាមួយ ដែលធ្វើឲ្យប្រជាពលរដ្ឋបាត់បង់ចំណូល ១,២០០ រៀលក្នុងមួយថ្ងៃ (០,៣០ ដុល្លារ ឬស្មើនឹងតម្លៃទឹកបរិសុទ្ធពីរដបដែលលក់នៅតាមថ្នល់នៅទីក្រុងភ្នំពេញ) នោះនឹងធ្វើឲ្យអត្រាភាពក្រីក្រនៅកម្ពុជាឆ្នាំ២០១១ កើនឡើងទ្វេដង។ (**ក្រាហ្វិក ខ**)

**តើប្រជាពលរដ្ឋក្រីក្រទៅទីណាអស់ហើយ?ពួកគេទៅមិនឆ្ងាយទេ។ ប្រជាពលរដ្ឋក្រីក្រភាគច្រើនគ្រាន់តែ មានជីវភាពធូរធារបន្តិចបន្តួចប៉ុណ្ណោះ។**[2] ពួកគេអាចក្លាយជាប្រជាពលរដ្ឋក្រីក្រវិញ ប្រសិនបើមានហេតុការណ៍ណាមួយប៉ះពាល់ជាអវិជ្ជមានដល់ពួកគេ។ មូលហេតុដែលនាំឲ្យការកាត់បន្ថយភាពក្រីក្របានលឿន ក៏ដោយសារតែនៅឆ្នាំ ២០០៤ មានប្រជាពលរដ្ឋមួយភាគធំស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រ ហើយកំណើនសេដ្ឋកិច្ចមានការកើនឡើងនៅតាមទីជនបទបានជំរុញឲ្យប្រជាពលរដ្ឋទាំងនោះឋិតលើបន្ទាត់ភាពក្រីក្រវិញនៅ ឆ្នាំ២០១១។

**របកគំហើញពីការសិក្សាផ្សេងៗទៀតក៏បានបង្ហាញថាជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជាត្រូវបានលើកកម្ពស់។ របកគំហើញទាំងនេះបញ្ជាក់ឲ្យឃើញថាការគណនាដែលបង្ហាញថា ភាពក្រីក្រមានការធ្លាក់ចុះពិតជាត្រឹមត្រូវ។** ឧទាហរណ៍ទី១៖ របាយការណ៍វាយតម្លៃវឌ្ឍនភាពរបស់បណ្តាប្រទេសនានាលើគោលដៅសហស្សវត្សរ៍បានរកឃើញថា កម្ពុជាជាប់ចំណាត់ថ្នាក់ទី ៥ ក្នុងចំណោម ៧៦ ប្រទេស ដែលមានវឌ្ឍនភាពយ៉ាងល្អក្នុងការសម្រេចបានគោលដៅសហស្សវត្សរ៍។ ឧទាហរណ៍ទី២៖ របាយការណ៍របស់ភ្នាក់ងារអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ស្តីអំពីសូចនាករនៃការអភិវឌ្ឍមនុស្សបានរកឃើញថា ចាប់ពីឆ្នាំ ២០០០ រហូតដល់ ឆ្នាំ ២០១០ កម្ពុជាជាប់ចំណាត់ថ្នាក់ជាប្រទេស ដែលមានការរីកចម្រើនខាងផ្នែកអភិវឌ្ឍន៍

**ក្រាហ្វិក ខ.១៖** អត្រាភាពក្រីក្រនៅកម្ពុជា ឆ្នាំ២០០៤- ២០១១




**ក្រាហ្វិក ខ.២៖** របាយនៃការចំណាយរបស់ប្រជាពលរដ្ឋកម្ពុជា




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ផ្អែកតាមអ.ស.ស.ក។

មនុស្សហើយ ការវិវត្តន៍មានភាពប្រសើរជាងបណ្តាប្រទេសមួយចំនួនដូចជាប្រទេស ចិន ឡាវ និងវៀតណាម។

## កត្តាសំខាន់ៗដែលជួយកាត់បន្ថយភាពក្រីក្រ

**គោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលបានផ្តល់ឱកាសឲ្យប្រជាពលរដ្ឋជាច្រើនគ្រួសារអាចចាកផុតពីភាពក្រីក្រ។** គោលនយោបាយទាំងនោះរួមមាន៖ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តមានដូចជា ផ្លូវទូរគមនាគមន៍ និងប្រព័ន្ធធារាសាស្រ្ត, ការជំរុញផលិតកម្ម និងពាណិជ្ជកម្មស្រូវអង្ករ, ការកំណត់ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យកាត់ដេរ, និងគោលនយោបាយឧស្សាហកម្មទូទៅ ដែលគោលនយោបាយទាំងនេះបានផ្តល់ឱកាសសម្រាប់ប្រជាពលរដ្ឋក្រីក្រទាញយកផលប្រយោជន៍បម្រើដល់ជីវភាពរបស់ខ្លួន។

ដើម្បីកំណត់កត្តាសំខាន់ៗ ដែលបានជួយកាត់បន្ថយភាពក្រីក្រ របាយការណ៍នេះបានធ្វើនិម្មិតកម្មមួយដោយពិនិត្យកត្តាសំខាន់ៗនានា ដែលជំរុញប្រាក់ចំណូលរបស់ប្រជាពលរដ្ឋកើនឡើង ហើយពិនិត្យមើលឥទ្ធិពលនៃកត្តាទាំងនោះលើភាពក្រីក្រ។ យើងប្រើព័ត៌មានអង្កេតសេដ្ឋកិច្ចសង្គម ដើម្បីពិនិត្យមើលបម្រែបម្រួលឥរិយាបថគ្រួសារប្រជាពលរដ្ឋពាក់ព័ន្ធនឹងប្រាក់ចំណូល និងព័ត៌មានកសិកម្មរបស់ពួកគាត់ពី ឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១។ យើងក៏ប្រើប្រភពទិន្នន័យផ្លូវការផ្សេងទៀតដែរមានជាអាទិ៍ ផលិតកម្មស្រូវ តម្លៃអង្ករ អតិផរណាទូទៅ ដើម្បីប៉ាន់ស្មានឥទ្ធិពលនៃបម្រែបម្រួលតម្លៃអង្ករលើជីវភាពរបស់ប្រជាពលរដ្ឋ។

**ក្រាហ្វិក គ៖** កត្តាសំខាន់ៗក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ឆ្នាំ ២០០៤ ដល់២០១១




**លទ្ធផលបានបង្ហាញថា ការកាត់បន្ថយភាពក្រីក្រមួយភាគធំកើតមាននៅទីជនបទរបស់កម្ពុជា ជាទីដែលប្រជាពលរដ្ឋក្រីក្រប្រមាណ ៩០ ភាគរយរស់នៅ ហើយកត្តានាំមុខនៃការកាត់បន្ថយភាពក្រីក្រនេះ គឺការធ្វើស្រែចម្ការ។** ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩ ថ្លៃអង្ករ (គិតជាថ្លៃគោល) បានកើនឡើង ៣៧,១ ភាគរយ។ កំណើនតម្លៃស្រូវបានជួយកសិករយ៉ាងច្រើន ព្រមទាំងបានលើកទឹកចិត្តឲ្យកសិករប្រឹងប្រែងផលិតស្រូវបន្ថែមទៀត។ និម្មិតកម្មនេះបានបង្ហាញថា កត្តាសំខាន់ៗដែលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅទីជនបទរួមមាន៖ កត្តាកំណើនថ្លៃស្រូវខ្ពស់ (២៤ ភាគរយ), កត្តាកំណើនផលិតកម្មស្រូវ (២៣ ភាគរយ), អត្រាថ្លៃឈ្នួលពលកម្មខ្ពស់ជាងមុន (១៦ ភាគរយ), និងកំណើនប្រាក់ចំណូលពីការប្រកបរបរជំនួញតូចតាច (១៩ ភាគរយ)។[3] (**ក្រាហ្វិក គ**)

**ការកាត់បន្ថយភាពក្រីក្រនៅតាមទីប្រជុំជនដោយសារកំណើនប្រជាពលរដ្ឋធ្វើការមានប្រាក់បៀវត្សរ៍ជាប្រចាំ។** ក្នុងចំណោមកម្លាំងពលកម្មទាំងអស់តាមតំបន់ប្រជុំជន អត្រាអ្នកធ្វើការមានប្រាក់បៀវត្សរ៍ជាប្រចាំមាន៥០ភាគរយនៅឆ្នាំ២០១១។ កម្លាំងពលកម្មនៅតាមទីប្រជុំជនមានកម្រិតវប្បធម៌ខ្ពស់ជាងកម្លាំងពលកម្មនៅតាមតំបន់ជនបទ ហេតុនេះហើយ ទើបពួកគេអាចរកចំណូលបានខ្ពស់។

**កម្លាំងពលកម្មស្ត្រីភាគច្រើនបានទទួលអត្ថប្រយោជន៍ពីឧស្សាហកម្មកាត់ដេរ ប៉ុន្តែគម្លាតប្រាក់បៀវត្សរ៍នៅតែមាន។** ក្នុងចំណោមឧស្សាហកម្មនានាដែលផ្តល់ការងារមានប្រាក់បៀវត្សរ៍ជាប្រចាំដល់កម្មករ ឧស្សាហកម្មកាត់ដេរជាឧស្សាហកម្មដ៏សំខាន់មួយ ដែលផ្តល់ការងារជូនប្រជាពលរដ្ឋ។ កម្មករប្រមាណ ៨៥ ភាគរយ ធ្វើការក្នុងឧស្សាហកម្មកាត់ដេរជាស្ត្រី។ ជាទូទៅ កម្មការនីក្នុង

ឧស្សាហកម្មនេះទទួលបានប្រាក់បៀវត្សរ៍ខ្ពស់ជាងកម្មការនីក្នុងឧស្សាហកម្មផ្សេងទៀត ប៉ុន្តែប្រាក់បៀវត្សរ៍ របស់ស្ត្រីនៅតែមានកម្រិត ៣០ ភាគរយ តិចជាងប្រាក់បៀវត្សរ៍របស់បុរស បើទោះជាពួកគេមានកម្រិតវប្បធម៌ និងអាយុប្រហាក់ប្រហែលគ្នាក៏ដោយ។

## លើកកម្ពស់ការអភិវឌ្ឍមនុស្ស

**សុខភាព និងការអប់រំល្អជួយជំរុញសុខុមាលភាពរបស់ប្រជាពលរដ្ឋ ហើយកត្តាទាំងពីរនេះជួយបំពេញឲ្យគ្នាទៅវិញទៅមក។** ប្រជាពលរដ្ឋដែលមានសុខភាពល្អនឹងបំពេញកិច្ចការងារគ្រប់យ៉ាងបានលទ្ធផលប្រសើរ។ ប្រជាពលរដ្ឋដែលមានសុខភាពល្អមិនគ្រាន់តែបំពេញកិច្ចការងារប្រកបដោយគុណភាពប៉ុណ្ណោះទេ ប៉ុន្តែពួកគេនឹងមានលទ្ធភាពបំពេញការងារមានគម្រោងផែនការចាត់ចែងល្អិតល្អន់ និងអាចបំពេញកិច្ចការងារច្រើនដំណាលគ្នាបាន។ ប្រជាពលរដ្ឋដែលមានចំណេះវិជ្ជាជ្រៅជ្រះនឹងជួយបង្កើតឲ្យមានឱកាសការងារមានប្រាក់ខែខ្ពស់។ ចំណេះវិជ្ជាក៏ជួយឲ្យប្រជាពលរដ្ឋដែលប្រកបមុខរបរដោយខ្លួនឯង ឲ្យមានលទ្ធភាពបែងចែកមុខជំនួញរបស់ពួកគេបានប្រសើរ និងបង្កើនចំណូលពីការវិនិយោគ និងពលកម្មរបស់ពួកគេផងដែរ។ បន្ថែមលើសពីនេះទៀត កត្តាសុខភាព និងអប់រំនឹងជួយបំពេញឲ្យគ្នាទៅវិញទៅមក។ ឧទាហរណ៍៖ កុមារដែលខ្វះជីវជាតិប្រហែលជាមិនអាចដើរទៅសាលារៀនទេ ហើយសមត្ថភាពរបស់កុមារក្នុងការរៀនក៏នឹងត្រូវថមថយ។ ដូចគ្នានេះដែរ ម្តាយដែលមានកម្រិតវប្បធម៌ នឹងប្រើចំណេះដឹងរបស់គាត់ដែលទទួលបានពីសាលា ដើម្បីចិញ្ចឹមបីបាច់កូនរបស់គាត់ឲ្យមានសុខភាពល្អ។

**គេសង្កេតឃើញថា សូចនាករវិស័យអប់រំ និងសុខាភិបាលជាច្រើនត្រូវបានលើកកម្ពស់ដោយសារសាលារៀន និងមន្ទីរពេទ្យកាន់តែខិតទៅជិតប្រជាពលរដ្ឋ។** ចាប់តាំងពីឆ្នាំ២០០៤ ដល់ ឆ្នាំ២០១១ គេសង្កេតឃើញថា សូចនាករវិស័យអប់រំ និងសុខាភិបាលជាច្រើនត្រូវបានលើកកម្ពស់មានជាអាទិ៍៖ មនុស្សពេញវ័យអាយុ ២៥ ឆ្នាំឡើងដែលបានបញ្ចប់បឋមសិក្សាបានកើនឡើង ១០ ភាគរយ, អត្រាអ្នកចេះអក្សរក្នុងចំណោមមនុស្សពេញវ័យអាយុ ១៥-២៤ ឆ្នាំ បានកើនឡើង ១១ ភាគរយ, គម្លាតរវាងបុរស និងស្ត្រីដែលចេះអក្សរត្រូវបានកាត់បន្ថយពី ៧,៤ ភាគរយ មកក្រោម ១ ភាគរយ។ អត្រាចុះឈ្មោះចូលរៀនពិតនៅមធ្យមសិក្សាបានកើនឡើង ១៨,៤ ភាគរយ។ លើសពីនេះទៀត គេលែងឃើញមានគម្លាតរវាងកុមារា និងកុមារីក្នុងអត្រាចុះឈ្មោះចូលរៀនពិតទាំងកម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាទៀតហើយ។ សម្រាប់សូចនាករខាងសុខាភិបាលវិញ គេក៏ឃើញមានការរីកចម្រើនគួរឲ្យកត់សម្គាល់ពី ឆ្នាំ២០០៥ដល់ឆ្នាំ២០១០។ ឧទាហរណ៍៖ អត្រាមរណមាតាបានធ្លាក់ចុះពី ៤៣៧នាក់ នៃ ១០០.០០០ កំណើតរស់ មកត្រឹម ២៨៨ នាក់, អត្រាមរណទារកអាយុពី ០-១ ខែ បានធ្លាក់ចុះពី ៣០ នាក់ នៃ ១.០០០ កំណើតរស់ មកត្រឹម ២៥ នាក់, អត្រាមរណទារកអាយុពី ១-១២ ខែ បានធ្លាក់ចុះពី ៦៦ នាក់នៃ ១.០០០ កំណើតរស់មកត្រឹម ៤៥នាក់, អត្រាមរណកុមារអាយុ១-៥ ឆ្នាំ បានធ្លាក់ចុះពី ៣៧ នាក់ នៃកំណើតរស់មកត្រឹម ២២ នាក់។ ទារកដែលទើបនឹងកើតមកទទួលបាននូវការចាក់វ៉ាក់សាំងបានកើនឡើងពី ៧៩ ភាគរយ ដល់ ៩៣ ភាគរយ ទារកដែលទើបនឹងកើតមកទទួលវ៉ាក់សាំង DTB បានកើនឡើងពី ៨២ ភាគរយ ដល់ ៩២ ភាគរយ។ ហើយការសំរាលកូនដោយឆ្មបជំនាញ បានកើនឡើងពី ៤៤ ភាគរយ ដល់ ៧១ ភាគរយ។

**ក្នុងវិស័យសុខាភិបាល អ្វីដែលមិនមានការរីកចម្រើននោះគឺបញ្ហាកុមារខ្វះជីវជាតិ។** ទោះបីជា បញ្ហាកុមារខ្វះជីវជាតិបានធ្លាក់ចុះយ៉ាងច្រើនកាលពី ឆ្នាំ២០០០ ដល់ឆ្នាំ២០០៥ ក៏ដោយ ប៉ុន្តែចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ មក គេឃើញវឌ្ឍនភាពនេះមានកម្រិតនៅឡើយ ឬអាចអាក្រក់ជាងមុនទៅវិញ។ ឧទាហរណ៍៖ អត្រាកុមារគ្រិនអាយុ០-៦០ ខែបានធ្លាក់ចុះពី ៤២ ភាគរយ មកត្រឹម៤០ ភាគរយប៉ុណ្ណោះ។ អត្រាកុមារស្គមស្គាំងនៅដដែលក្នុងកម្រិត ៣៨ ភាគរយ។ គេមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងអំពីស្ថានភាពកង្វះជីវជាតិពីព្រោះតាមការអង្កេតនានា យើងឃើញថា ការចំណាយរបស់គ្រួសារប្រជាពលរដ្ឋលើចំណីអាហារបានកើនឡើងគួរឲ្យកត់សម្គាល់ ប៉ុន្តែបញ្ហាកង្វះជីវជាតិ បែរជាមិនមានការប្រែប្រួលជាវិជ្ជមានទៅវិញ។

គេមិនទាន់រកឃើញពីមូលហេតុច្បាស់លាស់នៅឡើយទេ ប៉ុន្តែអ្នកវិភាគជាច្រើនបានយល់ស្របគ្នាថា ដើម្បីដោះស្រាយបញ្ហាកង្វះអាហាររូបត្ថម្ភ គេត្រូវមានវិធានការពហុវិស័យ ក្រៅតែពីជំរុញឲ្យមានម្ហូបអាហារទទួលទានគ្រប់គ្រាន់ ហើយវិធានការទាំងនោះរួមមាន ដោះស្រាយបញ្ហាគុណភាព ចំណីអាហារ កាត់បន្ថយ ការបន្ទោរបង់ពាសវាលពាសកាល និងលើកកម្ពស់អនាម័យលាងដៃឲ្យបានស្អាត លាងសម្អាតចំណីអាហារ និងរបស់របរផ្សេងៗឲ្យបានស្អាត។ ការសិក្សានានាបានរកឃើញថា អត្រាភាគរយកុមារក្រិនមានច្រើនក្នុងចំណោមក្រុមប្រជាពលរដ្ឋក្រីក្រ ក្រុមគ្រួសារប្រជាពលរដ្ឋដែលម្តាយមានកម្រិតវប្បធម៌ទាប និងនៅតាមភូមិ ដែលមានប្រជាពលរដ្ឋជាងពាក់កណ្តាលបន្ទោរបង់ពាសវាលពាសកាល។

**គេឃើញក្រុមប្រជាពលរដ្ឋក្រីក្រមានបញ្ហាសុខភាពញឹកញាប់ជាងប្រជាពលរដ្ឋមិនមែនក្រីក្រ។** ក្រុមប្រជាពលរដ្ឋក្រីក្រមានបញ្ហាសុខភាពធ្ងន់ធ្ងរដូចជា៖ អត្រាមរណកុមារមិនមានលទ្ធភាពធ្វើផែនការយកកូន មិនសូវបានទៅពិនិត្យសុខភាពអំឡុងពេលមានផ្ទៃពោះ (ឲ្យបានយ៉ាងតិច ៤ ដង) និងសម្រាលកូនពុំមានឆ្មបជំនាញ។ កម្មវិធីសមធម៌សុខាភិបាល និងកម្មវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ IDPoor បានជួយឲ្យប្រជាពលរដ្ឋក្រីក្រមានលទ្ធភាពទៅព្យាបាលសុខភាពនៅមន្ទីរពេទ្យ និងមណ្ឌលសុខភាព ប៉ុន្តែលទ្ធភាពគ្របដណ្តប់របស់កម្មវិធីសុខភាពនេះ នៅមានកម្រិតនៅឡើយ។ ឧទាហរណ៍៖ ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រដែលទៅរកសេវាសុខាភិបាល មានតែប្រជាពលរដ្ឋ ៣០ ភាគរយ ប៉ុណ្ណោះ ដែលរាយការណ៍ថា ពួកគាត់បានទទួលការព្យាបាលដោយឥតគិតថ្លៃ ឬព្យាបាលដោយមានការឧបត្ថម្ភពីកម្មវិធីសមធម៌។

**សម្រាប់ប្រជាពលរដ្ឋក្រីក្រ គេសង្កេតឃើញថា ពួកគាត់ភាគច្រើនបានទៅរកសេវាព្យាបាលសុខភាពពីសេវាឯកជនដែលពុំមានជំនាញច្បាស់លាស់។** ប្រជាពលរដ្ឋក្រីក្រជាងពាក់កណ្តាលបានទៅរកសេវាព្យាបាលពីហាងឬឱសថស្ថាន ដែលពុំមានជំនាញច្បាស់លាស់ ហើយបើធៀបនឹងប្រជាពលរដ្ឋអ្នកមានវិញ គឺមានតែ ១៧,៩ ភាគរយប៉ុណ្ណោះ។ សេវាសុខាភិបាលទាំងនោះពុំមានការគ្រប់គ្រងពីរដ្ឋច្បាស់លាស់ទេ ហើយគេឃើញមានរបាយការណ៍ជាញឹកញាប់ថា សេវាសុខាភិបាលទាំងនោះបានផ្តល់ការពិគ្រោះសុខភាព និងផ្តល់ថ្នាំព្យាបាលខុសធ្ងន់ធ្ងរជារៀងរាល់ថ្ងៃ។

**ទោះបីជាវិស័យអប់រំ និងសុខភាពត្រូវបានកែលម្អយ៉ាងច្រើនក្តី ប៉ុន្តែការកែលម្អនេះធ្វើឡើងពីកម្រិតយ៉ាប់យ៉ឺនកាលពីពេលមុន។** បញ្ហានេះមានស្ទើរតែគ្រប់សូចនាករទាំងអស់។ ឧទាហរណ៍៖ គិតមកត្រឹម ឆ្នាំ ២០១១ អត្រាមនុស្សពេញវ័យ អាយុ ២៥ ឆ្នាំដែលបញ្ចប់បឋមសិក្សាមានតែ ២៩ ភាគរយ ប៉ុណ្ណោះ អត្រាចេះអក្សរក្នុងចំណោមមនុស្សពេញវ័យអាយុ១៥-២៤ ឆ្នាំ មានតែ ១១,១ ភាគរយប៉ុណ្ណោះ អត្រាចុះឈ្មោះពិតនៅបឋមសិក្សាមាន ៤៨,៨ ភាគរយ ហើយអត្រាចុះឈ្មោះចូលរៀនពិតមាន ៥៤,២ ភាគរយ អត្រាមរណរបស់មាតានិងកុមារនៅកម្ពុជានៅតែមានកម្រិតខ្ពស់ជាងមធ្យមភាគរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់នៅអាស៊ី និង ប៉ាស៊ីហ្វិច (ប្រហែលពីរដង)។ ចំពោះប្រជាពលរដ្ឋក្រីក្រ ការលើកកម្ពស់ខាងអប់រំ និងសុខភាពនៅតែមានកម្រិតទាបជាងប្រជាពលរដ្ឋ ដែលមានជីវភាពមធ្យមនៅឡើយ។

**បញ្ហាធំបំផុតនៅកម្រិតបឋមសិក្សា គឺការចូលរៀនយឺតរបស់កុមារ ដែលត្រូវចូលរៀនថ្នាក់ទីមួយ។** ក្នុងចំណោមកុមារចុះឈ្មោះចូលរៀនថ្នាក់ទីមួយ គឺមានចំនួន ៤០ ភាគរយនៃកុមារទាំងនោះ ចូលរៀនយឺតរយៈពេលពីរឆ្នាំ ហើយកុមារទាំងនោះភាគច្រើនបោះបង់ការសិក្សាជាហេតុធ្វើឲ្យជាមធ្យមគិតត្រឹមថ្នាក់ទី ៦ ពួកគេខាតពេលអស់រយៈពេល ៣,១ឆ្នាំ។ មូលហេតុនេះហើយ ទើបគេសង្កេតឃើញថា កុមារភាគច្រើនបញ្ចប់បឋមសិក្សានៅអាយុ ១៥ ឆ្នាំ មិនមែននៅអាយុ១២ ឆ្នាំទេ។ ការដែលកុមារលើសអាយុហើយទៅចូលរៀន គេសង្កេតឃើញថាពួកគេប្រឈមនឹងបញ្ហាពីរយ៉ាង។ ទីមួយ កុមារដែលចូលរៀនយឺតធ្វើឲ្យខកខានពេលវេលា សម្រាប់ការវិវត្តន៍ខួរក្បាល ហើយជាមូលហេតុដែលធ្វើឲ្យកុមាររៀនមិនសូវឆ្លាត។ ទីពីរ ការដែលកុមារចូលរៀនយឺតអាចបង្កឲ្យពួកគេបោះបង់ការសិក្សាលឿន ដែលនេះជាមូលហេតុ

នាំឲ្យប៉ះពាល់ដល់អត្រាចុះឈ្មោះចូលរៀនពិត និងបន្តការសិក្សានៅកម្រិតមធ្យមសិក្សា។

**មូលហេតុចម្បងៗដែលកុមារចុះឈ្មោះចូលរៀនតិច ការបន្តការសិក្សាតិច និង បោះបង់ការសិក្សាច្រើននៅកម្រិតមធ្យមសិក្សា គឺដោយសារបញ្ហាសេដ្ឋកិច្ច និងចម្ងាយរបស់សាលា។** ចំនួនសាលារៀនត្រូវបានបង្កើនយ៉ាងច្រើន ប៉ុន្តែចម្ងាយរបស់សាលារៀននៅតែជាឧបសគ្គសម្រាប់ក្មេងៗរៀននៅមធ្យមសិក្សា។ មូលហេតុមួយទៀតដែលធ្វើឲ្យចំនួនកុមារដែលឆ្លងទៅមធ្យមសិក្សាមានចំនួនតិច ដោយសារតែពួកគេបានចូលរៀនយឺតនៅកម្រិតបឋមសិក្សា ហើយមួយចំនួនទៀត ពេលបន្តការសិក្សាមិនបានប៉ុន្មានផង ក៏បោះបង់ចោលការសិក្សាតែម្តង។ មូលហេតុចម្បងដែលគេរកឃើញពាក់ព័ន្ធនឹងបញ្ហានេះច្រើនកើតឡើងចំពោះកុមារី។ មូលហេតុផ្សេងទៀតដូចជាការជួយកិច្ចការផ្ទះដែលជាកត្តារារាំងមិនឲ្យកុមារទៅរៀនកើតឡើងតែតិចជាង១៤ភាគរយនៃកុមារបោះបង់ការសិក្សាប៉ុណ្ណោះ (អត្រានេះមិនមានភាពខុសគ្នារវាងកុមារា និងកុមារីទេ)។

**គេសង្កេតឃើញថា ការបញ្ចប់ការសិក្សារបស់ប្រជាពលរដ្ឋក្រីក្រប្រជាពលរដ្ឋជនជាតិភាគតិច និងប្រជាពលរដ្ឋ នៅតាមទីជនបទនៅមានកម្រិតទាបនៅឡើយ។** បញ្ហាដែលកើតមានទាំងអម្បាលមាណខាងលើនេះកើតមានចំពោះគ្រប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ប៉ុន្តែបញ្ហានេះកើតមានយ៉ាងធ្ងន់ធ្ងរចំពោះប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋជនជាតិភាគតិច។ នេះជាមូលហេតុធ្វើឲ្យមានគម្លាតអត្រាចុះឈ្មោះចូលរៀនពិតនៅមធ្យមសិក្សារវាងកុមារក្នុងគ្រួសារអ្នកមាន និងកុមារក្នុងគ្រួសារអ្នកក្រមានការកើនឡើងខ្លាំងនៅឡើយ។

**ក្រៅពីមូលនិធិសមធម៌ក្នុងវិស័យសុខាភិបាល និងកម្មវិធីអាហាររូបករណ៍អប់រំ គេពុំឃើញមានកម្មវិធីគាំពារសង្គមធំៗដែលរដ្ឋជាអ្នកផ្តល់មូលនិធិទេ។** កម្មវិធីនានាពាក់ព័ន្ធនឹងកិច្ចការគាំពារសង្គមហាក់ដូចជាទស្សនាទានថ្មីសម្រាប់រាជរដ្ឋាភិបាល ហើយការគាំពារសង្គមនៅកម្ពុជាភាគច្រើន គឺនៅក្រៅប្រព័ន្ធផ្លូវការរបស់រដ្ឋ ដូចជាការជួយពីសាច់ញាតិ មិត្តភក្តិ និងវត្តអារាម។ ការជួយគាំពារទាំងនោះភាគច្រើនជាម្ហូបអាហារ ហើយធ្វើឡើងនៅពេលមានវិបត្តិផ្សេងៗ ដូចជាពេលមានគ្រោះធម្មជាតិជាដើម។

**យុទ្ធសាស្ត្រជាតិគាំពារសង្គមមិនទាន់ត្រូវបានអនុវត្តនៅឡើយទេ។** កាលពី ឆ្នាំ២០១១ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយុទ្ធសាស្ត្រជាតិគាំពារសង្គម ដែលជាយុទ្ធសាស្ត្រលើកដំបូងបង្អស់ទាក់ទងនឹងការគាំពារសង្គមនៅកម្ពុជា។ យុទ្ធសាស្ត្រនេះត្រូវបានដាក់ចេញនូវក្របខណ្ឌការងារគាំពារសង្គមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រកបដោយនិរន្តរភាព សម្រាប់ជួយដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ក្នុងរយៈពេលវែង។ ទោះបីជាយុទ្ធសាស្ត្រនេះមានកម្មវិធីដែលតម្រូវឲ្យប្រជាពលរដ្ឋដាក់វិភាគទានផ្ទាល់ខ្លួន ដើម្បីផ្តល់មូលដ្ឋានគោលការណ៍គ្រឹះនានាក៏ដោយ ក៏ការអនុវត្តយុទ្ធសាស្ត្រនេះនៅមានភាពយឺតយ៉ាវនៅឡើយ។ គិតមកត្រឹម ឆ្នាំ២០១៣ គេសង្កេតឃើញមានការរៀបចំឲ្យមានគំនិតផ្តួចផ្តើមតិចតួចប៉ុណ្ណោះដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ។

## មេរៀននានាដែលមានកន្លងមក

ដើម្បីកាត់បន្ថយភាពក្រីក្រឲ្យបានច្រើន គេត្រូវអនុវត្តសកម្មភាពទាំងឡាយណា ដែលផ្តោតនៅតាមតំបន់នានាដែលប្រជាពលរដ្ឋក្រីក្ររស់នៅ ហើយសកម្មភាពទាំងអស់ត្រូវជួយដល់ការប្រើប្រាស់ទ្រព្យ ដែលប្រជាពលរដ្ឋក្រីក្រមាន។ មានមេរៀនចំនួនពីរពីការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១។ មេរៀនទីមួយ គឺការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋត្រូវធ្វើនៅតាមទីជនបទ ដើម្បីឲ្យការកាត់បន្ថយភាពក្រីក្របានលឿន (ពីព្រោះក្នុងចំណោមប្រជាពលរដ្ឋក្រីក្រ ១០ នាក់ មាន ៩ នាក់រស់នៅតាមទីជនបទ)។ មេរៀនទីពីរ គឺសកម្មភាពនានាត្រូវតែពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ច ដែលប្រជាពលរដ្ឋក្រីក្របានចូលរួម ក្នុងនោះមានការងារកសិកម្ម ហើយសកម្មភាពនានាធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋក្រីក្រប្រើប្រាស់ឲ្យបានអតិប្បរមានូវទ្រព្យសំខាន់ៗពីរដែលពួកគេមាន គឺ ដីធ្លី និងកម្លាំងពលកម្ម។

**ចាប់ពីឆ្នាំ២០០៤ ដល់ ឆ្នាំ២០១១ ប្រជាពលរដ្ឋក្រីក្រជាងពាក់កណ្តាលទាំងអ្នកនៅតាមទីជនបទ និងនៅតាមទីប្រជុំជនមានលទ្ធភាពប្រើប្រាស់ទ្រព្យ ដែលគេមានគឺ ដីធ្លីនិងកម្លាំងពលកម្ម ដើម្បីរកចំណូលជាអតិបរមា។** ប្រការនេះបានជួយឲ្យពួកគេភាគច្រើនចាកចេញពីភាពក្រីក្រ។ គេក៏សង្កេតឃើញថា កត្តាសំខាន់ៗមួយចំនួនទៀតបានជួយសម្រួលជីវភាពរបស់ប្រជាពលរដ្ឋក្រីក្រ ក្នុងនោះរួមមានហេដ្ឋារចនាសម្ព័ន្ធ និងទូរគមនាគមន៍ប្រសើរជាងមុន លក្ខខណ្ឌសេដ្ឋកិច្ចអំណោយផល និងគោលនយោបាយរដ្ឋអនុញ្ញាតឲ្យមានការធ្វើពាណិជ្ជកម្មដោយសេរី។ គោលនយោបាយរដ្ឋដែលមិនដាក់ពន្ធធ្ងន់ធ្ងរដល់វិស័យកសិកម្ម និងគោលនយោបាយឧស្សាហកម្ម ដែលគាំទ្រដល់ការរីកចំរើននៃវិស័យឧស្សាហកម្ម ក៏បានជួយសម្រួលជីវភាពប្រជាពលរដ្ឋឲ្យបានធូរជារដែរ។ កត្តាគោលនយោបាយទាំងនេះ បានអនុញ្ញាតឲ្យប្រជាពលរដ្ឋជ្រើសរើសការប្រកបរបរចិញ្ចឹមជីវិតដោយសេរី ហើយបានជួយឲ្យពួកគេទទួលបានអត្ថប្រយោជន៍នានា ដើម្បីចាកចេញពីភាពក្រីក្រ។

**បើទោះបីជាកត្តានាំមុខទាំងនេះបានធ្វើឲ្យភាពក្រីក្រធ្លាក់ចុះក៏ដោយ ក៏កត្តានាំមុខទាំងនេះអាចនឹងគាំងនាពេលអនាគត។** ជាអាទិ៍ ការកើនឡើងនៃតម្លៃស្រូវអង្ករមានផលប៉ះពាល់ជាវិជ្ជមានដល់ជីវភាពរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្ររបស់ប្រទេស ប៉ុន្តែតម្លៃស្រូវអង្ករនេះទំនងជាមិនអាចកើនឡើងទៀតទេ។ ដូច្នេះគោលនយោបាយដើម្បីកាត់បន្ថយភាពក្រីក្រនាពេលអនាគតមិនត្រូវរំពឹង លើការកើនឡើងថ្លៃស្រូវអង្ករទេ។

**កម្ពុជាមិនមានគោលនយោបាយត្រួតត្រាតម្លៃទំនិញទេ ហើយរដ្ឋក៏មិនបានបង្កើតឲ្យមានឧបសគ្គនានាដល់ការប្រកបមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដោយសេរីទេ។** នេះជារឿងដ៏ត្រឹមត្រូវដែលរដ្ឋបានធ្វើ។ បទពិសោធន៍ពីបណ្តាប្រទេសនានាលើសកលលោកបង្ហាញថា ការត្រួតត្រាថ្លៃទំនិញពីរដ្ឋមិនត្រឹមតែកំហិតការប្រកបមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដោយសេរីប៉ុណ្ណោះទេ ប៉ុន្តែក៏បានកំហិតដល់ការរីកចម្រើនជីវភាពរបស់ប្រជាពលរដ្ឋដែរ។ បទពិសោធន៍នេះ ក៏បានបង្ហាញថា ការត្រួតត្រាថ្លៃទំនិញគ្រាន់តែជាការយកផលប្រយោជន៍ពីក្រុមប្រជាពលរដ្ឋមួយក្រុមទៅឲ្យប្រជាពលរដ្ឋមួយក្រុមទៀតតែប៉ុណ្ណោះ ហើយជារឿយៗ មិនបានជួយដល់ក្រុមប្រជាពលរដ្ឋក្រីក្រទេ។ ដូចករណីកម្ពុជា ប្រជាពលរដ្ឋក្រីក្រភាគច្រើនជាអ្នកស្រែចម្ការ ប្រសិនបើរដ្ឋធ្វើការត្រួតត្រាតម្លៃកសិផលនេះមានន័យថា រដ្ឋនឹងយកអត្ថប្រយោជន៍ពីប្រជាពលរដ្ឋក្រីក្រទៅវិញទេ។ ម្យ៉ាងទៀតការត្រួតត្រារបស់រដ្ឋលើតម្លៃទំនិញនឹងបង្កការលំបាក និងកំហិតដល់ចលនាប្រកបមុខរបរចិញ្ចឹមជីវិតដោយសេរីរបស់ប្រជាប្រជាពលរដ្ឋ នៅពេលដែលស្ថានភាពសេដ្ឋកិច្ចប្រែប្រួល។

**មិនមែនរាល់ការកាត់បន្ថយភាពក្រីក្រទាំងអស់ គឺដូចៗគ្នាទេ។** ល្បឿននៃការកាត់បន្ថយភាពក្រីក្រអាចកើតឡើងខុសៗគ្នា អាស្រ័យលើក្រុមប្រជាពលរដ្ឋណាខ្លះដែលបានទទួលប្រយោជន៍ពីកំណើនសេដ្ឋកិច្ច ហើយកម្រិតរបស់វាអាស្រ័យលើទំហំនៃកំណើនចំណូលនិងការចាយវាយ។ នៅកម្ពុជា គេសង្កេតឃើញថា ការកាត់បន្ថយភាពក្រីក្រ ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ មាន ល្បឿនលឿន ក៏ប៉ុន្តែប្រជាពលរដ្ឋភាគច្រើនមានជីវភាពធូរជារបន្តិចបន្តួចប៉ុណ្ណោះ។ ប្រជាពលរដ្ឋភាគច្រើននៅតែងាយធ្លាក់ចូលក្នុងភាពក្រីក្រវិញ ប្រសិនបើជួបគ្រោះតូចមួយក៏ដោយ។

**ការអនុវត្តយុទ្ធសាស្រ្តជាតិគាំពារសង្គមទាមទារឲ្យមានការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការនានាពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់របស់រដ្ឋ។** គេត្រូវទទួលស្គាល់ថា ការអនុវត្តយុទ្ធសាស្រ្តជាតិគាំពារសង្គមឲ្យបានជោគជ័យ ទាមទារឲ្យមានកិច្ចសហប្រតិបត្តិការពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនានា មិនត្រឹមតែលើការកំណត់គោលដៅប៉ុណ្ណោះទេ ប៉ុន្តែលើបញ្ហានានា ធ្វើយ៉ាងណាឲ្យសម្រេចគោលដៅទាំងនោះ។ គេពិនិត្យឃើញថា ស្ថាប័នដែលអនុវត្តគោលនយោបាយជាតិនេះត្រូវការឲ្យមានការគាំទ្រខ្លាំងក្លា ជាពិសេសនៅដំណាក់កាលដំបូងៗ ហើយគំនិតផ្តួចផ្តើមលើការអនុវត្តការគាំពារសង្គមថ្មីៗតម្រូវឲ្យមានការចូលរួមគាំទ្រពីក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់។

**ទ្រព្យដែលប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះមាន គឺមិនមែននៅឋិតថេររហូតទេ តែអាចប្រែប្រួលពីពេលមួយទៅពេលមួយ។** វិធីមួយទៀតដើម្បីជួយជីវភាពប្រជាពលរដ្ឋក្រីក្រឲ្យមានជីវភាពធូធារ គឺការបង្កើនទ្រព្យរបស់ពួកគេ។ ការបង្កើនទ្រព្យឲ្យប្រជាពលរដ្ឋទាំងនោះ អាចធ្វើបានតាមរយៈផ្តល់ឱកាសថ្មីៗ ដើម្បីឲ្យពួកគេអាចបានចំណូលច្រើនជាងមុនពីសកម្មភាពដែលគេធ្វើប្រចាំថ្ងៃ ឬក៏អាចធ្វើឡើងតាមរយៈការជំរុញឲ្យពួកគេប្រកបរបរផ្សេងៗ។ ការជំរុញនេះត្រូវធ្វើឡើងដោយរដ្ឋដែលជាអ្នកផ្តល់សេវាអប់រំនិងការថែទាំសុខភាព។ ចំពោះគោលនយោបាយនានាពាក់ព័ន្ធនឹងសេវាអប់រំ និងការថែទាំសុខភាពមានបង្ហាញជូនបន្ថែមនៅក្នុងផ្នែកពាក់ព័ន្ធនឹង អនុសាសន៍គោលនយោបាយ។

## អនុសាសន៍គោលនយោបាយសំខាន់ៗ

### ធ្វើឲ្យសេដ្ឋកិច្ចជនបទមានភាពខ្លាំងក្លា

**បន្តវិនិយោគលើការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ។** គេរំពឹងថា ប្រជាពលរដ្ឋក្រីក្រនឹងបានទទួលផលពីការកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ដែលក្នុងនោះរួមមាន ការកែលម្អផ្លូវលំជនបទ ការពង្រីកប្រព័ន្ធស្រោចស្រព ការផ្តល់នូវអគ្គិសនីប្រើប្រាស់ ទឹកស្អាត និង បង្គន់អនាម័យ។

**បង្កើនសេវាបច្ចេកទេសកសិកម្មដែលជំរុញទិន្នផលឲ្យបានប្រសើរ។** ការដាំដំណាំស្រូវចាំបាច់ត្រូវធ្វើឲ្យបានពីរ ដងក្នុងមួយឆ្នាំ នៅតាមតំបន់ណាដែលបច្ចុប្បន្ននេះដាំតែមួយដងប៉ុណ្ណោះក្នុងមួយឆ្នាំ។ ការធ្វើប្រពលវប្បកម្មដំណាំស្រូវនេះតម្រូវឲ្យកសិករប្តូរទម្លាប់ពីការធ្វើស្រែដើម្បីតែបង្គ្រប់ការហូបចុកផ្ទាល់ខ្លួនទៅជាការធ្វើស្រែដើម្បីបំរើការងារពាណិជ្ជកម្ម។ សកម្មភាពនានារួមមានការផ្តល់ពូជស្រូវល្អ និងការជំរុញការធ្វើពិពិធកម្មដំណាំជាពិសេស ទៅតាមភូមិសាស្រ្តមួយចំនួនដែលសមស្របដំណាំកសិកម្មក្រៅពីស្រូវ។ ប្រសិនបើធ្វើបែបនេះបាននឹងផ្តល់អត្ថប្រយោជន៍ពីរទន្ទឹមគ្នា ពោលគឺ ទីមួយបង្កើនផលិតភាពកសិកម្ម និងទីពីរ ជានាឲ្យមានដំណាំច្រើនសម្រាប់ហូបចុក។

**គេត្រូវគាំទ្រសកម្មភាពទាំងឡាយណាដែលបង្កើតតម្លៃបន្ថែមដល់កសិផល។** តម្លៃបន្ថែមអាចធ្វើបានចាប់ពីផលិតផលដើមរហូតដល់ការវេចខ្ចប់មុនពេលយកទៅលក់នៅតាមហាង ឬផ្សារនានា។ សកម្មភាពទាំងឡាយណាដែលជំរុញខ្សែសង្វាក់ផលិតកម្មពីកសិដ្ឋាននឹងជួយរក្សាតម្លៃបន្ថែម នៃផលិតផលទាំងនោះ នៅក្នុងស្រុក ជាជាងឲ្យប្រទេសជិតខាងចាប់យកតម្លៃបន្ថែមទាំងនោះ។ ការបង្កើតតម្លៃបន្ថែមរួមមាន ការធ្វើទីផ្សារការកែច្នៃ (ដូចជាម៉ាស៊ីនកិនស្រូវជាដើម) ការវេចខ្ចប់ និងការធ្វើពាណិជ្ជកម្ម។ និយាយរួម ធ្វើយ៉ាងណាចាប់យកតម្លៃបន្ថែមឲ្យបានច្រើនចាប់ពីកសិដ្ឋានដល់ដៃអ្នកប្រើប្រាស់។ ដើម្បីសម្រេចគោលដៅនេះ គេត្រូវចាំបាច់ពង្រឹងទំនាក់ទំនងរវាងកសិដ្ឋាននិងកសិករជាមួយខ្សែសង្វាក់ផលិតកម្មទាំងអស់ដោយប្រើប្រាស់មធ្យោបាយមួយចំនួន មានដូចជា៖ ជំរុញកសិករឲ្យរៀបចំជាសហករណ៍ ពង្រឹងការចែករំលែកព័តមានផ្សេងៗ ផ្តល់ឥណទានសមស្របដល់សហគ្រាសធុនតូច និងមធ្យម និងការចែករំលែកនូវជោគជ័យផ្សេងៗពីកន្លែងមួយទៅកន្លែងមួយទៀត។

**រដ្ឋាភិបាលគួរតែជៀសវាងប្រើគោលនយោបាយត្រួតត្រាតម្លៃកសិផល ឬដាក់អត្រាពន្ធដែលមិនសមស្របលើកសិផល ពីព្រោះការធ្វើបែបនេះនឹងធ្វើឲ្យខូចតម្លៃទីផ្សារ។** កម្ពុជាមានលក្ខណៈខុសប្លែកពីបណ្តាប្រទេសជាច្រើននៅក្នុងតំបន់ ហើយទីផ្សារកសិកម្មរបស់កម្ពុជាភាគច្រើនមិនមានអន្តរាគមន៍ពីសំណាក់រាជរដ្ឋាភិបាលទេ ហើយប្រការនេះផ្តល់អត្ថប្រយោជន៍ចំនួនពីរ។ អត្ថប្រយោជន៍ទីមួយគឺនឹងជួយឲ្យកសិករទទួលបានប្រយោជន៍ទាំងស្រុងពីការឡើងថ្លៃកសិផល។ដោយសារតែប្រជាពលរដ្ឋក្រីក្រភាគច្រើនប្រកបមុខរបរកសិកម្មអត្ថប្រយោជន៍នៃការឡើងថ្លៃកសិផលបានដល់ដៃប្រជាពលរដ្ឋទាំងនោះ។ អត្ថប្រយោជន៍ទីពីរ គឺនឹងមិនបង្កើតឲ្យមានឧបសគ្គដល់ការដាំដុះ ឬសកម្មភាពជាក់លាក់ណាមួយតែបង្កលក្ខណៈងាយស្រួលដល់កសិករ និងក្រុមគ្រួសាររបស់ពួកគេអាចប្រកបរបរចិញ្ចឹមជីវិត តាមរយៈការប្រើកម្លាំងពលកម្មយ៉ាងមានប្រសិទ្ធភាព។ ដូច្នេះហើយ ការបន្តអនុវត្ត

គោលនយោបាយទាំងនេះនាពេលអនាគតមិនគ្រាន់តែអនុញ្ញាតឲ្យជនជាតទាំងឡាយហូរចេញ និងហូរចូលក្នុងវិស័យកសិកម្មតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយប្រជាពលរដ្ឋនៅជនបទឲ្យប្រើប្រាស់ទ្រព្យធនដែលគាត់មានបានប្រសើរជាងមុនដែរ។

**ថ្វីបើវិស័យកសិកម្មអាចជួយដល់ប្រជាពលរដ្ឋភាគច្រើនឲ្យចាកចេញពីភាពក្រីក្រយ៉ាងណាក្តី ក៏វិស័យតែមួយមុខនេះប្រហែលជាមិនអាចរក្សាល្បឿននៃការកាត់បន្ថយភាពក្រីក្រកន្លងមកបានទេ។** ក្នុងរយៈពេលមធ្យមទៅរយៈពេលវែង សកម្មភាពសេដ្ឋកិច្ចដែលមិនមែនកសិកម្មនឹងដើរតួនាទីយ៉ាងសំខាន់ ដើម្បីឲ្យកំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព ហើយជីវភាពរបស់ប្រជាពលរដ្ឋកាន់តែមានភាពធូរជារឡើង។ កម្ពុជាត្រូវតែសំឡឹងមើល និងត្រៀមជាស្រេចដើម្បីបង្កើនកិច្ចខិតខំរបស់ខ្លួនក្នុងការជំរុញវិស័យឧស្សាហកម្មនិងសេវាកម្មនៅតាមទីប្រជុំជននិងតាមទីជនបទនានា។

## បន្តវិនិយោគលើការអភិវឌ្ឍន៍មនុស្ស

**ជាចាំបាច់ ត្រូវធ្វើយ៉ាងណាឲ្យកុមារនៅតាមទីជនបទចូលរៀនបានឆាប់។** លើសពីនេះទៀត កុមារក្នុងគ្រួសារក្រីក្រ និងគ្រួសារជនជាតិភាគតិចដែលមិនបានចូលសាលារៀនត្រូវតែនាំពួកគេឲ្យមកចូលក្នុងប្រព័ន្ធអប់រំ។ នៅតាមទីជនបទ គោលនយោបាយវិស័យអប់រំគួរតែផ្តោតទៅលើកម្រិតបឋមសិក្សា ជាពិសេស ការកាត់បន្ថយការចុះឈ្មោះចូលរៀនយឺត និងជំរុញឲ្យកុមារក្នុងគ្រួសារក្រីក្រ និងគ្រួសារជនជាតិភាគតិច ដែលមិនទាន់បានចូលសាលារៀនឲ្យមកចុះឈ្មោះចូលរៀន។ដើម្បីដោះស្រាយបញ្ហានេះ គេរកឃើញថា ការផ្តល់អាហារូបករណ៍ និងចំណីអាហារបំប៉ននៅក្នុងសាលារៀនជាវិធីដ៏មានប្រសិទ្ធិភាព ដែលគេបានអនុវត្តន៍នៅកម្ពុជា និងនៅទូទាំងពិភពលោក។ ដើម្បីដោះស្រាយមធ្យមសិក្សាសម្រាប់កុមារនៅតាមទីជនបទ គេត្រូវបង្កើតសាលាមធ្យមសិក្សាឲ្យកាន់តែខិតជិតប្រជាពលរដ្ឋ ដោយសារតែគេឃើញមានតម្រូវការរបស់កុមារជាច្រើនចូលរៀនមធ្យមសិក្សា។

**នៅទីប្រជុំជន អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាអាចកាត់បន្ថយបាន ប្រសិនបើគេមានកម្មវិធីអាហារូបករណ៍ និងជំរុញឲ្យកុមារចូលរៀនបឋមសិក្សាបានលឿន។** សម្រាប់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលងាយរងគ្រោះ នៅតាមទីប្រជុំជន ជំនាញកាន់តែខ្ពស់នឹងជួយឲ្យពួកគេបំពេញការងារមានផលិតភាពខ្ពស់ ហើយ ទទួលបានប្រាក់បៀវត្សរ៍ច្រើន។ អនុសាសន៍សំខាន់របស់របាយការណ៍នេះ គឺការបន្តលើកកម្ពស់ការអប់រំដល់កុមារបច្ចុប្បន្ននេះដើម្បីឲ្យពួកគេបង្កើនផលិតភាពពេលឈានចូលទីផ្សារពលកម្មនៅថ្ងៃខាងមុខ។ ការរៀបចំបង្កើតឲ្យមានកម្មវិធីផ្ទេរសាច់ប្រាក់ និងកម្មវិធីផ្សេងៗទៀតអាចសមស្របដើម្បីលើកកម្ពស់ការអប់រំកម្រិតមធ្យមសិក្សានៅកម្ពុជា។

**ចាំបាច់ត្រូវតែបង្កើនការផ្តល់ និងការប្រើប្រាស់ប័ណ្ណសមធម៌ជូនដល់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះ។** តម្លៃសេវានៅតាមមន្ទីពេទ្យ និងមណ្ឌលសុខភាពសាធារណៈក៏ត្រូវតែរក្សាឲ្យនៅតម្លៃទាប។ ចំពោះប្រជាពលរដ្ឋមួយភាគធំដែលមានប័ណ្ណសមធម៌ ពួកគាត់មិនបានប្រើប្រាស់ប័ណ្ណទាំងនោះទេ។ អាស្រ័យហេតុនេះហើយ អ្វីដែលត្រូវធ្វើបន្ត គឺការពង្រឹងយន្តការតាមដានត្រួតពិនិត្យ ដើម្បីធានាថា ប្រជាពលរដ្ឋដែលមានប័ណ្ណសមធម៌ដឹងអំពីផលប្រយោជន៍ របស់ប័ណ្ណ ហើយយកទៅប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។ ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃប័ណ្ណសមធម៌ គេត្រូវរៀបចំឲ្យមានការសិក្សាមួយច្បាស់លាស់។

**រដ្ឋាភិបាលត្រូវរឹតបន្តឹងសេវាព្យាបាលតាមគ្លីនិកឯកជន (ការផ្តល់ថ្នាំពេទ្យ និងសេវាពិគ្រោះឯកជន)។** ការពង្រឹងការត្រួតពិនិត្យ និងការគ្រប់គ្រងលើគ្លីនិកឯកជនជាបញ្ហាចាំបាច់ដែលត្រូវធ្វើ។ ដូចគ្នានេះដែរ គេត្រូវរៀបចំវិធានការដើម្បីប្រយុទ្ធនឹងថ្នាំក្លែងក្លាយ។ សម្រាប់ពេលអនាគត យើងសូមផ្តល់អនុសាសន៍ឲ្យមានការវាយតម្លៃយ៉ាងល្អិតល្អន់លើការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ហើយការវាយតម្លៃនេះ គួរតែបង្ហាញឲ្យដឹងថា តើជំនាញអ្វីខ្លះដែលពួកគេត្រូវការបំប៉នបន្ថែមនាពេលអនាគត។

**ដើម្បីដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភរបស់មាតា និងកុមារ គេចាំបាច់ត្រូវរៀបចំឲ្យមានវិធានការពហុវិស័យ។** គេចាំបាច់ត្រូវគាំទ្រនូវកម្មវិធីនានានៅតាមសហគមន៍ ហើយកិច្ចការនេះ ទាមទារឲ្យមានការលុបបំបាត់ការបន្ទោបង់ពាសវាលពាសកាល ការបំប៉នចំណីអាហារដល់កុមារឲ្យបានប្រសើរជាងមុន និងផ្តល់គ្រាប់ថ្នាំជីវជាតិដល់កុមារក្រីក្រ។ បច្ចុប្បន្ននេះ កុមារកម្ពុជាមួយភាគធំមិនទាន់បានទទួលអាហាររូបត្ថម្ភគ្រប់គ្រាន់នៅឡើយទេ។ ដូចនេះប្រព័ន្ធសុខាភិបាលត្រូវតែពង្រឹង និងត្រួតពិនិត្យការលូតលាស់របស់កុមារនៅតាមមណ្ឌលសុខភាពនានា (ធ្វើឲ្យដូចការតាមដានជំងឺផ្សេងៗទៀត)។ ក្រសួងសុខាភិបាលត្រូវមានវិធានការឆ្លើយតបសមរម្យសម្រាប់កុមារខ្វះជីវជាតិ។ ការឆ្លើយតបទាំងនោះរួមមានដូចជាៈ ការផ្តល់ចំណេះដឹងអំពីម្ហូបអាហារដែលផ្តល់ជីវជាតិ ការផ្តល់អាហារបំប៉នបន្ថែម និងការប្រឹក្សាអំពីរបៀបផ្តល់ចំណីអាហារដល់ទារក និងកុមារ។

## ពង្រឹងការអនុវត្តប្រព័ន្ធគាំពារសង្គម

**ចាំបាច់ត្រូវតែផ្តល់ការគាំទ្រដល់ស្ថាប័ន ដែលអនុវត្តន៍យុទ្ធសាស្ត្រជាតិស្តីពីការគាំពារសង្គម។** គេចាំបាច់ត្រូវតែផ្តល់ថវិកាឲ្យបានសមស្របដល់ស្ថាប័ននានា ដើម្បីជំរុញល្បឿនអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការគាំពារសង្គម។ គេចាំបាច់ត្រូវតែផ្តល់តួនាទីឲ្យសំខាន់ជាងនេះដល់ស្ថាប័នថ្នាក់កណ្តាលដែលទទួលខុសត្រូវសម្របសម្រួលការងារជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀត ប៉ុន្តែការទទួលខុសត្រូវនេះត្រូវតែភ្ជាប់ជាមួយនូវធនធាន និងមធ្យោបាយផ្សេងៗ ដើម្បីឲ្យស្ថាប័ននេះ អាចអនុវត្តគំនិតផ្តួចផ្តើមថ្មីៗមួយចំនួន ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីការគាំពារសង្គម។ ការធ្វើបែបនេះអាចជួយឲ្យស្ថាប័នថ្នាក់កណ្តាលទាក់ទាញធនធានផ្សេងៗទៀតពីដៃគូពាក់ព័ន្ធនានា។

**កម្មវិធីគាំពារសង្គមនានាមិនត្រូវផ្តោតតែលើប្រជាពលរដ្ឋក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវផ្តោតលើប្រជាពលរដ្ឋងាយរងគ្រោះផងដែរ។** អត្រាភាពក្រីក្រ ដែលបានធ្លាក់ចុះយ៉ាងច្រើនពីឆ្នាំ២០០៤ ដល់ឆ្នាំ ២០១១ មិនមានន័យថាកម្មវិធីគាំពារសង្គម គួរកាត់បន្ថយចំនួនអ្នកដែលអាចទទួលបានផលប្រយោជន៍ពីកម្មវិធីនោះទេ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋដែលពីមុនជាប្រជាពលរដ្ឋក្រីក្រ ហើយឥឡូវលែងជាប្រជាពលរដ្ឋក្រីក្រពុំទាន់មានជីវភាពធូរធារជំដុំនៅឡើយទេ ពួកគេនៅតែងាយរងគ្រោះ ហើយអាចធ្លាក់មកភាពក្រីក្រវិញបានយ៉ាងងាយ។ ដូចនេះរាល់ការធ្វើផែនការដើម្បីអនុវត្តកម្មវិធីគាំពារសង្គមនានាត្រូវរាប់បញ្ចូល ប្រជាពលរដ្ឋដែលងាយរងគ្រោះផងដែរ។

**គេគួរតែជំរុញឲ្យមានការអនុវត្តន៍បទដ្ឋានការងារដែលអនុវត្តន៍បានយ៉ាងជោគជ័យក្នុងវិស័យកាត់ដេរទៅក្នុងវិស័យដទៃៗទៀត។** ក្នុងកិច្ចការនេះ គេគួរជំរុញឲ្យមានការអនុវត្តន៍ច្បាប់ការងារឲ្យមានប្រសិទ្ធភាពកាន់តែខ្ពស់ ហើយជំរុញកម្មករ និយោជិកឲ្យចូលរួមក្នុងប្រព័ន្ធរបបសន្តិសុខសង្គម ដោយសារប្រព័ន្ធនេះអាចជួយកាត់បន្ថយភាពងាយរងគ្រោះរបស់កម្មករ និងបង្កើនកម្រិតជីវភាពរបស់ពួកគេ។ ក្នុងកិច្ចការនេះ រដ្ឋាភិបាលមានជម្រើសនានា ដើម្បីពង្រីកការអនុវត្តន៍បទដ្ឋានការងារទៅលើវិស័យដទៃៗទៀត ដើម្បីការពារកម្មករទាំងអស់ ហើយបទពិសោធន៍អាចដកស្រង់ពីវិស័យកាត់ដេរដែលបានអនុវត្តន៍នៅកម្ពុជាកន្លងមក។

### ចំណាំជើងទំព័រ

1. របាយការណ៍នេះ ប្រើតួលេខ និងលទ្ធផលផ្សេងៗ ពីវិធីសាស្ត្រគណនា របស់ធនាគារពិភពលោក។ ការប្រៀបធៀបលទ្ធផលពីវិធីសាស្ត្រទាំងពីរ មានបង្ហាញនៅឧបសម្ព័ន្ធទី២។
2. មតិ លោក ប្រេជ បាឡាដ មន្ត្រីភ្នាក់ងារអភិវឌ្ឍន៍ប្រទេសអូស្ត្រាលីក្នុងកិច្ចប្រជុំពិនិត្យឯកសារនេះ។
3. អត្រាកាត់បន្ថយភាគក្រីក្រសរុបគឺ ៣២,៧ ភាគរយ។

# តើមានរឿងអ្វីកើតឡើងចំពោះប្រជាពលរដ្ឋក្រីក្រ ?

# ជំពូក ១

ចាប់ពី ឆ្នាំ២០០៤ ដល់ ឆ្នាំ២០១១ សេដ្ឋកិច្ចរបស់កម្ពុជាមានកំណើនគួរឲ្យភ្ញាក់ផ្អើល។ ផលិតផលក្នុងស្រុកក្នុងម្នាក់ៗ (ផ.ស.ស) បានកើនឡើង ៥០,៩ ភាគរយ ហើយការចំណាយប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋម្នាក់ៗគិតជាមធ្យមបានកើនឡើង ៣៨ ភាគរយ។ ទន្ទឹមគ្នានេះដែរ ចាប់ពីឆ្នាំ ២០០៧ មក វិសមភាពបានចាប់ផ្តើមធ្លាក់ចុះជាបន្តបន្ទាប់ ហើយនេះជាមូលហេតុបន្ថែម ដែលឆ្លុះបញ្ចាំងថា ចំណូលប្រជាពលរដ្ឋក្រីក្រកើនឡើង។ ភាពក្រីក្រនៅកម្ពុជា ត្រូវបានកាត់បន្ថយលឿនជាងការរំពឹងទុក ហើយកម្ពុជាសម្រេចបានគោលដៅសហស្សវត្សរ៍អំពីកម្រិតភាពក្រីក្ររួចទៅហើយ។ កំណើនសេដ្ឋកិច្ចបានជួយឲ្យប្រជាពលរដ្ឋជាច្រើនចាកចេញពីភាពក្រីក្រ ប៉ុន្តែ សម្រាប់ប្រជាពលរដ្ឋទាំងនោះការចាកចេញពីភាពក្រីក្រកម្រិតបច្ចុប្បន្នមិនមានន័យថាជីវភាពរបស់ពួកគេបាន ធូរធារណាស់ណានោះទេ។ ជីវភាពរបស់ប្រជាពលរដ្ឋ ភាគច្រើនកំពុងស្ថិតនៅលើបន្ទាត់ភាពក្រីក្របន្តិចបន្តួចប៉ុណ្ណោះ ហើយពួកគេអាចធ្លាក់ចូលភាពក្រីក្រវិញប្រសិនមានព្រឹត្តិការណ៍ណាមួយកើតឡើង។

ជំពូកនេះនឹងបរិយាយអំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់សេដ្ឋកិច្ចកម្ពុជា។ ទន្ទឹមគ្នានេះដែរ ជំពូកនេះនឹងបង្ហាញស្ថានភាពក្រីក្រ និងចរិតលក្ខណៈរបស់គ្រួសារពលរដ្ឋក្រីក្រ។ ជំពូកនេះមានបំណងសំខាន់កំណត់កត្តាសំខាន់ៗ ដែលបានចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជាកន្លងមក ហើយតាមរយៈកត្តាទាំងនេះ គឺអាចជួយយើងក្នុងការរៀបចំគោលនយោបាយ ដើម្បីកាត់បន្ថយភាពក្រីក្របន្ថែមទៀត នាពេលអនាគត។

## លក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ច

អំឡុងទសវត្សរ៍ ឆ្នាំ១៩៩០ និង ដើមសហស្សវត្សរ៍ថ្មី គេសង្កេតឃើញថា ផលិតផលជាតិសរុប (ផ.ជ.ស) (Gross National Income, GNI) ក្នុងម្នាក់ៗ របស់កម្ពុជា មិនមានកំណើនខ្លាំងក្លានោះទេ។ ក៏ប៉ុន្តែ ចាប់តាំងពីឆ្នាំ២០០៤ មក ផ.ជ.ស ក្នុងម្នាក់ៗបានកើនឡើងក្នុងល្បឿនគួរភ្ញាក់ផ្អើល ក្នុងអត្រា ១៤,៥ ភាគរយ ក្នុងរយៈ ពេល ៧ ឆ្នាំ ដែលធ្វើឲ្យ ផ.ជ.ស ក្នុងម្នាក់ៗ ឡើងដល់ ៨៣០ ដុល្លារ កើនឡើងទ្វេដង ធៀបនឹង ផ.ជ.ស ឆ្នាំ២០០៤ (**ក្រាហ្វិក ១**)។ ទោះជាយ៉ាងនេះក្តី ល្បឿនកំណើនសេដ្ឋកិច្ចនេះមិនទាន់ជួយឲ្យប្រទេសកម្ពុជាចាកផុតពីក្រុមប្រទេសមានចំណូលទាបនៅឡើយទេ ដោយសារកម្រិតនៃផ.ជ.សក្នុងម្នាក់ៗរបស់កម្ពុជាមានកំណើនពីកម្រិតទាប ៤០០ ដុល្លារ ក្នុងម្នាក់ៗ កាលពីដើមឡើយ

ក្នុងឆ្នាំ ២០០៤ ហើយមកដល់ ឆ្នាំ២០១១ ផ.ជ.ស ក្នុងម្នាក់ៗនៅទាបជាង ១.០២៦ ដុល្លារ នៅឡើយ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី កម្ពុជានឹងប្រើរយៈពេលមិនយូរទេ ដើម្បីចាកចេញពីក្រុមប្រទេសមានចំណូលទាបនេះ។ ប្រសិនកម្ពុជាអាចរក្សាល្បឿនកំណើនសេដ្ឋកិច្ច ដូចប៉ុន្មានឆ្នាំមុននេះ នោះកម្ពុជានឹងក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមនៅឆ្នាំ២០១៤ ឬ ឆ្នាំ២០១៥។ សូមគូសបញ្ជាក់ថា តម្លៃលេខ គិតជាផលិតផលស្រុកសរុប (ផ.ស.ស) (Gross Domestic Product, GDP) ក្នុងម្នាក់ៗ គណនាដោយរាជរដ្ឋាភិបាលកម្ពុជា មានតម្លៃស្រដៀងតម្លៃលេខ ផ.ជ.ស របស់ធនាគារពិភពលោក នៅគ្រប់គ្រាទាំងអស់។

**ក្រាហ្វិក ១៖** ផលិតផលជាតិសរុប(ផ.ជ.ស) ក្នុងម្នាក់ៗ អំឡុងឆ្នាំ១៩៩៥-២០២០




**សម្គាល់៖** លក្ខដ្ឋានសម្រាប់វាស់វែងកម្រិតចំណូលមធ្យម របស់ធនាគារពិភពលោក ត្រូវបានធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ដើម្បីចាប់យកនូវឥទ្ធិពលនៃបម្រែបម្រួលអតិផរណា។ ខ្សែកោងដាច់ៗតំណាងឲ្យលទ្ធផលព្យាករណ៍ ដែលទទួលបានតាមរយៈការប្រើប្រាស់អត្រាកំណើនថេរ ដោយគណនាចេញពីការរកមធ្យមភាគអំឡុង ៤ ឆ្នាំ ចុងក្រោយ។

**ប្រភព៖** តួលេខ ផ.ជ.ស ត្រូវបានដកស្រង់ចេញពី«សូចនាករអភិវឌ្ឍន៍ពិភពលោក (World Development Indicators)»របស់ធនាគារពិភពលោក។ ចំណែកឯតួលេខ ផ.ស.ស វិញ ត្រូវបានដកស្រង់ចេញពីរបាយការណ៍ម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា។

**ក្រាហ្វិក ២៖** សមាសធាតុ ផ.ស.ស បែងចែកតាមវិស័យ (១៩៩៥-២០១១)




**ប្រភព៖** គណនីជាតិ (វ.ជ.ស)។

**សមាសធាតុនៃសេដ្ឋកិច្ចកម្ពុជាមានការប្រែប្រួលយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ១៩៩៥ មក។ គេសង្កេតឃើញថា ការចូលរួមរបស់វិស័យកសិកម្ម ក្នុងសេដ្ឋកិច្ចកម្ពុជាកាន់តែតូចទៅៗ រីឯការចូលរួមរបស់វិស័យឧស្សាហកម្មវិញកាន់តែធំទៅៗ។** ការចូលរួមរបស់វិស័យកសិកម្មជាតិក្នុងសេដ្ឋកិច្ចកម្ពុជា បានធ្លាក់ចុះពី ៤៥ ភាគរយ នៅឆ្នាំ ១៩៩៥ មកត្រឹម ២៦ ភាគរយ នៅឆ្នាំ២០១១ ហើយចំណូលភាគច្រើនត្រូវបានចូលរួមចំណែកពីវិស័យឧស្សាហកម្ម។ បម្រែបម្រួលសមាសធាតុនៃសេដ្ឋកិច្ចកម្ពុជា កើតឡើងនៅ ចុងទសវត្សរ៍ ឆ្នាំ១៩៩០ និងដើមសហស្សវត្សរ៍នេះ។ ចាប់តាំងពី ឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ គេសង្កេតថា ចំណែករបស់វិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ក្នុងសេដ្ឋកិច្ចកម្ពុជាប្រែប្រួលតិចតួចប៉ុណ្ណោះ។ (**ក្រាហ្វិក ២**)

**សេដ្ឋកិច្ចកម្ពុជាមានកំណើនយ៉ាងខ្លាំងក្លា ក្នុងកម្រិត១០ ភាគរយ ក្នុងមួយឆ្នាំៗ ចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០០៨។** កំណើនដ៏ខ្លាំងក្លានេះនាំមុខដោយសារវិស័យ ៤ គឺ វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម។ កំណើនដ៏ខ្លាំងក្លានេះអាចធ្វើទៅបាន អាស្រ័យដោយកត្តា រួមផ្សំ ៤៖ (១) កម្ពុជាទទួលបានសន្តិភាព និងស្ថិរភាពពេញលេញ ដែលអនុញ្ញាតឲ្យប្រទេសកម្ពុជាទទួលបាននូវការវិនិយោគពីខាងក្រៅ និងជំនួយអភិវឌ្ឍន៍ពីបរទេស, (២) អំឡុងពេលនោះ បរិយាកាសសកលនិងតំបន់ មានអំណោយផល ហើយកម្ពុជាបានចាប់យកឱកាសទាំងនោះ តាមរយៈគោលនយោបាយបើកទូលាយពាណិជ្ជកម្ម និងការវិនិយោគ, (៣) គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ត្រូវបានអនុវត្តបានល្អ ដែលនាំឲ្យសេដ្ឋកិច្ចកម្ពុជាមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បើទោះបីជារដ្ឋាភិបាលអាចប្រើប្រាស់តែគោលនយោបាយសារពើពន្ធក៏ដោយ។ គោលនយោបាយរូបិយវត្ថុមិនសូវមានប្រសិទ្ធភាពទេ ព្រោះកម្ពុជាប្រើប្រាស់ប្រាក់ដុល្លារអាមេរិចច្រើនពេក, (៤) កំណើននៃវិស័យកាត់ដេរអាចធ្វើបាន ដោយសារតែកិច្ចព្រមព្រៀងទ្វេភាគីជាមួយសហរដ្ឋអាមេរិក និងកិច្ចព្រមព្រៀងជាមួយសហគមន៍អឺរ៉ុប តាមរយៈកិច្ចព្រមព្រៀងនាំចេញ «អ្វីៗក៏បាន លើកលែងតែគ្រឿងសព្វាវុធ (Every Thing But Arms)»។ កិច្ចព្រមព្រៀងទាំងពីរនេះ ជួយឲ្យផលិតផលកម្ពុជាងាយស្រួលចូលទីផ្សារសហរដ្ឋអាមេរិក និង សហគមន៍អឺរ៉ុប។

**ប៉ុន្តែកំណើនសេដ្ឋកិច្ចដ៏ខ្ពស់នេះ ត្រូវបានបង្អាក់នៅឆ្នាំ២០០៧-២០០៩ ដោយសារកត្តាខាងក្នុង និងកត្តាខាងក្រៅ។** សេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ ២០០៧ និង ឆ្នាំ ២០០៨ មានសន្ទុះខ្លាំងក្លាពេក ដែលធ្វើឲ្យប្រាក់កម្ចីដល់វិស័យឯកជន មានការកើនឡើងយ៉ាងខ្លាំង ហើយតម្លៃអចលនទ្រព្យ ក៏កើនឡើងយ៉ាងសម្បើមដែរ។ ដោយសារកត្តាទាំងពីរនេះរួមផ្សំនឹងកត្តាខាងក្រៅដូចជា កត្តាតម្លៃម្ហូបអាហារ និងប្រេងឥន្ធនៈខ្ពស់ អតិផរណានៅកម្ពុជាបានហក់ឡើងដល់ ៣៥,៨ ភាគរយ នៅខែឧសភា ឆ្នាំ២០០៨ ហើយបន្ទាប់មក សេដ្ឋកិច្ចកម្ពុជាបានរងនូវឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុសកល។ វិបត្តិនេះបានធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាមិនមានកំណើនទេនៅ ឆ្នាំ២០០៩។ ជាការឆ្លើយតបនឹងវិបត្តិហិរញ្ញវត្ថុសកល រាជរដ្ឋាភិបាលបានចាត់វិធានការ ដោយបង្កើនអត្រាទុនបម្រុងរបស់ធនាគារពាណិជ្ជ និងបង្កើនចំណាយនានា ដើម្បីរក្សាកំណើនសេដ្ឋកិច្ច។

**ដោយសារវិធានការឆ្លើយតបសមស្រប និងបរិយាកាសសេដ្ឋកិច្ចពិភពលោកអំណោយផល បញ្ហាសេដ្ឋកិច្ចនៅកម្ពុជាបានធូរស្រាលវិញចាប់ពី ឆ្នាំ២០១០ មក។** កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច ៦ ភាគរយ នៅឆ្នាំ ២០១០ និង ៧,១ ភាគរយ នៅឆ្នាំ២០១១។ កំណើន នេះសម្រេចបានដោយសារតែវិស័យកសិកម្មមានកំណើនខ្លាំងក្លា ហើយវិស័យឧស្សាហកម្ម និងសំណង់មានកំណើនល្អវិញ ខណៈដែលវិស័យទេសចរណ៍ក៏មានកំណើនដែរ។ នៅឆ្នាំ២០១២នេះការព្យាករណ៍ចុងក្រោយរបស់រាជរដ្ឋាភិបាលកម្ពុជាបង្ហាញថា សេដ្ឋកិច្ចកម្ពុជាមានកំណើនដល់ទៅ ៧,៣ ភាគរយ។ ការព្យាករណ៍នេះត្រូវបានតម្លើងពីកម្រិត ៧,១ ភាគរយ ក្នុងការព្យាករណ៍កាលពីគ្រាមុន ដោយសារកំណើនវិស័យកសិកម្ម និងទេសចរណ៍អាចកើនឡើងលើសពីការរំពឹងទុក។ ឱនភាពជញ្ជីងពាណិជ្ជកម្ម នៅឆ្នាំ២០១១ មានប្រមាណ ២ ពាន់លានដុល្លារ ស្មើនឹង ៨ ភាគរយ នៃ ផ.ស.ស។ ឱនភាពជញ្ជីងពាណិជ្ជកម្មនេះបណ្តាលមកពីការនាំចូលប្រេងឥន្ធនៈ និងគ្រឿងសំណង់សម្រាប់សាងសង់វារីអគ្គិសនី ក្រោមកិច្ចព្រមព្រៀង «សាងសង់ ប្រតិបត្តិការ និងផ្ទេរ (Build Operate and Transfer, BOT)»។ ទំហំទុនវិនិយោគពីបរទេសមកកម្ពុជាវិញមានចំនួន ១,៥ ពាន់លានដុល្លារ នៅឆ្នាំ២០១២។ កត្តានេះបានជួយឲ្យជញ្ជីងទូទាត់សេដ្ឋកិច្ចកម្ពុជាបានល្អប្រសើរ ហើយឱនភាពជញ្ជីងពាណិជ្ជកម្ម មានប្រមាណ ១២ ភាគរយ នៃ ផ.ស.ស។ ការវិភាគលទ្ធភាពសងបំណុលរបស់កម្ពុជាបានឲ្យដឹងថា កម្ពុជាមិនមានបញ្ហាធំក្នុងការសងបំណុលនៅឡើយទេ ក៏ប៉ុន្តែ ស្ថានភាពបំណុលរបស់កម្ពុជាអាចនឹងមានបញ្ហា ប្រសិនមានហានិភ័យណាមួយ កើតឡើងលើកិច្ចសន្យា (BOT)សាងសង់អគ្គិសនី។ ដោយហេតុនេះហើយ កម្ពុជាត្រូវតែបន្តកំណែទម្រង់នានាបន្ថែម ដើម្បីរឹតត្បិតការចំណាយពង្រីកការប្រមូលចំណូល និងកែលម្អបំណុលសាធារណៈ។ ( **ក្រាហ្វិក ៣-ក និង ៣-ខ** )

**ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចទាំងមូល មានលក្ខណៈវិជ្ជមាន។** គេព្យាករសេដ្ឋកិច្ចនៅឆ្នាំ២០១៣ថា មានកម្រិត ៧ ភាគរយ ហើយកំណើននេះ ដោយសារកំណើនខ្លាំងក្លារបស់វិស័យទេសចរណ៍ កសិកម្ម និង វិស័យកាត់ដេរ។ វិស័យសំណង់ក៏ត្រូវបានគេព្យាករថា មានកំណើនដែរ តែតិចជាងមុន។ សម្រាប់ឆ្នាំ២០១៣នេះ អតិផរណា

**ក្រាហ្វិក ៣-ក.៖** តុល្យភាពជញ្ជីងពាណិជ្ជកម្ម (គិតជាលានដុល្លារ)




**ប្រភព៖** ជញ្ជីងទូទាត់ (ធនាគារជាតិនៃកម្ពុជា)

**ក្រាហ្វិក ៣-ខ.៖** គណនីចរន្ត និងការវិនិយោគផ្ទាល់ពីបរទេស (គិតជាលានដុល្លារ)




**ប្រភព៖** ជញ្ជីងទូទាត់ (ធនាគារជាតិនៃកម្ពុជា)

ប្រហែលជាមិនខ្ពស់ទេ។ គេព្យាករថា អតិផរណានឹងមានប្រហែល ៣ ភាគរយ។ អត្រាប្តូរប្រាក់ក៏មានស្ថិរភាពដែរ។ គេមើលឃើញថា ការគ្រប់គ្រងការចំណាយ និងគោលនយោបាយសារពើពន្ធនៅមានលក្ខណៈសមស្របនៅឡើយទេ។ ចំណែកឯបញ្ហាបំណុល ក៏មើលទៅមិនមានបញ្ហាធំដែរ។ នេះដោយសារ គោលនយោបាយរបស់រាជរដ្ឋាភិបាលជៀសវាងយកនូវប្រាក់កម្ចីណា ដែលមិនមានលក្ខណៈសម្បទានខ្ពស់ ហើយការប្រើប្រាស់កម្ចីទៀតសោត គឺត្រូវបានយកទៅវិនិយោគលើវិស័យសំខាន់ៗ។ ទាំងនេះជាការអនុវត្តន៍ដ៏ល្អ ដើម្បីគ្រប់គ្រងបំណុលឲ្យមានស្ថិរភាព។

បំណុលរបស់រដ្ឋត្រូវបានគេប៉ាន់ស្មានថា មានចំនួន ៣០ ភាគរយ នៃ ផ.ស.ស នៅឆ្នាំ២០១២។ ស្ថានភាពសារពើពន្ធរបស់កម្ពុជាអាចមានបញ្ហា ដោយសារតែរដ្ឋាភិបាលបានព្រមព្រៀងទិញថាមពលពីរោងចក្រវារីអគ្គិសនី ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដែលចំណាយនោះ សរុបមានតម្លៃប្រមាណជា ១៥ ភាគរយនៃ ផ.ស.ស។ ចំណែកឯវិស័យហិរញ្ញវត្ថុវិញ ក៏មានលក្ខណៈល្អប្រសើរ បើទោះបីជាប្រាក់កម្ចីត្រូវបានផ្តល់ទៅដល់វិស័យឯកជនមានចំនួនច្រើនយ៉ាងណាក៏ដោយ។ នេះដោយសារតែប្រាក់កម្ចីទាំងនេះ មិនមែនផ្តល់ឲ្យទៅវិស័យតែមួយប៉ុណ្ណោះទេ ប៉ុន្តែគេបានផ្តល់ទៅពហុវិស័យ។

**គេរំពឹងទុកថា លំហូរទុនវិនិយោគពីបរទេសមានប្រមាណ ៩,៣ ភាគរយ នៃ ផ.ស.ស ឆ្នាំ២០១២។** គិតត្រឹម ៦ ខែដើមឆ្នាំ ២០១២ នេះ រាជរដ្ឋាភិបាលបានអនុម័តយល់ព្រមលើគម្រោងវិនិយោគចំនួន៧២គម្រោង។ បើប្រៀបធៀបក្នុងរយៈពេលដូចគ្នាក្នុង ឆ្នាំ២០១១ គឺមានតែ ៥៧ គម្រោងប៉ុណ្ណោះ។ ក្នុងចំណោមអ្នកវិនិយោគទាំងនេះ វិនិយោគិនមកពីប្រទេសកូរ៉េ ចិន និងជប៉ុន ជាអ្នកនាំមុខគេ។ ក្នុងរយៈពេល ៦ ខែ ដើមឆ្នាំ ២០១២ នេះដែរ ចំនួនក្រុមហ៊ុនដែលមកចុះបញ្ជីមានតែ ១.៥៦៣ក្រុមហ៊ុនប៉ុណ្ណោះ។ ទុនបម្រុងរបស់កម្ពុជាបានបន្តកើនឡើងថែមទៀត សម្រេចបាន ៣,២ ពាន់លានដុល្លារ គិតត្រឹមដំណាច់ឆ្នាំ ២០១២។ បរិមាណនេះអាចយកទៅទូទាត់ការនាំចូលស្មើបាន ៤,៥ ខែ។

ការប្រមូលចំណូលថវិការដ្ឋ នៅឆ្នាំ ២០១១ មិនបានកើនឡើងទេ គឺបានប្រមាណ ១៣,២ ភាគរយ នៃ ផ.ស.ស ហើយចំនួននេះប្រហាក់ប្រហែលការប្រមូលពន្ធរបស់រដ្ឋនៅឆ្នាំ ២០១០។ ចំណែកឯ ការចំណាយរបស់រដ្ឋាភិបាលនៅឆ្នាំ ២០១២ មានប្រមាណជា ២២,២ ភាគរយ នៃ ផ.ស.ស។ ដូច្នោះ ឱនភាពនៃការចំណាយរបស់រាជរដ្ឋាភិបាលមានកម្រិតខ្ពស់ម្តងទៀត នៅឆ្នាំ ២០១១ មានប្រហែល ៩ ភាគរយនៃ ផ.ស.ស (នៅឆ្នាំ ២០១០ ឱនភាពនេះមានតែ ៧,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុបប៉ុណ្ណោះ ដែលកាលនោះរាជរដ្ឋាភិបាលបានចាត់វិធានការកាត់ចំណាយចរន្តដែលមិនចាំបាច់ជាច្រើន)។

**សម្រាប់ ឆ្នាំ២០១៣ និងឆ្នាំ ២០១៤ គេរំពឹងថាតុល្យភាពសារពើពន្ធរបស់រដ្ឋាភិបាលនឹងប្រសើរឡើង។** នេះដោយសារគេសង្កេតឃើញថាការប្រមូលចំណូលបានកើនឡើង ២៩ ភាគរយ បើគិតត្រឹម ៦ខែ ដើមឆ្នាំ២០១២ ធៀបនឹងរយៈពេលដូចគ្នាកាលពី ឆ្នាំ២០១១។ កំណើនចំណូលនេះដោយសារតែកំណើនការប្រមូលពន្ធប្រយោលនិងពន្ធផ្ទាល់។ ប៉ុន្តែ ទោះជាការគ្រប់គ្រងសារពើពន្ធមានលក្ខណៈល្អប្រសើរក្តី កម្ពុជាអាចមានបញ្ហាចំណោទដែលទាក់ទងនឹងហិរញ្ញប្បទានពីបរទេស និងកំណើនចំណាយផ្សេងៗទៀតរបស់រដ្ឋដែលពិបាកព្យាករ។

**សេដ្ឋកិច្ចកម្ពុជាអាចប្រឈមហានិភ័យមួយចំនួនដែលបណ្តាលមកពីសេដ្ឋកិច្ចពិភពលោក និងកត្តាខាងក្នុងដូចជា កំណើនយ៉ាងលឿននៃការផ្តល់ប្រាក់កម្ចីដល់វិស័យឯកជន បំណុលសាធារណៈរបស់រដ្ឋ និងការប្រែប្រួលអាកាសធាតុ។** ប្រសិនបើវិបត្តិនៅសហគមន៍អឺរ៉ុបនិងវិបត្តិហិរញ្ញវត្ថុសកលធ្ងន់ធ្ងរ វិបត្តិទាំងនោះនឹងប៉ះពាល់ដល់ការនាំចេញសម្លៀកបំពាក់ និងវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ ចំណែកឯប្រាក់កម្ចី ដែលផ្តល់ដល់វិស័យឯកជនវិញនោះ គេកំពុងតែមានការព្រួយបារម្ភណាស់ ពីព្រោះសមត្ថភាពរបស់ធនាគារជាតិ ក្នុងការត្រួតពិនិត្យមើលធនាគារពាណិជ្ជ នៅមានលក្ខណៈទន់ខ្សោយនៅឡើយ

បើទោះបីគេសង្កេតឃើញថា អត្រាប្រាក់កម្ចីទៅឯកជនបានធ្លាក់ចុះពី ២៩,២ ភាគរយ នៅខែមករា ឆ្នាំ២០១៣ ធៀបនឹង ៣៤,៦ ភាគរយ នៅឆ្នាំ២០១២ ក៏ដោយ។ គម្រោងសហការគ្នារវាងរដ្ឋ និងឯកជន ក្នុងវិស័យអគ្គិសនី ក៏អាចបង្កហានិភ័យដល់រាជរដ្ឋាភិបាលផងដែរ ប្រសិនបើដំណើរការនេះ មិនបានដូចនឹងការគ្រោងទុកនោះ ពីព្រោះកិច្ចសន្យា ក្នុងវិស័យអគ្គីសនីនេះ នឹងជះឥទ្ធិពលដល់កម្ពុជា។ កម្ពុជានៅតែងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍៖ ទឹកជំនន់ទន្លេមេគង្គ កាលពីពេលថ្មីនេះៗ បានបង្កឲ្យខូចខាតដល់កសិកម្ម និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ។

**ប្រសិនបើ ហានិភ័យទាំងនេះពិតជាកើតឡើងមែននោះ គោលនយោបាយរបស់រដ្ឋាភិបាលដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមាននានានឹងនៅមានកម្រិត។** ដោយសារតែកម្ពុជាបានប្រើប្រាស់ដុល្លារអាមេរិក កម្ពុជាមានលទ្ធភាពតិចតួចណាស់ក្នុងការប្រើគោលនយោបាយហិរញ្ញវត្ថុដើម្បីបញ្ចៀសផលអវិជ្ជមានពីហានិភ័យទាំងនោះ។ ប្រការនេះមានន័យថា រាជរដ្ឋាភិបាលកម្ពុជាអាចពឹងផ្អែកទៅលើគោលនយោបាយសារពើពន្ធតែមួយប៉ុណ្ណោះ ដើម្បីគ្រប់គ្រងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ប៉ុន្តែប្រាក់បម្រុងរបស់រាជរដ្ឋាភិបាលនៅមានកម្រិតទាបណាស់ដែលបញ្ហានេះមានន័យថា គោលនយោបាយសារពើពន្ធរបស់រដ្ឋដែលអាចប្រើដើម្បីបញ្ចៀសបញ្ហានានា ដែលបង្កឡើងដោយហានិភ័យផ្សេងៗ ក៏នៅមានកម្រិតដែរ។ អាស្រ័យហេតុនេះហើយ កម្ពុជាត្រូវតែធ្វើកំណែទម្រង់បន្ថែមទៀត ដើម្បីអាចទប់ទល់ហេតុការណ៍ដែលកើតឡើងជាយថាហេតុផ្សេងៗ។ កំណែទម្រង់រួមមាន៖ ត្បិតត្បៀតលើចំណាយ បង្កើនការប្រមូលចំណូល និងការគ្រប់គ្រងបំណុលឲ្យបានប្រសើរជាងមុន។

**ការអភិវឌ្ឍវិស័យឯកជននៅកម្ពុជាមានភាពប្រឈមដោយសារតែបរិយាកាសធ្វើអាជីវកម្មមិនសូវមានអំណោយផល។** តាមការសិក្សាមួយស្តីអំពីភាពងាយស្រួលក្នុងការធ្វើអាជីវកម្មបានបង្ហាញថា កម្ពុជាជាប់ចំណាត់ថ្នាក់លេខ ១៣៣ ក្នុងចំណោម ១៨៥ ប្រទេស ហើយចំណាត់ថ្នាក់នេះ ទាបជាងមធ្យមភាគនៃបណ្តាប្រទេសនៅអាស៊ី និងអាស៊ីប៉ាស៊ីហ្វិកទាំងមូល ដែលតំបន់នេះបានចំណាត់ថ្នាក់ទី ៨៦។ ឧទាហរណ៍៖ បើគេចង់ចាប់ផ្តើមអាជីវកម្មនៅកម្ពុជា គេត្រូវបំពេញសំណុំបែបបទ ហើយត្រូវប្រើពេលរហូតដល់ ៨៥ ថ្ងៃ។ ចំណែកឯថ្លៃចំណាយវិញស្មើនឹង ១០,៥ ភាគរយនៃចំណូលមធ្យមរបស់ប្រជាពលរដ្ឋកម្ពុជា។ ក្នុងផ្នែកនេះ កម្ពុជាជាប់ចំណាត់ថ្នាក់ទី ១៧៥។ ចំពោះផ្នែកផ្សេងៗទៀត កម្ពុជាក៏មិនជាប់ចំណាត់ថ្នាក់ល្អប៉ុន្មានទេ ពោលគឺកម្ពុជាជាប់ចំណាត់ថ្នាក់ទី ១៥២ ទាក់ទងនឹងការដោះស្រាយការក្ស័យធនរបស់ក្រុមហ៊ុន, ចំណាត់ថ្នាក់ទី ១៤៩ ទាក់ទងទៅនឹងការសុំសិទ្ធិសាងសង់, ចំណាត់ថ្នាក់ទី ១៤២ ទាក់ទងនឹងកាតព្វកិច្ចសន្យា, ចំណាត់ថ្នាក់ទី ១៣២ ទាក់ទងនឹងថាមពលអគ្គិសនី, ហើយចំណាត់ថ្នាក់ទី ១១៨ ទាក់ទងនឹងការធ្វើពាណិជ្ជកម្មឆ្លងដែន។ ការអង្កេតមួយនៅឆ្នាំ២០១២ស្តីអំពីបរិយាកាសកម្ពុជាបានបង្ហាញថា ឧបសគ្គធំៗចំនួនបីដែលបង្កការលំបាកដល់ការធ្វើអាជីវកម្ម រួមមានថ្លៃអគ្គិសនីខ្ពស់ អំពើពុករលួយ និងបញ្ហាខាងការដឹកជញ្ជូន។ ការចំណាយខ្ពស់ក្នុងការធ្វើអាជីវកម្មនេះហើយដែលបានធ្វើឲ្យប៉ះពាល់ដល់សហគ្រាសតូចៗជាច្រើន ដែលសហគ្រាសប្រភេទនេះមានប្រមាណ ៩៩,៦ ភាគរយនៃសហគ្រាសសរុបនៅកម្ពុជា។

## ភាពក្រីក្រ និងសុខុមាលភាព

ផលិតផលក្នុងស្រុកក្នុងម្នាក់ៗជាមធ្យមបានកើនឡើងចំនួន ៦,១ ភាគរយ ពីឆ្នាំ២០០៤ ដល់ឆ្នាំ ២០១១ (៥០,៩ ភាគរយ បើគិតអំឡុងពេលនេះទាំងមូល)។ មូលហេតុដែលយើងប្រើផលិតផលក្នុងស្រុកក្នុងម្នាក់ៗគិតតាមថ្លៃគោល ក៏ព្រោះតែវិធីនេះអាចវាស់វែងកម្រិតជីវភាពប្រជាពលរដ្ឋបានប្រសើរជាងផលិតផលក្នុងស្រុកគិតតាមតំលៃបច្ចុប្បន្ន។ នេះដោយហេតុថា កាលណាមានអតិផរណាកើតឡើង នោះនឹងប៉ះពាល់ដល់បរិមាណទំនិញនិងសេវា ដែលពលរដ្ឋអាចទិញបាន។ កំណើនសេដ្ឋកិច្ចកម្ពុជាមានសន្ទុះយឺតនៅឆ្នាំ២០០៨ ហើយមិនមានកំណើននោះទេនៅឆ្នាំ២០០៩ បន្ទាប់ពីសេដ្ឋកិច្ចនេះបានកើនឡើងដល់ជិត ១០ ភាគរយ ក្នុងរយៈពេល ៣ ឆ្នាំជាប់ៗគ្នា។ នៅឆ្នាំ២០១១ សេដ្ឋកិច្ចបានងើបឡើងវិញ ហើយសម្រេចបានកំណើន ៥,៥ ភាគរយ។ វិស័យនីមួយៗមានអត្រាកំណើនមិនដូចគ្នាទេ។ សម្រាប់វិស័យឧស្សាហកម្ម

កំណើនខ្ពស់បំផុតមាននៅឆ្នាំ២០១១ គឺ១៧,៣ ភាគរយ ហើយកំណើនដែលទាបបំផុតមាននៅឆ្នាំ ២០០៩ (១០,៩ ភាគរយ)។ សម្រាប់វិស័យកសិកម្មវិញ កំណើនហាក់នៅថេរក្នុងរយៈពេល ៧ ឆ្នាំ ចុងក្រោយនេះ។ នៅ ឆ្នាំ ២០០៩ កំណើនវិស័យកសិកម្មមិនមានការធ្លាក់ចុះទេ។ (**ក្រាហ្វិក ៤**)

## អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា (អ.ស.ស.ក)

**នៅកម្ពុជា ការវាស់វែងភាពក្រីក្របានធ្វើឡើងដំបូងបំផុតនៅឆ្នាំ១៩៩៧ ដោយប្រើប្រាស់ទិន្នន័យពីការអង្កេតសេដ្ឋកិច្ចសង្គម (អ.ស.ស.ក) ឆ្នាំ ១៩៩៣/៩៤។** ការអង្កេតនោះបានប្រើសំណាកដែលរៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិ ដែលហៅកាត់ថា អ៊ុនតាក់ (UNTAC)។ ការអង្កេតនោះបានសម្ភាសន៍ប្រជាពលរដ្ឋចំនួន ៥.៥៧៨ គ្រួសារ ហើយអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិ (វ.ជ.ស) ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (A.D.B) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។ ការអង្កេតធ្វើនៅខេត្ត ក្រុង ចំនួន ១៥ ក្នុងចំណោមខេត្ត ក្រុងចំនួន ២១ ទូទាំងប្រទេស (ស្មើ ៥៩ ភាគរយនៃភូមិទាំងអស់ទូទាំងប្រទេស)។ ការអង្កេតនោះមិនបានធ្វើឡើងនៅតំបន់ទាំងឡាយណា ដែលមានប្រជាពលរដ្ឋរស់នៅតិចតួច ឬក៏តំបន់ទាំងឡាយណាដែលមិនអាចចូលទៅដល់ ឬតំបន់ដែលមានបញ្ហាអសន្តិសុខ។ ចំណែកឯកម្រងសំណួរវិញ គេឃើញមានសំណួរមួយចំនួនមានលក្ខណៈស្តង់ដារ ដូចជា ការអង្កេតវាស់វែងជីវភាពរស់នៅលក្ខណៈសកលដែរ។ អាស្រ័យហេតុនេះ គេអាចប្រើប្រាស់ព័ត៌មានពីអង្កេត ដើម្បីគណនាការចំណាយលើការប្រើប្រាស់របស់ពលរដ្ឋម្នាក់ៗ និងគណនាបន្ទាត់ភាពក្រីក្របាន។

**នៅចុងទសវត្សរ៍ ទី ៩០ គេសង្កេតឃើញមានការចុះអង្កេតស្រដៀងនេះ ចំនួនបីដងទៀត ក៏ប៉ុន្តែការចុះអង្កេតទាំងនោះ មានចន្លោះប្រហោងច្រើនពេក។** ការអង្កេតនៅឆ្នាំ ១៩៩៦ គ្រាន់តែបញ្ចូលសំណួរ ដែលទាក់ទងនឹងការចំណាយមិនគ្រប់តែប៉ុណ្ណោះ។ ការអង្កេតនៅឆ្នាំ ១៩៩៧ មានការប្រមូលទិន្នន័យតែពីរខែប៉ុណ្ណោះ ហើយចំពេលដែលកម្ពុជាមានវិបត្តិនយោបាយយ៉ាងធ្ងន់ធ្ងរ។ ការអង្កេតនៅឆ្នាំ១៩៩៩ ក៏មានបញ្ហាដែរពាក់ព័ន្ធនឹងការបណ្តុះបណ្តាល

**ក្រាហ្វិក ៤៖** កំណើនផលិតផលក្នុងស្រុកក្នុងម្នាក់ៗតាមវិស័យឆ្នាំ២០០៤-២០១១




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយផ្អែកតាមគណនីជាតិ។

ដល់អ្នកសម្ភាសន៍ធ្វើមិនបានគ្រប់គ្រាន់ ដែលជាមូលហេតុនាំឲ្យការកត់ត្រាព័ត៌មានពីប្រជាពលរដ្ឋមិនបានត្រឹមត្រូវ។

ទើបតែដល់ឆ្នាំ ២០០៤ ប៉ុណ្ណោះទេដែលវិធីសាស្ត្រនៃការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ត្រូវបានគេរៀបចំឲ្យមានលក្ខណៈស្តង់ដារមួយ ហើយចាប់ពី ឆ្នាំ ២០០៧ មក ការអង្កេតនេះ ត្រូវបានគេធ្វើឡើងជារៀងរាល់ឆ្នាំ រហូតដល់ឆ្នាំ២០១៣ នេះ។ សំណាកសម្រាប់ការអង្កេតឆ្នាំ២០០៤ ដល់ឆ្នាំ ២០០៩ មានចំនួន ១២.០០០ គ្រួសារ។ សម្រាប់ឆ្នាំដទៃទៀត សំណាកមានតែ ៣.៦០០ គ្រួសារប៉ុណ្ណោះ។ ក្នុងការអង្កេតនេះ គេប្រមូលព័ត៌មានពេញមួយឆ្នាំតែម្តង ហើយលទ្ធផលពីការវិភាគអាចប្រើប្រាស់តំណាងឲ្យតំបន់ភ្នំពេញ តំបន់ទីប្រជុំជនដទៃទៀត តំបន់ជនបទ ព្រមទាំងប្រទេសកម្ពុជាទាំងមូល។

ចាប់ពីឆ្នាំ ២០០៤ មកកម្រងសំណួរមានការប្រែប្រួលមួយចំនួន សំណួរមួយចំនួនត្រូវបានបន្ថែម សំណួរមួយចំនួនត្រូវបានគេកែសម្រួល ឬលុបចោល។ ក៏ប៉ុន្តែសំណួរភាគច្រើន ដែលទាក់ទងនឹងការវាស់វែងភាពក្រីក្រត្រូវបានរក្សាទុកនៅដដែល ជាពិសេស ចាប់តាំងពីការអង្កេតនៅឆ្នាំ ២០០៧ មកម្ល៉េះ។ ការអង្កេតនេះទទួលបានជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីភ្នាក់ងារអភិវឌ្ឍន៍សហប្រជាជាតិប្រទេសស៊ុយអ៊ែតដែលហៅកាត់ថា ស៊ីដា (SIDA)។ ចាប់តាំងពីឆ្នាំ ២០០៤មក ក្រុមបច្ចេកទេសរបស់ស៊ីដាបានរៀបចំកម្រងសំណួរឲ្យមានលក្ខណៈស្តង់ដារតែមួយ ហើយកាត់បន្ថយការកែប្រែសំណួរបានយ៉ាងច្រើន។

## ការវាស់វែងភាពក្រីក្រនៅកម្ពុជា

**ការវាស់វែងភាពក្រីក្រនៅកម្ពុជាបានធ្វើឡើងជាលើកដំបូងបង្អស់ ដោយប្រើព័ត៌មានពី អ.ស.ស.ក ឆ្នាំ ១៩៩៣-១៩៩៤។** សូចនាករដែលគេយកមកប្រើប្រាស់ដើម្បីវាស់វែងភាពក្រីក្រ និងកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ គឺការចំណាយប្រចាំថ្ងៃលើការប្រើប្រាស់របស់មនុស្សម្នាក់ៗ។ បន្ទាត់ភាពក្រីក្រម្ហូបអាហារត្រូវបានគណនាដោយយកកម្រិតចំណាយលើម្ហូបអាហារ ដែលពលរដ្ឋក្រីក្របរិភោគនៅឆ្នាំ ១៩៩៣-១៩៩៤។ បន្ទាត់ភាពក្រីក្រសរុបបានមកពីបន្ទាត់ភាពក្រីក្រម្ហូបអាហារបូកនឹងបន្ទាត់ភាពក្រីក្រមិនមែនម្ហូបអាហារ។ គេប្រើទិន្នន័យរំពឹងដើម្បីគណនាចំណាយលើការប្រើប្រាស់។ ចំពោះផ្នែកណាដែលទិន្នន័យរំពឹងពុំមាន គេប្រើទិន្នន័យកំណត់ហេតុ។

ក្រោយមក គេកែសម្រួលសំណួរមួយចំនួន ក៏ប៉ុន្តែការកែសម្រួលនោះ មិនត្រូវបានយកមកប្រើក្នុងការគណនាភាពក្រីក្រក្នុងអំឡុងពេលនោះទេ ដោយសារគេមិនចង់ផ្លាស់ប្តូររបៀបគណនាចំណាយលើការប្រើប្រាស់។ ការធ្វើបែបនេះគឺ ដើម្បីធានាថា ការគណនាភាពក្រីក្រ ពីមួយឆ្នាំទៅមួយឆ្នាំ អាចប្រៀបធៀបគ្នាបាន។ ទោះបីជាយ៉ាងនេះក្តី ចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋកម្ពុជាមានការប្រែប្រួល ចាប់ពីឆ្នាំ ១៩៩៣-១៩៩៤ មកម្លេះ ដែលបញ្ហានេះតម្រូវឲ្យគេផ្លាស់ប្តូរវិធីសាស្ត្រក្នុងការគណនាភាពក្រីក្រនៅកម្ពុជា។

ចាប់តាំងពីការគណនាភាពក្រីក្រលើកដំបូងរហូតដល់ឆ្នាំ២០១០ ធនាគារពិភពលោកជាស្ថាប័ននាំមុខដឹកនាំកិច្ចការនេះ ដោយមានកិច្ចសហប្រតិបត្តិការពីរាជរដ្ឋាភិបាលកម្ពុជា។ ធនាគារពិភពលោកបានផ្តល់វគ្គបណ្តុះបណ្តាលជូនដល់មន្ត្រីរាជរដ្ឋាភិបាល ដើម្បីធ្វើយ៉ាងណាឲ្យពួកគេមានលទ្ធភាពគណនាអត្រាភាពក្រីក្របាន ហើយអាចបកស្រាយ និងវិភាគលទ្ធផលពីការគណនានេះឲ្យបានប្រសើរជាងមុន។ នៅឆ្នាំ ២០១១ រាជរដ្ឋាភិបាលកម្ពុជាបានចាត់តាំងអ្នកបច្ចេកទេសមួយក្រុម ដើម្បីវាស់វែងភាពក្រីក្រឡើងវិញ។ ចំណែកឯធនាគារពិភពលោកវិញ ក៏មានអ្នកជំនាញមួយក្រុមធ្វើកិច្ចការនេះដែរ។ ក្រុមការងារទាំងពីរនេះបានផ្លាស់ប្តូរមតិយោបល់គ្នាទៅវិញទៅមក។ ក្រុមការងារធនាគារពិភពលោកបានទទួលយោបល់ល្អៗពីសំណាក់ក្រុមការងាររបស់រាជរដ្ឋាភិបាល ហើយយោបល់ទាំងនេះត្រូវបានដាក់បញ្ចូលក្នុងការគណនាភាពក្រីក្រថ្មី។ ក្រុមការងាររបស់រាជរដ្ឋាភិបាលក៏ទទួលបានមតិមួយចំនួនជាពិសេសទាក់ទងនឹងគោលការណ៍គណនាភាពក្រីក្រ ដែលត្រូវបានគេអនុវត្តជាលក្ខណៈអន្តរជាតិពីក្រុមការងារ

ធនាគារពិភពលោក ដែរ (**ប្រអប់ ១**)

**ព័ត៌មានស្តីពីការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជា (អ.ស.ស.ក) ឆ្នាំ ២០០៩ ត្រូវបានយកមកប្រើដើម្បីកែលម្អវិធីសាស្ត្រគណនាភាពក្រីក្រនៅកម្ពុជា។** ការកែលម្អនោះ អនុវត្តតាមគោលការណ៍សំខាន់ៗមួយចំនួននៃការវាស់វែងភាពក្រីក្រ និងកម្រិតជីវភាពរស់នៅដែលបានអនុវត្តនៅកម្ពុជាកន្លងមក។ អ្វីដែលខុសប្លែកគ្នាមានដូចជា៖ (ទី១) ប្រើព័ត៌មានដែលមានទាំងអស់ ចាប់តាំងពីឆ្នាំ ២០០៤, (ទី២) ប្រើកម្រិតថាមពលចំណីអាហារថ្មី, (ទីបី) ប្រើមុខទំនិញ ដែលប្រជាពលរដ្ឋបានប្រើប្រាស់នៅឆ្នាំ ២០០៩, (ទី៤) បន្ទាត់ភាពក្រីក្រមិនមែនម្ហូបអាហារគណនាចេញពីក្រុមប្រជាពលរដ្ឋក្រីក្រ នៅឆ្នាំ ២០០៩, និង (ទី៥) ប្រើសន្ទស្សន៍ថ្លៃទំនិញដែលគ្របដណ្តប់ទូទាំង

## ប្រអប់ ១៖ វាស់វែងភាពក្រីក្រនៅកម្ពុជា៖ វិធីសាស្ត្ររបស់ធនាគារពិភពលោកឆ្នាំ២០០៩

សំណួរវែងអំពីចំណាយលើការប្រើប្រាស់ក្នុងការអង្កេតសេដ្ឋកិច្ចសង្គមឆ្នាំ ២០០៩ ត្រូវបានយកមកប្រើ ដើម្បីគណនាចំណាយលើការប្រើប្រាស់របស់មនុស្សម្នាក់ៗ។ សំណួរទាំងនោះរួមមានម្ហូបអាហារដែលបរិភោគនៅផ្ទះ (តាមរយៈការទិញ ការធ្វើខ្លួនឯង ឬអំណោយពីអ្នកដទៃក៏ដោយ), ថ្លៃផ្ទះសម្បែង (ការជួលគេ ឬមានផ្ទះខ្លួនឯងក៏ដោយ), ស្ថានភាពផ្ទះសម្បែង, អុស, ភ្លើង, ហ្គាស, ទឹក ជាដើម, គមនាគមន៍និងទំនាក់ទំនង, ការទិញរបស់របរសម្រាប់ប្រើប្រាស់ក្នុងផ្ទះ, ការទិញរបស់របរផ្ទាល់ខ្លួន, ចំណាយលើការលំហែនិងកម្សាន្ត, ចំណាយលើការសិក្សាអប់រំ និងថែទាំសុខភាព ។ល។ ការចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋ ត្រូវបានគណនាប្រចាំខែ សម្រាប់គ្រួសារនីមួយៗ។ បន្ទាប់មក ដើម្បីឲ្យងាយស្រួលយល់ ចំនួននេះត្រូវបានគណនាជាប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់ៗ។ ក្នុងការគណនាចំណាយសរុបរបស់គ្រួសារនីមួយៗ យើងជំនួសព័ត៌មានដែលអត់មាន ឬក៏ព័ត៌មានដែលប្រមូលមកខុសដោយព័ត៌មានត្រឹមត្រូវតាមរយៈគ្រួសារដែលមានស្ថានភាពស្រដៀងគ្នា។ ប៉ុន្តែករណីនេះកើតមានតែគ្រួសារចំនួន ៣,៣ ភាគរយប៉ុណ្ណោះ សម្រាប់គ្រួសារភាគច្រើនដទៃទៀត យើងមិនឃើញមានបញ្ហាទាំងនេះទេ។ ការគណនាបង្ហាញថា ការចំណាយលើការប្រើប្រាស់ជាមធ្យមប្រចាំថ្ងៃ មាន ១៥.៧០៩ រៀលសម្រាប់ពលរដ្ឋរស់នៅទីក្រុងភ្នំពេញ ១០.១៨៤ រៀល សម្រាប់ពលរដ្ឋដែលរស់នៅទីប្រជុំជនដទៃទៀត និង ៦.០១៣ រៀល សម្រាប់ពលរដ្ឋនៅតាមជនបទ ដោយគិតជាការចំណាយលើការប្រើប្រាស់សម្រាប់មនុស្សម្នាក់ៗប្រចាំថ្ងៃដោយប្រើថ្លៃបច្ចុប្បន្ន។

បន្ទាត់ភាពក្រីក្រសរុបបានមកពីបន្ទាត់ភាពក្រីក្រម្ហូបអាហារបូកនឹងចំណាយលើមុខទំនិញ និងសេវាដែលមិនមែនម្ហូបអាហារ

ការចំណាយលើការប្រើប្រាស់សរុបនៅកម្ពុជា ឆ្នាំ២០០៩

- ម្ហូបអាហារដែលបរិភោគនៅក្នុងផ្ទះនិងក្រៅផ្ទះ(២០)
- តម្លៃជួលផ្ទះប្រចាំថ្ងៃ(២)
- ថ្លៃទឹក និងថ្លៃភ្លើង(១០)
- គមនាគមន៍និងទំនាក់ទំនង(២)
- ទិញវត្ថុប្រើប្រាស់ក្នុងផ្ទះ(១៦)
- ចំណាយលើការលំហែរនិងកម្សាន្ត(៣)
- ចំណាយលើការសិក្សាអប់រំ(៧)xចំនួនសមាជិកគ្រួសារ
- ចំណាយលើការថែទាំសុខភាព(២x២xចំនួនសមាជិកគ្រួសារ)
- ចំណាយផ្សេងៗរាប់ទាំងរបស់របរដែលគេឲ្យ(៤)

ផ្សេងៗ (ផ្ទះសម្បែង,សម្លៀកបំពាក់, របស់របរផ្ទាល់ខ្លួន, និងការលំហែផ្សេងៗ)។ ការគណនាម្ហូបអាហារប្រើព័ត៌មានពីកម្រងសំណួរកំណត់ត្រា ហើយក្រុមពលរដ្ឋដែលយើងយកមកគណនាបន្ទាត់ភាពក្រីក្រ គឺក្រុមពលរដ្ឋសត្តភាគ ទី៥ ដល់សត្តភាគទី២៥។ បន្ទាត់ភាពក្រីក្រម្ហូបអាហារគណនាដោយយោងលើបរមាណម្ហូបអាហារសរុប ដែលផ្តល់ថាមពល ២.២០០ គីឡូកាឡូរីក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ។ បន្ទាប់មកយើងគណនាថា ដើម្បីបានថាមពល ២.២០០ គីឡូកាឡូរីក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ គេត្រូវចំណាយប្រាក់អស់ប៉ុន្មានរៀល? យើងគណនាតាមវិធីនេះដាច់ដោយឡែកពីគ្នា ដើម្បីបានបន្ទាត់ភាពក្រីក្រម្ហូបអាហារសម្រាប់ប្រជាពលរដ្ឋនៅភ្នំពេញ, បន្ទាត់ភាពក្រីក្រម្ហូបអាហារសម្រាប់ប្រជាពលរដ្ឋនៅតាមទីប្រជុំជន, និងបន្ទាត់ភាពក្រីក្រម្ហូបអាហារសម្រាប់ប្រជាពលរដ្ឋនៅតាមទីជនបទ។ ចំណែកឯការគណនាបន្ទាត់ភាពក្រីក្រមិនមែនម្ហូបអាហារវិញ យើងយកស្មើនឹងអត្រាចំណាយលើទំនិញ និងសេវាមិនមែនម្ហូបអាហាររបស់ក្រុមពលរដ្ឋណាដែលបានចំណាយសុរបលើការប្រើប្រាស់ស្មើនឹងបន្ទាត់

ភាពក្រីក្រម្ហូបអាហារ។ នៅឆ្នាំ ២០០៩ គេសង្កេតឃើញថា មានប្រជាពលរដ្ឋចំនួន ៤៤៨ គ្រួសារ មានការចំណាយលើការប្រើប្រាស់សរុបរបស់ពួកគាត់ស្ថិតក្នុងរង្វង់ ១០ ភាគរយនៃបន្ទាត់ភាពក្រីក្រម្ហូបអាហារ។ សម្រាប់ក្រុមប្រជាពលរដ្ឋទាំងនោះ ការចំណាយលើម្ហូបអាហារមាន ៦៦ ភាគរយនៃការចំណាយសរុបរបស់ពួកគាត់ ហើយការចំណាយលើទំនិញ និងសេវាមិនមែនម្ហូបអាហារមាន ៣៦ ភាគរយ សម្រាប់ប្រជាពលរដ្ឋនៅភ្នំពេញ និង ៣៤ ភាគរយ សម្រាប់ប្រជាពលរដ្ឋនៅតំបន់ផ្សេងទៀត។ បន្ទាប់ពីបានអត្រានេះហើយ យើងយកវាទៅគុណជាមួយបន្ទាត់ភាពក្រីក្រសរុបដែលមានតម្លៃ៥.៣២៦ រៀល សម្រាប់ប្រជាពលរដ្ឋនៅភ្នំពេញ ៤.២៧៣ រៀល សម្រាប់ប្រជាពលរដ្ឋ ទីប្រជុំជនដទៃទៀតនិង ៣.៩១៤ រៀល សម្រាប់ប្រជាពលរដ្ឋនៅទីជនបទ (ដោយគិតក្នុងម្នាក់ៗ ក្នុងមួយថ្ងៃ និងតាមតម្លៃបច្ចុប្បន្ន)។

ប្រជាពលរដ្ឋណាដែលបានចំណាយប្រចាំថ្ងៃក្រោមបន្ទាត់ភាពក្រីក្រត្រូវបានចាត់ជាប្រជាពលរដ្ឋក្រីក្រ ហើយប្រជាពលរដ្ឋណាដែលបានចំណាយលើបន្ទាត់ភាពក្រីក្រមិនត្រូវបានចាត់ជាប្រជាពលរដ្ឋក្រីក្រទេ។ បន្ទាប់ពីប្រៀបធៀបកម្រិតចំណាយនឹងបន្ទាត់ភាពក្រីក្រ ការគណនាបានបង្ហាញថា អត្រាភាពក្រីក្រទូទាំងប្រទេសកម្ពុជាឆ្នាំ ២០០៩ មានកម្រិត ២៣,៩ ភាគរយ។ ចំណែកឯនៅភ្នំពេញមានកម្រិត ៩,៣ ភាគរយ នៅតាមទីជនបទ មានកម្រិត ២៧,៥ ភាគរយ ហើយនៅតាមទីប្រជុំជនផ្សេងៗទៀតមានកម្រិត ១២,៧ ភាគរយ។ បើប្រៀបធៀបទៅនឹងការគណនាតាមវិធីសាស្ត្រមុន អត្រាភាពក្រីក្រទូទាំងប្រទេសកម្ពុជានៅឆ្នាំ ២០០៩ មាន ២០,៧ ភាគរយ។ ការប្រៀបធៀបលម្អិតរវាងវិធីសាស្ត្រថ្មី និងវិធីសាស្ត្រពីមុនមានបង្ហាញជូននៅឧបសម្ពន្ធ័ទី១។

ប្រទេសកម្ពុជា។ ឧបសម្ពន្ធ័ទីមួយមានពន្យល់លម្អិតអំពីរបៀបគណនាចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋ និងការកំណត់បន្ទាត់ភាពក្រីក្រនៅកម្ពុជា។

**នៅខែ វិច្ឆិកា ឆ្នាំ ២០១២ រាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោកបានប្រៀបធៀបលទ្ធផលគណនាទទួលបានពីក្រុមការងារទាំងពីរ ហើយបានឯកភាពគ្នាថា អត្រាភាពក្រីក្រមានតួលេខប្រហាក់ប្រហែលគ្នាទេ។** បន្ទាប់ពីគណនាអត្រាភាពក្រីក្រនៅឆ្នាំ ២០០៩ មក ក្រុមការងារទាំងពីរនេះក៏បានគណនាអត្រាភាពក្រីក្រសម្រាប់ឆ្នាំ ២០០៤, ២០០៧, ២០០៨, ២០១០ និង ឆ្នាំ ២០១១។ ជាទូទៅគេសង្កេតឃើញថា លទ្ធផលគណនាបានពីក្រុមការងារទាំងពីរនេះស្ទើរតែដូចគ្នាទាំងស្រុងខុសគ្នាប្រហែល ១ ភាគរយ ឬតិចជាង ១ ភាគរយ ប៉ុណ្ណោះ លើកលែងតែនៅឆ្នាំ ២០០៧ និង ឆ្នាំ ២០០៨ ដែលលទ្ធផលខុសគ្នាប្រហែលជា ២,៣ ភាគរយ ហើយមូលហេតុគឺដោយសារតែក្រុមការងារធនាគារពិភពលោកបានប្រើប្រាស់សន្ទស្សន៍ថ្លៃទំនិញខុសពីសន្ទស្សន៍ថ្លៃទំនិញដែលក្រុមការងាររាជរដ្ឋាភិបាលបានប្រើប្រាស់។ ក្រុមការងារពិភពលោកប្រើសន្ទស្សន៍មួយផ្សេងទៀតដោយសារតែ នៅឆ្នាំ ២០០៨ ថ្លៃទំនិញមានការប្រែប្រួលលឿន។ ឧបសម្ពន្ធ័ទី២មានបរិយាយយ៉ាងលម្អិតពីអត្រាភាពក្រីក្រ ដែលគណនាដោយក្រុមការងារធនាគារពិភពលោក និងក្រុមការងាររាជរដ្ឋាភិបាល។ ក្រៅពីគោលបំណងគណនាអត្រានៃភាពក្រីក្រ ធនាគារពិភពលោកនឹងប្រើលទ្ធផលពីការវិភាគភាពក្រីក្រសម្រាប់គោលបំណងជាច្រើនទៀត ហេតុដូច្នេះហើយទើបក្រុមការងារទាំងពីរបានសម្រេចថា ធនាគារពិភពលោក និងរាជរដ្ឋាភិបាលកម្ពុជាអាចប្រើប្រាស់វិធីសាស្ត្រគណនារៀងៗខ្លួនបាន។ ក្នុងរបាយការណ៍នេះ យើងប្រើលទ្ធផលគណនាពីវិធីសាស្ត្ររបស់ធនាគារពិភពលោក។

## កម្រិត និងនិន្នាការនៃភាពក្រីក្រនៅកម្ពុជា

**ក្នុងរយៈពេល៧ឆ្នាំ កម្ពុជាបានកាត់បន្ថយភាពក្រីក្របានជាងពាក់កណ្តាល។ បើគិតត្រឹម ឆ្នាំ ២០១១ អត្រាភាពក្រីក្រនៅកម្ពុជាស្មើ ២០,៥ ភាគរយ។** ការកាត់បន្ថយភាពក្រីក្រមានល្បឿនល្មមពីឆ្នាំ ២០០៤ ដល់ ឆ្នាំ២០០៧ ប៉ុន្តែបន្ទាប់ពីពេលនោះមក ភាពក្រីក្រត្រូវបានកាត់បន្ថយយ៉ាងលឿនពីកម្រិត ៥០,១ ភាគរយ នៅឆ្នាំ ២០០៧

មកត្រឹម ២៣,៩ ភាគរយ នៅឆ្នាំ ២០០៩។ គេសង្កេតឃើញថា មានតែប្រទេសមួយចំនួនតូចប៉ុណ្ណោះ ដែលអាចកាត់បន្ថយអត្រាភាពក្រីក្របានលឿន ដូចកម្ពុជាក្នុងឆ្នាំ ២០០៩។ បន្ទាប់ពីឆ្នាំ ២០០៩ មក ល្បឿននៃការកាត់បន្ថយភាពក្រីក្រមានកម្រិតល្មមវិញ។ (**ក្រាហ្វិក ៥**)

**គ្មាននរណាម្នាក់គិតថា កម្ពុជាអាចកាត់បន្ថយភាពក្រីក្របានយ៉ាងលឿនដូច្នោះទេ។** ដោយហេតុនេះហើយ បន្ទាប់ពីលទ្ធផលនៃការគណនាបានចេញមក មានអ្នកវិភាគជាច្រើនបានត្រួតពិនិត្យលើការគណនានេះ ក្នុងនោះរួមមានទាំងអ្នកជំនាញទាំងនៅខាងក្នុង និងខាងក្រៅធនាគារពិភពលោក។ ហើយលទ្ធផលពីការគណនានេះត្រូវបានយកទៅប្រៀបធៀបជាមួយនឹងសូចនាករដទៃៗទៀត។ ការគណនាអតិផរណាឆ្នាំ ២០០៨ អាចមិនមានសុក្រិតភាព ប៉ុន្តែជាទូទៅ ក្រុមអ្នកវិភាគបានយល់ស្របគ្នាថា បញ្ហានេះមិនមែនកើតឡើងនៅឆ្នាំ ២០០៧ និងឆ្នាំ ២០០៩ ទេ។

**ក្រាហ្វិក ៥៖ អត្រាភាពក្រីក្រនៅទូទាំងកម្ពុជា និងកម្រិតលម្អៀងស្ថិតិពីការគណនា**




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាម អ.ស.ស.ក

**ក្រាហ្វិក ៦៖ អត្រាភាពក្រីក្រតាមតំបន់សំខាន់ៗឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១**




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាម អ.ស.ស.ក ។

**ភាពក្រីក្រត្រូវបានកាត់បន្ថយគ្រប់តំបន់ទាំងអស់ នៅទូទាំងប្រទេស ប៉ុន្តែបានកើតឡើង ក្នុងពេលខុសៗគ្នា។** ដោយសារប្រជាពលរដ្ឋប្រមាណ ៨០ ភាគរយ រស់នៅតាមទីជនបទ វាមិនមែនជាការចម្លែកទេ ដែលអត្រាភាពក្រីក្រនៅទូទាំងកម្ពុជាមានទំនោរ ដូចនឹងអត្រាភាពក្រីក្រនៅតាមទីជនបទ។ នៅភ្នំពេញ ការកាត់បន្ថយភាពក្រីក្រស្ទើរតែទាំងអស់បានកើតឡើងពីឆ្នាំ ២០០៤ ដល់ ឆ្នាំ ២០០៧ ហើយអត្រាភាពក្រីក្របានកើនឡើង នៅឆ្នាំ ២០១០។ ចំណែកឯនៅទីប្រជុំជនដទៃទៀត អត្រាភាពក្រីក្របានធ្លាក់ចុះពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១០ ហើយបានកើនឡើងនៅឆ្នាំ ២០១១។ (**ក្រាហ្វិក ៦**)

**បើសិនជាគេរៀបចំកម្មវិធី ដើម្បីជួយកាត់បន្ថយភាពក្រីក្រ កម្មវិធីទាំងនោះត្រូវតែផ្តោតទៅលើប្រជាពលរដ្ឋនៅតាមទីជនបទ ហើយសកម្មភាពរបស់កម្មវិធីត្រូវតែលើកកម្ពស់មូលធនមនុស្ស និងប្រាក់ចំណូល នៅតាមតំបន់ជនបទ ដែលក្នុងនោះរួមមានសុខភាព អប់រំ កសិកម្មផលផល និងការងារពាក់ព័ន្ធមួយចំនួនទៀត។** គិតមកត្រឹមឆ្នាំ២០១១ អត្រានៃភាពក្រីក្រនៅទីជនបទមានអត្រាខ្ពស់ជាងតំបន់ដទៃទៀត។ នៅជនបទ អត្រាភាពក្រីក្រមានកម្រិត ២៣,៧ភាគរយ នៅភ្នំពេញ ១,៥ ភាគរយនិងនៅទីប្រជុំជនដទៃទៀត ១៦,១ ភាគរយ។ ទោះបីជាអត្រាភាពក្រីក្រនៅជនបទធៀបនឹងទីក្រុងបានធ្លាក់ចុះក្តី (ពី ២៧,៦ ភាគរយ ក្នុងឆ្នាំ ២០០៤ មក ១៤,៩ ភាគរយ ក្នុងឆ្នាំ ២០១១) ចំនួនពលរដ្ឋក្រីក្រនៅជនបទនៅតែមានចំនួនច្រើននៅឡើយ។ ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រទូទាំងប្រទេស ១០ នាក់ មាន ៩ នាក់រស់នៅទីជនបទ។ នេះដោយសារ ប្រជាពលរដ្ឋរស់នៅទីក្រុង មានតែ ២១,២ ភាគរយនៃប្រជាពលរដ្ឋសរុបប៉ុណ្ណោះ។ ចំណែកឯទីជនបទ មានប្រជាពលរដ្ឋរហូតដល់ ៧៨,៨ ភាគរយឯណោះ។ (**មើលតារាង ១**)

**សម្រាប់ក្រុមគ្រួសារដែលមានស្ត្រីជាមេគ្រួសារ គេមិនឃើញថា ភាពក្រីក្រមានកម្រិតខ្ពស់ជាងគ្រួសារដែលមានបុរសជាមេគ្រួសារឡើយ។** តាមទំនោរពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ ក្នុងឆ្នាំខ្លះ គ្រួសារដែលមានស្ត្រីជាមេគ្រួសារមានអត្រាភាពក្រីក្រខ្ពស់ជាងគ្រួសារ ដែលមានបុរសជាមេគ្រួសារ ប៉ុន្តែនៅឆ្នាំខ្លះ គ្រួសារដែលមានស្ត្រីជាមេគ្រួសារមានអត្រាភាពក្រីក្រទាបជាងគ្រួសារ ដែលមានបុរសជាមេគ្រួសារ ដូច្នេះហើយ គម្លាតនេះមានតិចតួចប៉ុណ្ណោះ (**តារាងទី១**) ។ ប្រជាពលរដ្ឋដែលពុំមែនជាពលរដ្ឋខ្មែរមានប្រមាណ ២,៩ ភាគរយ នៃប្រជាពលរដ្ឋសរុប ហើយព័ត៌មានដែលបានមកពីការអង្កេត សម្រាប់ពួកគេអាចជឿជាក់បានតែឆ្នាំ ដែលសំណាកគំរូធំប៉ុណ្ណោះ។ ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩ គ្រួសារដែលមានមេគ្រួសារមិនមែនជាជនជាតិខ្មែរមានអត្រាភាពក្រីក្រ ៦,៥ ភាគរយ ខ្ពស់ជាងគ្រួសារដែលមានមេគ្រួសារជាជនជាតិខ្មែរ។

**នៅកម្ពុជា អត្រាភាពក្រីក្រ ក្នុងចំណោមកុមារនៅតែមានកម្រិតខ្ពស់យ៉ាងខ្លាំង ។ អត្រាភាពក្រីក្រក្នុងចំណោមប្រជាពលរដ្ឋពេញវ័យ មានកម្រិតទាបជាង។** អត្រាភាពក្រីក្រ ក្នុងចំណោមកុមារ ដែលមានអាយុ ៦ ឆ្នាំឬទាបជាងនេះមានកម្រិត ២៧,២ ភាគរយ កម្រិតនេះលើសអត្រាភាពក្រីក្រក្នុងចំណោមមនុស្សពេញវ័យ ១០ ភាគ រយ។ អត្រាភាពក្រីក្រកាន់តែមានកម្រិតទាប សម្រាប់ក្រុមប្រជាពលរដ្ឋអាយុកាន់តែខ្ពស់ឡើងៗ ហើយសម្រាប់ក្រុមប្រជាពលរដ្ឋមនុស្សចាស់អត្រានេះ មានកម្រិតទាបបំផុត។ ក្នុងចំណោមប្រជាពលរដ្ឋដែលមានអាយុ ៦០ ឆ្នាំឡើងទៅ អត្រាភាពក្រីក្រមានតែ ១៥,៤ ភាគរយ ប៉ុណ្ណោះ។ ប្រការនេះបានឆ្លុះបញ្ចាំងពី ប្រពៃណី របស់ប្រជាពលរដ្ឋកម្ពុជា ដែលនៅតែទំនុកបម្រុង មនុស្សចាស់។ ការទំនុកបម្រុងមនុស្សចាស់ ក៏មានភាពងាយស្រួលជាងមុនដែរ ដោយសារតែក្នុងគ្រួសារនីមួយៗ មានមនុស្សពេញវ័យធ្វើការ ចំនួនច្រើនជាងមុន។

**ភាពក្រីក្រនៅកម្ពុជាមិនត្រឹមតែថយចុះប៉ុណ្ណោះទេ ប៉ុន្តែប្រជាពលរដ្ឋក្រីក្របច្ចុប្បន្ន មានស្ថានភាពល្អប្រសើរជាងប្រជាពលរដ្ឋក្រីក្រពីអតីតកាល ក្នុងនោះរាប់ទាំងប្រជាពលរដ្ឋមានជីវភាពជុនដាបផង។** សន្ទស្សន៍គម្លាតនៃភាពក្រីក្រដែលជាសន្ទស្សន៍សម្រាប់វាស់វែងថា តើប្រជាពលរដ្ឋក្រីក្រមានកម្រិតភាពក្រីក្រដល់កម្រិតណានោះ បានធ្លាក់ចុះគួរឲ្យកត់សម្គាល់ពីអត្រា ១៦,២ ភាគរយនៅឆ្នាំ ២០០៤ មកត្រឹម ៤,២ភាគរយនៅឆ្នាំ២០១១។ សូម្បីតែសន្ទស្សន៍ជម្រៅនៃភាពក្រីក្រ ដែលជាវិធីសាស្ត្រសម្រាប់វាស់វែងស្ថានភាពរបស់ប្រជាពលរដ្ឋក្រីក្របំផុតក្នុងចំណោមប្រជាពលរដ្ឋក្រីក្រទាំងអស់ក៏បានថយចុះនៅក្នុងអំឡុងពេលដូចគ្នានេះ ដោយបានថយចុះពី ៦,៦ ភាគរយមកត្រឹម ១,៣ ភាគរយ។ ដោយសន្ទស្សន៍ទាំងពីរនេះមានទំនោរធ្លាក់ចុះទាំងនៅតំបន់ជនបទ និងនៅតំបន់ទីប្រជុំជន។

**ចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋម្នាក់ៗ បានកើនឡើង ៣៧,៨ ភាគរយ ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ (៤,៧ ភាគរយក្នុង ១ឆ្នាំ)។ ចំណែកឯកំណើននៃផលិតផលក្នុងស្រុកក្នុងម្នាក់ៗ ក្នុងអំឡុងពេលដូចគ្នា មាន ៥០,៩ ភាគរយ ។** ដោយសារតែបន្ទាត់ភាពក្រីក្រត្រូវបានកំណត់តាមថ្លៃថេរពីមួយឆ្នាំទៅមួយឆ្នាំ អត្រាភាពក្រីក្រអាស្រ័យទៅនឹងការប្រែប្រួលនៃចំណាយ និងរបាយនៃកម្រិតចំណាយរបស់ពលរដ្ឋទូទាំងប្រទេស។ ដើម្បីឲ្យគេអាចស្វែងយល់អំពីស្ថានភាពនៃការកាត់បន្ថយភាពក្រីក្រ គេត្រូវប្រៀបធៀបកំណើននៃចំណាយលើការប្រើប្រាស់របស់ពលរដ្ឋម្នាក់ៗ ទៅនឹងកំណើនផលិតផលក្នុងស្រុកក្នុងម្នាក់ៗ។ ការប្រៀបធៀបបានបង្ហាញថា ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ កំណើនសរុបនៃចំណាយលើការប្រើប្រាស់របស់មនុស្សម្នាក់ៗមាន ៣៧,៨ ភាគរយ ចំណែកឯ កំណើនផលិតផលក្នុងស្រុកក្នុងម្នាក់ៗ មាន ៥០,៩ ភាគរយ។

## សូចនាកររវាស់វែងកម្រិតជីវភាពពលរដ្ឋផ្សេងៗទៀត

**របាយការណ៍នេះ បានគណនាសន្ទស្សន៍ទ្រព្យសម្បត្តិដោយរាប់បញ្ចូលនូវរបស់របរប្រើប្រាស់ចំនួន ៤៤ មុខនិងស្ថានភាពលំនៅដ្ឋាន ៣៤ សូចនាករ ដោយប្រើព័ត៌មានដែលបានមកពីការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា។**

**តារាង ១៖** អត្រាភាពក្រីក្រ, គម្លាតភាពក្រីក្រ, ជម្រៅភាពក្រីក្រ,និងការរួមចំណែករបស់កត្តាទាំងនេះក្នុងការកាត់បន្ថយភាពក្រីក្រ

| | ឆ្នាំ | | | | | |
|---|---|---|---|---|---|---|
| | ២០០៤ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
| **អត្រាភាពក្រីក្រ** | | | | | | |
| **សរុប** | **៥៣,២%** | **៥០,១%** | **៣៨,៨%** | **២៣,៩%** | **២២,១%** | **២០,៥%** |
| មេគ្រួសារជាបុរស | ៥៣,៦% | ៥១,១% | ៣៨,៧% | ២៤,២% | ២២,៦% | ២០,១% |
| មេគ្រួសារជាស្ត្រី | ៥១,៣% | ៤៥,៥% | ៣៩,០% | ២២,៤% | ១៩,៣% | ២២,៥% |
| មេគ្រួសារជាជនជាតិខ្មែរ | ៥៣,០% | សំណាកតូច | សំណាកតូច | ២៣,៦% | សំណាកតូច | សំណាកតូច |
| មេគ្រួសារមិនមែនជាជនជាតិខ្មែរ (ជនជាតិភាគតិច) | ៥៩,២% | សំណាកតូច | សំណាកតូច | ៣០,៣% | សំណាកតូច | សំណាកតូច |
| ០-៦ ឆ្នាំ | ៦២,៥% | ៥៧,៦% | ៤៧,៧% | ៣០,៤% | ៣០,៦% | ២៧,២% |
| ៧-២០ ឆ្នាំ | ៥៧,៣% | ៥៤,៧% | ៤៣,៥% | ២៧,០% | ២៥,៤% | ២៣,៩% |
| ២១-៥៩ ឆ្នាំ | ៤៨,២% | ៤៥,៦% | ៣៤,២% | ២០,៩% | ១៨,៦% | ១៧,៣% |
| ៦០ ឆ្នាំ | ៤២,៩% | ៤១,២% | ៣០,១% | ១៧,០% | ១៣,០% | ១៥,៤% |
| **សន្ទស្សន៍គម្លាតភាពក្រីក្រ** | | | | | | |
| **សរុប** | ១៦,២% | ១៥,៦% | ១០,៤% | ៥,៣% | ៤,៧% | ៤,២% |
| ភ្នំពេញ | ៤,០% | ០,៤% | ០,៦% | ០,៩% | ០,៨% | ០,២% |
| ទីប្រជុំជនផ្សេងទៀត | ១១,៦% | ១០,៤% | ៦,៥% | ២,៥% | ២,៤% | ៣,៥% |
| ជនបទ | ១៨,១% | ១៨,២% | ១២,១% | ៦,១% | ៥,៤% | ៤,៨% |
| **ជម្រៅភាពក្រីក្រ(សន្ទស្សន៍ជម្រៅភាពក្រីក្រ)** | | | | | | |
| **សរុប** | **៦,៦%** | **៦,៥%** | **៣,៩%** | **១,៧%** | **១,៥%** | **១,៣%** |
| **ការរួមចំណែករបស់កត្តាទាំងនេះ:** | | | | | | |
| **សរុប** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** |
| ភ្នំពេញ | ២,៥% | ០,៥% | ០,៦% | ១,៧% | ២,០% | ០,៨% |
| ទីប្រជុំជនផ្សេងទៀត | ៨,១% | ៧,២% | ៧,១% | ៥,១% | ៥,៩% | ៨,២% |
| ជនបទ | ៨៩,៤% | ៩២,៣% | ៩២,៣% | ៩៣,២% | ៩២,១% | ៩១,០% |
| **ចំណាយលើការប្រើប្រាស់ជាមធ្យមរបស់ពលរដ្ឋម្នាក់ៗក្នុងមួយថ្ងៃ គិតតាមថ្លៃថេរឆ្នាំ២០០៩, ភ្នំពេញ (បន្ទាត់ភាពក្រីក្រ = ៥.៣២៦,៣៦)** | | | | | | |
| **ទូទាំងកម្ពុជា** | **៦.៣៩៩** | **៧.១៧៦** | **៧.៥៨០** | **៩.៣២៥** | **៩.១០៥** | **៨.៨១៥** |
| កំណើនក្នុងមួយឆ្នាំៗចាប់ពីឆ្នាំ២០០៤ | | ៣,៩% | ៤,៣% | ៧,៨% | ៦,១% | ៤,៧% |
| កំណើនសរុបចាប់ពីឆ្នាំ២០០៤ | | ១២,១% | ១៨,៥% | ៤៥,៧% | ៤២,៣% | ៣៧,៨% |

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយផ្អែកតាមគណនីជាតិ។

(សន្ទស្សន៍ទ្រព្យសម្បត្តិជាការវាស់វែងរបស់របរប្រើប្រាស់នៅក្នុងផ្ទះនិងស្ថានភាពលំនៅដ្ឋាន ហើយវិធីសាស្ត្រនេះ ត្រូវបានគេយកមកប្រើប្រាស់ ដើម្បីវាស់វែងជីវភាពរបស់ប្រជាពលរដ្ឋសម្រាប់រយៈពេលវែង ជំនួសសូចនាករចំណាយលើការប្រើប្រាស់របស់ពលរដ្ឋម្នាក់ៗ)។ យើងប្រើសូចនាករសន្ទស្សន៍ទ្រព្យសម្បត្តិពីរយ៉ាង។ ទី១ ប្រៀបធៀបការប្រែប្រួលសន្ទស្សន៍ទ្រព្យសម្បត្តិនឹងការប្រែប្រួលចំណាយលើការប្រើប្រាស់របស់ពលរដ្ឋម្នាក់ៗ។ ទី២ យើងប្រៀបធៀបអត្រាភាពក្រីក្រ ដែលបានមកពីការគណនាសន្ទស្សន៍ទ្រព្យសម្បត្តិ ទៅនឹងភាពក្រីក្រជាក់ស្តែងដែលបានការគណនាការចំណាយរបស់ពលរដ្ឋពីឆ្នាំ ២០០៤ ដល់ ឆ្នាំ ២០១១។ (**តារាង ២**)

**លទ្ធផលបានបង្ហាញថា ទំនោរនៃសន្ទស្សន៍ទ្រព្យ-សម្បត្តិមានលក្ខណៈស្រដៀងទៅនឹងទំនោរចំណាយលើការប្រើប្រាស់ ហើយអត្រាភាពក្រីក្រគណនាពីវិធីសាស្ត្រទាំងពីរនេះ ក៏មានទំនោរស្រដៀងគ្នាដែរ។** កំណើនសន្ទស្សន៍ទ្រព្យសម្បត្តិបានកើនឡើង ៤៥,៦ ភាគរយក្នុងរយៈពេល ៧ឆ្នាំ ទាបជាងកំណើនជាមធ្យមនៃចំណាយលើការប្រើប្រាស់ជាមធ្យមរបស់ពលរដ្ឋម្នាក់ៗ ដែលបានកើនឡើង ៥៦,៥ ភាគរយ។ លើសពីនេះទៀត ពីឆ្នាំ ២០០៤ ដល់ ឆ្នាំ ២០១១ អត្រាភាពក្រីក្របានពីការគណនាតាមសន្ទស្សន៍ទ្រព្យសម្បត្តិបានធ្លាក់ចុះប្រមាណ ៦៣,៣ភាគរយ ចំណែកឯអត្រាភាពក្រីក្រពិតគណនាតាមចំណាយលើការប្រើប្រាស់បានធ្លាក់ចុះប្រមាណ ៦១,៤ ភាគរយ។

**ការសិក្សាឯករាជ្យផ្សេងៗក៏បានបង្ហាញថា ជីវភាពរបស់ពលរដ្ឋកម្ពុជាពិតជាបានរីកចម្រើនគួរឲ្យកត់សម្គាល់មែន។** នៅឆ្នាំ ២០១០ ការសិក្សាមួយបានធ្វើឡើងដោយ ឡេអូ (Leo) និង បាមីញ៉ែ (Barmeier) ស្តីពីវឌ្ឍនភាពគោលដៅសហស្សវត្សន៍របស់ប្រទេសប្រហែលចំនួន៧៦ ដែលជាប្រទេសក្រីក្របំផុត ចាត់ថ្នាក់ដោយសមាគមអភិ-វឌ្ឍន៍អន្តរជាតិនៃធនាគារពិភពលោក (IDA)។ ការសិក្សានេះបានប្រៀបធៀបភាពរីកចម្រើនរបស់ប្រទេសនីមួយៗ ទៅនឹងចំណុចដៅសំខាន់ៗរបស់គោលដៅសហស្សវត្សន៍ មានជាអាទិ៍ភាពក្រីក្រភាពអត់ឃ្លាន វិសមភាព យេនឌ័រ វិស័យអប់រំ អត្រាមរណៈកុមារ វិស័យសុខភាព និង វិស័យទឹកស្អាត។ ប្រសិនបើសូចនាករនីមួយៗ ដែលមានភាពរីកចម្រើនអាចសម្រេចបានចំណុចដៅ ឬក៏សម្រេចលើសចំណុចដៅនោះ គេឲ្យពិន្ទុមួយ។ ចំពោះសូចនាករទាំងឡាយណាដែលមានភាពរីកចម្រើនតែ ៥០ ភាគរយ គេឲ្យពិន្ទុវា ចំនួនកន្លះពិន្ទុ។ ចំពោះសូចនាករផ្សេងៗទៀត ដែលមានការរីកចម្រើនទាបជាង គេឲ្យពិន្ទុសូន្យ។ កម្ពុជាបានទទួលពិន្ទុ ៥,៥ ហើយពិន្ទុនេះបានធ្វើឲ្យកម្ពុជាជាប់ថ្នាក់ល្អបំផុតទី៥ ស្មើនឹងប្រទេសនេប៉ាល់ ហើយទាបជាងប្រទេសឡាវ និងប្រទេសវៀតណាមតែបន្តិចប៉ុណ្ណោះ។

**ចំណាត់ថ្នាក់របស់កម្ពុជាពាក់ព័ន្ធទៅនឹងការអភិវឌ្ឍមនុស្សនៅតែមានកម្រិតទាប ក៏ប៉ុន្តែការប្រែប្រួលចំណាត់ថ្នាក់នេះ ក្នុងរយៈពេល ១០ ឆ្នាំ ចុងក្រោយ ល្អជាងគេបំផុត ក្នុងចំណោមប្រទេសនានាក្នុងតំបន់។**ការអភិវឌ្ឍន៍មនុស្សនៅលើពិភពលោកត្រូវបានតាមដានវាយតម្លៃដោយភ្នាក់ងារអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដោយប្រើសន្ទស្សន៍អភិវឌ្ឍមនុស្ស។ សន្ទស្សន៍អភិវឌ្ឍមនុស្សត្រូវបានគណនា ដោយប្រើសូចនាករសំខាន់ៗ

**តារាង ២៖** សន្ទស្សន៍ទ្រព្យសម្បត្តិនិងចំណាយលើការប្រើប្រាស់នៅកម្ពុជា

| វិធីសាស្ត្រវាស់វែង | តម្លៃ | | | អត្រាភាពក្រីក្រ | | |
|---|---|---|---|---|---|---|
| | ២០០៤ | ២០១១ | បម្រែបម្រួល | ២០០៤ | ២០១១ | បម្រែបម្រួល |
| សន្ទស្សន៍ទ្រព្យសម្បត្តិ | ១,៦ | ២,៣ | ៤៥,៦% | ៤១,៦% | ១៥,៣% | -៦៣,៣% |
| ចំណាយលើការប្រើប្រាស់ | ២.៦៩៣ | ៤.២១៤ | ៥៦,៥% | ៥៣,២% | ២០,៥% | -៦១,៤% |

ពាក់ព័ន្ធនឹងបញ្ហាសុខភាព បញ្ហាអប់រំ និងកម្រិតជីវភាពរស់នៅរបស់ពលរដ្ឋ។ លទ្ធផលនៃសន្ទស្សន៍នេះបានបង្ហាញថា ចាប់ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១០ ប្រទេសកម្ពុជា មានការកែលម្អច្រើនជាងគេបំផុត បើធៀបនឹងប្រទេសនានា ក្នុងតំបន់ក្នុងអត្រា ១៨ ភាគរយដែលអត្រានេះខ្ពស់ជាងប្រទេសចិន និងប្រទេសឡាវ (១៦ ភាគរយ) ព្រមទាំងប្រទេសវៀតណាម (១២ ភាគរយ)។ ទោះបីជាយ៉ាងនេះក្តី បើប្រៀបធៀបបណ្តាប្រទេសនានា ក្នុងតំបន់នៅឆ្នាំ ២០១១ កម្ពុជានៅតែមានចំណាត់ថ្នាក់អន់ជាងគេបំផុត និងចំណាត់ថ្នាក់ទី ១៣៩ លើពិភពលោក ដោយសារសន្ទស្សន៍អភិវឌ្ឍមនុស្សនៅកម្ពុជាស្មើនឹង ០,៥២៣។ (**ក្រាហ្វិក ៧**)

## ស្ថានភាពផ្ទះសម្បែង និងរបស់របរប្រើប្រាស់ក្នុងផ្ទះ

គេសង្កេតឃើញថាស្ថានភាពផ្ទះសម្បែងរបស់ពលរដ្ឋមានការកែលម្អគ្រប់ផ្នែកទាំងអស់ រួមមានការកែលម្អដំបូល ជញ្ជាំង និងកម្រាលឥដ្ឋការ៉ូ មានទឹកស្អាត អគ្គិសនី និងមានបង្គន់អនាម័យប្រើប្រាស់។ ជាអាទិ៍ក្នុងរយៈពេលប្រាំពីរឆ្នាំ គឺពី ឆ្នាំ ២០០៤ ដល់ ឆ្នាំ ២០១១ គេសង្កេតឃើញថា លំនៅដ្ឋានរបស់ពលរដ្ឋកម្ពុជាមានការកែលម្អគួរឲ្យកត់សម្គាល់។ ចំនួនគ្រួសារ ដែលមានដំបូលផ្ទះរឹងមាំបានកើនឡើងពីមួយភាគបី ទៅមួយភាគពីរ, ចំនួនគ្រួសារដែលមានភ្លើងប្រើប្រាស់បានកើនឡើង៣ដង មានចំនួន ៣៧,៥ភាគរយនៅ ឆ្នាំ ២០១១, ចំនួនគ្រួសារដែលមានចង្កៀងប្រេងកាតសម្រាប់បំភ្លឺបានថយចុះពីមួយភាគពីរមកត្រឹមមួយភាគបួន, ចំនួនគ្រួសារដែលមានបង្គន់អនាម័យបានកើនឡើងទ្វេរដង, ចំនួនគ្រួសារដែលមានទឹកស្អាតប្រើប្រាស់បានកើនឡើងជិត ១០ភាគរយ។ ប៉ុន្តែអ្វីដែលជាបញ្ហានោះ គេសង្កេតឃើញថា ការប្រើប្រាស់អុសសម្រាប់ចម្អិនម្ហូបអាហារមានការធ្លាក់ចុះតិចតួចនៅទូទាំងប្រទេស ហើយបើនៅតាមទីជនបទវិញស្ទើរតែមិនមានការធ្លាក់ចុះបន្តិចសោះ។ សម្រាប់សូចនាករទាំងនេះ គេសង្កេតឃើញថា ក្រុមប្រជាពលរដ្ឋក្រីក្របំផុតនៅឆ្នាំ២០១១ មានស្ថានភាពប្រសើរជាងក្រុមប្រជាពលរដ្ឋជីវភាពមធ្យមកាលពីឆ្នាំ២០០៤។ ឧទាហរណ៍ប្រជាពលរដ្ឋក្រីក្របំផុតនៅឆ្នាំ ២០១១ មានលទ្ធភាពប្រើប្រាស់ភ្លើងអគ្គិសនី ទឹកស្អាត បង្គន់អនាម័យ និងមានដំបូលផ្ទះគ្រាន់បើជាងប្រជាពលរដ្ឋជីវភាពមធ្យមកាលពីឆ្នាំ ២០០៤។ (**តារាង ៣**)

ពីឆ្នាំ២០០៤ដល់ឆ្នាំ២០១១គេសង្កេតឃើញរបស់របរប្រើប្រាស់នៅក្នុងផ្ទះរបស់ប្រជាពលរដ្ឋមានការកើនឡើងគួរឲ្យកត់សម្គាល់។ **តារាងទី ៤**បានបង្ហាញថា អត្រាគ្រួសារប្រជាពលរដ្ឋ ដែលមានរបស់របរប្រើប្រាស់ក្នុងផ្ទះនៅ ឆ្នាំ២០១១ មានច្រើនជាង ៧ឆ្នាំមុនប្រហែលពីរដង។ ប្រជាពលរដ្ឋក្រីក្របំផុតនៅឆ្នាំ ២០១១មានរបស់របរប្រើប្រាស់ក្នុងផ្ទះ ច្រើនជាងប្រជាពលរដ្ឋ មានជីវភាពមធ្យមកាលពីឆ្នាំ២០០៤។ **តារាងទី ៤**បានបង្ហាញថា ប្រជាពលរដ្ឋបញ្ចូភាគទាបបំផុតនៅឆ្នាំ២០១១មានរបស់របរប្រើប្រាស់ក្នុងផ្ទះច្រើនជាង ប្រជាពលរដ្ឋក្នុងបញ្ចូភាគកណ្តាលកាលពីឆ្នាំ ២០០៤ ស្ទើរតែគ្រប់មុខទាំងអស់ លើកលែងតែទូរទស្សន៍មួយចេញ។ (**តារាង ៤**)

**ក្រាហ្វិក ៧៖** បម្រែបម្រួលសូចនាករអភិវឌ្ឍន៍មនុស្សរបស់បណ្តាប្រទេសមួយចំនួនពីឆ្នាំ២០០០ ដល់ឆ្នាំ២០១០




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោកដោយយោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់ភ្នាក់ងារអភិវឌ្ឍន៍អង្គការសហប្រជាជាតិ

**រយៈពេលខ្វះខាតស្បៀងរបស់ប្រជាពលរដ្ឋដែលជួបប្រទះការខ្វះខាតស្បៀងមានរយៈពេលខ្លីជាងមុន។ តាមសហគមន៍ ប្រជាពលរដ្ឋមានសុវត្ថិភាពជាងមុន ហើយឧក្រិដ្ឋកម្មក៏មានតិចជាងមុនដែរ។** វិធីសាស្ត្រមួយទៀតដើម្បីវាស់វែងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋគឺការសាកសួរប្រជាពលរដ្ឋដោយផ្ទាល់អំពីស្ថានភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ហើយបន្ទាប់មកត្រូវយកចម្លើយនោះយកមកប្រៀបធៀបគ្នា ពីពេលមួយទៅពេលមួយ។ កាលពីឆ្នាំ ២០០៤ ប្រជាពលរដ្ឋក្រីក្រដែលជួបប្រទះការខ្វះខាតស្បៀងមានរយៈពេលប្រហែលពីរសប្តាហ៍ ប៉ុន្តែនៅឆ្នាំ ២០១១ រយៈពេលជួបប្រទះការខ្វះខាតស្បៀងមានប្រហែលកន្លះសប្តាហ៍ប៉ុណ្ណោះ។ លើសពីនេះទៅទៀតសុវត្ថិភាពនៅតាមសហគមន៍បានកើនឡើងប្រហែលមួយភាគបី។ ប្រជាពលរដ្ឋជិត ៨០ ភាគរយបាននិយាយថាសហគមន៍របស់គាត់មានសុវត្ថិភាពជាងមុន ចំណែកឯអំពើឆក់ប្លន់បានធ្លាក់ចុះពី ៤ ភាគរយនៅឆ្នាំ ២០០៤ មកត្រឹម ២,៦ ភាគរយនៅឆ្នាំ ២០១១។ (**តារាង ៥**)

## វិសមភាពនៃការចំណាយរបស់ប្រជាពលរដ្ឋម្នាក់ៗ និងកំណើននៃការចំណាយ

**ចាប់ពីឆ្នាំ២០០៧មក គេសង្កេតឃើញថា វិសមភាពបានធ្លាក់ចុះ ៤ ឆ្នាំជាប់ៗគ្នា។** មុននេះបន្តិច កាលពីឆ្នាំ ២០០៤ ដល់ ឆ្នាំ២០០៧ គេសង្កេតឃើញថា វិសមភាព

**តារាង ៣៖** ស្ថានភាពលំនៅដ្ឋានសំខាន់ៗ (%នៃគ្រួសារ) តាមឆ្នាំ និងតាមបញ្ចភាគនៅកម្ពុជាឆ្នាំ២០០៤-២០១១

| | | ឆ្នាំ | |
|---|---|---|---|
| | | ២០០៤ | ២០១១ |
| ដំបូល | លោហៈ | ៣៤,៥% | ៤,១% |
| ប្រភពភ្លើងសម្រាប់អគ្គិសនី | ភ្ជាប់ទៅនឹងបណ្តាញអគ្គិសនី | ១២,៧% | ៣៧,៥% |
| | អាគុយ | ២៤,៤% | ៣៥០% |
| | ចង្កៀងប្រេងកាត | ៥៥,០% | ២៣,៤% |
| ទឹកស្អាតប្រើប្រាស់នៅរដូវប្រាំង | ទុយោ,អណ្តូងមានគម្រប, ទឹកស្ទឹង,ទឹកភ្លៀង | ៣៧,៦% | ៤៦,២% |
| | | ៣៥,៧% | ៣៥,៩% |
| បង្គន់អនាម័យ | បង្គន់អនាម័យមានគម្របត្រឹមត្រូវ | ២០,៨% | ៤២,១% |
| | បង្គន់អនាម័យពុំមានគម្របត្រឹមត្រូវ | ៧៤,២% | ៥៤,០% |
| ប្រភពថាមពលសម្រាប់ចម្អិនអាហារ | ហ្គាស | ៥,៩% | ១២,២% |
| | អុស | ៨៤,៦% | ៧៩,៨% |




សូចនាករដែលមានពណ៌លឿងមានន័យថាជីវភាពពលរដ្ឋមានភាពវិជ្ជមាន។ Q3 នៅឆ្នាំ២០០៤គឺជាបញ្ចភាគកណ្តាល។ Q1 នៅឆ្នាំ២០១១គឺជាបញ្ចភាគក្រោមគេបំផុត។
ប្រភព៖ ការប៉ាន់ស្មានរបស់ធនាគារពិភពលោក ដោយផ្អែកតាមអង្កេតខាងសង្គម និងសេដ្ឋកិច្ចកម្ពុជា (អ.ស.ស.ក)

បានកើន ដែលបញ្ហានេះជាឧបសគ្គចម្បងរារាំងការកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា បើទោះបីជាប្រទេសនេះមានកំណើនសេដ្ឋកិច្ចខ្ពស់ក៏ដោយ។ ប៉ុន្តែចាប់ពីឆ្នាំ ២០០៧ មក លទ្ធភាពបង្កើនការចំណាយ មិនគ្រាន់តែកើតមានក្នុងចំណោមប្រជាពលរដ្ឋក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែកំណើននេះក៏បានកើតមានក្នុងចំណោមប្រជាពលរដ្ឋក្រីក្របំផុតផងដែរ។ មេគុណជីនីបានកើនឡើងពី ០,៣២៦ ក្នុងឆ្នាំ ២០០៤ មក ០,៣៧៤ ក្នុងឆ្នាំ២០០៧។ ប៉ុន្តែចាប់ពីឆ្នាំ ២០០៧ មក របាយនៃការចាយវាយរបស់ប្រជាពលរដ្ឋនៅកម្ពុជាមានភាពស្មើគ្នាច្រើនជាងមុន ដោយគិតត្រឹមឆ្នាំ ២០១១ មេគុណជីនីស្មើនឹង ០,២៨២។ បើគេប្រើប្រាស់វិធីវិភាគម្យ៉ាងទៀត ដោយប្រៀបធៀបការចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋក្រីក្រ ទៅនឹងការចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋអ្នកមាន គេឃើញថាក្រុមប្រជាពលរដ្ឋអ្នកមានចំណាយលើសក្រុមប្រជាពលរដ្ឋអ្នកក្រីក្រ ៥ ដងកាលពី ឆ្នាំ២០០៤ បន្ទាប់មកកើនឡើងជាង ៦ ដង កាលពីឆ្នាំ២០០៧ ប៉ុន្តែវាបានធ្លាក់ចុះរហូតនាឆ្នាំបន្តបន្ទាប់មកទៀត ធ្លាក់ចុះដល់ ៤ ដងនៅឆ្នាំ២០១១។ (**ក្រាហ្វិក ៨**)

**វិសមភាពក្នុងតំបន់នីមួយៗរបស់កម្ពុជាបានធ្លាក់ចុះ ចំណែកឯវិសមភាពរវាងតំបន់នីមួយៗស្ទើរតែមិនមានការប្រែប្រួលទេ។** ដើម្បីវិភាគបញ្ហាវិសមភាគ គេគណនាសន្ទស្សន៍ថេល ដែលជាសន្ទស្សន៍មួយទៀតប្រើដើម្បីរក

**តារាង ៤៖** សូចនាកររបស់របរប្រើប្រាស់ក្នុងផ្ទះ(%នៃគ្រួសារ)តាមឆ្នាំ និងបញ្ចាភាគនៅកម្ពុជាពីឆ្នាំ២០០៤ដល់២០១១

| | ២០០៤ | ២០១១ |
|---|---|---|
| ទូរទស្សន៍ | ៤៦,១% | ៦៣,០% |
| កង្ហារ | ១២,៤% | ២៨,៦% |
| ចង្ក្រានដាំបាយ | ២៩% | ២៤,៦% |
| គែព្រូក | ៣០៤% | ៤៤,៣% |
| តុអាហារ | ៦,៨% | ១៣,២% |
| ម៉ាស៊ីនបូមទឹក | ៨,៣% | ១៤,០% |
| ម៉ូតូ | ២៨៦% | ៥៦,៥% |
| ទូរស័ព្ទដៃ | ១២,៧% | ៦៣,០% |




Q៣ នៅឆ្នាំ២០០៤គឺជាបញ្ចភាគកណ្ដាល។ Q១ នៅឆ្នាំ២០១១គឺជាបញ្ចភាគក្រោមគេបំផុត។

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

**តារាង ៥៖** ចំណែកនៃចំណាយលើការប្រើប្រាស់របស់ក្រុមប្រជាពលរដ្ឋ តាមបញ្ចាភាគនិងតម្លៃនៃមេគុណជីនីនៅកម្ពុជា

| | ២០០៤ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|---|---|
| ចំណែកបញ្ចភាគប្រជាពលរដ្ឋក្រី ក្របំផុត ២០% | ៨,៤% | ៧,៥% | ៨,៤% | ៨,៥% | ៩,០% | ៩,៦% |
| ចំណែកបញ្ចភាគប្រជាពលរដ្ឋ មានបំផុត ២០% | ៤២% | ៤៦% | ៤១% | ៤១% | ៤០% | ៣៨% |
| ចំណែកបញ្ចភាគមានបំផុត/ក្របំផុត | ៤,៩ | ៦,១ | ៤,៩ | ៤,៨ | ៤,៤ | ៤,០ |
| មេគុណជីនី x១០០ | ៣២,៦ | ៣៧,៤ | ៣២,៣ | ៣១,៩ | ៣០,២ | ២៨,២ |
| សន្ទស្សន៍ថេល x១០០ | ១៨,៦ | ២៧,០ | ១៨,២ | ១៧,៩ | ១៦,០ | ១៣,៧ |

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

មូលហេតុដែលនាំឲ្យមានវិសមភាព។ សន្ទស្សន៍នេះអាចវិភាគវិសមភាពក្នុងតំបន់នីមួយៗ និងវិសមភាពរវាងតំបន់នីមួយៗ ហើយវាអាចជួយយើងឲ្យស្វែងយល់ពីបញ្ហាវិសមភាព និងទំនោរវិសមភាព។ លទ្ធផលបង្ហាញថា សន្ទស្សន៍ថេល មានទំនោរដូចសន្ទស្សន៍ជីនីដែរ គឺថាកើនឡើងកាលពីឆ្នាំ ២០០៧ បន្ទាប់មកមានការថយចុះនាឆ្នាំបន្តទៀត។ គេសង្កេតឃើញថាវិសមភាពក្នុងតំបន់នីមួយៗស្ទើរតែនៅដដែល ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១។ កាលពីឆ្នាំ២០០៤ ស្មើ ០,០៣០ ហើយឆ្នាំ ២០១១ ស្មើ ០,០៣២។

**កំណើនចំណាយលើការប្រើប្រាស់ជាមធ្យមអាស្រ័យទៅនឹងកំណើនលើការប្រើប្រាស់របស់ក្រុមប្រជាពលរដ្ឋនីមួយៗ។** កាលពី ឆ្នាំ២០០៧ គេឃើញចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋកម្ពុជាជាមធ្យមបានកើនឡើង ក៏ប៉ុន្តែ សម្រាប់ប្រជាពលរដ្ឋក្រីក្រមិនមានឃើញកើនឡើងទេ (នេះជាមូលហេតុ ដែលវិសមភាពបានកើនឡើងនៅឆ្នាំនោះ)។ ក្នុងឆ្នាំ ២០០៨ និងឆ្នាំ ២០០៩ ការចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋកម្ពុជាសរុបបានកើនឡើង លើកលែងតែចំពោះប្រជាពលរដ្ឋ ដែលជាអ្នកមានបំផុតប៉ុណ្ណោះ ដែលមិនបានបង្កើនចំណាយលើការប្រើប្រាស់របស់ពួកខ្លួនទេ ដោយសារទទួលរងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចសកល។ នៅឆ្នាំ២០១០និងឆ្នាំ២០១១មានតែប្រជាពលរដ្ឋបញ្ចភាគទាបបំផុតទាំងពីរប៉ុណ្ណោះ ដែលមានលទ្ធភាពបង្កើនចំណាយលើការប្រើប្រាស់របស់ខ្លួន ចំណែកឯក្រុមប្រជាពលរដ្ឋបញ្ចភាគខ្ពស់បំផុតទាំងពីរបានបន្ថយលើការប្រើប្រាស់របស់ខ្លួន។ ហេតុនេះហើយទើបគេសង្កេតឃើញថា អត្រានៃភាពក្រីក្របានធ្លាក់ចុះតិចតួច។ (**ក្រាហ្វិក ៩**)

កត្តាទាំងពីរដែលបានរៀបរាប់ខាងលើ (របាយចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋ និងកំណើនចំណាយលើការប្រើប្រាស់) បានដើរតួនាទីធ្វើឲ្យភាពក្រីក្រមានការប្រែប្រួល។ ដើម្បីពន្យល់ថាតើកត្តាទាំងពីរនេះមានឥទ្ធិពលលើភាពក្រីក្រយ៉ាងដូចម្តេច? យើងបានធ្វើការវិភាគមួយ ហើយលទ្ធផលនៃការវិភាគនេះគឺគួរឲ្យចាប់អារម្មណ៍ណាស់ ពោលគឺនៅឆ្នាំខ្លះ កំណើនចំណាយលើការប្រើប្រាស់ជាកត្តានាំមុខក្នុងការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែនៅឆ្នាំខ្លះទៀត របាយនៃការចំណាយរបស់ក្រុមប្រជាពលរដ្ឋជាកត្តានាំមុខក្នុងការកាត់បន្ថយភាពក្រីក្រ។ ចំពោះឆ្នាំខ្លះទៀតកត្តាទាំងពីរនេះបានជួយកាត់បន្ថយភាពក្រីក្រព្រមគ្នា ហើយឆ្នាំខ្លះទៀត កត្តាទាំងពីរនេះមិនបានជួយកាត់បន្ថយភាព

**ក្រាហ្វិក ៨៖** សន្ទស្សន៍ថេល និងបម្រែបម្រួលនៃសន្ទស្សន៍ថេលនៅកម្ពុជាឆ្នាំ២០០៤ដល់ឆ្នាំ២០១១




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

ក្រីក្រទៅវិញទៅមកទេ។ ឧទាហរណ៍ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៧ កំណើនលើការប្រើប្រាស់ជាកត្តាចម្បងក្នុងការកាត់បន្ថយអត្រាភាពក្រីក្រទាំងមូលចំណែកឯវិសមភាពវិញ បានធ្វើឲ្យអត្រាភាពក្រីក្រកើនឡើង។ ពីឆ្នាំ ២០០៧ ដល់ឆ្នាំ២០០៨ កត្តាទាំងពីរនេះបានជួយកាត់បន្ថយភាពក្រីក្រព្រមគ្នា។ ប៉ុន្តែពីឆ្នាំ២០០៨ដល់ឆ្នាំ២០០៩ កំណើនចំណាយលើការប្រើប្រាស់ជាកត្តាសំខាន់ម្តងទៀតក្នុងការកាត់បន្ថយភាពក្រីក្រ ខណៈដែលវិសមភាពមិនមានតួនាទីអ្វីទេ។ ក្នុងរយៈពេល ២ ឆ្នាំចុងក្រោយ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១១ វិសមភាពជាកត្តាចម្បងដែលបានកាត់បន្ថយភាពក្រីក្រ ចំណែកឯកំណើនលើការប្រើប្រាស់ធ្វឲ្យភាពក្រីក្រកើនឡើង ដោយសារតែវាមិនមានកំណើនទេ។ (**តារាង ៦**)

## ភាពងាយរងគ្រោះ

ការកាត់បន្ថយភាពក្រីក្រដ៏ខ្លាំងក្លារបស់កម្ពុជា ពីឆ្នាំ ២០០៤ ដល់ឆ្នាំ២០១១ បង្ហាញឲ្យឃើញថាជីវភាពរបស់ប្រជាពលរដ្ឋជាច្រើន បានប្រែប្រួលមុខមាត់ ប៉ុន្តែការប្រែប្រួលមុខមាត់នេះមិនទាន់ធ្វើឲ្យប្រជាពលរដ្ឋមានជីវភាពធូរធារសម្បើមនៅឡើយទេ ប្រសិនបើមានហេតុការណ៍ចៃដន្យណាមួយបានកើតឡើង ដែលគេមិនបានរំពឹងទុក ហេតុការណ៍នោះនឹងធ្វើឲ្យប្រជាពលរដ្ឋជាច្រើនធ្លាក់ចូលក្នុងភាពក្រីក្រវិញជាមិនខាន។ ក្នុងការវិភាគពីភាពក្រីក្រ គេប្រើបន្ទាត់ភាពក្រីក្រ ដើម្បីបែងចែកឲ្យដឹងថា ប្រជាពលរដ្ឋណាម្នាក់ចាត់ជាប្រជាពលរដ្ឋក្រីក្រ ឬមិនមែនជាប្រជាពលរដ្ឋក្រីក្រ ប៉ុន្តែអ្វីដែលសំខាន់ដែរនោះ គេត្រូវដឹងថា ជីវភាពប្រជាពលរដ្ឋទាំងនោះ នៅចម្ងាយពីបន្ទាត់ភាពក្រីក្រកម្រិតណា។ យើងបានប្រើទស្សនទាននេះ ដើម្បីស្វែងយល់អំពីភាពក្រីក្រ និងភាពងាយរងគ្រោះនៅកម្ពុជា ហើយធ្វើការពន្យល់នៅកថាខណ្ឌខាងក្រោម។

**មូលហេតុដែលអត្រាភាពក្រីក្រធ្លាក់ចុះយ៉ាងច្រើននោះដោយសារតែប្រជាពលរដ្ឋមួយភាគធំមានជីវភាពក្រោមបន្ទាត់ភាពក្រីក្រតែបន្តិចបន្តួចប៉ុណ្ណោះ។** កំណើនចំណាយលើការប្រើប្រាស់បានជួយឲ្យប្រជាពលរដ្ឋកម្ពុជាមួយភាគធំចាកចេញពីភាពក្រីក្រ។ បើយើងមើលរបាយនៃការចំណាយរបស់ប្រជាពលរដ្ឋនៅ **ក្រាហ្វិកទី ១០** បានបង្ហាញថា កាលពីឆ្នាំ២០០៤ ប្រជាពលរដ្ឋមួយភាគធំផ្តុំគ្នានៅខាងឆ្វេងបន្ទាត់ភាពក្រីក្របន្តិច ប៉ុន្តែនៅឆ្នាំ២០១១វិញ ចំនួនប្រជាពលរដ្ឋមួយភាគធំផ្តុំគ្នានៅខាងស្តាំនៃបន្ទាត់ភាពក្រីក្របន្តិច (បន្ទាត់ភាពក្រីក្រមានតម្លៃ ៥.២៣៦រៀល

**ក្រាហ្វិក ៩៖** ចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋម្នាក់ៗ (គិតជាមធ្យមតាមបញ្ចភាគ, កម្ពុជា, ឆ្នាំ២០០៤-២០១១)




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

ក្នុងមនុស្សម្នាក់ៗ ក្នុងមួយថ្ងៃ)។ នេះ សបញ្ជាក់ឲ្យឃើញថា អត្រាភាពក្រីក្រងាយនឹងប្រែប្រួលណាស់ប្រសិនបើចំណាយលើការប្រើប្រាស់របស់ពលរដ្ឋមានភាពប្រែប្រួលនោះ។

**ការកាត់បន្ថយភាពក្រីក្របានយ៉ាងលឿននេះអាចកើតឡើងបាន ដោយសារតែរបាយចំណាយរបស់ប្រជាពលរដ្ឋពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩។** ដើម្បីពន្យល់ចំណុចនេះ យើងបានគណនាការចំណាយលើការប្រើប្រាស់របស់ក្រុមប្រជាពលរដ្ឋ ដែលមានជីវភាពចម្ងាយ ២០,៥ ភាគរយ ពីបន្ទាត់ភាពក្រីក្រនៅ ឆ្នាំ២០១១ និង ចម្ងាយ ៥៣,២ ភាគរយ ពីបន្ទាត់ភាពក្រីក្រ នៅឆ្នាំ ២០០៤។ សម្រាប់ក្រុមប្រជាពលរដ្ឋនេះ ពួកគាត់ជាអ្នកក្រីក្រកាលពីឆ្នាំ២០០៤ ក៏ប៉ុន្តែ គ្មាននរណាម្នាក់ជាអ្នកក្រីក្រទេនៅឆ្នាំ ២០១១។ ចម្ងាយជាមធ្យមសម្រាប់ក្រុមប្រជាពលរដ្ឋទៅបន្ទាត់ភាពក្រីក្រនៅ ឆ្នាំ ២០០៤ គឺ ១.០៧២ រៀល ក្នុងម្នាក់ក្នុងមួយថ្ងៃ។ និយាយម៉្យាងទៀត ក្នុងឆ្នាំ២០០៤ ប្រជាពលរដ្ឋម្នាក់ៗ ត្រូវបានបង្កើនចំណូលជាង ១.០០០ រៀលប៉ុណ្ណោះដើម្បីឲ្យខ្លួនចាកចេញពីភាពក្រីក្របាន។ នៅឆ្នាំ ២០១១ ប្រជាពលរដ្ឋដែលស្ថិតក្នុងសត្តភាគទី ២០,៥ ដល់សត្តភាគទី ៥៣,២ លែងជាប្រជាពលរដ្ឋក្រីក្រទៀតហើយ ដោយសារពួកគាត់បានបង្កើនចំណាយលើការប្រើប្រាស់របស់ខ្លួន ១.២០២ រៀល លើបន្ទាត់ភាពក្រីក្រ។ (**ក្រាហ្វិក ១០**)

**គេសង្កេតឃើញថា ភាពងាយរងគ្រោះនៅកម្ពុជាបានកើនឡើងគួរឲ្យកត់សម្គាល់។** ដោយសារតែ ពលរដ្ឋមួយភាគធំមានជីវភាពនៅលើបន្ទាត់ភាពក្រីក្រ ដូចនេះប្រសិនបើការចំណាយលើការប្រើប្រាស់ពលរដ្ឋងាយរងគ្រោះធ្លាក់ចុះបន្តិចនោះ ពលរដ្ឋទាំងនោះនឹងធ្លាក់ចុះភាពក្រីក្រវិញ។ ឧទាហរណ៍៖ បើគេកាត់បន្ថយចំណូល ១,១៩២ រៀល សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃអត្រាភាពក្រីក្ររបស់កម្ពុជានឹងកើនឡើងទ្វេដង នៅឆ្នាំ ២០១១។ នេះមានន័យថា បម្រែបម្រួល(elasticity) នៃចំណាយធៀបទៅនឹងបន្ទាត់ភាពក្រីក្រនៅ ឆ្នាំ២០១១ មានប្រមាណ ៣,៥ ហើយបើប្រៀបធៀបទៅនឹង ឆ្នាំ២០០៤ កាលណោះមានតែ ១,១ ភាគរយប៉ុណ្ណោះ។

**គេរំពឹងថា ការវិវត្តប្រជាសាស្ត្រនៅកម្ពុជានឹងបន្តឥទ្ធិពលវិជ្ជមានលើសេដ្ឋកិច្ច ក៏ប៉ុន្តែ កត្តានេះក៏បង្កការគំរាមកំហែងដល់ប្រព័ន្ធគាំពារសង្គមតាមបែបប្រពៃណីផងដែរ។** អត្រាកំណើតទាបជួយកាត់បន្ថយចំនួនអ្នកនៅក្នុងបន្ទុកក្នុងបីទស្សវត្សរ៍ទៀត ដែលកត្តានេះនឹងជួយជំរុញ

**តារាង ៦៖** ការរួមចំណែករបស់កំណើនលើការប្រើប្រាស់ និងរបាយលើការប្រើប្រាស់ ចំពោះការកាត់បន្ថយភាពក្រីក្រ (គិតជា%, កម្ពុជា, ឆ្នាំ២០០៤-២០១១)

| | អំឡុងពេល | | | | |
|---|---|---|---|---|---|
| | ០៤-០៧ | ០៧-០៨ | ០៨-០៩ | ០៩-១០ | ១០-១១ |
| ការកាត់បន្ថយភាពក្រីក្រ | -៣,២% | -១១,៣% | -១៤,៨% | -១,៩% | -១,៥% |
| កំណើនលើការប្រើប្រាស់ | -៨,៨% | -៤,០% | -១៣,៧% | ១,៩% | ២,២% |
| របាយលើការប្រើប្រាស់ | ៤,៨% | -៦,៣% | -០,២% | -៣,២% | -៣,៩% |
| អន្តរសកម្មភាពរវាងកំណើន និងរបាយលើការប្រើប្រាស់ | -០,៩% | ០,៩% | ០,៩% | ០,៥% | -០,២% |

កំណើន=កំណើនចំណាយលើការប្រើប្រាស់ជាមធ្យមនៅឆ្នាំទីមួយធៀបទៅនិងកំណើននៃការប្រើប្រាស់នៅឆ្នាំទីពីរ
របាយ=របាយលើការប្រើប្រាស់នៅឆ្នាំទីមួយនិងរបាយលើការប្រើប្រាស់នៅឆ្នាំទីពីរ

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

ឲ្យមានកំណើនសេដ្ឋកិច្ច។ ក៏ប៉ុន្តែបើធៀបនឹង ១៥ ឆ្នាំមុន កំណើនពលរដ្ឋនឹងតិចជាងមុន។ បើទោះបីជាអត្រាកំណើតមានទាបក៏ដោយ ប្រសិនបើពលរដ្ឋកម្ពុជាមានអាយុកាន់តែវែងនោះ ចំនួនអ្នកនៅក្នុងបន្ទុកក្នុងគ្រួសារនីមួយៗនឹងកើនឡើង ហើយអាចបណ្តាលឲ្យប៉ះពាល់ដល់ប្រព័ន្ធគាំពារតាមបែបប្រពៃណីដែលមានកន្លងមក។ ដើម្បីដោះស្រាយបញ្ហានេះ គេត្រូវធ្វើយ៉ាងណាបង្កើនផលិតភាពរបស់ប្រជាពលរដ្ឋម្នាក់ៗ ដើម្បីឲ្យក្បាលម៉ាស៊ីនកំណើននៅតែដំណើការ។ ទន្ទឹមនឹងនេះដែរ គេត្រូវរៀបចំឲ្យមានការសន្សំប្រាក់សោធននិវត្តន៍សម្រាប់និយោជិតទាំងអស់។

**ក្នុងរយៈពេលវែង ការថែទាំកុមារកាន់តែមានភាពងាយស្រួលជាងមុន ចំណែកឯការថែទាំមនុស្សចាស់មានភាពលំបាកកាន់តែច្រើន។** ចំនួនមនុស្សនៅក្នុងបន្ទុកត្រូវបានគេប៉ាន់ស្មានថា នឹងធ្លាក់ចុះរហូតដល់ឆ្នាំ២០៣០ ដែលក្នុងនោះចំនួនមនុស្សវ័យចំណាស់នឹងមានចំនួនច្រើនជាងមនុស្សវ័យក្មេង (**ក្រាហ្វិកទី ១១**)។ នៅឆ្នាំ២០១០ មនុស្សពេញវ័យចំនួន ២ នាក់ ជួយទ្រទ្រង់កុមារតែម្នាក់ ប៉ុន្តែ បើនៅឆ្នាំ ២០៥៥ មនុស្សពេញវ័យជិត៤នាក់ជួយទ្រទ្រង់កុមារតែម្នាក់ប៉ុណ្ណោះ។ ចំពោះការទ្រទ្រង់មនុស្សវ័យចំណាស់វិញនៅឆ្នាំ២០១០ មនុស្សពេញវ័យ ១៧នាក់ទ្រទ្រង់មនុស្សវ័យចំណាស់ម្នាក់ ប៉ុន្តែ នៅឆ្នាំ ២០៥៥ មនុស្សពេញវ័យ ៤នាក់ទ្រទ្រង់មនុស្សចាស់ម្នាក់។

## ចរិតលក្ខណៈគ្រួសារប្រជាពលរដ្ឋក្រីក្រ

ជាទូទៅគេសង្កេតឃើញថា គ្រួសារប្រជាពលរដ្ឋក្រីក្ររស់នៅទីជនបទជាមធ្យមមានសមាជិក ៥,៧ នាក់ បានចំណាយប្រាក់ជិត ២ ភាគ ៣ លើម្ហូបអាហារ, មានដំបូលផ្ទះរឹងមាំ, មិនមានអគ្គិសនីប្រើប្រាស់ទេ, មានដីស្រែទំហំជិតមួយហិកតា, មានកង់, មានមេគ្រួសារជាបុរសអាយុលើសពី ៤៥ឆ្នាំ មានភរិយា និងមានមនុស្សពេញវ័យមានកម្រិតវប្បធម៌ជាមធ្យមត្រឹមថ្នាក់ទីបី។ ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រ មានម្នាក់ក្នុងចំណោម៥នាក់ស្ថិតក្នុងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ហើយ ៤១ ភាគរយ នៃគ្រួសារទាំងនោះបានទទួលប្រាក់ឧបត្ថម្ភពីសមាជិកគ្រួសារដែលប្រកបរបរ។

**ពីឆ្នាំ ២០០៤ ដល់ ឆ្នាំ ២០១១ គេសង្កេតឃើញថា ស្ថានភាពផ្ទះសម្បែង និងរបស់របរប្រើប្រាស់របស់ប្រជា-**

**ក្រាហ្វិក ១០៖** របាយនៃការចំណាយរបស់ក្រុមប្រជាពលរដ្ឋ កម្ពុជាឆ្នាំ២០០៤ ដល់ឆ្នាំ២០១១




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

**ពលរដ្ឋក្រីក្រមានភាពប្រសើរឡើង ប៉ុន្តែរយៈពេលនៃការសិក្សាអប់រំ, លទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់ និងទំហំគ្រួសារស្ទើរតែមិនមានការប្រែប្រួលទេ។** ការប្រើប្រាស់បង្គន់អនាម័យរបស់ប្រជាពលរដ្ឋក្រីក្របានកើនឡើងពី ៦,២ ភាគរយ ទៅ ១៣,២ ភាគរយ។ អត្រាប្រជាពលរដ្ឋដែលមានអគ្គិសនីប្រើប្រាស់បានកើនឡើងពី ៥,៤ភាគរយ ទៅ ៨,៥ ភាគរយ។ របស់របរប្រើប្រាស់ដូចជា ទូរស័ព្ទដៃបានកើនឡើងពី១,៤ ភាគរយ ទៅ ៣៩,១ ភាគរយ, ម៉ូតូបានកើនឡើងពី ១២,៩ ភាគរយ ទៅ ២៩,៧ ភាគរយ ហើយគ្រែបានកើនឡើងពី ១៧,៥ ភាគរយ ទៅ ២៦,១ ភាគរយ។ កម្រិតវប្បធម៌ប្រជាពលរដ្ឋក្រីក្រពេញវ័យធ្វើការប្រែប្រួលតិចតួចពី ៣,១ ឆ្នាំដល់ ៣,៣ឆ្នាំ, មានទឹកស្អាតប្រើប្រាស់ដោយប្រើទឹកអណ្តូងទាំងរដូវប្រាំង និងរដូវវស្សាកើនឡើងពី ៤២,៧ ភាគរយ ទៅ ៤៣,៥ ភាគរយ ហើយទំហំគ្រួសារមានសមាជិកពី ៥,៥៩ នាក់ ទៅ ៥,៦៧ នាក់។ (**តារាង ៧**)

**ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋមានជីវភាពមធ្យមមានស្ថានភាពស្រដៀងគ្នាផង និងស្ថានភាពខុសគ្នាផង។** គឺថា មេគ្រួសារនៃគ្រួសារក្រីក្រ និងគ្រួសារជីវភាពមធ្យមមានលក្ខណៈស្រដៀងគ្នា ពាក់ព័ន្ធនឹងអាយុ ភេទ និងស្ថានភាពអាពាហ៍ពិពាហ៍, មានទំហំដីកសិកម្មប្រហែលគ្នា, មានទឹកអណ្តូងប្រើប្រាស់ទាំងរដូវប្រាំង និងរដូវវស្សា, មានប្រាក់ឧបត្ថម្ភ និងមានកង់ប្រើប្រាស់។ អ្វីដែលខុសគ្នា

**ក្រាហ្វិក ១១៖ ផលធៀបអ្នកនៅក្នុងបន្ទុក នៅកម្ពុជា ឆ្នាំ១៩៩៥ ដល់ឆ្នាំ២០៥៥**







ផលធៀបអ្នកនៅក្នុងបន្ទុក = (ចំនួនកុមារសរុបបូកនិងចំនួនមនុស្សចាស់សរុប) / មនុស្សពេញវ័យធ្វើការ។ ប្រើជាមធ្យមភាគនៃបីឆ្នាំ។

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

រវាងគ្រួសារក្រីក្រ និងគ្រួសារមានជីវភាពមធ្យមមានដូចតទៅ៖ គ្រួសារមានជីវភាពមធ្យមមានសមាជិកគ្រួសារតិចជាងគ្រួសារក្រីក្រម្នាក់, ហើយមានអាយុពី ០-២០ឆ្នាំ, គ្រួសារប្រជាពលរដ្ឋដែលមានជីវភាពមធ្យមចំណាយប្រាក់លើម្ហូបអាហារ ៥៦,៥ ភាគរយ នៃប្រាក់ចំណាយសរុប, ចំណែកឯគ្រួសារក្រីក្រចំណាយលើថ្លៃម្ហូបអាហារ ៦៣,៨ភាគរយនៃចំណាយសរុប។ ៤២ភាគរយនៃគ្រួសារប្រជាពលរដ្ឋដែលមានជីវភាពមធ្យម មានបង្គន់អនាម័យប្រើប្រាស់ចំណែកឯគ្រួសារប្រជាពលរដ្ឋក្រីក្រមានជាង ១០ ភាគរយប៉ុណ្ណោះដែលមានបង្គន់អនាម័យប្រើប្រាស់។ ៣៧,៧ ភាគរយនៃគ្រួសារប្រជាពលរដ្ឋ ដែលមានជីវភាពមធ្យមមាន**អគ្គិសនី**ប្រើប្រាស់ ចំណែកឯគ្រួសារក្រីក្រមានអគ្គិសនីប្រើប្រាស់តែជាង ១០ ភាគរយប៉ុណ្ណោះ។ កម្រិតវប្បធម៌របស់សមាជិកក្នុងគ្រួសារ ដែលមានជីវភាពមធ្យម ខ្ពស់ជាងកម្រិតវប្បធម៌របស់សមាជិកក្នុងគ្រួសារក្រីក្រចំនួន ២ឆ្នាំ។ ក្នុងចំណោមប្រជាពលរដ្ឋមានជីវភាពមធ្យម ៦៣ភាគរយមានទូរស័ព្ទប្រើប្រាស់ហើយ ៥៦,៥ភាគរយ មានម៉ូតូប្រើប្រាស់។ ចំណូលដែលបានមកពីការឧបត្ថម្ភរបស់ប្រជាពលរដ្ឋមានជីវភាពមធ្យមមានចំនួនពីរដងលើសចំណូលពីការឧបត្ថម្ភរបស់ប្រជាពលរដ្ឋក្រីក្រ (**តារាងទី ៧**)។

ដើម្បីរកឲ្យឃើញថាស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋមានឥទ្ធិពលយ៉ាងណាទៅលើភាពក្រីក្រ គេបានគណនារីហ្គ្រេស៊ីន រវាងចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋម្នាក់ៗ និងសូចនាករមួយចំនួនរបស់គ្រួសារនីមួយៗ ដែលមានដូចជា ទំហំគ្រួសារ កម្រិតអប់រំរបស់មេគ្រួសារ ទំហំដីធ្លីមានកម្មសិទ្ធ ដំណាំស្រូវអង្ករ ចំនួនម៉ោងធ្វើការ និងរបស់របរប្រើប្រាស់ក្នុងផ្ទះ។ ដោយសារគេប្រើអញ្ញត្តិទាំងអស់ក្នុងពេលដំណាលគ្នា គេអាចដឹងថា សូចនាករទាំងអស់មានឥទ្ធិពលយ៉ាងណាទៅលើភាពក្រីក្រ ហើយសូចនាករណាមួយមានឥទ្ធិពលខ្លាំងឬតិចជាងគេ។ ប៉ុន្តែការគណនារីហ្គ្រេសិននេះមិនអាចពន្យល់អំពីឥទ្ធិពលកំណើនសេដ្ឋកិច្ចទៅលើភាពក្រីក្របានទេ ព្រោះសូចនាករដែលគេប្រើសុទ្ធតែជាសូចនាករបង្ហាញពីស្ថានភាពរស់នៅរបស់គ្រួសារប្រជាពលរដ្ឋនីមួយៗ។ ម្យ៉ាងទៀតដោយសារតែសូចនាករនីមួយៗ មានទំនាក់ទំនងទៅនឹងការប្រែប្រួលភាពក្រីក្រកម្រិតគ្រួសារ លទ្ធផលដែលបានមកពីការគណនារីហ្គ្រេសិននេះ គ្រាន់តែបង្ហាញឲ្យឃើញពីទំនាក់ទំនងរវាងសូចនាករ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប៉ុណ្ណោះ ប៉ុន្តែវាមិនអាចបង្ហាញឲ្យឃើញថា កត្តាណាមួយជាមូលហេតុចម្បង ធ្វើឲ្យចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋកើនឡើងទេ ហើយគេក៏មិនអាចដឹងបានថា តើកំណើនចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋជាមូលហេតុនាំឲ្យសូចនាករណាមួយកើនឡើងដែរ។ ឧទាហរណ៍៖ មានដីធ្លីច្រើនអាចបង្កើនចំណូលរបស់ប្រជាពលរដ្ឋ ក៏ប៉ុន្តែបើប្រជាពលរដ្ឋនោះមានចំណូលច្រើន គាត់ក៏អាចបង្កើនផ្ទៃដីរបស់គាត់ដែរ។

**កត្តាសំខាន់បំផុតដែលកំណត់ភាពក្រីក្រនៅកម្ពុជាគឺកត្តាភូមិសាស្ត្រ។** លទ្ធភាពចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋរស់នៅទីជនបទទាបជាងលទ្ធភាពចំណាយរបស់ប្រជាពលរដ្ឋដែលរស់នៅតំបន់ដទៃៗទៀត ហើយប្រជាពលរដ្ឋដែលរស់នៅតំបន់ខ្ពង់រាប និងតំបន់ភ្នំមានអត្រាភាពក្រីក្រខ្ពស់ជាងប្រជាពលរដ្ឋដែលរស់នៅតំបន់ដទៃៗទៀត។

**ក្រុមគ្រួសារដែលមានមេគ្រួសារជាស្ត្រីមិនមែនមានន័យថាសុទ្ធតែជាប្រជាពលរដ្ឋក្រីក្រនោះទេ។** ការប៉ាន់ស្មានពីចំណាយលើការប្រើប្រាស់បានបង្ហាញថា ក្រុមគ្រួសារដែលមានមេគ្រួសារជាស្ត្រីបានចំណាយប្រហាក់ប្រហែលនឹងក្រុមគ្រួសារដែលមានមេគ្រួសារជាបុរស (គេសង្កេតឃើញលទ្ធផលនេះមាននៅគ្រប់ឆ្នាំទាំងអស់មានដូចជាឆ្នាំ២០០៤ ២០០៩ និង ២០១១)។ ក៏ប៉ុន្តែ ក្រុមគ្រួសារដែលមានមេគ្រួសារមិនមែនជាជនជាតិខ្មែរអាចមានអត្រាភាពក្រីក្រខ្ពស់។ ចំពោះក្រុមគ្រួសារដែលមានមេគ្រួសារអាចនិយាយបានច្រើនភាសាឬក៏មេគ្រួសារមានអាយុច្រើន គ្រួសារនោះមិនមែនជាគ្រួសារក្រីក្រទេ។

**កាលណាទំហំគ្រួសារកាន់តែធំ គេសង្កេតឃើញថាការចំណាយការប្រើប្រាស់ក្នុងមនុស្សម្នាក់ៗ មានការថយចុះលើកលែងតែគ្រួសារមានសមាជិកវ័យចំណាស់ភាគច្រើនតែប៉ុណ្ណោះ។** ប្រសិនបើគ្រួសារមួយមានសមាជិកអាយុ ៦ឆ្នាំ ឬក្មេងជាងនេះកើនឡើងម្នាក់ក្នុងបន្ទុកគ្រួសារនោះនឹងមានការចំណាយលើការប្រើប្រាស់ក្នុងមនុស្សម្នាក់ៗ

**តារាង ៧៖** សូចនាកររបស់គ្រួសារក្រីក្រ និងមធ្យម នៅកម្ពុជាឆ្នាំ ២០០៤ និងឆ្នាំ ២០១១

| សូចនាករ | គ្រួសារក្រីក្រ | | គ្រួសារមានជីវភាពមធ្យម | |
|---|---|---|---|---|
| | ២០០៤ | ២០១១ | ២០០៤ | ២០១១ |
| គ្រួសារនៅទីជនបទ | ៨៩,៨% | ៩២,២% | ៨១,៤% | ៧៩,៣% |
| ទំហំគ្រួសារ | ៥,៥៩ | ៥,៦៧ | ៤,៩៨ | ៤,៥៣ |
| # ០-៦ ឆ្នាំ | ០,៩៣ | ១,០៥ | ០,៧០ | ០,៦៣ |
| # ៧-២០ ឆ្នាំ | ២,១៩ | ១,៩៨ | ១,៨២ | ១,៣៦ |
| # ២១-៥៩ ឆ្នាំ | ២,១៩ | ២,៣១ | ២,១៥ | ២,១៩ |
| # ៦០ ឆ្នាំ | ០,២៨ | ០,៣៣ | ០,៣១ | ០,៣៥ |
| អាយុរបស់មេគ្រួសារ | ៤៣,៧ | ៤៥,៥ | ៤៤,៩ | ៤៦,៦ |
| មេគ្រួសារជាស្ត្រី | ២០,១% | ២២,០% | ២១,៦% | ២២,៧% |
| មេគ្រួសារមានប្តីឬប្រពន្ធ | ៨០,៩% | ៧៨,៨% | ៧៩,៤% | ៧៧,៩% |
| ចំណាយលើម្ហូបអាហារ/ចំណាយសរុប | ៦៣,៣% | ៦៣,៨% | ៥៩,៥% | ៥៦,១% |
| ចំណាយថ្លៃផ្ទះ,ទឹក,ភ្លើង/ចំណាយសរុប | ២១,១% | ១៦,៦% | ១៩,៥% | ១៨,៧% |
| ចំណាយការធ្វើដំណើរនិងទំនាក់ទំនង/ចំណាយសរុប | ១,៣% | ៤,០% | ៣,០% | ៦,៤% |
| ដំបូលផ្ទះរឹងមាំ,ក្បឿង,ហ្វីប្រូ,ស័ង្កសី | ៥៩,១% | ៧៣,១% | ៧១,០% | ៨៨,៥% |
| ទឹកស្អាតប្រើប្រាស់ទាំងរដូវប្រាំងនិងរដូវវស្សា | ៤២,៧% | ៤៣,៥% | ៤៦,៩% | ៤៥,៩% |
| បង្គន់អនាម័យ | ៦,២% | ១៣,២% | ២០,៨% | ៤២,១% |
| អគ្គិសនី | ៥,៤% | ៨,៥% | ១៩,៧% | ៣៧,៤% |
| កម្រិតការសិក្សាជាមធ្យមរបស់សមាជិកគ្រួសារអាយុពី២០-៦០ឆ្នាំ | ៣,១ | ៣,៣ | ៣,៩ | ៥,១ |
| ទំហំដីស្រែចម្ការះគិតជាហិកតា | ១,០៤ | ,៩៦ | ,៩៨ | ,៩៧ |
| ចំនួនគ្រួសារដែលធ្វើស្រែ | ៧៥% | ៦៩% | ៦៥% | ៥៩% |
| ការទទួលបានប្រាក់ឧបត្ថម្ភ | | ៤០,៦% | | ៤៣,៤% |
| ប្រាក់ឧបត្ថម្ភជាមធ្យមសម្រាប់គ្រួសារម្នាក់ៗ | | ១១៨ | | ៣២១ |
| ទូទឹកកក | ០,០% | ០,០% | ១,៩% | ៤,៧% |
| ទូសម្លៀកបំពាក់ | ៥,៣% | ១៤,២% | ១៨,២% | ៤៤,១% |
| ទូរស័ព្ទ | ១,៤% | ៣៩,១% | ១២,៧% | ៦៣,០% |
| គ្រែពូក | ១៧,៥% | ២៦,១% | ៣០,៤% | ៤៤,៣% |
| ម៉ូតូ | ១២,៩% | ២៩,៧% | ២៨,៦% | ៥៦,៥% |
| កង់ | ៦៤,១% | ៦៧,៤% | ៦៤,០% | ៦៨,០% |

* តម្លៃនេះត្រូវបានគណនាជាមធ្យមនៃគ្រួសារនីមួយៗ

**សម្គាល់៖** មធ្យមភាគគិតជាមធ្យមភាគនៃចំនួនគ្រួសារ មិនមែនគិតជាមធ្យមភាគនៃចំនួនប្រជាពលរដ្ឋម្នាក់ៗទេ។

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

ទាបច្រើន បើធៀបទៅនឹងគ្រួសារដែលមានសមាជិកវ័យជំទង់ និងមិនមានមនុស្សចាស់នៅក្នុងបន្ទុក។

**ចំពោះគ្រួសារ ដែលមានសមាជិករបស់ខ្លួនប្រកបមុខរបរច្រើន គ្រួសារនោះនឹងមានចំណាយក្នុងមនុស្សម្នាក់ៗកាន់តែខ្ពស់។** សម្រាប់គ្រួសារណាក៏ដោយ បើមធ្យមភាគនៃកម្រិតការអប់រំកាន់តែខ្ពស់ គេសង្កេតឃើញថា មធ្យមភាគនៃការចំណាយលើការប្រើប្រាស់ក្នុងមនុស្សម្នាក់ៗក៏កាន់តែខ្ពស់ដែរ។

**គ្រួសារដែលមានដីកសិកម្មតូចក៏អាចកាត់បន្ថយភាពក្រីក្របានដែរ។** កាលពីឆ្នាំ២០០៤ គេសង្កេតឃើញថា លុះត្រាតែគ្រួសារនោះមានទំហំដីចាប់ពី ២ ហិកតា ទើបគេឃើញគ្រួសារនោះ មានលទ្ធភាពចំណាយ លើការប្រើប្រាស់ខ្ពស់។ ប៉ុន្តែនៅឆ្នាំ២០១១ គ្រួសារដែលមានដីត្រឹមតែកន្លះហិកតា ក៏អាចមានលទ្ធភាពចំណាយ លើការប្រើប្រាស់ខ្ពស់ដែរ នេះដោយសារតែតម្លៃស្រូវអង្ករបានកើនឡើងខ្លាំង។ ចំពោះគ្រួសារណាដែលមានម៉ូតូ និងមានរបស់របរប្រើប្រាស់សំខាន់ៗដទៃទៀតទំនងជាគ្រួសារមិនមែនក្រីក្រទេ។

**គ្រួសារដែលមេគ្រួសារមានមុខរបរជាកសិករចំណាយលើការប្រើប្រាស់តិចជាងគ្រួសារ ដែលមានមេគ្រួសារមានមុខរបរផ្សេងៗទៀត។** ដីកសិកម្មកាន់តែធំនឹងជួយឲ្យប្រជាពលរដ្ឋមានលទ្ធភាពចំណាយកាន់តែធំ។ ក៏ប៉ុន្តែ ការវិភាគនេះមិនបានរកឃើញកម្រិតចំណាយខុសរវាងគ្រួសារដែលប្រកបមុខរបរធ្វើស្រែ និងគ្រួសារដែលប្រកបមុខរបរដាំដំណាំផ្សេងៗទេ។ (**តារាង ៨**)

**តារាង ៨៖** សូចនាករសំខាន់ៗពាក់ព័ន្ធនឹងភាពក្រីក្រនៅកម្ពុជាឆ្នាំ២០០៤, ២០០៩ និង ២០១១

| | | ២០០៤ | ២០០៩ | ២០១១ |
|---|---|---|---|---|
| អញ្ញត្តិ | | ៨,៨ ** | ៨,៩ ** | ៩.២ ** |
| ភូមិសាស្ត្រ (លើកលែងភ្នំពេញ) | តំបន់ជនបទនៅខ្ពង់រាប/ភ្នំ | -0,៣៣ ** | -0,២៦ ** | -0.៣៤ ** |
| | តំបន់ជនបទមិនមែននៅខ្ពង់រាប/ភ្នំ | -0,១៧ ** | -0,២១ ** | -0.៣0 ** |
| | តំបន់ទីប្រជុំជនផ្សេងៗទៀតនៅខ្ពង់រាប/ភ្នំ | -0,២0 ** | -0,១៦ * | -0.២៩ ** |
| | តំបន់ទីប្រជុំជនផ្សេងៗមិនមែននៅខ្ពង់រាប/ភ្នំ | -0,0៧ * | -0,0៤ ns | -0.១៩ ** |
| មេគ្រួសារ | មេគ្រួសារជាស្ត្រី | -0,0២ ns | 0,0៣ ns | 0.0២ ns |
| | មេគ្រួសារមិនមែនជាជនជាតិខ្មែរ | -0,0៥ * | 0,0៥ ns | -0.១៤ ** |
| | មេគ្រួសារនិយាយបានច្រើនជាងមួយភាសារ | 0,១៦ ** | 0,១៦ ** | 0.១0 * |
| | មេគ្រួសារមានប្តីឬប្រពន្ធ | 0,0៦ ** | 0,0៧ ** | 0.0៣ ns |
| | អាយុមេគ្រួសារ | 0,0១ ** | 0,0១ ** | 0.0១ ** |
| | មេគ្រួសារទ្វេរគុណ (គុណ ១00) | -0,0១ ** | -0,0១ ** | -0.0១ ** |
| ទំហំគ្រួសារ (ចំនួនសមាជិក) | 0 ដល់ ៦ ឆ្នាំ | -0,១៧ ** | -0,១៤ ** | -0.១៧ ** |
| | ៧ ដល់ ២0 ឆ្នាំ | -0,១0 ** | -0,១0 ** | -0.១១ ** |
| | ២១ ដល់ ៥៩ ឆ្នាំ | -0,0៦ ** | -0,0៧ ** | -0.0៨ ** |
| | ៦0 ឆ្នាំ និងចាស់ជាងនេះ | -0,0៤ ** | -0,0៦ ** | -0.0៧ ** |
| កម្រិតអប់រំគិតជាមធ្យមរបស់សមាជិកគ្រួសារអាយុ ២0-៦0 ឆ្នាំ | | 0.0៥ ** | 0,0៥ ** | 0,0៥ ** |
| ធ្វើស្រែចម្ការ | | -0.១៤ ** | -0,១៤ ** | -0,១៣ ** |
| ទំហំដីកសិកម្មគិតជាហិកតា | > ៥0 ម២ ដល់ 0,៥ ហ.ត | -0,00២ ns | 0,0១ ns | 0.0៤ ns |
| | > 0,៥ ហ.ត ដល់ ១ ហ.ត | -0,0១ ns | 0,0៤ * | 0.0៧ ** |
| | > ១ ហ.ត ដល់ ២ ហ.ត | 0,0២ ns | 0,0៤ ns | 0.0៩ ** |
| | > ២ ហ.ត ដល់ ៤ ហ.ត | 0,0៦ ** | 0,0៦ ** | 0.១២ ** |
| | > ៤ ហ.ត | 0,២0 ** | 0,១៨ ** | 0.២២ ** |
| ចំនួនម៉ោងធ្វើការដោយបានទទួលប្រាក់កម្រៃ | | 0.00៣ ** | 0,00២ ** | 0,00១ ns |
| មានម៉ូតូ ឬក៏អត់កាលពីឆ្នាំមុន | | 0.២៩ ** | 0,១៨ ** | 0,១៩ ** |
| R២ | | 0,៤៦ | 0,៤0 | 0,៥0៧ |

** ជឿជាក់(significant)នៅកម្រិត p ≤ 0,0៥;  * ជឿជាក់(significant)នៅកម្រិត p ≤ 0,១៥

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

# ប្រភពចំណូលផ្សេងៗរបស់ប្រជាពលរដ្ឋ | ជំពូក ២

ជំពូកមុនបង្ហាញថា ចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋមានការកើនឡើងយ៉ាងខ្លាំង វិសមភាពត្រូវបានកាត់បន្ថយ ហើយអត្រាភាពក្រីក្របានធ្លាក់ចុះយ៉ាងលឿន។ គេនឹងមានចម្ងល់ថា តើមានកត្តាអ្វីខ្លះ ដែលបានជំរុញឲ្យភាពក្រីក្របានធូរស្រាលច្រើនយ៉ាងនេះ? ក្នុងជំពូកនេះ យើងមានគោលបំណងកំណត់ប្រភពចំណូលសំខាន់ៗរបស់ពលរដ្ឋ និង បង្ហាញឲ្យឃើញថា កត្តាអ្វីខ្លះបានចូលរួមលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ។ ជំពូកនេះនឹងពិនិត្យមើលអំពីការវិវត្តទីផ្សារការងារនៅតាមទីប្រជុំជន (ដែលរួមមាន វិស័យសេដ្ឋកិច្ចសំខាន់ៗ ដែលប្រជាពលរដ្ឋបានប្រកបការងារ ភាពខុសគ្នារវាងកម្លាំងការងារជាបុរស និងកម្លាំងការងារជាស្ត្រី ប្រាក់បៀវត្សរ៍ធៀបនឹងកម្រិតអប់រំរបស់និយោជិតជាដើម)។ ជំពូកនេះនឹងវិភាគបញ្ហានានា ដែលអាចជំរុញឲ្យភាពក្រីក្របានធូរស្រាលច្រើនបន្ថែមទៀត។ ទីពីរ ជំពូកនេះនឹងបង្ហាញអំពីការវិវត្តន៍របស់ទីជនបទនានា ដោយចាប់ផ្តើមពិនិត្យមើលអំពីការប្រែប្រួលនៃការចំណាយលើការប្រើប្រាស់របស់ប្រជាពលរដ្ឋ និងការប្រែប្រួលនៃប្រភពចំណូលរបស់ពួកគេ (ដែលក្នុងនោះរួមមាន ចំណូលពីកសិផល ចំណូលពីការលក់កម្លាំងពលកម្ម និង ចំណូលពីការប្រកបរបរជំនួញជាដើម។ បន្ទាប់មកយើងនឹងបង្ហាញអំពីបញ្ហាសំខាន់ៗដែលត្រូវដោះស្រាយបន្តទៀត។ នៅចុងបញ្ចប់នៃជំពូកនេះ យើងនឹងប្រើប្រាស់ព័ត៌មានអំពីប្រភពចំណូលផ្សេងៗរបស់ប្រជាពលរដ្ឋពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១១ ដើម្បីកំណត់ឲ្យឃើញថាកត្តាណាខ្លះជាកត្តានាំមុខជំរុញឲ្យប្រជាពលរដ្ឋកម្ពុជាមានជីវភាពធូរធារ។ ការវិភាគនេះបានប្រើទិន្នន័យពីការសង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា និងទិន្នន័យផ្សេងទៀតពីរាជរដ្ឋាភិបាលកម្ពុជា។ គោលបំណងសំខាន់នៃការវិភាគនេះធ្វើយ៉ាងណារកឲ្យឃើញពីកត្តានាំមុខនានា ដែលធ្វើឲ្យភាពក្រីក្រនៅកម្ពុជាធ្លាក់ចុះយ៉ាងលឿន។

## ការវិវត្តការងារនៅតាមទីប្រជុំជន

### ទំនោរទីផ្សារការងារនិងតួនាទីរបស់វាក្នុងការកាត់បន្ថយភាពក្រីក្រ

**ទោះបីជាបម្រែបម្រួលនៃអត្រាភាពក្រីក្រកើតមានទាំងនៅតាមទីជនបទ និង នៅតាមទីប្រជុំជនក៏ដោយ គេសង្កេតឃើញថាបម្រែបម្រួលនេះ បានកើតឡើងក្នុងពេលវេលាខុសៗគ្នា។** ការគណនាបានបង្ហាញថា អត្រាភាពក្រីក្របានធ្លាក់ចុះពី ៥៣,៣ ភាគរយ នៅឆ្នាំ២០០៤ មកត្រឹម ២០,៥ ភាគរយ នៅឆ្នាំ២០១១ ហើយក្នុងនោះការ

កាត់បន្ថយភាពក្រីក្រភាគច្រើនកើតមាននៅតាមទីជនបទ ពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០០៩ (ប្រហែល ៨៦ភាគរយនៃការកាត់បន្ថយភាពក្រីក្រសរុប)។ ចំណែកឯការកាត់បន្ថយភាពក្រីក្រនៅទីក្រុងភ្នំពេញវិញ កើតឡើងមុនអំឡុងពេលនេះពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧ (ប្រហែល ៩២ភាគរយនៃការកាត់បន្ថយភាពក្រីក្រសរុបក្នុងអំឡុងពេលនោះ)។ ចំណែកឯនៅតាមទីប្រជុំជនផ្សេងៗទៀត ក្រៅពីទីក្រុងភ្នំពេញ គេសង្កេតឃើញថា ការកាត់បន្ថយភាពក្រីក្រមានលក្ខណៈស្រដៀងទីក្រុងភ្នំពេញផង និងស្រដៀងទៅនឹងទីជនបទផង ប៉ុន្តែមានលក្ខណៈស្រដៀងនឹងទីជនបទជាង (**ក្រាហ្វិក ១២ និងតារាង ៩**)។

**តាមទីប្រជុំជននានានៅកម្ពុជា ចំនួនប្រជាពលរដ្ឋដែលធ្វើការមានប្រាក់បៀវត្សរ៍មានប្រមាណមួយភាគបីនៃកម្លាំងពលកម្មសរុបរបស់ប្រទេសទាំងមូល។** តាមបណ្តាប្រទេសនានា ឱកាសការងារជាកត្តាសំខាន់បំផុត ដែលជួយឲ្យប្រជាពលរដ្ឋអាចចាកចេញពីភាពក្រីក្របាន ពីព្រោះអ្វីដែលប្រជាពលរដ្ឋក្រីក្រមានសំខាន់បំផុតនោះគឺ កម្លាំងពលកម្ម និងដីធ្លី។ នៅកម្ពុជាគេក៏សង្កេតឃើញកត្តាទាំងនេះជាកត្តាសំខាន់ដែរ។ ចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ២០១១ ទីផ្សារការងារនៅកម្ពុជាមានបម្រែបម្រួលយ៉ាងខ្លាំង។ ចំនួនអ្នកធ្វើការទទួលប្រាក់បៀវត្សរ៍ជាប្រចាំដែលជាប្រភពផ្តល់ស្ថិរភាពប្រាក់ចំណូលដល់ក្រុមគ្រួសារ បើធៀបទៅនឹងប្រភេទមុខរបរដទៃៗទៀតបានកើនឡើងពី ២០,៦ ភាគរយនៅឆ្នាំ ២០០៤ ដល់ ៣០,៣ ភាគរយ នៅឆ្នាំ២០១១។ ចំណែកឯនៅតាមទីប្រជុំជនផ្សេងៗទៀត ចំនួនអ្នកធ្វើការទទួលប្រាក់បៀវត្សរ៍ទៀងទាត់ មានប្រមាណ ៥០,៥ ភាគរយ នៅឆ្នាំ ២០១១។

**ភាពខុសគ្នានៃអំឡុងពេលនៃការកាត់បន្ថយភាពក្រីក្រឆ្លុះបញ្ចាំងឲ្យឃើញថា ទីជនបទរបស់កម្ពុជាខុសពីទីប្រជុំជន។** ចំនួនអ្នកធ្វើការមានប្រាក់បៀវត្សរ៍ទៀងទាត់ភាគច្រើនមានតែនៅតាមទីប្រជុំជនប៉ុណ្ណោះ ចំណែកឯនៅតាមទីជនបទវិញ កម្មករភាគច្រើនធ្វើការ ដោយមិនទទួលបានប្រាក់បៀវត្សរ៍ទេ ការងារដែលពួកគេធ្វើភាគច្រើនគឺការជួយដល់ក្រុមគ្រួសារ ឬក៏ប្រកបមុខរបរដោយខ្លួនឯង។ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨ ចំនួនកម្មករដែលមានប្រាក់បៀវត្សរ៍ទៀងទាត់នៅតាមទីប្រជុំជនបានកើនឡើង ៩,៨ ភាគរយ ប៉ុន្តែនៅតាមទីជនបទវិញ ចំនួនកម្មករដែលមានប្រាក់បៀវត្សរ៍ទៀងទាត់ស្ទើរតែមិនមានភាពប្រែប្រួលទេ កើនឡើងតែ ០,៩ ភាគរយ ប៉ុណ្ណោះ។ សម្រាប់ឆ្នាំ ២០០៨ ដល់ឆ្នាំ ២០១១ វិញ ចំនួនកម្មករដែលមានប្រាក់បៀវត្សរ៍ទៀងទាត់នៅតាមទីប្រជុំជនកើនឡើងមិនច្រើនទេ (កើនឡើង ៤,១ ភាគរយ)។ ចំណែកឯកម្មករដែលប្រកបមុខរបរដោយខ្លួនឯង ស្ទើរតែមិនមានការប្រែប្រួល ពីឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០១១ (កើនតែ ០,៣ ភាគរយ

**ក្រាហ្វិក ១២៖** អត្រាភាពក្រីក្រតាមតំបន់ (ឆ្នាំ ២០០៤=១០០%), កម្ពុជាពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១១




**តារាង ៩៖** បម្រែបម្រួលអត្រាភាពក្រីក្រ

បម្រែបម្រួលអត្រាភាពក្រីក្រ = ១០០%

| អំឡុងពេល | ភ្នំពេញ | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| អត្រាកាត់បន្ថយភាពក្រីក្រ | ១៤,៣% | ២៣,៦% | ៣៥,៣% |
| ២០០៤-២០១១ | ១០០% | ១០០% | ១០០% |
| ២០០៤-២០០៧ | ៩២% | ២០% | ៣% |
| ២០០៧-២០០៩ | -១១% | ៩៥% | ៨៦% |
| ២០០៩-២០១១ | ១៩% | -១៥% | ១១% |

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

ប៉ុណ្ណោះ) ប៉ុន្តែនៅតាមទីជនបទវិញ ចំនួនកម្មករដែលប្រកបមុខរបរដោយខ្លួនឯងបានកើនឡើង ៧,៤ ភាគរយក្នុងអំឡុងពេលដូចគ្នានេះ។ នេះសបញ្ជាក់ឲ្យឃើញថា ការប្រកបមុខរបរដោយខ្លួនឯងនៅតាមទីជនបទបានធ្វើឲ្យចំណូលរបស់ពួកគេមានការប្រែប្រួលយ៉ាងខ្លាំង។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក្នុងរយៈពេល៧ឆ្នាំនេះ ពីឆ្នាំ២០០៤ ដល់ឆ្នាំ ២០១១ គេសង្កេតឃើញថា ចំនួនកម្មករដែលប្រកបមុខរបរដោយខ្លួនឯងបានថយចុះយ៉ាងច្រើន (**ក្រាហ្វិក ១៣**)។

**កត្តាមួយក្នុងចំណោមកត្តាសំខាន់ៗដែលជំរុញឲ្យមានការកាត់បន្ថយភាពក្រីក្រយ៉ាងលឿនគឺការកើនឡើងចំនួនកម្មករដែលមានប្រាក់បៀវត្សរ៍ប្រចាំខែ។** កត្តានេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការចំណាយរបស់គ្រួសារ នីមួយៗតាមប្រភេទមុខរបររបស់មេគ្រួសារ។ ក្នុងរបាយការណ៍នេះ យើងបានគណនាចំណាយលើការប្រើប្រាស់ជាមធ្យមរបស់ប្រជាពលរដ្ឋម្នាក់ៗ ទៅតាមមុខរបររបស់មេគ្រួសារ។ ផលធៀបនៃការចំណាយរបស់ប្រជាពលរដ្ឋម្នាក់ៗក្នុងគ្រួសារ ដែលមានមេគ្រួសារប្រកបមុខរបរមានប្រាក់បៀវត្សរ៍ទៀងទាត់ ធៀបទៅនឹងគ្រួសារដែលមានមេគ្រួសារប្រកបមុខរបរដោយខ្លួនឯងត្រូវបានគណនា ដើម្បីវាស់វែងអំពីកម្រិតខុសគ្នានៃការចំណាយរបស់ពួកគេ (**ក្រាហ្វិក ១៤**)។

ការគណនានៃការចំណាយនេះ ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ បានបង្ហាញថា ការចំណាយរបស់សមាជិកម្នាក់ៗក្នុងក្រុមគ្រួសារ ដែលមានមេគ្រួសារដែលប្រកបមុខរបរមានប្រាក់បៀវត្សរ៍ទៀងទាត់មានកម្រិតខ្ពស់ជាងការចំណាយរបស់សមាជិកគ្រួសារដែលមានមេគ្រួសារប្រកបមុខរបរដោយខ្លួនឯង។ ជាឧទាហរណ៍នៅ ឆ្នាំ២០០៤ ជាមធ្យមសមាជិកក្នុងគ្រួសារដែលមានមេគ្រួសារប្រកបមុខរបរមានប្រាក់បៀវត្សរ៍ទៀងទាត់បានចំណាយលើសសមាជិកគ្រួសារដែលមានមេគ្រួសារប្រកបមុខរបរដោយខ្លួនឯង

**ក្រាហ្វិក ១៤៖** ចំណាយលើការប្រើប្រាស់របស់កម្មករដែលទទួលបានប្រាក់បៀវត្សរ៍ទៀងទាត់ កម្ពុជា ឆ្នាំ២០០៤-២០១១




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

**ក្រាហ្វិក ១៣៖** ប្រភេទមុខរបរនីមួយៗនៅតាមទីប្រជុំជននិងជនបទ




**សម្គាល់៖** ប្តីឬប្រពន្ធដែលបានចាត់ថ្នាក់ជាកម្មករធ្វើការដោយមិនមានប្រាក់កម្រៃត្រូវបានចាត់ថ្នាក់ឡើងវិញថាជាកម្មករដែលប្រកបមុខរបរដោយខ្លួនឯង។ កម្មករដែលជានិយោជកមានតិចជាងពីរភាគរយនៃកម្លាំងពលកម្មសរុបហើយត្រូវបានចាត់ថ្នាក់ជាកម្មករដែលទទួលបានប្រាក់បៀវត្សរ៍ទៀងទាត់។ កម្មករផ្សេងៗទៀតដែលមានចំណែកតិចជាង ០,៥ ភាគរយ នៃកម្លាំងពលកម្មសរុបត្រូវបានចាត់ថ្នាក់ជាកម្មករធ្វើការឲ្យគ្រួសារហើយមិនទទួលបានប្រាក់បៀវត្សរ៍។

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

ប្រមាណ ១៦ ភាគរយ។ ហើយក្នុងរយៈពេល៧ឆ្នាំ កម្រិតខុសគ្នានេះកើនឡើងរហូតទៅដល់ ១០ ភាគរយ (លើកលែងតែក្នុងឆ្នាំ ២០១០ មួយចេញ ដែលវាបានធ្លាក់មកត្រឹម ៤ភាគរយ)។ នៅឆ្នាំ២០១១ ជាមធ្យមចំណាយរបស់សមាជិកក្នុងក្រុមគ្រួសារដែលមានមេគ្រួសារមានប្រាក់បៀវត្សរ៍ មានកម្រិតលើសសមាជិកដែលមានមេគ្រួសារប្រកបមុខរបរដោយខ្លួនឯង ចំនួន ១០ ភាគរយ។

មុននឹងយើងពិនិត្យមើលទីផ្សារការងារ និងការផ្គត់ផ្គង់កម្លាំងពលកម្ម យើងសង្កេតឃើញថាកម្ពុជាកំពុងប្រឈមនឹងបញ្ហាសំខាន់មួយ គឺការបង្កើតការងារឲ្យប្រជាពលរដ្ឋគ្រប់អាយុចូលធ្វើការនាពេលអនាគត។កម្ពុជាសម្បូរប្រជាពលរដ្ឋគ្រប់អាយុចូលធ្វើការណាស់ បើគិតត្រឹមឆ្នាំ២០១០ មានប្រជាពលរដ្ឋកម្ពុជាពីរភាគបីកើតក្រោយឆ្នាំ១៩៩៣។

## សមាសភាពនៃការងារ៖ តួនាទីយេនឌ័រ ការសិក្សាអប់រំ និងការងារប្រសើរជាងមុន

**ស្ត្រី និងក្មេងៗវ័យជំទង់ចូលរួមក្នុងទីផ្សារពលកម្មផ្លូវការមានកម្រិតទាប ប៉ុន្តែកម្លាំងពលកម្មកម្ពុជាមានកម្រិតសិក្សាអប់រំខ្ពស់ជាងមុន។** ផលធៀបកម្លាំងការងារទៅនឹងប្រជាពលរដ្ឋសរុបត្រូវបានគណនា ដោយបែងចែកទៅតាមយេនឌ័រ តាមអាយុ និងតាមកម្រិតនៃការសិក្សាអប់រំ (**តារាង ១០**)។ ផលធៀបកម្លាំងពលកម្មទៅនឹងប្រជាពលរដ្ឋសរុបជាសូចនាករ ដែលត្រូវបានគេយកមកប្រើជាទូទៅនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីវាស់វែងអំពីស្ថានភាពទីផ្សារពលកម្ម ពីព្រោះសូចនាករនេះមានភាពប្រសើរជាងសូចនាករនៃភាពអត់ការងារធ្វើ ដែលជាទូទៅគេសង្កេតឃើញថា មានកម្រិតទាប ហើយវាមិនឆ្លុះបញ្ចាំងពីទីផ្សារពលកម្មពិតនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នោះទេ។ បើគិតតាមអាយុប្រជាពលរដ្ឋកម្ពុជា ដែលមានអាយុពី ២៥ ឆ្នាំ ទៅ ៤៤ ឆ្នាំ បានចូលរួមក្នុងទីផ្សារពលកម្មខ្ពស់ជាងប្រជាពលរដ្ឋអាយុដទៃៗទៀត។ បើគិតតាមភេទ បុរសដែលមានអាយុពី ២៥ ឆ្នាំដល់ ៤៤ ឆ្នាំ បានចូលរួមក្នុងទីផ្សារការងារច្រើនជាងស្ត្រី។ ចំពោះកម្រិតនៃការសិក្សាអប់រំវិញ គឺភាគច្រើន អ្នកដែលចូលទីផ្សារពលកម្ម មានកម្រិតសិក្សាទាបពេក ឬក៏មានកម្រិតសិក្សាខ្ពស់ពេក។ អ្វីដែលគេព្រួយបារម្ភជាងគេក្នុងទីផ្សារកម្ពុជាសព្វថ្ងៃ គឺចំនួនការងារមិនគ្រប់គ្រាន់ ដូចនេះរដ្ឋាភិបាលត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនថែមទៀត ដើម្បីបង្កើតការងារឲ្យប្រជាពលរដ្ឋឲ្យបានច្រើន។

**បើទោះបីជាបុរសនៅកម្ពុជាបានចូលក្នុងទីផ្សារពលកម្មច្រើនជាងស្ត្រីក៏ដោយ ក៏ស្ត្រីនៅកម្ពុជាបានចូលរួមក្នុងទីផ្សារពលកម្មបានច្រើនជាងស្ត្រីនៅតាមបណ្តាប្រទេសផ្សេងៗទៀត ដែលមានកម្រិតអភិវឌ្ឍន៍ ប្រហាក់ប្រហែលនឹងកម្ពុជា** (**ក្រាហ្វិក ១៥**)។ ក្នុងការវិភាគដើម្បីបង្ហាញពីទំនាក់ទំនងកម្រិតនៃការអភិវឌ្ឍរបស់ប្រទេសមួយទៅនឹងការចូលរួមរបស់ស្ត្រីទៅទីផ្សារពលកម្ម គេច្រើនប្រើការវិភាគមួយហៅថា ការវិភាគរាងអក្សរអ៊ុយ (U)។ ក្នុងប្រទេសណាក៏ដោយ នៅពេលដែលសេដ្ឋកិច្ចចាប់ផ្តើមរីកលូតលាស់

**តារាង ១០៖ ផលធៀបចំនួនអ្នកមានការងារធ្វើទៅនឹងចំនួនប្រជាពលរដ្ឋ**

| កម្រិតអប់រំ | ២០០៤ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|---|---|
| ពុំមាន | ៧៣% | ៩៥% | ៩២% | ៨៣% | ៨៩% | ៨៩% |
| បឋមសិក្សា | ៨២% | ៨៦% | ៨៥% | ៨៦% | ៨៧% | ៨៧% |
| អនុវិទ្យាល័យ | ៧៦% | ៧៧% | ៧៥% | ៧៥% | ៨២% | ៨២% |
| វិទ្យាល័យ | ៧០% | ៨៧% | ៨២% | ៧៩% | ៦៨% | ៦៨% |
| បុរស | ៨៥% | ៩០% | ៨៩% | ៨៧% | ៨៨% | ៨៩% |
| ស្ត្រី | ៧៤% | ៧៧% | ៧៥% | ៧៧% | ៨០% | ៨១% |

| អាយុ | ២០០៤ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|---|---|
| ១៥-២៤ | ៧៦% | ៧៨% | ៧៦% | ៧៦% | ៧៨% | ៧៨% |
| ២៥-៣៤ | ៨៧% | ៩០% | ៩០% | ៩០% | ៩១% | ៩៤% |
| ៣៥-៤៤ | ៨៨% | ៩២% | ៩១% | ៩២% | ៩៤% | ៩៤% |
| ៤៥-៥៤ | ៨៥% | ៨៩% | ៨៩% | ៩០% | ៩២% | ៩០% |
| ៥៥-៦៤ | ៧២% | ៨០% | ៧៨% | ៧៨% | ៨១% | ៨៣% |
| ៦៥+ | ៤៣% | ៤៥% | ៤២% | ៤៣% | ៤៦% | ៥០% |

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

ចំនួនប្រជាពលរដ្ឋ ដែលធ្វើការនៅផ្នែកកសិកម្មបានចាកចេញពីវិស័យនេះទៅរកវិស័យកម្មន្តសាល និងសេវាកម្ម ហើយជាទូទៅ គេសង្កេតឃើញថា នៅពេលមានហេតុការណ៍នេះកើតឡើង កម្លាំងពលកម្មជាបុរសទទួលបានប្រាក់បៀវត្សរ៍ខ្ពស់ជាងកម្លាំងពលកម្មជាស្ត្រី។ លើសពីនេះទៀត ការផ្លាស់ប្តូរសេដ្ឋកិច្ចនៅតាមប្រទេសនានា តែងតែនាំឲ្យមានការផ្លាស់ប្តូរខាងផ្នែកសង្គម ជាពិសេសទាក់ទងនឹងការចូលរួមក្នុងទីផ្សារពលកម្មរបស់ស្ត្រី។ គេសង្កេតឃើញដែរថា ចំណូលរបស់គ្រួសារមួយកើនឡើងបាន លុះត្រាតែស្ត្រីដែលពីមុនធ្វើការងារដែលមិនទទួលបានប្រាក់បៀវត្សរ៍ ដូចជាការចិញ្ចឹមបីបាច់កូន កិច្ចការងារផ្ទះ បានងាកមកចូលរួមក្នុងទីផ្សារពលកម្មផ្លូវការវិញ ដែលការចូលរួមនេះធ្វើឲ្យស្ត្រីទទួលបានប្រាក់បៀវត្សរ៍ទៀងទាត់។ ជាទូទៅ ស្ត្រីដែលចូលរួមក្នុងទីផ្សារពលកម្មនេះធ្វើការងារក្នុងវិស័យឧស្សាហកម្ម។ អ្វីដែលជំរុញឲ្យទីផ្សារពលកម្មមានដំណើរការល្អនោះ គឺថាកាលណាស្ត្រីភាគច្រើនបានចូលរួមក្នុងទីផ្សារពលកម្មផ្លូវការ ពួកគេនឹងវិនិយោគលើការអប់រំ និងការថែទាំសុខភាពដើម្បីលើកកម្ពស់មូលធនរបស់គេ។ នាពេលបច្ចុប្បន្ននេះ ការចូលរួមរបស់ស្ត្រីនៅក្នុងទីផ្សារពលកម្មមានកម្រិតខ្ពស់ជាងបណ្តាប្រទេសនានា ដែលមានកម្រិតសេដ្ឋកិច្ចប្រហាក់ប្រហែលកម្ពុជា (**តារាង ១៥**)។

**នៅតាមទីប្រជុំជននានា ការកើនឡើងនៃចំនួនកម្មករដែលប្រកបមុខរបរមានប្រាក់បៀវត្សរ៍ទៀងទាត់កើតមានទាំងកម្មករជាស្ត្រី និង កម្មករជាបុរស។** ជាឧទាហរណ៍ ចំនួនស្ត្រី និងបុរសដែលធ្វើការពុំមានប្រាក់បៀវត្សរ៍ទៀងទាត់បានធ្លាក់ចុះពី ២៥ ភាគរយ នៅឆ្នាំ២០០៤ មកជិត ១១ ភាគរយ នៅឆ្នាំ ២០១១។ សម្រាប់កម្មករស្ត្រីដែលប្រកបមុខរបរដោយខ្លួនឯង មិនមានការប្រែប្រួលច្រើនទេ គឺ ០,៧ ភាគរយ។ ចំណែកបុរសដែលប្រកបមុខរបរដោយខ្លួនឯង ក៏មិនមានភាពប្រែប្រួលច្រើនដែរ (ប្រែប្រួល ១,១ ភាគរយ តែប៉ុណ្ណោះ)។ ការថយចុះ នៃចំនួនប្រជាពលរដ្ឋដែលធ្វើការពុំមានប្រាក់ចំណូល ដោយសារតែប្រជាពលរដ្ឋភាគច្រើន រាប់ទាំងស្ត្រី និង បុរសបានទៅប្រកបការងារទទួលប្រាក់បៀវត្សរ៍ទៀងទាត់ នៅតាមបណ្តាទីប្រជុំជននានា។ ចំពោះស្ត្រី គេសង្កេតឃើញថា ស្ត្រីដែលប្រកប

**ក្រាហ្វិក ១៥៖** ការរួមចំណែករបស់កម្មករជាស្ត្រី និងផលិតផលក្នុងស្រុកសរុប តួលេខឆ្នាំចុងក្រោយដែលមាន




**ប្រភព៖** ធនាគារពិភពលោក, របាយការណ៍អភិវឌ្ឍន៍ពិភពលោក។

ការងារទទួលបានប្រាក់បៀវត្សរ៍ទៀងទាត់បានកើនឡើងពី ២៨,៩ ភាគរយ នៅឆ្នាំ២០០៤ ហើយ ៣៨,៣ ភាគរយ នៅឆ្នាំ២០០៨ ហើយបានកើនឡើងដល់ ៤៣,៥ ភាគរយ នៅឆ្នាំ២០១១។ អត្រាស្ត្រីដែលប្រកបមុខរបរទទួលបានប្រាក់បៀវត្សរ៍ទៀងទាត់ បានកើនឡើង គួរឲ្យកត់សម្គាល់ បានកើនឡើងពី ៤៤,១ ភាគរយ ក្នុងឆ្នាំ២០០៤ មក ៥៣,២ ភាគរយ នៅឆ្នាំ២០០៨ និងកើនឡើងដល់ ៥៤,៧ ភាគរយ នៅឆ្នាំ២០១១ (**ក្រាហ្វិក ១៦**)។

គេសង្កេតឃើញថា កម្មករប្រកបមុខរបរដោយខ្លួនឯងភាគច្រើន មានកម្រិតការសិក្សាអប់រំទាប (កម្រិតបឋមសិក្សា ឬ មិនមានការសិក្សាអប់រំទេ) ហើយជាពិសេសនៅតាមទីប្រជុំជននានា។ ទោះបីជា កម្មករដែលមានការសិក្សាអប់រំទាបមានពីរភាគបីនៃចំនួនកម្មករសរុប ដែលប្រកបមុខរបរដោយខ្លួនឯងនៅតាមទីប្រជុំជនក៏ដោយ ក៏ចំនួននេះបានធ្លាក់ចុះមកត្រឹម ៤៤,១ ភាគរយ។ នៅតាមទីជនបទរបស់កម្ពុជាវិញ ក្នុងចំណោមកម្មករប្រកបមុខរបរដោយខ្លួនឯងមាន ៨៤,៤ ភាគរយ ជាកម្មករដែលមានកម្រិតការសិក្សាទាប។ ក្នុងចំណោមកម្មករប្រកបមុខរបរទទួលបានប្រាក់បៀវត្សរ៍ទៀងទាត់វិញ ៧៥,៩ ភាគរយ ជាកម្មករដែលមានកម្រិតការសិក្សាទាប (**តារាង ១១**)។ កម្លាំងពលកម្មនៅកម្ពុជាភាគច្រើននៅវ័យក្មេង ហើយទីផ្សារពលកម្មមិនអាចស្រូបយកកម្លាំងពលកម្មទាំងអស់នោះមកធ្វើការក្នុងវិស័យនានា ដែលមានប្រាក់បៀវត្សរ៍ទៀងទាត់នោះទេ។

បើធៀបទៅនឹង ឆ្នាំ២០០៤ កម្រិត នៃការសិក្សាអប់រំរបស់កម្មករ ដែលធ្វើការនៅទីប្រជុំជនត្រូវបានលើកកម្ពស់ ប៉ុន្តែកម្មករនៅទីជនបទវិញកម្រិតការសិក្សាអប់រំរបស់ពួកគេមានការលើកកម្ពស់តិចតួចណាស់។ ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ ២០១១ អត្រាប្រជាពលរដ្ឋដែលប្រកបមុខរបរដោយខ្លួនឯង ដែលមានការសិក្សាថ្នាក់មធ្យមសិក្សាបឋមភូមិ បានកើនឡើងពី ២០ ភាគរយទៅ ២៤,៣ ភាគរយ តែប៉ុណ្ណោះ។ ចំណែកឯចំនួនប្រជាពលរដ្ឋប្រកបមុខរបរដោយខ្លួនឯង នៅទីជនបទ ដែលបានបញ្ចប់ការសិក្សាទុតិយភូមិបានកើនឡើងពី ៣ ភាគរយ ទៅ ៧,៧ភាគរយ ក្នុងអំឡុងពេលដូចគ្នានេះ។ នៅតាមទីប្រជុំជនវិញ អត្រាប្រជាពលរដ្ឋ ដែលប្រកបមុខរបរមានប្រាក់បៀវត្សរ៍ទៀងទាត់ដែលបានបញ្ចប់កម្រិតទុតិយភូមិ បានកើនឡើងរហូតដល់ ១៦,៤ ភាគរយប៉ុណ្ណោះ (ស្មើនឹងអត្រាប្រជាពលរដ្ឋ

**ក្រាហ្វិក ១៦៖** កម្មករជាស្ត្រី និងបុរសនៅតាមទីប្រជុំជនបែងចែកតាមប្រភេទការងារ




**សម្គាល់៖** ប្ដីឬប្រពន្ធត្រូវបានចាត់ថ្នាក់ឡើងវិញពីកម្មករដែលធ្វើការក្នុងគ្រួសារទៅជាកម្មករដែលធ្វើការដោយខ្លួនឯង។ និយោជិតត្រូវបានចាត់ថ្នាក់ថាជាអ្នកធ្វើការដែលមានប្រាក់បៀវត្សរ៍ទៀងទាត់កម្មករផ្សេងទៀតត្រូវបានចាត់ថ្នាក់ជាកម្មករធ្វើការក្នុងគ្រួសារដោយមិនមានប្រាក់បៀវត្សរ៍

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

ដែលប្រកបមុខរបរដោយខ្លួនឯងពីរដង។ ក្នុងចំណោមប្រជាពលរដ្ឋដែលប្រកបមុខរបរទទួលបានប្រាក់បៀវត្សរ៍ទៀងទាត់នៅតាមតំបន់ទីប្រជុំជនមាន ២៥ ភាគរយ រៀនបញ្ចប់មហាវិទ្យាល័យ បើធៀបទៅនឹងប្រជាពលរដ្ឋដែលប្រកបមុខរបរដោយខ្លួនឯងមានតែ ១,៧ ភាគរយប៉ុណ្ណោះដែលរៀនបញ្ចប់មហាវិទ្យាល័យ (**តារាងទី ១១**)។

**ដោយសារតែកម្ពុជាមានកម្លាំងពលកម្មក្មេងៗច្រើន កម្ពុជាកំពុងជួបប្រទះភាពប្រឈមក្នុងការបង្កើតមុខរបរដែលផ្តល់ប្រាក់បៀវត្សរ៍ទៀងទាត់ដល់កម្លាំងពលកម្មទាំងនោះ។** ដូច្នេះ ក្នុងរយៈពេលមធ្យម ការប្រកបមុខរបរដោយខ្លួនឯង និង ជួយធ្វើការក្នុងគ្រួសារនៅតែជាប្រភពការងារដ៏សំខាន់។ ការសិក្សានៅប្រទេសដទៃទៀតក៏បានបង្ហាញឲ្យឃើញថា សហគ្រាសបែបគ្រួសារជាកន្លែងដ៏សំខាន់ដែលផ្តល់ការងារដល់ប្រជាពលរដ្ឋក្មេងៗ។ ឧទាហរណ៍ ហ្វុកស៍ និងផេវ បានធ្វើការសិក្សា នៅឆ្នាំ ២០១២ ហើយរកឃើញថា សម្រាប់ប្រទេសនៅប៉ែកអាហ្វ្រិក សហគ្រាសបែបគ្រួសារបានបង្កើតការងារយ៉ាងច្រើនដល់ក្មេងៗគ្រប់អាយុធ្វើការ។ ហើយអ្នកនិពន្ធទាំងពីរបានសន្និដ្ឋានថា សហគ្រាសបែបគ្រួសារទាំងនេះជាប្រភពកំណើនសេដ្ឋកិច្ច ដែលអាចផ្តល់ផ្លែផ្កាដល់ប្រជាពលរដ្ឋភាគច្រើន ពីព្រោះទោះបីជាសេដ្ឋកិច្ចមានកំណើនខ្ពស់យ៉ាងណាក៏ដោយ សេដ្ឋកិច្ចនោះមិនអាចមានលទ្ធភាពស្រូបយកក្មេងៗ ដែលគ្រប់អាយុធ្វើការឲ្យចូលធ្វើការទាំងអស់នោះទេ ហើយក៏មិនអាចស្រូបយកកម្លាំងពលកម្មដែលធ្វើការនៅស្រែចម្ការទាំងអស់ដែរ។ ចំពោះកម្មករទាំងនោះ ពួកគេមិនមានកម្រិតសិក្សាអប់រំគ្រប់គ្រាន់ ដើម្បីទៅប្រកួតប្រជែងការងារធ្វើនៅក្នុងសហគ្រាសផ្លូវការបានទេ មានតែសហគ្រាសតាមបែបគ្រួសារនេះហើយ ដែលបានផ្តល់ឱកាសការងារដល់ពួកគេ។ អ្នកនិពន្ធទាំងពីរក៏បានរកឃើញថា ប្រសិនបើគ្រួសារណាមួយមានសមាជិករបស់ខ្លួនធ្វើការក្នុងសហគ្រាសបែបគ្រួសារ ជីវភាពរបស់គ្រួសារនោះហាក់ដូចជាមានភាពធូរជារច្រើន។ ជាសង្ខេប អ្នកនិពន្ធទាំងពីរបានសន្និដ្ឋានថា បើជាមធ្យម មានគ្រួសារចំនួនពី ៤០ ភាគរយ ទៅ ៥០ ភាគរយ ធ្វើការនៅក្នុងសហគ្រាសមិនមែនកសិកម្ម ការវិនិយោគណាមួយរបស់រដ្ឋាភិបាលដែលជួយទៅដល់សហគ្រាសតាមបែបគ្រួសារទាំងនោះ សូម្បីតែត្រឹមពាក់កណ្តាលក៏ដោយ នឹងមានឥទ្ធិពលជាវិជ្ជមានយ៉ាងខ្លាំងទៅដល់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។

**ដើម្បីគណនាប្រាក់ចំណូលរបស់ប្រជាពលរដ្ឋដែលទទួលបានប្រាក់បៀវត្សរ៍ទៀងទាត់អាយុពី ១៥ ឆ្នាំ ទៅ ៦៥ ឆ្នាំ ទៅតាមកម្រិតសិក្សារបស់ពួកគេ យើងបានធ្វើរ៉ែហ្គ្រេសិនចំនួនពីរ។** សមីការរបស់រ៉េហ្គ្រេស្យុងមានចំនួនប្រាក់បៀវត្សរ៍ប្រចាំខែ គិតជាប្រាក់រៀល ជាអញ្ញាតសមីការ ហើយកត្តាសម្រាប់ពន្យល់អញ្ញាតនោះ គឺកម្រិតអប់រំ របស់ប្រជាពលរដ្ឋ។ សម្រាប់រ៉េហ្គ្រេស្យុងទីមួយ កត្តាអប់រំ គឺប្រើប្រាស់ចំនួនឆ្នាំ ដែលចំណាយទៅលើការសិក្សា។ សម្រាប់រ៉េហ្គ្រេស្យុងទីពីរ គេប្រើប្រាស់កម្រិតអប់រំ បញ្ចប់បឋមសិក្សា បញ្ចប់អនុវិទ្យាល័យ បញ្ចប់វិទ្យាល័យ និង បញ្ចប់ថ្នាក់មហាវិទ្យាល័យ ជាកត្តាសម្រាប់ពន្យល់ (ប្រសិនបើប្រជាពលរដ្ឋណាម្នាក់ដែលរៀនបានកម្រិតខ្ពស់ជាងគេនោះ គេនឹងដាក់ពិន្ទុមួយឲ្យ ហើយប្រជាពលរដ្ឋណាក៏ដោយដែលមានកម្រិតអប់រំផ្សេងពីនេះ គេដាក់ពិន្ទុសូន្យឲ្យ)។ ក្នុងការធ្វើរ៉េហ្គ្រេស្យុងនោះដែរគេក៏បានបញ្ចូលអញ្ញាតមួយចំនួនទៀត ដើម្បីធានាថា កត្តាអប់រំមិនមានឥទ្ធិពលទៅវិញទៅមកជាមួយនឹងលក្ខខណ្ឌគ្រួសារទេ។

**តារាង ១១៖** ប្រភេទការងារតាមកម្រិតអប់រំ ទីលំនៅ និងប្រាក់ឈ្នួល (កម្ពុជា, ឆ្នាំ២០០៤-២០១១)

| | | ប្រាក់បៀវត្សរ៍ | | មុខរបរដោយខ្លួនឯង | |
|---|---|---|---|---|---|
| | | ២០០៤ | ២០១១ | ២០០៤ | ២០១១ |
| ទីប្រជុំជន | ពុំមាន | ០,១% | ០,០% | ០,៥% | ០,០% |
| | បឋមសិក្សា | ៤៧,៩% | ៤១,៥% | ៧៦,០% | ៦៦,៣% |
| | អនុវិទ្យាល័យ | ២៨,២% | ២៤,២% | ២០,០% | ២៤,៣% |
| | វិទ្យាល័យ | ១៣,៩% | ១៦,៤% | ៣,០% | ៧,៧% |
| | មហាវិទ្យាល័យ | ៩,៩% | ១៧,៩% | ០,៥% | ១,៧% |
| | សរុប | ១០០% | ១០០% | ១០០% | ១០០% |
| ទីជនបទ | ពុំមាន | ០,៣% | ០,០% | ០,៥% | ០,៤% |
| | បឋមសិក្សា | ៧៥,៦% | ៧៥,៩% | ៨៧,៨% | ៨៤,៤% |
| | អនុវិទ្យាល័យ | ១៨,៤% | ១៦,៩% | ១១,០% | ១២,១% |
| | វិទ្យាល័យ | ៤,៧% | ៥,៩% | ០,៧% | ៣,០% |
| | មហាវិទ្យាល័យ | ១,១% | ១,៣% | ០,១% | ០,១% |
| | សរុប | ១០០% | ១០០% | ១០០% | ១០០% |

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

**កម្មករដែលមានកម្រិតអប់រំកាន់តែខ្ពស់ ទទួលបានប្រាក់បៀវត្សរ៍កាន់តែច្រើន ហើយកម្មករដែលរៀនចប់មហាវិទ្យាល័យបានទទួលប្រាក់បៀវត្សរ៍ខ្ពស់ជាងគេ។** នៅ ឆ្នាំ ២០១១ កម្រិតអប់រំឡើងបានមួយឆ្នាំនាំឲ្យប្រាក់បៀវត្សរ៍កើនឡើង ៥,៦ ភាគរយ។ បើគេប្រៀបធៀបប្រាក់បៀវត្សរ៍កម្មករទៅតាមកម្រិតនៃការសិក្សារបស់កម្មករ គេឃើញថា អ្នកដែលរៀនចប់ត្រឹមមធ្យមសិក្សាបឋមភូមិបានប្រាក់បៀវត្សរ៍ខ្ពស់ជាងអ្នកដែលរៀនចប់ត្រឹមបឋមសិក្សា ១៦,១ ភាគរយ ហើយអ្នកដែលរៀនចប់មធ្យមសិក្សាទុតិយភូមិបានប្រាក់បៀវត្សរ៍ខ្ពស់ជាងអ្នករៀនចប់មធ្យមសិក្សាបឋមភូមិ ៨,៤ ភាគរយ។ ចំពោះអ្នករៀនចប់មហាវិទ្យាល័យ ពួកគេបានប្រាក់បៀវត្សរ៍ខ្ពស់ជាងអ្នករៀនចប់បឋមភូមិចំនួន ៨៤,៥ ភាគរយ (**តារាង ១២**)។

**ផលដែលបានមកវិញពីការវិនិយោគលើការអប់រំនៅកម្ពុជាបានធ្លាក់ចុះចាប់ពីឆ្នាំ២០០៨។** លទ្ធផលដែលបានមកពីការធ្វើរ៉េហ្គ្រេស្យុងបានបង្ហាញទំនោរមួយយ៉ាងច្បាស់ទាក់ទងនឹងផលដែលបានមកវិញពីការអប់រំចាប់ពីឆ្នាំ ២០០៨ មក។ ផលដែលបានមកវិញពីការបង្កើនការអប់រំមួយឆ្នាំបានធ្លាក់ចុះ ១,៨ ភាគរយ ពី ៧,៤ ភាគរយក្នុងឆ្នាំ ២០០៨ មក ៥,៦ ភាគរយ នៅឆ្នាំ២០១១។ ផលដែលបានមកវិញរបស់អ្នករៀនចប់មធ្យមសិក្សាធៀបនឹងអ្នករៀនចប់បឋមសិក្សាធ្លាក់ចុះពីមួយភាគបី មកជិតមួយភាគពីរ ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១១ ហើយផលដែលបានមកវិញរបស់អ្នករៀនចប់មហាវិទ្យាល័យក៏បានធ្លាក់ចុះដែរ ប៉ុន្តែមានការធ្លាក់តិចតួច។

**ការវិនិយោគលើការអប់រំនឹងហុចផល នៅពេលចូលទីផ្សារពលកម្ម ប៉ុន្តែគេសង្កេតឃើញថាការសិក្សាជំនាញបច្ចុប្បន្ននេះ មិនត្រូវជាមួយតម្រូវការទីផ្សារពលកម្មទេ។** ផលត្រឡប់មកវិញពីការបង្កើនកម្រិតអប់រំបានថយចុះ ហើយការសិក្សាមួយផ្សេងទៀតរបស់ធនាគារពិភពលោកបានរកឃើញថា ទីផ្សារកម្លាំងពលកម្ម និង ការសិក្សាជំនាញរបស់កម្លាំងពលកម្មមិនស៊ីសង្វាក់គ្នាទេ (World Bank, ២០១២)។ បើទោះបីជាការអប់រំនឹងផ្តល់ផលមកវិញច្រើនក៏ដោយ ក៏កម្មករភាគច្រើនរៀនចប់ត្រឹមកម្រិតបឋមសិក្សាប៉ុណ្ណោះ។

ចំនួនក្រុមហ៊ុនដែលបានរាយការណ៍ថា កម្មករកម្ពុជាខ្វះជំនាញជាកត្តារាំងការរីកចម្រើនខ្លាំងរបស់ក្រុមហ៊ុន នៅឆ្នាំ២០០៧ មានប្រមាណ ១៥,៥ ភាគរយ។ ក្រុមហ៊ុនបរទេសដែលប្រតិបត្តិការនៅកម្ពុជាក៏បានរាយការណ៍ដែរថា កង្វះជំនាញរបស់កម្មករកម្ពុជាជា"ឧបសគ្គធំ ឬឧបសគ្គធំណាស់" ដែលរារាំងការរីកចម្រើនលូតលាស់លឿនរបស់អាជីវកម្មពួកគេ (World Bank, ២០១២)។ ឧទាហរណ៍មួយដែលបង្ហាញពីភាពមិនស៊ីសង្វាក់គ្នារវាងការផ្គត់ផ្គង់ជំនាញ និងតម្រូវការទីផ្សារពលកម្មក្នុងឧស្សាហកម្មកាត់ដេរ។ អ្នកបច្ចេកទេស និងប្រធានផ្នែកភាគច្រើននៅ

**តារាង ១២៖** ផលដែលបានមកវិញពីការអប់រំតាមឆ្នាំ និងតាមកម្រិតអប់រំ កម្ពុជាឆ្នាំ២០០៤ ដល់ ឆ្នាំ២០១១

| | ២០០៤ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|---|---|
| រ៉េហ្គ្រេសិនទីមួយ៖ ផលដែលបានមកវិញទៅតាមចំនួនឆ្នាំនៃការអប់រំដែលបានបញ្ចប់ | | | | | | |
| ឆ្នាំនៃការអប់រំ | ០,០៦៩ | ០,០៧០ | ០,០៧៤ | ០,០៦២ | ០,០៥៣ | ០,០៥៦ |
| រ៉េហ្គ្រេសិនទីពីរ៖ ផលដែលបានមកវិញទៅតាមកម្រិតអប់រំដែលបានបញ្ចប់ (មិនរាប់បញ្ចូលបឋមសិក្សា) | | | | | | |
| ពុំមាន | ០,៤៥១ | -០,៥៩១ | -០,៦៨៩ | -០,៣១៦ | * | * |
| អនុវិទ្យាល័យ | ០,២៨២ | ០,១៩២ | ០,២២០ | ០,២៣៩ | ០,១៣២ | ០,១៦១ |
| វិទ្យាល័យ | ០,៥៩៨ | ០,៤៣៨ | ០,៤០២ | ០,៤៤៧ | ០,២២៦ | ០,២៤៥ |
| មហាវិទ្យាល័យ | ០,៩៩២ | ០,៩៥៨ | ១,១៤៧ | ០,៨៧៧ | ០,៨៦៧ | ០,៨៤៦ |

ក្នុងឆ្នាំ២០១០ និងឆ្នាំ២០១១ គេពុំឃើញមានប្រជាពលរដ្ឋ ណាម្នាក់ដែលពុំមានកម្រិតសិក្សាអប់រំទេ

ក្នុងរោងចក្រកាត់ដេរនៅកម្ពុជាជាជនជាតិចិនដែលបានបញ្ជូនមកដោយក្រុមហ៊ុនគ្រប់គ្រងបុគ្គលិកមានមូលដ្ឋាននៅប្រទេសចិន (Natusuda, Toto, និង Thobun, ២០០៩)។ សូម្បីតែនិស្សិតដែលបញ្ចប់ថ្នាក់មហាវិទ្យាល័យក៏ដោយ ក៏ជំនាញភាគច្រើនដែលពួកគេរៀនមិនសូវត្រូវនឹងទីផ្សារការងារដែរ។ មូលហេតុនេះហើយ ដែលគេសង្កេតឃើញថា និស្សិតបញ្ចប់មហាវិទ្យាល័យពិបាករកការងារធ្វើទៅតាមជំនាញដែលខ្លួនរៀន។ និស្សិតបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកជំនួញ និង នីតិសាស្ត្រមានច្រើនពេក រីឯនិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកវិស្វករមានតិចតួចពេក (World Bank, ២០១២)។

កម្ពុជាកំពុងខ្វះខាតកម្លាំងពលកម្មជាថ្នាក់ដឹកនាំជាន់ខ្ពស់ដែលមានជំនាញវិជ្ជាជីវៈគ្រប់គ្រាន់។ បញ្ហានេះតម្រូវឲ្យនិយោជិតទាំងអស់ខិតខំពង្រឹងសមត្ថភាពខ្លួនថែមទៀត។ យោងតាមការសិក្សាមួយរបស់ធនាគារពិភពលោកនៅឆ្នាំ២០១២ ស្តីពីជំនាញរបស់កម្មករនៅកម្ពុជា ដោយប្រើព័ត៌មានពីការអង្កេតនៅឆ្នាំ២០១១ ដោយក្រុមហ៊ុន អេច.អា.អ៊ីន. (HRINC) បានបង្ហាញថា ក្រុមហ៊ុនជាង ៧០ ភាគរយបានរាយការណ៍ថា បុគ្គលិករបស់ពួកគេខ្វះជំនាញគ្រប់គ្រង, ៣៦ ភាគរយ បានរាយការណ៍ថា បុគ្គលិករបស់ពួកគេខ្វះជំនាញគ្រប់គ្រងថ្នាក់កណ្តាល និង ប្រធានផ្នែក ហើយ៣៤ភាគរយរាយការណ៍ថា បុគ្គលិកជាទូទៅខ្វះជំនាញវិជ្ជាជីវៈ។ ក្រៅពីជំនាញការងារជំនាញទន់ដែលខ្វះធំបំផុតគឺ ៥២ ភាគរយឆ្លើយថា មានអាកប្បកិរិយាមិនសូវល្អក្នុងពេលបំពេញការងារ, ៤២ភាគរយឆ្លើយថា ខ្វះជំនាញក្នុងការធ្វើការសម្រេចចិត្តពេលធ្វើការងារ ហើយ៦៤ ភាគរយឆ្លើយថា ខ្វះជំនាញវិភាគ។ លើសពីនេះទៀត ក្រុមហ៊ុនទាំងនោះ បានលើកឡើងថាពួកគេមានការលំបាកក្នុងការស្វែងរកកម្មករជំនាញសូម្បីរកត្រឹមតែកម្មករជំនាញ ដែលតម្រូវត្រឹមឲ្យចេះអាន និងគណនាបានច្បាស់លាស់ កុំថាឡើយដល់តម្រូវឲ្យចេះជំនាញការងារតែម្តង។ របាយការណ៍របស់ធនាគារពិភពលោកនេះក៏បានរកឃើញថាកម្ពុជាកំពុងខ្វះកម្មករបច្ចេកទេស ទោះបីជានិស្សិតដែលបញ្ចប់ការសិក្សាពីមហាវិទ្យាល័យមានច្រើនក៏ដោយ ក៏ក្រុមហ៊ុនមានការលំបាកក្នុងការស្វែងរកសាលា ដើម្បីបណ្តុះបណ្តាលជំនាញបន្ថែមដល់និយោជិត។

ក្នុងចំណោមអ្នកដែលប្រកបមុខរបរមានប្រាក់បៀវត្សរ៍ទៀងទាត់ គេឃើញមានគម្លាតប្រាក់បៀវត្សរ៍រវាងកម្មករជាបុរស និងកម្មករជាស្ត្រី ក្នុងឆ្នាំ២០០៩។ ប្រាក់បៀវត្សរ៍ជាមធ្យមរបស់កម្មករជាបុរសខ្ពស់ជាងប្រាក់បៀវត្សរ៍ជាមធ្យមរបស់កម្មករជាស្ត្រី ៣០ភាគរយ។ ក្នុងរបាយការណ៍នេះ យើងប្រើប្រាស់វិធីសាស្ត្រវិភាគហៅថា អុកសាកា (Oaxaca Decomposition) ដើម្បីស្វែងយល់ពីភាពខុសគ្នានៃប្រាក់ឈ្នួលគោលដោយប្រើកត្តាពីរ៖ កត្តាទីមួយ ភាពខុសគ្នានៃទាយទាន (ឧ. គម្លាតនៃកម្រិតអប់រំ) និងកត្តាទីពីរគឺភាពខុសគ្នានៃផលដែលបានមកវិញពីទាយទាន (ឧទាហរណ៍ ភាពខុសគ្នានៃកម្រិតបានមកវិញពីទាយទាន)។ លទ្ធផលនៃការវិភាគនេះបានបង្ហាញថា ភាពខុសគ្នានៃយេនឌ័រពាក់ព័ន្ធនឹងផលដែលបានមកវិញពីទាយទានជាកត្តាសំខាន់បំផុត ដែលធ្វើឲ្យមានគម្លាតប្រាក់បៀវត្សរ៍រវាងបុរសនិងស្ត្រី (**តារាង ១៣**)។ ជាពិសេសប្រាក់បៀវត្សរ៍របស់កម្មករជាស្ត្រីមានកម្រិតទាប ប្រសិនបើគាត់រៀបអាពាហ៍ពិពាហ៍ ហើយរស់នៅតាមទីប្រជុំជន។ ម្យ៉ាងវិញទៀត កត្តាផ្សេងទៀតដែលធ្វើឲ្យមានគម្លាតនេះដោយសារស្ត្រីបានរៀនសូត្រតិចជាងបុរស (នេះបើយើងពិនិត្យមើលភាពខុសគ្នានៃទាយទានរវាងបុរស និងស្ត្រី ពាក់ព័ន្ធនឹងគោលនយោបាយរបស់រដ្ឋាភិបាលចំពោះស្ត្រី និងបុរស)។

## វិស័យវាយនភ័ណ្ឌ

**វិស័យវាយនភ័ណ្ឌនៅកម្ពុជា បានផ្តល់អត្រាការងារដល់ស្ត្រីភាគច្រើន បើធៀបទៅនឹងវិស័យដទៃទៀត។** ដោយសារតែកម្មករជាស្ត្រីមានប្រហែល ៨០ ភាគរយ នៃកម្មករទាំងអស់ក្នុងវិស័យវាយនភ័ណ្ឌ។ វិស័យនេះអាចជាការពិសោធន៍មួយពាក់ព័ន្ធនឹងការផ្តល់ឱកាសផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (**តារាង ១៤**)។ បើគេដាក់ចេញគោលនយោបាយនានាដែលជួយផ្តល់អត្ថប្រយោជន៍បន្ថែម និងលើកកម្ពស់លក្ខខណ្ឌការងារដល់ឧស្សាហកម្មនានា ដែលមានស្ត្រីចូលរួមភាគច្រើន គេទំនងជាអាចជួយលើកកម្ពស់សុខមាលភាពរបស់ប្រជាពលរដ្ឋបានច្រើន ដូចជា៖ អាចជួយដល់បុត្រធីតារបស់ពួកគេក្នុងការសិក្សាអប់រំ។ ឆ្នាំ២០១១ វិស័យផ្សេងៗ

ទៀតដែលមានកម្មករជាស្ត្រីចូលរួមភាគច្រើនក្នុងមុខរបរលក់ដូរ និងជំនួញតូចតាច (៦៨,៨ ភាគរយ) និងរុក្ខាប្រមាញ់ (៦៦,៦ ភាគរយ)។ ចំណែកឯចំនួនស្ត្រីដែលធ្វើការនៅក្នុងវិស័យកសិកម្ម និងសេវាកម្មផ្សេងៗ ក្នុងឆ្នាំ២០១១ មានប្រមាណ ៥០ ភាគរយ។

ស្ត្រីដែលធ្វើការនៅក្នុងឧស្សាហកម្មកាត់ដេរ មានជីវភាពប្រសើរជាងស្ត្រីដែលធ្វើការនៅក្នុងឧស្សាហកម្មផ្សេងទៀត។ គម្លាតប្រាក់បៀវត្សរ៍រវាងបុរសនិងស្ត្រីនៅថេរ លើកលែងតែក្នុង ឆ្នាំ២០០៩ ដែលហាក់ដូចជាមានការកើនឡើងបន្តិច។ បើសិនជាយើងធ្វើការវិភាគដោយមិនខ្វល់ពីភាពខុសគ្នានៃកម្រិតអប់រំ និង កត្តាប្រជាសាស្ត្រផ្សេងៗទៀតគេរកឃើញថា ជាមធ្យមក្នុងឆ្នាំ២០០៩ ប្រាក់បៀវត្សរ៍របស់ស្ត្រីទាបជាងប្រាក់បៀវត្សរ៍របស់បុរស ២០ ភាគរយ ហើយនៅ ឆ្នាំ២០១១ គម្លាតនេះកើនឡើងដល់កម្រិតជិត ៣០ ភាគរយ។ ការសិក្សាផ្សេងទៀត ដែលធ្វើនៅកម្ពុជាក៏បានរកឃើញគម្លាតនៃប្រាក់បៀវត្សរ៍រវាងស្ត្រី និងបុរសដែរ (Savchenko et al. ២០១១)។

វិស័យកាត់ដេរបានផ្តល់ផលប្រយោជន៍ច្រើនដល់ស្ត្រី។ ការវិភាគដោយប្រើវិធីសាស្ត្រ រ៉េហ្គ្រេស្យុង បានបង្ហាញថា ស្ត្រីដែលធ្វើការនៅក្នុងវិស័យកាត់ដេរបានទទួលប្រាក់រង្វាន់ផ្សេងៗទៀតខ្ពស់ ក្រៅពីប្រាក់ខែគោល (**ក្រាហ្វិកទី ១៧**) បើធៀបទៅនឹងស្ត្រីដែលធ្វើការនៅវិស័យផ្សេងៗទៀត។ បន្ទាប់ពី ឆ្នាំ២០០៩មក គេសង្កេតឃើញថា ប្រាក់បៀវត្សរ៍របស់កម្មករជាស្ត្រីនៅក្នុងវិស័យកាត់ដេរ

**តារាង ១៣៖** ការវិភាគប្រើវិធីសាស្ត្រ អុកសាកា(Oaxaca) អំពីភាពខុសគ្នានៃប្រាក់ឈ្នួលតាមយេនឌ័រ កម្ពុជាឆ្នាំ២០០៩

| | ទាយទាន (វិសមភាពនៃឱកាស) | ផលដែលទទួលបានមកវិញនៃទាយទាន |
|---|---|---|
| រារាំងនឹងស្ត្រី | មហាវិទ្យាល័យ /0,0២៥***<br>អនុវិទ្យាល័យ /0,0១៣*** | រៀបការ /0,0៦៤*** |
| | វិទ្យាល័យ /0,00៧*** | ទីប្រជុំជន/0,0៥២*** |
| អព្យាក្រិត | ទីប្រជុំជន /0,00១<br>អាយុ /0,000 | អនុវិទ្យាល័យ /0,00១<br>វិទ្យាល័យ /0,00១<br>មហាវិទ្យាល័យ /-0,00១<br>កុងស្តង់/ 0,0៨៨ |
| ជួយដល់ស្ត្រី | វិស័យ (ទាំងមូល) /-0,0៩១ | វិស័យ (ទាំងមូល) /-0,0៦៧<br>អាយុ /-0,0១៩ |
| ឥទ្ធិពលសរុប | ជួយតិចតួច / -0,0៤0 | រារាំងតិចតួច/ 0,១២0 |

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

**តារាង ១៤៖** ការចូលរួមចំណែករបស់ស្ត្រីតាមវិស័យសេដ្ឋកិច្ច កម្ពុជាឆ្នាំ២០០៤ ដល់ឆ្នាំ២០១១

| | កសិកម្ម | ព្រៃឈើ | សេវាម្ហូបអាហារ | វាយនភ័ណ្ឌ | គ្រឿងឈើ | ឧស្សាហកម្មផ្សេងទៀត | សំណង់ | ការលក់ដូរ | ការដឹកជញ្ជូន | រដ្ឋបាលសាធារណៈ | សេវាសង្គមផ្សេងទៀត | សេវាផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០០៤ | ៥0,0% | ៤៨,៦% | ៤៥,៨% | ៨១,៣% | ៦១,៨% | ២៨,៩% | ១២,៤% | ៦៨,១% | ៧,១% | ១៣,៣% | ៣៦,៩% | ៤៤,0% |
| ២០១១ | ៥0,៨% | ៦៦,៦% | ៤៥,១% | ៨៤,២% | ២៥,៨% | ៣៣,៤% | ៨,៨% | ៦៨,៨% | ៤,៤% | ១១,៨% | ៤៤,៦% | ៥0,១% |

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

បានកើនឡើងជាលំដាប់។ នេះប្រហែលមកពីបរិយាកាសសេដ្ឋកិច្ចមានអំណោយផល មានកម្មវិធីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (Better Work Program) ដែលបានជួយឲ្យលក្ខខណ្ឌការងារមានភាពប្រសើរឡើង។ម៉្យាងទៀតគោលនយោបាយរបស់រដ្ឋាភិបាលដែលកំណត់ប្រាក់បៀវត្សរ៍អប្បបរមាក្នុងវិស័យនេះអាចជាកត្តាជួយមួយផ្នែកទៀត ក្នុងការជំរុញឲ្យលក្ខខណ្ឌនានាកាន់តែប្រសើរ។

**បន្ទាប់ពីកិច្ចព្រមព្រៀងវាយនភណ្ឌពិភពលោក (MFA) បញ្ចប់នៅឆ្នាំ ២០០៤មក ឧស្សាហកម្មនៅកម្ពុជាមានភាពប្រែប្រួលយ៉ាងខ្លាំង។** សមិទ្ធិផលមួយយ៉ាងសំខាន់ដែលរាជរដ្ឋាភិបាលកម្ពុជាបានសម្រេច គឺគោលនយោបាយគាំទ្រឲ្យបន្តកម្មវិធី "គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា" ដែលជាកិច្ចព្រមព្រៀងមួយរវាងកម្ពុជា និងសហរដ្ឋអាមេរិកនៅកម្ពុជាក្រោមកិច្ចព្រមព្រៀងវាយនភណ្ឌពិភពលោក ដែលបញ្ចប់នៅឆ្នាំ ២០០៤។ ក្រោមកិច្ចព្រមព្រៀងនេះ សហរដ្ឋអាមេរិកអនុញ្ញាតឲ្យកម្ពុជានាំសម្លៀកបំពាក់ទៅកាន់ទីផ្សារសហរដ្ឋអាមេរិកដោយមិនយកពន្ធ ប៉ុន្តែកម្ពុជាត្រូវធ្វើយ៉ាងណាឲ្យលក្ខខណ្ឌការងារនៅតាមរោងចក្រកាត់ដេរមានភាពប្រសើរឡើងតាមរយៈកម្មវិធី "គម្រោងរោងចក្រកាន់តែប្រសើរ"។ កម្មវិធីនេះបានរៀបចំឲ្យមានរចនាសម្ព័ន្ធគ្រប់គ្រង និងកិច្ចសហប្រតិបត្តិការបានយ៉ាងល្អរវាងរាជរដ្ឋាភិបាលកម្ពុជា, សមាគមរោងចក្រ, ក្រុមហ៊ុននានានិងសហជីព។ បច្ចុប្បន្ននេះ គម្រោងរោងចក្រកាន់តែប្រសើរត្រូវបានចាត់ចែងនិងត្រួតពិនិត្យដោយអង្គការពលកម្មអន្តរជាតិ (ILO) និងគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា, សមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC) និងសហជីពនានា។

**កម្មវិធីនេះបានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធទាំងអស់ រាប់ទាំងអ្នកបញ្ជាទិញអន្តរជាតិ។** កម្មវិធីនេះមិនគ្រាន់តែជួយតាមដានត្រួតពិនិត្យនិងវាយតម្លៃលក្ខខណ្ឌការងារនៅតាមរោងចក្រឲ្យសមស្របតាមនិយាម លក្ខខណ្ឌជាតិ និងអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានជួយរោងចក្រឲ្យបង្កើនផលិតភាពផងដែរ។ គេបានធ្វើការសិក្សាជាច្រើន ដើម្បីវាយតម្លៃប្រសិទ្ធភាពកម្មវិធីនេះលើរោងចក្រនានា ដោយពិនិត្យមើលថា តើលក្ខខណ្ឌការងារមានស្ថានភាពប្រែប្រួលយ៉ាងណា។ ការសិក្សាទាំងនោះបានពិនិត្យមើលកត្តាផ្សេងៗដែលមានឥទ្ធិពលលើការសម្រេចចិត្តរបស់រោងចក្រថា តើត្រូវពង្រីកលក្ខខណ្ឌការងារ និងពិនិត្យមើលលក្ខខណ្ឌការងារនៅតាមរោងចក្រនោះ មុននឹងចូលរួមក្នុងកម្មវិធីនេះ។ ការសិក្សាទាំងនោះបានពិនិត្យមើលទំនាក់ទំនងរវាងលក្ខខណ្ឌការងារ និងការបិទទ្វាររោងចក្រ ដើម្បីកំណត់ឲ្យឃើញមូលហេតុដែលធ្វើឲ្យរោងចក្របិទទ្វារ តើកត្តានោះមានពាក់ព័ន្ធនឹងលក្ខខណ្ឌការងារដែរឬទេ។ ការសិក្សាទាំងនោះបានសន្និដ្ឋានថា ការលើកកម្ពស់លក្ខខណ្ឌការងារ និងបំពេញលក្ខខណ្ឌការងារតាមផ្លូវច្បាប់មិនបានធ្វើឲ្យសមត្ថភាពប្រកួតប្រជែងរបស់ឧស្សាហកម្មកាត់ដេរកម្ពុជាបានធ្លាក់ចុះទេ ផ្ទុយទៅវិញការលើកកម្ពស់លក្ខខណ្ឌការងារបានជួយឲ្យរោងចក្រនានានៅកម្ពុជារក្សាតំណែងរបស់ខ្លួននៅលើឆាកអន្តរជាតិ។ យើងសូមសង្ខេបរបកគំហើញសំខាន់ៗនៃការសិក្សានេះដូចខាងក្រោម៖

- ការលើកកម្ពស់លក្ខខណ្ឌការងារមិនបានជំរុញឲ្យរោងចក្របិទទ្វារទេ ប៉ុន្តែផ្ទុយមកវិញ មានច្រើនករណីបង្ហាញថា ការលើកកម្ពស់លក្ខខណ្ឌការងារជួយរោងចក្រមិនឲ្យបិទទ្វារទៅវិញ។

- កេរ្តិ៍ឈ្មោះរោងចក្រមានភាពរសើបណាស់ពាក់ព័ន្ធនឹងការបញ្ចេញព័ត៌មានពីលក្ខខណ្ឌការងារ។ ដូចនេះ

**ក្រាហ្វិក ១៧៖** មេគុណនៃប្រាក់ឈ្នួល




គ្រប់មេគុណទាំងអស់ ទទួលបានការជឿជាក់ (significant)ខាងស្ថិតិ ក្នុងកម្រិតកំហុស ១%។
**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

ហើយ ទើបគេសង្កេតឃើញថា ការលែងតម្រូវឲ្យគម្រោងរោងចក្រកាន់តែប្រសើរលែងបញ្ចេញរបាយការណ៍វាយតម្លៃ បានធ្វើឲ្យអត្រាអនុវត្តន៍គោលការណ៍លើកកម្ពស់លក្ខខណ្ឌការងារបានថយចុះ។

- ដរាបណារោងចក្រចូលរួមលើកកម្ពស់ការអភិវឌ្ឍន៍លក្ខខណ្ឌការងាររបស់កម្មករឲ្យបានកាន់តែប្រសើរ ពួកគេកម្រឈប់ចូលរួមក្នុងកម្មវិធីនេះណាស់។ គេសង្កេតឃើញថា ស្ថានភាពនេះមានលក្ខណៈស្រដៀងទៅនឹងការអនុវត្តន៍បច្ចេកវិទ្យាថ្មីៗ។ ការចូលរួមរបស់រោង-ចក្រនៅក្នុងគម្រោងរោងចក្រកាន់តែប្រសើរបានបង្ហាញថាវាមិនធ្វើឲ្យប៉ះពាល់ និងការគ្រប់គ្រងផលិតភាពរបស់រោងចក្រនោះទេ។

មតិដែលជំទាស់ទៅនឹងការលើកកម្ពស់លក្ខខណ្ឌការងារនៅក្នុងរោងចក្រដោយសារពួកគេបារម្ភថា នឹងធ្វើឲ្យថ្លៃដើមកើនឡើង ហើយបាត់បង់សមត្ថភាពក្នុងការប្រកួតប្រជែង។ ប៉ុន្តែការសិក្សានោះរកមិនឃើញភស្តុតាងនានាគាំទ្រមតិនោះទេ។ ផ្ទុយទៅវិញលទ្ធផលនៃការសិក្សានេះបានបង្ហាញថា ការលើកកម្ពស់លក្ខខណ្ឌការងារអាចធ្វើឲ្យសមត្ថភាពប្រកួតប្រជែងរបស់រោងចក្រកាន់តែប្រសើររាប់ទាំងប្រាក់ចំណេញផង។ បច្ចុប្បន្ននេះ គេកំពុងធ្វើការស្រាវជ្រាវបន្ថែមទៀត ដើម្បីវាយតម្លៃលើការលើកកម្ពស់លក្ខខណ្ឌការងារ និងផលិតភាពនៅតាមរោងចក្រនានានៅកម្ពុជា។

**សម្រាប់ក្រុមហ៊ុន និងសហគ្រាសតូចៗ គេសង្កេតឃើញថា បរិយាកាសអាជីវកម្មមិនអំណោយផលទេ។** ទោះបីជាកម្លាំងពលកម្មភាគច្រើនបានធ្វើការនៅតាមរោងចក្រធំៗក៏ដោយ ក៏ប្រជាពលរដ្ឋកម្ពុជាប្រហែលមួយភាគបីប្រកបមុខរបរដោយខ្លួនឯង ជាពិសេសមុខរបរតូចតាច។ ជំរឿនសហគ្រាសនៅកម្ពុជាឆ្នាំ ២០១១ បានរកឃើញថា សហគ្រាសខ្នាតតូចមានប្រហែល ៩៩,៦ ភាគរយនៃសហគ្រាសសរុបទាំងអស់ដែលមាននៅកម្ពុជា។ ប៉ុន្តែកម្ពុជាជាប់ចំណាត់ថ្នាក់ទី ១៣៣ ក្នុងចំណោមប្រទេស ១៨៥ ពាក់ព័ន្ធនឹងភាពងាយស្រួលក្នុងការធ្វើអាជីវកម្មដែលសិក្សាដោយធនាគារពិភពលោកជារៀងរាល់ឆ្នាំ។ ទិដ្ឋភាពទាំងឡាយដែលកម្ពុជាមានពិន្ទុទាបនោះ គឺពាក់ព័ន្ធទៅនឹងបញ្ហានីតិរដ្ឋ (ការអនុវត្តច្បាប់ផ្សេងៗ) ដែលក្នុងនោះរួមមានការបិទបញ្ជីនៅពេលក្រុមហ៊ុនក្ស័យធន, ការសុំសិទ្ធិសាងសង់សំណង់, ការអនុវត្តកាតព្វកិច្ចសន្យា និងពាណិជ្ជកម្មឆ្លងដែន។ ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធវិញ ថ្លៃអគ្គិសនី និងដឹកជញ្ជូនជាឧបសគ្គដ៏ចម្បងពីក្នុងចំណោមឧបសគ្គចម្បង ៤ ដែលក្រុមហ៊ុនរាយការណ៍នៅក្នុងការអង្កេតស្តីពីបរិយាកាសវិនិយោគ (ICA survey)។

## អនុសាសន៍ពាក់ព័ន្ធនឹងគោលនយោបាយនានា

**ការងារដែលផ្តល់ប្រាក់បៀវត្សរ៍ទៀងទាត់បានជួយឲ្យកម្លាំងពលកម្មភាគច្រើនបង្កើនផលិតភាពរបស់ពួកគេ និងធ្វើឲ្យក្រុមគ្រួសាររបស់ពួកគេមានស្ថិរភាពចំណូល។** ដើម្បីឲ្យកម្ពុជាអាចបង្កើនការងារដែលមានប្រាក់បៀវត្សរ៍ទៀងទាត់បានច្រើន របាយការណ៍នេះសូមលើកយកអនុសាសន៍ចំនួនបួនដែលគេចាំបាច់ត្រូវយកមកអនុវត្តដើម្បីបង្កើនការងារបង្កើនផលិតភាព និងជំរុញការលើកកម្ពស់លក្ខខណ្ឌការងារ។

**កំណើនសេដ្ឋកិច្ចនាពេលអនាគតមិនត្រឹមតែបានមកពីវិស័យកសិកម្មតែមួយមុខទេ។** ទោះបីជាកម្ពុជានៅតែគ្របដណ្តប់ដោយតំបន់ជនបទក៏ដោយ ដើម្បីឲ្យប្រជាពលរដ្ឋកម្ពុជាមានចំណូលកើនឡើងជានិរន្តរ៍ គេត្រូវពង្រីកសកម្មភាពសេដ្ឋកិច្ចមិនមែនកសិកម្ម។ សម្រាប់ប្រជាពលរដ្ឋណាដែលមិនមានលទ្ធភាពប្រកបអាជីវកម្មដោយខ្លួនឯង ជម្រើសដ៏ប្រសើរបំផុតរបស់ពួកគេគឺធ្វើការឲ្យគេ។ ដូច្នេះរាជរដ្ឋាភិ-បាលត្រូវត្រៀមឲ្យបានរួចរាល់ ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការលើកកម្ពស់វិស័យឧស្សាហកម្ម និងសេវាកម្មផ្សេងៗដែលអនុញ្ញាតឲ្យកម្មករកម្ពុជាមានការងារធ្វើ ហើយទទួលបានប្រាក់បៀវត្សរ៍ទៀងទាត់។ របាយការណ៍នេះ មិនបានរៀបចំក្នុងបំណងផ្តល់អនុសាសន៍គោលនយោ-បាយវិស័យឧស្សាហកម្មប៉ុណ្ណោះទេ ប៉ុន្តែរបាយការណ៍នេះ បានរកឃើញថា ការងារដែលបានផ្តល់ប្រាក់បៀវត្សរ៍ទៀងទាត់ជាកត្តាសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ។

**ភាពមិនស៊ីសង្វាក់គ្នារវាងការផ្គត់ផ្គង់ និងតម្រូវការក្នុងទីផ្សារការងារកម្ពុជា ត្រូវតែកាត់បន្ថយដើម្បីឲ្យផលិតភាពបានកើនឡើង។** គេចាំបាច់ត្រូវធ្វើការកែលម្អប្រព័ន្ធអប់រំនៅកម្ពុជា ប៉ុន្តែគោលនយោបាយនានាត្រូវផ្តោតទៅលើ៖ ទីមួយការរៀបចំឲ្យមានការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាពនៅតាមសាលាបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈនានា។ ទីពីរ លើកកម្ពស់សាលាបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់ រាប់ទាំងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈឯកជន ដោយមានកិច្ចសហប្រតិបត្តិការជាមួយសហគ្រាសក្នុងស្រុក។ ទីបី លើកទឹកចិត្តឲ្យនិយោជកវិនិយោគលើការបណ្តុះបណ្តាលដល់កម្មករ។ ស្វែងរកហិរញ្ញប្បទានផ្សេងៗ ដើម្បីឲ្យសាលាបច្ចេកទេស និងមហាវិទ្យាល័យនានាផ្តល់វគ្គបណ្តុះបណ្តាលប្រកបដោយគុណភាព (ធនាគារពិភពលោក, ២០១២, Matching Aspirations)។

**ការលើកកម្ពស់លក្ខខណ្ឌការងារ ដែលបានអនុវត្តនៅពេលកន្លងមក គួរតែត្រូវបានផ្សព្វផ្សាយ និងលើកកម្ពស់បន្ថែមទៀត ដើម្បីកែលម្អស្ថិរភាព និងបរិយាកាសការងាររបស់និយោជិត។** ការអនុវត្តន៍លក្ខខណ្ឌការងារនេះជាគំរូដ៏ល្អមួយសម្រាប់បង្កឲ្យបរិយាកាសធ្វើការមានលក្ខណៈកាន់តែប្រសើរឡើង ហើយរាជរដ្ឋាភិបាលអាចធ្វើកិច្ចការពីរ។ ទីមួយ បង្កលក្ខណៈនានាដើម្បីឲ្យមានការចែករំលែកពីរោងចក្រកាត់ដេរទៅក្រុមហ៊ុនសហគ្រាសផ្សេងៗ ដើម្បីឲ្យមានការលើកកម្ពស់លក្ខខណ្ឌការងារនៅកម្ពុជា ហើយក្រុមហ៊ុននីមួយៗអាចបង្កើតយុទ្ធសាស្ត្ររបស់ពួកគេក្នុងការលើកកម្ពស់លក្ខខណ្ឌការងារ។ ទីពីរពង្រីកការអនុវត្តន៍ច្បាប់ស្តីពីលក្ខខណ្ឌការងារទៅវិស័យដទៃទៀត ដូចជាឧស្សហកម្មចំណីអាហារ ការកំសាន្ត និង ឧស្សាហកម្មនានាដែលទាក់ទងនឹងវិស័យទេសចរណ៍។ គេអាចប្រើគោលការប្រាក់បៀវត្សរ៍អប្បបរមា និងផលប្រយោជន៍ផ្សេងៗដែលបានធ្វើក្នុងវិស័យកាត់ដេរជាគំរូសម្រាប់វិស័យទាំងនេះ។

**រាជរដ្ឋាភិបាលគួរតែពិចារណាជួយដល់សហគ្រាសតាមគ្រួសារ និង សហគ្រាសតូចៗផ្សេងទៀត។** ការធ្វើបែបនេះអាចជួយឲ្យសហគ្រាសតូចៗតាមគ្រួសារពង្រីកអាជីវកម្មបានប្រសើរឡើង។ ការប្រកបមុខជំនួញដោយខ្លួនឯងជាប្រភពចំណូលដ៏សំខាន់ សម្រាប់ទ្រទ្រង់គ្រួសារ និងប្រភពបង្កើតការងារដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋផ្សេងៗទៀត ហើយវាក៏ជាមធ្យោបាយដែលអនុញ្ញាតឲ្យកម្មករមួយចំនួនបានសាកល្បងធ្វើការងារផងដែរ។ ការស្រាវជ្រាវមួយនាពេលថ្មីៗនេះ ស្តីអំពីការប្រកបមុខរបរដោយខ្លួនឯងបានរកឃើញថា ការប្រកបមុខរបរដោយខ្លួនឯងមិនមែនជាវិធីសាស្ត្រដោះទ័លនោះទេ ប៉ុន្តែវាជាវិធីសាស្ត្រកំណើនមួយ (FoxandPave Sohnesen, ២០១១)។ ការរៀបចំឲ្យមានច្បាប់ និងបទដ្ឋាននានា ដើម្បីជួយដល់សហគ្រាសតូចៗជាអ្វីដែលគេត្រូវធ្វើ។ ក្រៅពីនោះទៀត ធ្វើយ៉ាងណាឲ្យតម្លៃអគ្គិសនី និងការចំណាយលើការដឹកជញ្ជូនបានថយចុះ។ បញ្ហាទាំងនេះ ជាបញ្ហាអាទិភាពដើម្បីកែលម្អបរិយាកាសវិនិយោគនៅកម្ពុជា។

## តួនាទីនៃសេដ្ឋកិច្ចជនបទ

### ប្រជាពលរដ្ឋនៅតាមទីជនបទ

**កម្ពុជានៅតែជាប្រទេសដែលគ្របដណ្តប់ដោយតំបន់ជនបទនៅឡើយ។** ក្នុងចំណោម ១.៦២១ឃុំ ដែលកម្ពុជាមាន ៩០ ភាគរយ ត្រូវបានចាត់ទុកជាឃុំនៅតាមទីជនបទ។ ចំណែកឯអត្រាប្រជាពលរដ្ឋវិញជាង ៩០ភាគរយកំពុងតែរស់នៅតាមទីជនបទ ហើយចំនួននោះមានការប្រែប្រួលតិចតួចប៉ុណ្ណោះ។ យោងតាមការប៉ាន់ស្មានពីការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាពី ឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ អត្រាប្រជាពលរដ្ឋនៅទីជនបទបានថយចុះតែ ២ ភាគរយប៉ុណ្ណោះ ពី ៨១ ភាគរយ ក្នុងឆ្នាំ ២០០៤ មកត្រឹម ៧៩ ភាគរយ ក្នុងឆ្នាំ២០១១។ (**ក្រាហ្វិក ១៨**)

បើសិនជាគេពិនិត្យមើលប៉ុន្មានឆ្នាំមុននេះទៀត ដោយប្រើទិន្នន័យពីជំរឿនប្រជាសាស្ត្រវិញ ចំនួនប្រជាពលរដ្ឋនៅតាមទីជនបទបានធ្លាក់ចុះ ១,២ ភាគរយ ប៉ុណ្ណោះ ក្នុងរយៈពេល ១០ ឆ្នាំ (ពី ៨១,៧ ភាគរយ ក្នុងឆ្នាំ ១៩៩៨ មកត្រឹម ៨០,៥ ភាគរយ ក្នុងឆ្នាំ២០០៨)។ បើគិតត្រឹមឆ្នាំ២០១១ ប្រជាជនកម្ពុជាប្រមាណជា ២០ភាគរយ (ប្រមាណ ៣លាននាក់) កំពុងរស់តាមទីប្រជុំជននានា ហើយ

ក្នុងចំណោមនេះមានប្រហែលពាក់កណ្ដាលរស់នៅទីក្រុងភ្នំពេញ ចំណែកឯពាក់កណ្ដាលទៀត រស់នៅតាមបណ្ដាទីប្រជុំជន២៥ទៀត តាមបណ្ដាខេត្តនានាទូទាំងប្រទេស។

**ការធ្វើចំណាកស្រុកមកកាន់ទីប្រជុំជននៅកម្ពុជានៅមានកម្រិតទាបនៅឡើយដោយសារមានហេតុផលពីរយ៉ាង។** មូលហេតុទីមួយ ចំណាកស្រុកភាគច្រើនធ្វើឡើងពីតំបន់ជនបទមួយទៅតំបន់មួយផ្សេងទៀត។ គេសង្កេតឃើញបាតុភូតនេះ កាលពីធ្វើជំរឿន ប្រជាសាស្ត្រ ឆ្នាំ២០០៨។ ជំរឿនប្រជាសាស្ត្រឆ្នាំ២០០៨ បង្ហាញថា មានចំណាកស្រុកប្រហែល ៣,៥ លាននាក់ ហើយភាគច្រើននៃពួកជនចំណាកស្រុកពីតំបន់ជនបទមួយទៅតំបន់ជនបទមួយទៀតបានធ្វើឡើងនៅចុងទសវត្សរ៍ ទី៨០ និង ដើមទសវត្សរ៍ទី៩០។ អត្រាប្រជាពលរដ្ឋនៅតាមទីប្រជុំជនបានកើនឡើងពី ១៨,៣ ភាគរយ នៅឆ្នាំ១៩៩៨ មកត្រឹមតែ ១៩,៥ ភាគរយតែប៉ុណ្ណោះ(**ក្រាហ្វិកទី ១៨**)។

មូលហេតុទីពីរ កម្មករចំណាកស្រុកមកកាន់ទីប្រជុំជនទោះបីមករយៈពេលខ្លី ឬរយៈពេលវែងក្ដី ពួកគេនៅតែមានភាពងាយស្រួលទៅភូមិស្ថានឯទីជនបទវិញ ករណីមានវិបត្តិអ្វីមួយកើតឡើង។ នេះបង្ហាញឲ្យឃើញថា ជនបទជាសំណាញ់សុវត្ថិភាពមួយសម្រាប់ជួយប្រជាពលរដ្ឋនៅពេលប្រទេសជួបវិបត្តិ។ ហេតុការណ៍ត្រូវបានគេកត់សម្គាល់យ៉ាងច្បាស់នៅឆ្នាំ២០០៩ គ្រាដែលវិបត្តិហិរញ្ញវត្ថុសកលបានជះឥទ្ធិពលទៅលើវិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើង វិស័យសំណង់ និងវិស័យសេវាកម្មផ្សេងៗ។ កម្មករភាគច្រើនដែលបាត់បង់ការងារបានត្រឡប់ទៅរស់នៅជាមួយឪពុកម្ដាយ និងក្រុមគ្រួសាររបស់ពួកគេវិញនៅតាមទីជនបទ ដើម្បីរង់ចាំឱកាសត្រឡប់មកវិញ នៅពេលទីក្រុងមានការងារធ្វើវិញ។ មូលហេតុនេះហើយបានជាអត្រាប្រជាពលរដ្ឋនៅជនបទកាលពីឆ្នាំ ២០០៩ បានកើនឡើងមួយ ភាគរយបន្ថែមទៀតលើ ឆ្នាំ ២០១១។

## ការវិវត្តនៃភាពក្រីក្រជនបទពីឆ្នាំ២០០៤ដល់ឆ្នាំ២០១១

**កាលពីឆ្នាំ ២០០៧ អត្រាភាពក្រីក្រនៅមានកម្រិតខ្ពស់នៅឡើយ ប៉ុន្តែនៅ ឆ្នាំ២០០៩ ភាពក្រីក្រនៅតំបន់ជនបទបានធ្លាក់ចុះយ៉ាងគំហុគ មុនពេលដែលអត្រានេះបានធ្លាក់ចុះយឺតៗវិញនៅ ឆ្នាំ២០១១។** ការគណនាអត្រាភាពក្រីក្រ ដោយប្រើព័ត៌មានពីការអង្កេតសេដ្ឋកិច្ចកម្ពុជា បានបង្ហាញឲ្យឃើញថា អត្រាប្រជាពលរដ្ឋដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រនៅតាមតំបន់ជនបទបានធ្លាក់តិចតួចប៉ុណ្ណោះពី ៥៩ ភាគរយ នៅឆ្នាំ ២០០៩ មក ៥៨ ភាគរយ នៅឆ្នាំ ២០០៧។ ក៏ប៉ុន្តែអត្រានេះបានធ្លាក់ចុះ ២៨ ភាគរយ នៅឆ្នាំ ២០០៩ បន្ទាប់មកបានធ្លាក់ចុះយឺតៗ មក ២៤ ភាគរយ នៅឆ្នាំ ២០១១។

**គេសង្កេតឃើញថា ការកាត់បន្ថយភាពក្រីក្រពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៦ មានទំនោរច្បាស់លាស់បី។** ជាដំបូង ល្បឿននៃការកាត់បន្ថយភាពក្រីក្របានធ្លាក់ចុះយឺតៗក្នុងល្បឿន ០,៤ ភាគរយ ក្នុងមួយឆ្នាំៗ ក្នុងអំឡុងឆ្នាំ ២០០៤-២០០៧ ក៏ប៉ុន្តែវាមានល្បឿនយ៉ាងលឿនក្នុងកម្រិត ១៥,២ ភាគរយ ក្នុងមួយឆ្នាំៗ ក្នុងអំឡុងឆ្នាំ ២០០៧-២០០៩។ ទំនោរទីបី ល្បឿននៃភាពក្រីក្របានថមថយវិញក្នុងកម្រិត ១,៩ ភាគរយ ក្នុងមួយឆ្នាំៗអំឡុង ២០០៩-២០១១។ (**ក្រាហ្វិក ១៩**)

**ក្រាហ្វិក ១៨៖** អត្រាប្រជាពលរដ្ឋនៅជនបទ និងទីប្រជុំជន




**ប្រភព៖** វ.ជ.ស (២០០៩) និងសូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

បើប្រៀបទៅនឹងតំបន់ផ្សេងៗទៀត ល្បឿនកាត់បន្ថយភាពក្រីក្រនៅតាមទីជនបទមានកម្រិតប្រហាក់ប្រហែលល្បឿនការកាត់បន្ថយភាពក្រីក្រនៅតាមទីប្រជុំជនផ្សេងៗ។ ឧទាហរណ៍ ល្បឿននៃការកាត់បន្ថយភាពក្រីក្រនៅទីប្រជុំជនមានកម្រិត ១,៥ ភាគរយ ក្នុងមួយឆ្នាំអំឡុងឆ្នាំ២០០៤-២០០៧ ហើយមានកម្រិត ១១,២ ភាគរយ ក្នុងមួយឆ្នាំអំឡុង ឆ្នាំ២០០៧-២០០៩ ហើយបន្ទាប់មកមានកម្រិត ១,៧ ភាគរយ ក្នុងមួយឆ្នាំ អំឡុង ២០០៩-២០១១។ បើប្រៀបធៀបនឹងតំបន់នៅភ្នំពេញវិញ តំបន់ជនបទកម្ពុជាមានល្បឿននៃការបន្ថយភាពក្រីក្រ ៤,៤ភាគរយ ក្នុងមួយឆ្នាំ អំឡុងឆ្នាំ ២០០៤-២០០៧ បន្ទាប់មកអន់ថយមក ០,៨ ភាគរយ ក្នុងមួយឆ្នាំ អំឡុងឆ្នាំ២០០៧-២០០៩ និង ១,៤ ភាគរយ ក្នុងមួយឆ្នាំនៅអំឡុងឆ្នាំ២០០៩-២០១១។ (**ក្រាហ្វិក ២០**)

ដោយសារតែប្រជាពលរដ្ឋនៅទីតំបន់ជនបទមានប្រមាណ ៨០ ភាគរយនៃចំនួនប្រជាពលរដ្ឋសរុបនិងមានប្រជាពលរដ្ឋក្រីក្រប្រមាណ ៩០ ភាគរយ នៃប្រជាពលរដ្ឋក្រីក្រសរុប។ ការកាត់បន្ថយភាពក្រីក្រនៅតាមទីជនបទជាកត្តាកំណត់ល្បឿននៃការកាត់បន្ថយភាពក្រីក្ររបស់ប្រទេសកម្ពុជាទាំងមូល។ ល្បឿននៃការកាត់បន្ថយភាពក្រីក្ររបស់ប្រទេសកម្ពុជាទាំងមូលមានទំនោរដូចនឹងល្បឿននៃការកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា៖ គឺធ្លាក់ចុះយឺតៗ អំឡុងឆ្នាំ ២០០៤-២០០៧ យ៉ាងលឿនអំឡុងឆ្នាំ ២០០៧–២០០៩ ហើយអន់ថយមកវិញ នៅអំឡុងឆ្នាំ ២០០៩-២០១១។ ការគណនាបានបង្ហាញថា ល្បឿននៃការកាត់បន្ថយភាពក្រីក្រទាំងមូល មាន ១,១ ភាគរយ អំឡុងឆ្នាំ ២០០៤-២០០៧ មាន ១៣,១ ភាគរយ ក្នុងចន្លោះឆ្នាំ ២០០៧-២០០៩ ហើយ ១,៧ ភាគរយ ក្នុងអំឡុងឆ្នាំ ២០០៩-២០១១។

**ចលនាប្រជាពលរដ្ឋពីជនបទនៅតាមទីប្រជុំជនស្ទើរតែមិនមានឥទ្ធិពលបន្តិចសោះ ទៅលើការកាត់បន្ថយភាពក្រីក្រ។** នេះដោយសារតែចំនួនប្រជាពលរដ្ឋនៅតាមទីជនបទនៅតែមានចំនួនច្រើនដដែល គឺមានប្រមាណ ៨០ ភាគរយ។ យើងបានគណនា ឥទ្ធិពលនៃចំណាកស្រុកនៃជនបទទៅទីប្រជុំជនលើការកាត់បន្ថយភាពក្រីក្រដោយ

**ក្រាហ្វិក ១៩៖** អត្រាភាពក្រីក្រនៅជនបទ




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

**ក្រាហ្វិក ២០៖** ល្បឿននៃការកាត់បន្ថយភាពក្រីក្រ និងបម្រែបម្រួលចំណាយលើការប្រើប្រាស់ឆ្នាំ២០០៤–២០១១

**(a)** ល្បឿននៃការកាត់បន្ថយភាពក្រីក្រក្នុងមួយឆ្នាំ

**(b)** បម្រែបម្រួលចំណាយលើការប្រើប្រាស់ក្នុងមួយឆ្នាំ




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

ប្រើវិធីសាស្ត្រមួយ ឈ្មោះថា រ៉ាវ៉ាលៀន–ហុពី (Ravalion-Huppi Decomposition) ហើយពិនិត្យមើលពីឆ្នាំ ២០០៤–២០១១។ លទ្ធផលនៃការវិភាគបានបង្ហាញឲ្យឃើញថា ចលនាប្រជាពលរដ្ឋមកទីក្រុងបានកាត់បន្ថយភាពក្រីក្រតែ ០,៥ ភាគរយ ប៉ុណ្ណោះ។

## ចំណាយលើការប្រើប្រាស់

**ដើម្បីវាស់វែងការកាត់បន្ថយភាពក្រីក្រ គេត្រូវវាស់វែងបម្រែបម្រួលនៃចំណាយក្នុងការប្រើប្រាស់របស់ប្រជាពលរដ្ឋម្នាក់ៗ។** ការប៉ាន់ស្មានពីការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាបានបង្ហាញឲ្យឃើញថា ចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗដែលរស់នៅតាមទីជនបទជាមធ្យមបានកើនពី ៥.៦៤១ រៀលក្នុងឆ្នាំ២០០៤ មក ៦.៨៧៥ រៀល នៅឆ្នាំ ២០០៧ បានកើនឡើងប្រមាណ ៤ ភាគរយ ក្នុងអំឡុង ៥ ឆ្នាំ ឬ ១,៣ ភាគរយប៉ុណ្ណោះក្នុងមួយឆ្នាំៗ។ បើប្រៀបធៀបទៅនឹងតំបន់ពីរផ្សេងទៀត ការចំណាយរបស់ពួកគេ នៅតំបន់ជនបទមានកម្រិតទាបជាងប្រជាពលរដ្ឋដែលរស់នៅទីក្រុងភ្នំពេញ និងតំបន់ទីប្រជុំជនដទៃទៀត។ នៅភ្នំពេញ ចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋម្នាក់ៗ គិតជាមធ្យមបានកើនឡើងជាង ៤០ ភាគរយ ពីឆ្នាំ ២០០៤-២០០៧ ពី ១១.៣៣០ រៀល ទៅ ១៥.៨៨១ រៀល។ នៅតាមទីប្រជុំជនដទៃទៀត ការចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋបានកើនឡើង ២៤ ភាគរយ ពីឆ្នាំ ២០០៤-២០០៧ ពី ៨.១៨៣ ទៅ ១០.១៦៣។

**គិតមកត្រឹមឆ្នាំ២០០៩ ចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋម្នាក់ ដែលរស់នៅតាមទីជនបទគិតជាមធ្យមបានកើនឡើងយ៉ាងខ្លាំង គឺកើនដល់ ៨.១៨៣ រៀល។ បើគិតជាភាគរយវិញ កំណើននេះស្មើនឹង ៣៩ ភាគរយ ក្នុងរយៈពេលពីរឆ្នាំ ឬក៏ ១៩,៥ ភាគរយ ក្នុងមួយឆ្នាំៗ។** កំណើននេះមានភាពអស្ចារ្យណាស់បើធៀបនឹងកំណើននៃការចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដែលរស់នៅទីក្រុងភ្នំពេញនិងរស់នៅទីប្រជុំជនដទៃទៀត។ ក្នុងអំឡុងពេលដូចគ្នានេះនៅភ្នំពេញគេឃើញមានកំណើនតែមួយភាគរយប៉ុណ្ណោះ ក្នុងរយៈពេលពីរឆ្នាំ ចំណែកឯនៅទីប្រជុំជនផ្សេងទៀត កំណើនមានច្រើនគឺ ២៥ ភាគរយ នៅរយៈពេលពីរឆ្នាំឬ ១២,៥ ភាគរយ ក្នុងមួយឆ្នាំៗ។

បើគិតត្រឹមឆ្នាំ ២០១១ ចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋរស់នៅតាមទីជនបទ គិតជាមធ្យមបានធ្លាក់ចុះមកត្រឹម ៨.៨១៥ រៀល គឺធ្លាក់ប្រមាណ ៦ ភាគរយក្នុងរយៈពេលពីរឆ្នាំ ឬក៏បីភាគរយក្នុងមួយឆ្នាំៗ។ ទោះបីជាការចំណាយជាមធ្យមមានការធ្លាក់ចុះយ៉ាងណាក៏ដោយ ក៏អត្រាភាពក្រីក្រនៅទីជនបទអាចធ្លាក់ចុះបានដែរ ពីព្រោះគេឃើញប្រជាពលរដ្ឋក្រីក្របានបង្កើនចំណាយរបស់ខ្លួន។ (**ក្រាហ្វិក ២១**)

## ស្ថានភាពលំនៅដ្ឋាន និងរបស់របរនៅតាមទីជនបទ

**ការប្រែប្រួលជីវភាពនៅតាមទីជនបទមិនត្រឹមតែឆ្លុះបង្ហាញតាមរយៈកំណើននៃការចំណាយលើការប្រើប្រាស់**

**ក្រាហ្វិក ២១៖** ចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃរបស់ពលរដ្ឋម្នាក់ៗ នៅតំបន់សំខាន់ៗបី ឆ្នាំ ២០០៤–២០១១




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

**ប៉ុណ្ណោះទេ ប៉ុន្តែគេក៏ឃើញមានការកែលម្អស្ថានភាពលំនៅដ្ឋាន ហើយប្រជាពលរដ្ឋមានរបស់របរប្រើប្រាស់ក្នុងផ្ទះកាន់តែច្រើន។** ការប៉ាន់ស្មានពីស្ថានភាពលំនៅដ្ឋានដោយប្រើព័ត៌មានពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាបានបង្ហាញថា អត្រាគ្រួសារប្រជាពលរដ្ឋនៅតាមទីជនបទដែលផ្ទះដំបូលប្រក់ស្លឹកបានថយចុះពី ២៤ ភាគរយ ក្នុងឆ្នាំ ២០០៤មកត្រឹម ១៤ ភាគរយ នៅឆ្នាំ ២០១១។ប្រជាពលរដ្ឋនៅតាមទីជនបទភាគច្រើន បច្ចុប្បន្ននេះមានផ្ទះ ដែលមានដំបូលរឹងមាំប្រក់ស័ង្កសី ឬ ហ្វីប្រូស៊ីម៉ង់ ឬ ដំបូលបេតុង។ ចំនួនគ្រួសារដែលមានផ្ទះប្រក់ដំបូលស័ង្កសីបានកើនឡើងពី ៣១ ភាគរយក្នុងឆ្នាំ ២០០៤ ទៅ ១០ ភាគរយ នៅឆ្នាំ ២០១១។

**គេសង្កេតឃើញថា ប្រជាពលរដ្ឋនៅជនបទមានរបស់របរប្រើប្រាស់ដូចជាទូរទស្សន៍ ទូរស័ព្ទចល័ត និងម៉ូតូកើនឡើងគួរឲ្យកត់សម្គាល់។** នៅឆ្នាំ ២០១១ ៦១ភាគរយនៃគ្រួសារនៅទីជនបទបានរាយការណ៍ថា ពួកគេមានទូរទស្សន៍មួយគ្រឿង ៨៥ភាគរយ បានរាយការណ៍ថាមានទូរស័ព្ទយ៉ាងតិចមួយគ្រឿង ៦៤ ភាគរយរាយការណ៍ថាពួកគេមានម៉ូតូមួយគ្រឿង។ បើធៀបនឹងឆ្នាំ ២០០៤ គេឃើញថា គ្រួសារដែលមានទូរទស្សន៍ មានកំណើន ១៦ ភាគរយ គ្រួសារដែលមានទូរស័ព្ទចល័ត មានចំនួន ៧៧ ភាគរយ ហើយគ្រួសារដែលមានម៉ូតូ មានកំណើន ៣៧ ភាគរយ។ តួលេខនេះបង្ហាញឲ្យឃើញថាប្រជាពលរដ្ឋនៅតាមទីជនបទមានរបស់របរប្រើប្រាស់ក្នុងផ្ទះកើនឡើងយ៉ាងសម្បើម ហើយនេះបញ្ជាក់ឲ្យឃើញថា ជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជាមានការប្រែប្រួលយ៉ាងខ្លាំង។

## ចំណូលរបស់ប្រជាពលរដ្ឋ

នៅតាមទីជនបទរបស់កម្ពុជា មានការប្រែប្រួលជីវភាព និងភាពក្រីក្រអាចពន្យល់បានដោយពិនិត្យលើចំណូលរបស់គ្រួសារនីមួយៗ និងប្រភពចំណូលរបស់ពួកគាត់។ វិធីសាស្ត្រម្យ៉ាងទៀតដើម្បីវាស់វែងកម្រិតជីវភាពប្រជាពលរដ្ឋ គេត្រូវពិនិត្យលើចំណូលសរុប និងប្រភពចំណូលផ្សេងៗរបស់គ្រួសារនីមួយៗ។ ជាធម្មតាក្រុមគ្រួសារនៅតាមទីជនបទប្រកបរបរចិញ្ចឹមជីវិតពីប្រភពជាច្រើនដែលអាចឲ្យយើងកំណត់ថាតើប្រភពចំណូលមួយណាដែលគាត់ប្រើប្រាស់សម្រាប់ទប់ទល់ការចំណាយរបស់ពួកគាត់។ ជាទូទៅចំណូលមិនមានលំអានដូចគ្នាបេះបិទនឹងការចំណាយទេ។ ការប៉ាន់ស្មានចំណូលនៅកម្ពុជាដោយប្រែប្រួលព័ត៌មានអង្កេតសេដ្ឋកិច្ចសង្គមកិច្ចបានបង្ហាញឲ្យឃើញថា លំអានចំណូល និងចំណាយមានលក្ខណៈស្រដៀងគ្នា។ ចំណូលប្រចាំថ្ងៃសម្រាប់ប្រជាពលរដ្ឋម្នាក់ៗដែលរស់នៅទីជនបទដែលគិតជាមធ្យមបានកើនឡើង ៤.១០០ រៀល នៅឆ្នាំ២០០៤ ទៅ ៥.៨៨៤ រៀល នៅឆ្នាំ ២០០៩ គឺកើនឡើង ៨៤ ភាគរយ ក្នុងរយៈពេលប្រាំឆ្នាំ ឬ ៨,៧ ភាគរយ ក្នុងមួយឆ្នាំៗ។ បើគិតត្រឹមឆ្នាំ ២០១១ ចំណូលប្រចាំថ្ងៃបន្តកើនឡើងដល់ ៦.១៤៤ រៀល ហើយបើគិតជាកំណើនមានបួនភាគរយក្នុងរយៈពេលពីរឆ្នាំ។

## ចំណូលដែលមានប្រភពពីកសិផល

**ចំណូលដែលបានមកពីផលិតផលកសិកម្ម ជាប្រភពដ៏សំខាន់មួយ ដែលបានបង្កើនចំណូលគ្រួសារ នៅតាមទីជនបទ។** នេះដោយសារតែសកម្មភាពសេដ្ឋកិច្ច និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋភាគច្រើននៅតាមតំបន់ទីជនបទ គឺពឹងផ្អែកយ៉ាងខ្លាំង ទៅលើការងារកសិកម្ម។ ការគណនារបស់យើង ដោយប្រើព័ត៌មាន អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាបានបង្ហាញឲ្យឃើញថា ចំណូលប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដែលរស់នៅតាមទីជនបទពីកសិផលបានកើនឡើងទ្វេដង ក្នុងរយៈពេលប្រាំឆ្នាំ គឺកើនឡើង ៥០៧ រៀល ទៅ ១.០១១ រៀល នៅឆ្នាំ ២០០៧។ បើគិតជាភាគរយវិញ កំណើនពីឆ្នាំ ២០០៤–២០០៩ នេះគឺ ១,៧ ភាគរយ ក្នុងរយៈពេលប្រាំឆ្នាំឬ២៣ ភាគរយ ក្នុងរយៈពេលមួយឆ្នាំៗ ចាប់ផ្តើមពីឆ្នាំ ២០០៩ មក ចំនួនប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅតាមទីជនបទ ដែលមានប្រភពកសិផលនៅតែបន្តឡើងប្រមាណ ១២ ភាគរយ គឺ ១.២៣២ រៀល នៅឆ្នាំ២០១១។ (**ប្រអប់ ២**)

**ការកើនឡើងនៃចំណូលពីកសិផលភាគច្រើនបានពីស្រូវអង្ករ។** កម្ពុជាជាប្រទេសដែលនាំស្រូវអង្ករចេញ ហើយដំណាំស្រូវគ្របដណ្តប់ ៨៤ ភាគរយ នៃផ្ទៃដីដាំដុះសរុបដែលមានប្រមាណបីលានហិកតា។ ក្នុងចំណោម

ប្រជាពលរដ្ឋទាំងអស់ដែលរស់នៅទីជនបទប្រមាណ ៨៥ ភាគរយជាកសិករ។ ដោយសារតែដំណាំស្រូវគ្របដណ្តប់លើសលុបនេះហើយ ទើបគេប៉ាន់ស្មានថា បច្ចុប្បន្នកម្ពុជាមានស្រូវនៅសល់ពីបីទៅបួនលានតោនក្នុងមួយឆ្នាំៗ (បើគិតជាអង្ករវិញមានប្រមាណ ១,៥ លានតោន ទៅ ២,៥ លានតោន)។ មុនឆ្នាំ ២០០៨ គេប៉ាន់ស្មានថា ទំហំស្រូវអង្ករនៅកម្ពុជាមានប្រមាណពីរលានតោនក្នុងមួយឆ្នាំៗ (ប្រហែល ២ លានតោន នៅឆ្នាំ២០០៥, ២,៥លានតោន នៅឆ្នាំ ២០០៦ និង ២,៦ លានតោន នៅឆ្នាំ ២០០៧)។ ស្រូវតម្លៃជាមធ្យម ២៥០ ដុល្លារអាមេរិក ក្នុងមួយតោនដូចនេះស្រូវដែលកម្ពុជានៅសល់ បើគិតជាប្រាក់វិញ តម្លៃប្រមាណពី ៧៥០ លានដុល្លារ ទៅ ១.០០០ លានដុល្លារ សម្រាប់សេដ្ឋកិច្ចជនបទ ចាប់ពីឆ្នាំ ២០០៨ មក។ (**តារាង ១៥ និង ១៦**)

**ក្នុងចំណោមប្រជាពលរដ្ឋទាំងអស់នៅជនបទ ៣៧ ភាគរយ ជាអ្នកដែលមានស្រូវនៅសល់១៧-៤១ភាគរយ ជាអ្នកខ្វះស្រូវអង្ករ ហើយអ្នកផ្សេងៗទៀត មានស្រូវអង្ករសម្រាប់ហូបគ្រប់គ្រាន់តែប៉ុណ្ណោះ។** ដើម្បីឲ្យបានតួលេខនេះ គេគណនាបរិមាណទិន្នផលស្រូវសរុប ដែលគ្រួសារនីមួយៗបានផលិត និង បរិមាណសរុបដែលគាត់បានប្រើប្រាស់។ ការគណនាបានបង្ហាញថា ប្រសិនបើគ្រួសារមួយមានគ្នាប្រាំនាក់ ដើម្បីឲ្យសមាជិកគ្រួសារបានហូបគ្រប់ គេត្រូវការអង្ករ ប្រហែល ៧០៩ គីឡូក្រាម ឬ បើគិតជាស្រូវវិញ ១,៤ តោន (ការគណនានេះប្រភពព័ត៌មានពីការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ២០០៩)។ ដូចនេះ ដើម្បីឲ្យបានទិន្នផលសម្រាប់ហូបគ្រប់គ្រួសារដែលមានសមាជិកប្រាំនាក់នេះ ត្រូវតែមានដីស្រែទំហំយ៉ាងតិច០,៥ ហិកតា ហើយទិន្នផលវិញត្រូវតែបានយ៉ាងតិច ២,៧ តោនក្នុងមួយហិកតា។ ប៉ុន្តែ ដើម្បីបំពេញតម្រូវការសរុបទាំងអស់ ដែលរួមមានតម្រូវការសម្រាប់សមាជិកគ្រួសារតម្រូវការសម្រាប់ចំណីសត្វតម្រូវការសម្រាប់ទុកធ្វើពូជ និងការបាត់បង់ផ្សេងៗ គ្រួសារនោះត្រូវតែមានដីស្រែយ៉ាងតិចចន្លោះពី ០,៥ ទៅ ១ ហិកតា។

ការវិភាគដោយប្រើព័ត៌មានពីការអង្កេតសេដ្ឋកិច្ច

## ប្រអប់ ២៖ ប្រាក់ចំណូលរបស់គ្រួសារ ធៀបនឹងការចំណាយរបស់គ្រួសារ

នៅតាមបណ្តា ប្រទេសកំពុងអភិវឌ្ឍន៍ រាប់ទាំងកម្ពុជាដែរ វាជារឿងធម្មតាទេ ដែលរាល់ការអង្កេតនានាបង្ហាញថា កម្រិតចំណូលរបស់ប្រជាពលរដ្ឋទាបជាងកម្រិតចំណាយរបស់ពួកគាត់។ បញ្ហានេះ ដោយសារតែហេតុផលមួយចំនួនមានដូចជា

ចំណូលនិងចំណាយប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់ៗ ឆ្នាំ២០០៤-២០១១




**ប្រភព៖** CDRI (២០១៣) ដោយយោងតាមអ.ស.ស.ក និងសូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

ហេតុផលទីមួយមួយភាគធំលើការប្រើប្រាស់របស់ប្រជាពលរដ្ឋពិសេសពាក់ព័ន្ធនឹងម្ហូបអាហារបានពីការផលិតផ្ទាល់ខ្លួនរបស់ពួកគេឬបានមកពីដោះដូរឬ អំណោយផ្សេងៗ។ ហេតុផលទីពីរ ប្រជាពលរដ្ឋភាគច្រើននៅតាមទីជនបទប្រកបរបរដោយខ្លួនឯងធ្វើស្រែចម្ការឬរកស៊ីតូចតាចហើយពួកគេភាគច្រើនមិនមានចំណូលទៀងទាត់ទេ ចំណែកឯបញ្ជីស្មាមទាក់ទងនឹងចំណូលនោះក៏ពុំមានគ្រប់គ្រាន់ដែរ។ មូលហេតុទីបី ប្រជាពលរដ្ឋមិន ហ៊ានរាយការណ៍ពិត ពីចំណូលរបស់ខ្លួន ដោយសារបារម្ភពីសុវត្ថិភាព។ ដូចនេះ បើយើងចង់ប្រៀបធៀបចំណូល និងចំណាយ យើងត្រូវប្រយ័ត្នប្រយែងបំផុត។ ចំណូលជាទូទៅឡើងចុះយ៉ាងខ្លាំង សូម្បីតែក្នុងរយៈពេលខ្លីក៏ដោយ ដូចនេះ ដើម្បីឲ្យការរៀបចំឲ្យបានត្រឹមត្រូវ គេត្រូវប្រៀបគ្នាក្នុងរយៈពេលវែងមួយ។ របាយការណ៍នេះប្រៀបធៀបចំណូលនិងចំណាយសម្រាប់អំឡុងពេល ២០០៤-២០០៩ និង ២០០៩-២០១១។

**តារាង ១៥៖** សមាសភាពនិងបម្រែបម្រួលចំណូល

| | ចំណូល(រៀល/ថ្ងៃ) | | | % បម្រែបម្រួល | |
|---|---|---|---|---|---|
| | ២០០៤ | ២០០៩ | ២០១១ | ០៤-'០៩ | ០៩-'១១ |
| លក់កម្លាំងពលកម្ម | ៩១៨ | ១.៣៥៥ | ១.៨៣៥ | ៤៨% | ៣៥% |
| កសិផល | ៥០៧ | ១.១០១ | ១.២៣២ | ១១៧% | ១២% |
| ចិញ្ចឹមសត្វ | ៣៧៧ | ២៩៥ | ៣១៧ | -២២% | ៨% |
| នេសាទ | ២០១ | ២១៩ | ១៥១ | ៩% | -៣១% |
| រុក្ខនិងប្រមាញ់ | ២៨៦ | ៣១៩ | ៣២៤ | ១២% | ២% |
| ជំនួញបន្តិចបន្តួច | ៨៥៦ | ១.៣៩៨ | ១.២១១ | ៦៣% | -១៣% |
| ការឧបត្ថម្ភ | ៩៥៧ | ១.១៩៧ | ១.០៧៣ | ២៥% | -១០% |
| **សរុប** | **៤.១០០** | **៥.៨៨៤** | **៦.១៤៤** | **៤៤%** | **៤%** |

**ប្រភព៖** វិទ្យាស្ថាន CDRI (២០១៣) យោងតាមអ.ស.ស.ក។

**តារាង ១៦៖** ទំហំដីកសិកម្ម ( ភាគរយនៃគ្រួសារជនបទ)

| ហិកតា | CDRI ២០០២ | អ.ស.ស.ក (CSES) | | |
|---|---|---|---|---|
| | | ២០០៤ | ២០០៩ | ២០១១ |
| ពុំមាន | ២០ | ២១ | ១៧ | ១៦ |
| ០,០១-០,៥ | ២៥ | ២៥ | ២៤ | ២៦ |
| ០,៥១-១,០ | ២០ | ២១ | ២១ | ២២ |
| > ១,០ | ៣៥ | ៣៣ | ៣៧ | ៣៦ |
| ១,០១- ១,៥ | - | ១១ | ១១ | ១១ |
| ១,៥១-២,០ | - | ៨ | ៩ | ៩ |
| > ២,០ | - | ១៣ | ១៧ | ១៦ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |

**ប្រភព៖** ហេមម័រនិងអ្នកនិពន្ធដទៃទៀត(២០០៤)និ ងសូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

សង្គមកិច្ចកម្ពុជាឆ្នាំ២០០៩ បានរកឃើញថា ប្រជាពលរដ្ឋប្រមាណ ៣៧ ភាគរយ បានដាំដុះលើផ្ទៃដីទំហំធំជាងមួយហិកតា ដូចនេះពួកគេសុទ្ធតែមានស្រូវអង្ករនៅសល់។ ប្រជាពលរដ្ឋប្រហែល ២១ ភាគរយដាំដុះលើផ្ទៃដីទំហំពី ០,៥១–១ ហិកតា។ ផ្ទៃដីទំហំនេះផ្តល់ទិន្នផលស្រូវអង្ករសម្រាប់ប្រើប្រាស់បានគ្រប់គ្រាន់ប៉ុណ្ណោះ មិនមាននៅសល់ទេ។ ចំណែកក្រុមគ្រួសារដែលជាអ្នកទិញស្រូវអង្ករមានពីមាន ១៧–៤១ ភាគរយ ដែលក្នុងនោះ មាន ១៧ ភាគរយមិនមានដីកសិកម្មទាល់តែសោះ ហើយ២៤ ភាគរយទៀតមានដីកសិកម្មតិចជាងកន្លះហិកតា។ ដូច្នោះហើយ ការកើនឡើងនៃតម្លៃស្រូវអង្ករបានផ្តល់ផលប្រយោជន៍ទៅដល់ប្រជាពលរដ្ឋប្រមាណជាង ១/៣ នៅតាមទីជនបទ ហើយប្រជាពលរដ្ឋប្រមាណ ១/៣ ទៀត មិនបានរងផលប៉ះពាល់ទេ។ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់មានប្រមាណ ១/៣ ដែលមិនមានដីកសិកម្ម ឬក៏មានដីតិចជាង ០,៥ ហិកតា។

**ចំណូលដែលបានពីស្រូវអង្ករ បានមកពីការឡើងថ្លៃនៃតម្លៃស្រូវអង្ករ និង ទិន្នផលខ្ពស់ជាងមុន។** ទោះបីកម្ពុជាបានពង្រីកផ្ទៃដីដាំដុះពី ២,៣ លានហិកតា នៅឆ្នាំ ២០០៤ ដល់ ២,៦លានហិកតា នៅឆ្នាំ២០០៧ និងដល់ ៣ លានហិកតា នៅឆ្នាំ២០១១ ក៏ដោយ ក៏គេសង្កេតឃើញថា ទំហំដីជាមធ្យមរបស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទក្នុងមួយគ្រួសារមិនមានភាពប្រែប្រួលធំដុំទេ (ផ្ទៃដីនេះគិតទាំងការដាំដុះស្រូវប្រាំង និងវស្សា។ ផ្ទៃដីដែលពង្រីកបានមកពីផ្ទៃដីព្រៃរិចរិល និងផ្ទៃដីដែលដោះមីនហើយ)។ មូលហេតុមួយផ្នែកដោយសារចំនួនគ្រួសាររបស់ប្រជាពលរដ្ឋមានការកើនឡើង (ឧទាហរណ៍៖ បន្ទាប់ពីរៀបការរួច មានការកកើតគ្រួសារថ្មីៗ) មួយផ្នែកទៀតដោយសារតែកំណើនកសិដ្ឋានខ្នាតធំៗរបស់ក្រុមហ៊ុន។ ជាមធ្យម ប្រជាពលរដ្ឋមានដីទំហំប្រហែល ១,២–១,៤ ហិកតា។ (**ក្រាហ្វិក ២២**)

**ក៏ប៉ុន្តែ ការកើនឡើងនៃតម្លៃស្រូវអង្ករបានជួយឲ្យកសិករកើនចំណូលគួរឲ្យកត់សម្គាល់។** ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩ តម្លៃអង្ករនៅលើទីផ្សារអន្តរជាតិបានកើនឡើង ១៣៤ ភាគរយ នៅទីផ្សារថៃ និង ៨៨ ភាគរយ នៅទីផ្សារវៀតណាម។ ចំណែកឯតម្លៃអង្ករក្នុងស្រុកនៅតាមទីផ្សារនាទីក្រុងភ្នំពេញវិញ បានកើនឡើង ១១៩ ភាគរយ អំឡុងពេលដូចគ្នានេះ។ ការដាំដុះស្រូវភាគច្រើននៅកម្ពុជាប្រើតែកម្លាំងពលកម្ម ដូចនេះហើយ ការកើនឡើងនូវតម្លៃជី និងប្រេងឥន្ធនៈស្របពេលមានការកើនឡើងតម្លៃអង្ករបានផលប៉ះពាល់តិចតួចណាស់ដល់ប្រាក់ចំណេញរបស់កសិករ។ កសិករកម្ពុជាចាប់ផ្តើមទទួលបានផលចំណេញពីការកើនឡើងយ៉ាងខ្លាំងនៃតម្លៃស្រូវអង្ករចាប់តាំងពីដើមឆ្នាំ ២០០៨ ឯណោះ ពីព្រោះតែពួកគាត់ប្រមូលផលស្រូវឆ្នាំ ២០០៧ នៅចុងឆ្នាំ ២០០៧ និងដើមឆ្នាំ ២០០៨។ ការកើនឡើងនៃទិន្នផលបានរួមចំណែកបង្កើនចំណូលរបស់កសិករដែរ។ សម្រាប់ស្រូវរដូវវស្សា គេឃើញទិន្នផលជាមធ្យមបានកើនឡើងពី ១,៧ តោនក្នុងមួយហិកតានៅឆ្នាំ ២០០៤ ដល់ ២,៦ តោនក្នុងមួយហិកតាឆ្នាំ ២០០៩ បានកើនឡើងប្រមាណជា ៥២ភាគរយ។ សម្រាប់ស្រូវរដូវប្រាំង ទិន្នផលគិតជាមធ្យមបានកើនឡើងពី៣,៥តោនក្នុងមួយហិកតានៅឆ្នាំ២០០៤ ទៅ ៥ តោនក្នុងមួយហិកតា នៅឆ្នាំ ២០០៩ គឺកើនឡើង ៤៤ ភាគរយ។ (**ប្រអប់ ៣**)

**ក្រាហ្វិក ២២៖ ទិន្នផលស្រូវជាមធ្យមក្នុងមួយហិកតា**




**ប្រភព៖** របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ចំណូលដែលមានប្រភពពី ការលក់កម្លាំងពលកម្ម

**ការលក់កម្លាំងពលកម្មជាប្រភពចំណូលសំខាន់ទីពីរដែលបានបង្កើនចំណូលរបស់គ្រួសារ។** កំណើនប្រាក់ចំណូលពីការលក់កម្លាំងពលកម្ម ដោយសារតែក្នុងគ្រួសារនីមួយៗ ជាមធ្យមមានសមាជិកពេញកម្លាំងធ្វើការច្រើនជាងមុន, ធ្វើការច្រើនម៉ោងជាងមុន, ហើយប្រាក់ឈ្នួលក៏បានច្រើនជាងមុនដែរ។ ប្រាក់ចំណូលប្រចាំថ្ងៃពីការលក់កម្លាំងពលកម្មក្នុងប្រជាពលរដ្ឋម្នាក់បានកើនឡើង ៤៨ ភាគរយ ក្នុងរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩ ឬក៏ ៩,៥ ភាគរយក្នុងមួយឆ្នាំៗ។ កម្រិតចំណូលនេះបានកើនឡើងពី ៩១៨ រៀល ក្នុងមួយថ្ងៃ ទៅ ១.៣៥៥ រៀលក្នុងមួយថ្ងៃ ហើយបន្តកើនឡើងរហូតដល់ ១.៨៣៥ រៀលក្នុងមួយថ្ងៃនៅឆ្នាំ ២០១១។ ប្រជាពលរដ្ឋនៅតាមទីជនបទឥឡូវនេះធ្វើការច្រើនម៉ោងជាងពេលមុន ហើយប្រកបមុខរបរច្រើនជាងមួយ។ ចំណូលអំពីការលក់កម្លាំងពលកម្មរបស់ក្រុមប្រជាពលរដ្ឋ ដែលស្ថិតនៅក្នុងបញ្ចភាគ ២០ ភាគរយ ក្រោមគេ កើនឡើង ៦៩ ភាគរយ ដែលក្នុងនោះ ៥៤ ភាគរយបានមកពីកំណើនសមាជិកពេញវ័យចូលទីផ្សារការងារ, ៩ ភាគរយបានមកពីធ្វើការច្រើនម៉ោងជាងមុន, និង ៦ ភាគរយដែលនៅសល់បានមកពីកត្តាផ្សេងៗដូចជា ទំហំគ្រួសារ ថ្លៃឈ្នួល និង អន្តរកម្មរវាងកត្តាទាំងអស់នេះ។ (**ក្រាហ្វិក ២៣**)

**ប្រអប់ ៣៖** រឿងរ៉ាវចំនួនពីរ ដែលកើតមានឡើងនៅទីជនបទដោយសារឥទ្ធិពលនៃតម្លៃស្រូវខ្ពស់

**តម្លៃស្រូវខ្ពស់បានជួយឲ្យខេត្តបាត់ដំបងមានឈ្មោះឡើងវិញថា ជាជង្រុកស្រូវរបស់កម្ពុជា។**

មុនឆ្នាំ ១៩៧០ ខេត្តបាត់ដំបងត្រូវបានគេទទួលស្គាល់ថាជាជង្រុកស្រូវរបស់កម្ពុជា។ ក៏ប៉ុន្តែ បន្ទាប់ពីរបបខ្មែរក្រហមបានរលំរលាយនៅឆ្នាំ១៩៧៩ សង្គ្រាមស៊ីវិលក្នុងខេត្តនេះបានបន្តនៅទសវត្សរ៍ ទី៨០ និង ៩០ទៀត ដែលប្រការនេះបានរារាំងខេត្តបាត់ដំបងមិនឲ្យប្រែក្លាយជាខេត្តដែលមានតួនាទីសំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជា ហើយខេត្តដែលមកជំនួសខេត្តបាត់ដំបង គឺខេត្តកំពង់ចាម។ ខេត្តកំពង់ចាមមានតួនាទីសំខាន់ក្នុងសម័យនោះ ដោយសារតែខេត្តនេះជាច្រកពាណិជ្ជកម្មដ៏ធំជាមួយប្រទេសវៀតណាម។

ក្នុងដំណើរទស្សនកិច្ចទៅខេត្តបាត់ដំបងពីឆ្នាំ ២០០៣ ដល់ ២០០៥ គេសង្កេតឃើញថា ក្រុងនេះមានភាពស្ងប់ស្ងាត់ណាស់ មានសុទ្ធតែអគារដែលសល់ពីសម័យអាណានិគមន៍បារាំង។ ប៉ុន្តែស្ថានភាពបានប្រែប្រួលបន្ទាប់ពីតម្លៃស្រូវអង្ករចាប់ផ្តើមឡើងថ្លៃចាប់ពីឆ្នាំ២០០៧មក បន្ទាប់មកទៀតបានឡើងថ្លៃទ្វេដងនៅឆ្នាំ ២០០៨។ សមាគមរោងម៉ាស៊ីនកិនស្រូវកម្ពុជា និងពាណិជ្ជករវៀតណាមបានប្រកួតប្រជែងគ្នាយ៉ាងខ្លាំងជាមួយពាណិជ្ជករស្រូវថៃ ដើម្បីប្រជែងគ្នាទិញស្រូវពីកសិករនៅខេត្តបាត់ដំបង។ អាស្រ័យហេតុនេះ ទើបកសិករនៅខេត្តបាត់ដំបងជាច្រើនបានទទួលផលប្រយោជន៍ពីការប្រកួតប្រជែងនេះ ហើយឥឡូវនេះ ពួកគាត់មានស្ថានភាពធូរជារមួយកម្រិតធំ។ ឥឡូវនេះ កសិករបានប្តូរទម្លាប់ពីរបរកសិកម្មតែមួយគ្រប់ៗមក របរកសិកម្មដើម្បីលក់ដូរ។

**នៅខេត្តកណ្តាល តម្លៃស្រូវអង្ករខ្ពស់ និង ហេដ្ឋារចនាសម្ព័ន្ធល្អ បានជំរុញឲ្យប្រជាពលរដ្ឋវិនិយោគលើស្រែរបស់ពួកគេ។**

រឿងនេះកើតមានឡើងនៅឃុំរការជាន់ឈើ្លង ក្នុងខេត្តកណ្តាល។ មុនឆ្នាំ ២០១១ ដើម្បីឲ្យទៅដល់ឃុំនេះ គេចាំបាច់ត្រូវជិះទូកដរឆ្លងកាត់ទន្លេមេគង្គ ហើយចំណាយសោហ៊ុយថ្លៃណាស់។ ការឆ្លងមួយដងៗ អស់ប្រាក់ជាងមួយដុល្លារអាមេរិក (ឬជិត ៥.០០០ រៀល) ហើយត្រូវចំណាយពេល អស់ជាង មួយម៉ោង។ នៅឆ្នាំ ២០១១ បន្ទាប់ពីរាជរដ្ឋាភិបាលសាងសង់ស្ពានថ្មីមួយសម្រាប់ឆ្លងកាត់ទន្លេនេះ ការធ្វើដំណើរមានភាពងាយស្រួលជាងមុនច្រើន លឿនជាងមុនយ៉ាងច្រើន ហើយអស់សោហ៊ុយតិចជាងមុន យ៉ាងច្រើនទៀតផង។ លើសពីនេះ ទៀត ប្រព័ន្ធផ្លូវថ្នល់ត្រូវបានស្តារឡើងវិញនៅក្នុងឃុំ និងក្រៅឃុំដូចជា ការស្តារឡើងវិញនូវផ្លូវជាតិលេខ៨ និង ការកសាងផ្លូវថ្មីៗ នៅក្នុងឃុំ បានជួយសម្រួលដល់ការធ្វើដំណើរយ៉ាងច្រើន។

មុនពេលតម្លៃស្រូវមិនទាន់ឡើងតម្លៃទ្វេដង កសិករប្រើបច្ចេកទេសបុរាណ ហើយមិនបានស្វែងរកសេវាកម្មផ្នែកបច្ចេកទេសថ្មីៗអ្វីឡើយ។ ប៉ុន្តែ នៅពេលដែលតម្លៃស្រូវកាន់តែខ្ពស់នោះ ពួកគាត់បានចាប់ផ្តើមប្រកួតប្រជែងគ្នា ដើម្បីបូមទឹក ស្វែងរកបច្ចេកទេសកសិកម្មផ្សេងៗ និងខិតខំយ៉ាងខ្លាំង ដើម្បីឲ្យទិន្នផលរបស់ពួកគាត់កើនទ្វេដង ពួកគាត់ក៏បានប្រើពូជស្រូវដែលគេនិយមនៅលើទីផ្សារ។

**ប្រភព៖** សម្រង់មតិរបស់ឯកឧត្តម ហង់ ជួនណារ៉ុន ក្នុងកិច្ចប្រជុំពិនិត្យសម្រេចរបាយការណ៍វាយតម្លៃភាពក្រីក្រនៅកម្ពុជាឆ្នាំ២០១៣កាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣។

អត្រាថ្លៃឈ្នួលពលកម្មនៅតាមជនបទបានកើនឡើង **ជាងពីរដង ពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០១២។** ក្នុងនោះពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០០៨ អត្រាថ្លៃឈ្នួលពលកម្មបានកើនឡើងយ៉ាងគំហុក មានករណីខ្លះ ការកើនឡើងខ្ពស់ជាងអត្រាអតិផរណាទៅទៀត។ អត្រាអតិផរណានៅតាមទីជនបទកើនឡើងប្រមាណ ៥៧ ភាគរយ ពីឆ្នាំ២០០៧ ដល់២០០៨។ កត្តានេះបានជួយឲ្យប្រជាពលរដ្ឋជាច្រើន ជាពិសេសប្រជាពលរដ្ឋដែលពុំមានដីធ្វើកសិកម្មអាចទប់ទល់នឹងការកើនឡើងនូវតម្លៃម្ហូបអាហារ ដែលបានកើនឡើងយ៉ាងលឿនដែរ។ ការវិភាគដោយប្រើព័ត៌មានពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាបានបង្ហាញថា អត្រាថ្លៃឈ្នួលប្រចាំថ្ងៃសម្រាប់ការងារផ្សេងៗនៅទីជនបទបានកើនឡើងភ្លាមៗ ហើយការកើនឡើងនេះមានចំពោះកម្មករជាស្ត្រី និងកម្មករជាបុរស។ ពីឆ្នាំ ២០០៧ ដល់ឆ្នាំ២០០៨ អត្រាថ្លៃឈ្នួលរបស់កម្មករជាបុរស សម្រាប់ការងារភ្ជួររាស់បានកើនឡើង ៤៤ ភាគរយ គឺកើនឡើងដល់ ១៨.០០០រៀល ក្នុងមួយថ្ងៃ, ដកស្ទូងកើនឡើង ៤៥ ភាគរយ គឺកើនឡើងដល់ ១០.០០០ រៀល ក្នុងមួយថ្ងៃ, ច្រូតកាត់កើនឡើង ៤១ ភាគរយ គឺកើនឡើងដល់ ១០.០០០ រៀលក្នុងមួយថ្ងៃ, ធ្វើសំណង់កើនឡើង ៣៧ ភាគរយ គឺកើនឡើងដល់ ១០.០០០ រៀល ក្នុងមួយថ្ងៃ។ ចំណែកឯកម្មករជាស្ត្រីវិញ អត្រាប្រាក់ឈ្នួល សម្រាប់ការងារភ្ជួររាស់កើនឡើង ១២០ ភាគរយ គឺកើនឡើងដល់ ៦.០០០ រៀល ក្នុងមួយថ្ងៃ, ដកស្ទូងកើនឡើង ៤១ ភាគរយ គឺកើនឡើងដល់ ១០.០០០ រៀល ក្នុងមួយថ្ងៃ, ច្រូតកាត់កើនឡើង ៤៤ ភាគរយ គឺកើនឡើងដល់ ១០.០០០ រៀល ក្នុងមួយថ្ងៃ, ធ្វើការងារសំណង់កើនឡើង ២៣ ភាគរយ គឺកើនឡើងដល់ ៨.០០០ រៀល ក្នុងមួយថ្ងៃ។

នៅឆ្នាំ២០១២ អត្រាប្រាក់ឈ្នួលប្រចាំថ្ងៃបានបន្តកើនឡើងយ៉ាងគំហុកទៀត ដោយថ្លៃចំណាយសម្រាប់ទ្រទ្រង់ជីវភាពបានកើនឡើង ហើយអត្រាប្រាក់ឈ្នួលរបស់ប្រទេសជិតខាងក៏បានកើនឡើងដែរ។ ឧទាហរណ៍ ប្រាក់ឈ្នួលនៅតាមទីជនបទសម្រាប់ការងារភ្ជួររាស់ កើនឡើងដល់ ២០.០០០ រៀល–២៥.០០០ រៀល ក្នុងមួយថ្ងៃ, ស្ទូងកើនដល់ ១២.០០០–១៥.០០០ រៀល ក្នុងមួយថ្ងៃ និងសំណង់កើនដល់ ២០.០០០–២៥.០០០ រៀល ក្នុងមួយថ្ងៃ។ (**ក្រាហ្វិក ២៤**)

## ចំណូលប្រភពពីការប្រកបមុខរបរដោយខ្លួនឯង

**កត្តាដែលចូលរួមបង្កើនប្រាក់ចំណូលរបស់គ្រួសារប្រជាពលរដ្ឋនៅជនបទទីបី គឺចំណូលដែលមានប្រភពមកពីការប្រកបរបរដោយខ្លួនឯង។** នៅឆ្នាំ២០០៩ ការប្រកបរបរដោយខ្លួនឯងជារបរចម្បង ឬ របរបន្ទាប់បន្សំរបស់គ្រួសារពលរដ្ឋនៅតាមជនបទមានប្រហែលមួយភាគបី។ ការវិភាគព័ត៌មានពីការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាបានបង្ហាញឲ្យដឹងថា ចំណូលប្រចាំថ្ងៃក្នុងមនុស្សម្នាក់ៗពីការប្រកបរបរជំនួញតូចតាចកើនឡើង ៦៣ ភាគរយ ក្នុងរយៈពេល៥ឆ្នាំ ឬ ១២,៧ ភាគរយក្នុងមួយឆ្នាំៗ។ ចំណូលពីប្រភពនេះជាមធ្យមក្នុងមួយថ្ងៃបានកើនឡើងពី ៥៨៦ រៀល នាឆ្នាំ២០០៤ ទៅ ១.៣៩៨ រៀល

**ក្រាហ្វិក ២៣៖** បម្រែបម្រួលថ្លៃឈ្នួលកម្លាំងពលកម្មឆ្នាំ ២០០៧ និង២០០៨




**ប្រភព៖** ណូល (Knowles), ឆ្នាំ២០១០ ដោយយោងតាមអ.ស.ស.ក។

នៅឆ្នាំ២០០៩។ ប៉ុន្តែនៅឆ្នាំ២០១១ ចំណូលដែលមានប្រភពពីផ្នែកនេះបានធ្លាក់ចុះមកត្រឹម ១.១២៤ រៀល ឬស្មើ ១៣ ភាគរយ។

## ចំណូលដែលមានប្រភពពីប្រាក់ឧបត្ថម្ភផ្សេងៗ

**ចំណូលដែលមានប្រភពពីប្រាក់ឧបត្ថម្ភផ្សេងៗជាចំណូលតិចជាងគេបង្អស់ ដែលបានរួមចំណែកក្នុងការបង្កើនចំណូលសរុបរបស់គ្រួសារប្រជាពលរដ្ឋពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩។** បទពិសោធន៍ពីបណ្តាប្រទេសនានាបានបង្ហាញថា រាល់ការសម្ភាសន៍ជាមួយប្រជាពលរដ្ឋនៅតាមទីជនបទ ពួកគេតែងតែរាយការណ៍មិនពិតអំពីប្រាក់ឧបត្ថម្ភពីសាច់ញាតិ។ លើសពីនេះទៀត ការឧបត្ថម្ភផ្សេងៗពីរដ្ឋមិនសូវមានច្រើនទេ ដោយសារកម្ពុជាមិនទាន់មានកម្មវិធីផ្ទេរសាច់ប្រាក់ជួយដល់ជនក្រីក្រនៅឡើយ។ ការប៉ាន់ស្មានដោយប្រើព័ត៌មានអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាបានបង្ហាញថា ចំណូលប្រចាំថ្ងៃក្នុងពលរដ្ឋម្នាក់ៗដែលមានប្រភពពីប្រាក់ឧបត្ថម្ភផ្សេងៗ បានកើនឡើង ២៥ ភាគរយប៉ុណ្ណោះ ក្នុងរយៈពេល ៥ ឆ្នាំ ឬប្រហែល ៥ ភាគរយ ក្នុងមួយឆ្នាំៗ ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩។ កំណើនចំណូលមានប្រភពពីការឧបត្ថម្ភផ្សេងៗកើនឡើងតិចតួចណាស់ បើធៀបទៅនឹងចំណូលពីប្រភពផ្សេងៗទៀតដូចជា ចំណូលពីផលិតផលកសិកម្ម ការលក់កម្លាំងពលកម្ម និងប្រកបរបរជំនួញតូចតាច។

## ទស្សនៈផ្សេងៗរបស់ប្រជាពលរដ្ឋនៅតាមទីជនបទ

**ប្រជាពលរដ្ឋនៅតាមទីជនបទបានគិតថា ពួកគេអាចរកចំណូលពីដីធ្លី និងការលក់កម្លាំងពលកម្មរបស់ពួកគេបានច្រើនជាងនេះទៀត។** ការអង្កេតនៅតាមទីជនបទធ្វើឡើងកាលពីខែតុលា ឆ្នាំ២០១២ ដោយបានសម្ភាសន៍ប្រជាពលរដ្ឋ១.៥៦០ គ្រួសារ ក្នុង ៧៨ ភូមិ នៅ១៤ខេត្តទូទាំងប្រទេសកម្ពុជាបានបង្ហាញថា ជាទូទៅប្រជាពលរដ្ឋមានសុទិដ្ឋិនិយមអំពីការកើនឡើងបន្ថែមទៀតនូវចំណូលពីដីស្រែចម្ការ និង ពលកម្មរបស់ពួកគាត់។ ក្នុងចំណោម ១.៥៣៥ គ្រួសារ (ស្មើនឹង៩៨ភាគរយនៃប្រជាពលរដ្ឋត្រូវបានសម្ភាសន៍ទាំងអស់) ដែលប្រកបរបរកសិកម្មជាចម្បង ៣០ ភាគរយ បានគិតថា ចំណូលដែលបានពីកសិកម្មនឹងកើនឡើងក្នុងរយៈពេលបីឆ្នាំទៅមុខទៀត ពីព្រោះពួកគាត់គិតថា ទិន្នផល និងតម្លៃផលិតផលកសិកម្មនឹងបន្តកើនឡើង។ ចំណែកឯគ្រួសារ ៣៧ ភាគរយទៀតគិតថាចំណូលនេះនឹងនៅដដែល ហើយ ៤១ ភាគរយ ទៀតគិតថា ចំណូលពីប្រភពនេះនឹងធ្លាក់ចុះ។ មូលហេតុដែលពួកគាត់គិតថា ចំណូលនឹងធ្លាក់ចុះ ដោយសារតែបារម្ភអំពីបញ្ហាអាកាសធាតុ និងជំងឺផ្សេងៗដែលអាចយាយីដំណាំរបស់ពួកគាត់។ ម៉្យាងទៀត ការឡើងថ្លៃនៃការចំណាយក្នុងការ

**ក្រាហ្វិក ២៤៖** ការវិភាគពីកត្តាសំខាន់ៗដែលជំរុញឲ្យចំណូលពីលក់កម្លាំងពលកម្មកើនឡើង, កម្ពុជាឆ្នាំ២០០៩




**ប្រភព៖** ណូល (Knowles), ឆ្នាំ២០១០ ដោយយោងតាមអ.ស.ស.ក។

**តារាង ១៧៖** សមត្ថភាពកិនស្រូវ (តោនក្នុងមួយម៉ោង) កម្ពុជា

| | កិន | ប៉ូលា |
|---|---|---|
| ពាក់កណ្តាលឆ្នាំ២០០៩ | ៩៦ | ៧២ |
| ពាក់កណ្តាលឆ្នាំ២០១០ | ២៤៥ | ២០១ |
| ពាក់កណ្តាលឆ្នាំ២០១១ | ៣២២ | ៣០៥ |

**ប្រភព៖** ថម ស្លេតុន និងសុខ មុន្នីរដ្ឋ(២០១២)។

ធ្វើស្រែចម្ការក៏ជាមូលហេតុដែលពួកគាត់មានក្តីបារម្ភដែរ។ ចំនួនគ្រួសារដែលយល់ថា ចំណូលកសិកម្មនឹងកើនឡើងនេះ ហាក់ដូចជាស្របគ្នាទៅនឹងចំនួនគ្រួសារប្រជាពលរដ្ឋដែលមានស្រូវអង្ករនៅសល់និងចំនួនគ្រួសារប្រជាពលរដ្ឋដែលជាអ្នកទិញអង្ករ គឺថាក្រុមគ្រួសារប្រជាពលរដ្ឋ ៣៧ ភាគរយមានស្រូវអង្ករនៅសល់ រីឯ១៧ ភាគរយ ទៅ ៤១ ភាគរយជាអ្នកទិញអង្ករ។

**ចំណែកឯទស្សនៈពាក់ព័ន្ធនឹងប្រាក់ចំណូលពីការលក់កម្លាំងពលកម្មមានទំនោរស្រដៀងនឹងទស្សនៈពាក់ព័ន្ធនឹងវិស័យកសិកម្មដែរ។** ក្នុងចំណោមអ្នកឆ្លើយទាំងអស់ ១.១២៦ នាក់ (ស្មើ ៧២ ភាគរយនៃប្រជាពលរដ្ឋត្រូវបានសម្ភាសន៍ទាំងអស់) ដែលប្រើកម្លាំងពលកម្មជាចម្បង សម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃ ៤០ ភាគរយបានឆ្លើយថា ពួកគាត់គិតថា ចំណូលបានពីប្រភពនេះនឹងកើនឡើង, ៣៤ ភាគរយ គិតថា នៅដដែល, ហើយ ១៦ ភាគរយគិតថា វានឹងធ្លាក់ចុះ។

## ស្ថានភាពនៃវិស័យស្រូវអង្ករ

**កសិករកម្ពុជាភាគច្រើនធ្វើស្រែតែម្តងប៉ុណ្ណោះក្នុងមួយឆ្នាំ។** កសិករកម្ពុជាភាគច្រើនដាំស្រូវតែម្តងប៉ុណ្ណោះក្នុងមួយឆ្នាំ គឺនៅរដូវវស្សានេះ ដោយសារតែកង្វះប្រព័ន្ធស្រោចស្រព នៅរដូវប្រាំង និង ការប្រើប្រាស់បច្ចេកទេសបែបប្រពៃណី។ ជាលទ្ធផល ផលិតភាពកសិកម្មរបស់កម្ពុជាមិនទាន់គ្រប់សក្តានុពល ដែលខ្លួនមាននៅឡើយទេ។ ឧទាហរណ៍ នៅប្រទេសជិតខាង ថៃ និងវៀតណាម គេធ្វើស្រែយ៉ាងតិចពីរទៅបីដង ក្នុងមួយឆ្នាំហើយទិន្នផលក៏ខ្ពស់ជាងកម្ពុជាដែរ។

**សមត្ថភាពរោងម៉ាស៊ីនកិនស្រូវនៅកម្ពុជាកំពុងតែមានការរីកចម្រើន ប៉ុន្តែសមត្ថភាពនេះនៅតែមានកម្រិតនៅឡើយ។** ដោយមូលហេតុនេះហើយ ទើបស្រូវដែលកម្ពុជាផលិតបាននៅតែបន្តហូរទៅប្រទេសជិតខាង ដើម្បីកែច្នៃបន្ត។ បើទោះបីជារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គេឃើញមានទំនើបកម្មខាងរោងម៉ាស៊ីនកិនស្រូវតាមរយៈការវិនិយោគពីវិស័យឯកជនយ៉ាងណាក៏ដោយ ក៏ឧស្សាហកម្មកិនស្រូវរបស់កម្ពុជាទាំងមូលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីប្រកួតប្រជែងជាមួយប្រទេសជិតខាងនៅឡើយទេ។ មូលហេតុចម្បងៗ គឺកង្វះទុន កង្វះកន្លែង ស្តុកស្រូវ និងពុំទាន់មានសមត្ថភាពឆ្លើយតបនឹងស្តង់ដារដែលពាណិជ្ជករអន្តរជាតិតម្រូវ។ ពាណិជ្ជករកម្ពុជាភាគច្រើននាំគ្នាទិញស្រូវពីកសិករ ហើយលក់បន្តឲ្យពាណិជ្ជករថៃ និងវៀតណាមដែលនៅទីនោះ គេបានកែច្នៃបន្ថែមទៀត រួមមាន កិន វេចខ្ចប់ និងនាំចេញដើម្បីយកទៅផ្គត់ផ្គង់ទីផ្សារអន្តរជាតិ។

## គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា

**ការរីកចម្រើនច្រើន គួរឲ្យកត់សម្គាល់ នៅតាមទីជនបទកម្ពុជាកើតមានឡើងទៅបាន មួយផ្នែកដោយសារតែតម្លៃកសិផលបានកើនឡើងខ្ពស់ជាពិសេសតម្លៃស្រូវ ប៉ុន្តែមួយផ្នែកទៀតដោយសារគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។** អំឡុងពេលមានវិបត្តិស្បៀងអាហារសកលកាលពីឆ្នាំ ២០០៨ រាជរដ្ឋាភិបាលមិនបានធ្វើអន្តរាគមន៍ពាក់ព័ន្ធនឹងការកំណត់តម្លៃទេ រាជរដ្ឋាភិបាលបានប្រកាន់យកគោលនយោបាយបើកទូលាយពាក់ព័ន្ធទៅនឹងតម្លៃ និង ការធ្វើពាណិជ្ជកម្ម។ ការប្រកាន់យកយុទ្ធសាស្ត្របែបនេះបានធ្វើឲ្យទីផ្សារមានការប្រកួតប្រជែងគ្នាកាន់តែខ្លាំងឡើងៗជាអាទិ៍ចាប់ពីឆ្នាំ ២០០៨ មក គេឃើញមានការប្រកួតប្រជែងកាន់តែខ្លាំងរវាងពាណិជ្ជករក្នុងស្រុក និងក្រៅស្រុកក្នុងការទិញស្រូវពីប្រជាពលរដ្ឋនៅតាមទីជនបទ។ កសិករជាច្រើនមិនចាំបាច់ដឹកជញ្ជូនស្រូវរបស់ពួកគេទៅទីផ្សារទេ អ្នកទិញមកទិញដល់វាលស្រែតែម្តង ហើយ

ស្ថានភាពនេះ បានជួយកសិករច្រើនជាងប៉ះពាល់ដល់កសិករ។

**លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជានៅតែផ្តល់អាទិភាពខ្ពស់លើការស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការលើកកម្ពស់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។** រាជរដ្ឋាភិបាលបានបង្កើនចំណាយមូលធនលើវិស័យអាទិភាពទាំងនេះតាមរយៈក្រសួងពាក់ព័ន្ធដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) និង ក្រសួងអភិវឌ្ឍន៍ជនបទ (MRD)។ ការចំណាយមូលធនទាំងនោះផ្តោតទៅលើការលើកកម្ពស់វិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធជនបទ។ ការចំណាយមូលធនរបស់រាជរដ្ឋាភិបាលបានកើនឡើងពី ៨៨ ពាន់លានរៀល នៅឆ្នាំ ២០០៤ ទៅ ២២៨ ពាន់លានរៀល ក្នុងឆ្នាំ២០០៨ និង ៦១២ ពាន់លានរៀល ក្នុងឆ្នាំ២០១០ មុននឹងថយចុះមកត្រឹម ២១៦ ពាន់លានរៀលនៅក្នុងឆ្នាំ២០១១។ បើគិតជាភាគរយធៀបទៅនឹងការចំណាយសរុបរបស់រាជរដ្ឋាភិបាល កើនឡើងពី ៤,១ ភាគរយនៃការចំណាយសរុបនៅឆ្នាំ ២០០៤ ទៅ៤,៧ ភាគរយនៅឆ្នាំ ២០០៨ និង ៩,៥ ភាគរយនៅឆ្នាំ ២០១០ មុននឹងថយចុះមកត្រឹម ២,៨ ភាគរយនៅឆ្នាំ ២០១១។

**ការវិនិយោគរបស់រាជរដ្ឋាភិបាលទៅលើវិស័យអាទិភាពទាំងនេះមិនត្រឹមតែផ្តល់លទ្ធផលប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានជួយលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋជនបទដែរ។** គិតត្រឹមឆ្នាំ ២០១១ ផ្លូវថ្នល់ជនបទនៅទូទាំងប្រទេសប្រមាណ ៧៦ ភាគរយ ត្រូវបានជួសជុល និងកសាងឡើងវិញ។ កាលពីឆ្នាំ ២០០៥ មានតែ ៦៤ ភាគរយប៉ុណ្ណោះ ត្រូវបានជួសជុល និងកសាងឡើងវិញ។ ការកែលម្អផ្លូវថ្នល់បានជួយឲ្យប្រជាពលរដ្ឋតាមជនបទងាយស្រួលប្រើប្រាស់សេវាសាធារណៈផ្សេងៗ និងដឹកទំនិញរបស់ពួកគាត់ទៅកាន់ទីផ្សារ។ ប្រព័ន្ធស្រោចស្រពក៏ត្រូវបានស្តារឡើងវិញផងដែរ។ ក្នុងឆ្នាំ២០១០ ផ្ទៃដីដាំដុះស្រូវ ៤២ ភាគរយ អាចស្រោចស្រពបាន ហើយបើប្រៀបធៀបទៅឆ្នាំ ២០០៥ មានតែ ២០ភាគរយប៉ុណ្ណោះដែលអាចស្រោចស្រពបាន។ អត្រាគ្រួសារប្រជាពលរដ្ឋដែលមានទឹកស្អាតប្រើប្រាស់បានកើនឡើងពី ៤០ភាគរយ នៅឆ្នាំ ២០០០ ទៅ ៥៨ភាគរយ នៅឆ្នាំ២០១០ ចំណែកឯអត្រាគ្រួសារប្រជាពលរដ្ឋ ដែលមានអគ្គិសនីប្រើប្រាស់បានកើនឡើងពី ២ ភាគរយ នៅឆ្នាំ ២០០៤ ទៅ ២៤ ភាគរយនៅឆ្នាំ ២០១១។ (**ក្រាហ្វិក ២៥**)

## បញ្ហាដែលនៅសេសសល់

**បើទោះបីស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋតាមទីជនបទ មានភាពប្រែប្រួលគួរឲ្យកត់សម្គាល់ក្តី ក៏តម្រូវឲ្យគេមានការយកចិត្តទុកដាក់បន្តទៀត ហើយកិច្ចការនោះប្រហែលជាត្រូវធ្វើឲ្យបានខ្លាំងក្លាជាងមុនទៅទៀត។** ជីវភាពប្រជាពលរដ្ឋនៅតាមទីជនបទប្រែប្រួលពីកម្រិតទាបមួយដែលនេះមានន័យថា ភារកិច្ចក្នុងការកាត់បន្ថយភាពក្រីក្រមិនទាន់ចប់នៅឡើយទេ ហើយប្រហែលជាលំបាកជាងមុន។ ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រទាំងអស់ ៩០ ភាគរយ ជាប្រជាពលរដ្ឋក្រីក្ររស់នៅតាមជនបទដដែល ហើយមួយចំនួនរស់នៅតំបន់ជនបទដាច់ស្រយាល។ ប្រជាពលរដ្ឋក្រីក្រនៅពេលបច្ចុប្បន្ននេះមានលក្ខណៈខុសគ្នាពីប្រជាពលរដ្ឋក្រីក្រកាលពីទសវត្សរ៍ទី៩០។ ពួកគេមិនត្រឹមតែមានការរំពឹងទុកខ្ពស់ជាងមុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានមហិច្ឆតានាពេលអនាគតធំជាងមុនទៀតផង។ កាលពី១០ឆ្នាំមុន អាទិភាពចម្បងរបស់ ប្រជាពលរដ្ឋក្រីក្រ គឺធ្វើយ៉ាងណាឲ្យមានម្ហូបអាហារគ្រប់គ្រាន់សម្រាប់ចិញ្ចឹមសមាជិកគ្រួសារពួកគេ ប៉ុន្តែអាទិភាពនាពេលបច្ចុប្បន្ន ក្រៅពីមានម្ហូបអាហារ ត្រូវមានម៉ូតូ ទូរទស្សន៍ ទូរស័ព្ទដៃ ការអប់រំប្រកបដោយគុណភាពសម្រាប់កូនៗ និងប្រសិទ្ធភាពនៃសេវាសុខាភិបាល។

**ល្បឿនយឺតនៃការកាត់បន្ថយភាពក្រីក្រនៅឆ្នាំ ២០១១ បានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងច្បាស់ថា បញ្ហាភាពក្រីក្រមិនទាន់បញ្ចប់នៅឡើយទេ។** ល្បឿននៃការកាត់បន្ថយភាពក្រីក្រយ៉ាងលឿននៅឆ្នាំ ២០០៩ ជាព្រឹត្តិការណ៍ដែលអាចកើតឡើងតែម្តងប៉ុណ្ណោះ ដោយសារការកាត់បន្ថយភាពក្រីក្រនាពេលនោះមានកត្តាខាងក្រៅប្រកបដោយលក្ខណៈអំណោយផលច្រើន។ ល្បឿននៃការកាត់បន្ថយ

**ក្រាហ្វិក ២៥៖** ការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធនៅជនបទសំខាន់ៗ

**(a)** % នៃផ្លូវលំជនបទដែលបានស្តារនិងកសាង




**ប្រភព៖** រាជរដ្ឋាភិបាលកម្ពុជា (២០១២)។

**(b)** % នៃដំណាំស្រូវដែលមានប្រព័ន្ធស្រោចស្រព




**ប្រភព៖** វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (២០១១)។

**(c)** % ភាគរយគ្រួសារដែលមានទឹកស្អាតប្រើប្រាស់




**ប្រភព៖** JMP របស់ WHO/UNICEF។

**(d)** % ភាគរយគ្រួសារដែលមានអគ្គិសនីប្រើប្រាស់




**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

ភាពក្រីក្រនៅតាមទីជនបទដូចបានបង្ហាញខាងលើ បានថមថយមកកម្រិតតិចជាងពីរភាគរយក្នុងមួយឆ្នាំ បើប្រៀបធៀបទៅនឹងល្បឿន ១៥,២ ភាគរយ ក្នុងមួយឆ្នាំកាលពីអំឡុងឆ្នាំ ២០០៧–២០០៩ ដែលបញ្ជាក់ឲ្យឃើញច្បាស់ថា មានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ។

## កត្តាសំខាន់ៗនៃការកាត់បន្ថយភាពក្រីក្រ

ដោយយោងលើលទ្ធផលដែលបានបង្ហាញនៅជំពូកខាងលើនេះ យើងនឹងប្រើព័ត៌មានពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា និង ស្ថិតិផ្លូវការផ្សេងទៀតរបស់រាជរដ្ឋាភិបាល ដើម្បីពិនិត្យមើលទំនាក់ទំនងរវាងការកាត់បន្ថយភាពក្រីក្រ ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ និងកត្តាមួយចំនួនដូចជា កម្លាំងពលកម្ម តម្លៃកសិផល និង ការប្រកបរបរជំនួញតូចតាច។

**អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (ជាការអង្កេតដើម្បីវាស់វែងកម្រិតជីវភាពរបស់ប្រជាពលរដ្ឋ)**។ ការអង្កេតនេះមិនបានសម្ភាសន៍ប្រជាពលរដ្ឋដដែលៗ ពីមួយឆ្នាំទៅមួយឆ្នាំទេ។ ដោយសារមូលហេតុនេះហើយ ទើបគេមានការលំបាកសិក្សាពីទំនាក់ទំនងរវាងការកាត់បន្ថយភាពក្រីក្រ និងកត្តាចម្បងផ្សេងៗ ដែលបានចូលរួមកាត់បន្ថយភាពក្រីក្រ។ ម៉្យាងទៀតព័ត៌មានទាក់ទងនឹងចំណូលរបស់ពលរដ្ឋក៏មានកម្រិតដែរ។ ព័ត៌មានអាចប្រើប្រាស់ជាសញ្ញាណសម្រាប់ពិនិត្យមើលការប្រែប្រួលជីវភាពរបស់ប្រជាពលរដ្ឋពីពេលមួយទៅពេលមួយ ប៉ុន្តែគេត្រូវមានភាពប្រយ័ត្នប្រយែងក្នុងការបកស្រាយព័ត៌មានទាំងនោះ។ ដើម្បីកំណត់កត្តាចម្បងផ្សេងៗក្នុងការកាត់បន្ថយភាពក្រីក្រ យើងបានធ្វើការវិភាគមួយ ដោយបានប្រើអញ្ញាតិផ្សេងៗពីការអង្កេតសេដ្ឋកិច្ចកម្ពុជា និងលទ្ធផលពីការវិភាគអំពីតំបន់ទីប្រជុំជន និងជនបទនៅជំពូកទីពីរ។ ការវិភាគនេះបានកំណត់កត្តា

ចម្បងផ្សេងៗដែលបានចូលរួមកាត់បន្ថយភាពក្រីក្រពី ឆ្នាំ ២០០៤ ដល់ ឆ្នាំ ២០១១ និងតាមតំបន់ធំៗរបស់កម្ពុជាមានដូចជា ទីក្រុងភ្នំពេញ តំបន់ទីប្រជុំជនដទៃទៀត។ ចំពោះកត្តាពិសេសដែលមានតួនាទីសំខាន់សម្រាប់អំឡុងពេល ឬក៏តំបន់ណាមួយនោះជាក់លាក់ យើងបានកំណត់វាជាកត្តាដាច់ដោយឡែក។

**ការវិភាគបានបង្ហាញថា ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាពីឆ្នាំ ២០០៤ ដល់ឆ្នាំ២០១១ ភាគច្រើនបានកើតឡើងនៅតំបន់ជនបទ ហើយកើតឡើងក្នុងអំឡុង ឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩។** ការគណនាបានបង្ហាញថាក្នុងចំណោមការកាត់បន្ថយភាពក្រីក្រសរុបនៅកម្ពុជាក្នុងរយៈពេល ៧ ឆ្នាំនេះ ៣,៧ ភាគរយ បានកាត់បន្ថយនៅទីក្រុងភ្នំពេញ ៨,១ ភាគរយ បានកាត់បន្ថយនៅតាមទីប្រជុំជននានាទៀត ហើយ ៨៨,៣ ភាគរយ ត្រូវបានបន្ថយនៅទីជនបទ(**ក្រាហ្វិកទី ២៦A**)។ ម៉្យាងវិញទៀតការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាប្រមាណ ៨០ ភាគរយ កើតឡើងក្នុងអំឡុងឆ្នាំ ២០០៧ ដល់ឆ្នាំ ២០០៩ ហើយមួយចំណែកនៅសល់កើតឡើង នៅឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៧ ប្រមាណ ៩,៧ ភាគរយ និងអំឡុងឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១១ ប្រមាណ ១០,៤ ភាគរយ (**ក្រាហ្វិកទី ២៦B**)។

ចរិតលក្ខណៈរបស់ប្រជាពលរដ្ឋរស់នៅតាមទីប្រជុំជនផ្សេងៗ មានលក្ខណៈស្រដៀងនឹងប្រជាពលរដ្ឋរស់នៅទីក្រុងភ្នំពេញផង និង ប្រជាពលរដ្ឋរស់នៅតាមជនបទផង។ ឧទាហរណ៍ ប្រជាពលរដ្ឋរស់នៅតាមទីប្រជុំជនផ្សេងៗទៀតមានដីស្រែចម្ការ និងប្រកបរបរកសិកម្មលើដីធ្លីរបស់ខ្លួន ដែលនៅមិនឆ្ងាយប៉ុន្មានពីទីប្រជុំជនទេ (ជាទូទៅ គេអង្កេតឃើញថា មានចម្ងាយមិនដល់មួយ គ.ម ផង)។ ចរិតលក្ខណៈរបស់ជាពលរដ្ឋ នៅតាមទីប្រជុំជនមានលក្ខណៈស្រដៀងប្រជាពលរដ្ឋរស់នៅទីក្រុងភ្នំពេញមានដូចជា ស្ថានភាពលំនៅដ្ឋាន កម្រិតនៃការសិក្សាអប់រំ និងកម្រិតចំណាយលើការប្រើប្រាស់ជាដើម។ នេះជាមូលហេតុដែលយើងមានការលំបាកក្នុងការវិភាគកត្តានាំមុខនៃការកាត់បន្ថយ ភាពក្រីក្រនៅតាម «តំបន់ទីប្រជុំជនដទៃទៀត» ។ ដូច្នេះហើយ ក្នុងការវិភាគនេះ យើងប្រើតែពីរតំបន់ទេ គឺតំបន់ទីប្រជុំជន និង តំបន់ជនបទដោយចាត់ប្រជាពលរដ្ឋទីក្រុងភ្នំពេញថា ជាប្រជាពលរដ្ឋក្នុងតំបន់ទីប្រជុំជន រីឯប្រជាពលរដ្ឋក្នុង «តំបន់ទីប្រជុំជនផ្សេងទៀត» មួយចំនួនចាត់ចូលថា ជាប្រជាពលរដ្ឋក្នុងតំបន់ទីប្រជុំជន និង មួយចំនួនទៀតចាត់ចូលក្នុងតំបន់ជនបទអាស្រ័យលើស្ថានភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋនីមួយៗ។

**ក្រាហ្វិក ២៦៖** ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ឆ្នាំ២០០៤ ដល់ឆ្នាំ២០១១

**(a)** តាមតំបន់ **(b)** តាមអំឡុងពេល




ការកាត់បន្ថយភាពក្រីក្រសរុប = 32,7 ភាគរយ (លេខទី១) = 100% (លេខទី២)

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ដោយយោងតាមអ.ស.ស.ក។

## គ្រួសារដែលរស់នៅតាមទីប្រជុំជនក្នុងអំឡុងឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៧

ក្រុមគ្រួសារពលរដ្ឋរស់នៅតាមទីប្រជុំជននានានៅកម្ពុជា ភាគច្រើនប្រកបការងារក្នុងវិស័យឧស្សាហកម្ម។ ផលិតផលក្នុងស្រុកក្នុងមនុស្សម្នាក់ៗរបស់វិស័យឧស្សាហកម្មបានកើនឡើង ៤០,៨ ភាគរយ ពីឆ្នាំ ២០០៤ ដល់ ឆ្នាំ២០០៧។ ប៉ុន្តែនៅឆ្នាំ២០០៨ ដល់ឆ្នាំ២០០៩ ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់របស់វិស័យឧស្សាហកម្មមានការធ្លាក់ចុះ ទើបតែនៅឆ្នាំ ២០១០ ទេ ដែលវាបានងើបឡើងវិញ ហើយបានកើនឡើងស្មើនឹងកម្រិតរបស់ឆ្នាំ២០០៧វិញ។ចំណែកឯផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ៗ របស់វិស័យកសិកម្មវិញ បានកើនឡើង ៩,១ ភាគរយ ពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០០៨។ កាលពីទសវត្សរ៍កន្លងទៅ កំណើនការងារដែលមានប្រាក់បៀវត្សរ៍ទៀងទាត់នៅតាមទីប្រជុំជនបានធ្វើឲ្យភាពក្រីក្រធ្លាក់ចុះយ៉ាងលឿន ជាពិសេស ការធ្លាក់ចុះអត្រាភាពក្រីក្រនៅទីក្រុងភ្នំពេញ ពីឆ្នាំ ២០០៤ ដល់ ២០០៧។ ក្នុងអំឡុងពេលនោះហើយដែលគេសង្កេតឃើញថា ចំនួនការងារមានប្រាក់បៀវត្សរ៍ទៀងទាត់មានកំណើន ១០ ភាគរយ ប៉ុន្តែក្នុងអំឡុងពេលនោះ អត្រាភាពក្រីក្រនៅជនបទបានធ្លាក់ចុះត្រឹម ១,១ ភាគរយប៉ុណ្ណោះ ដោយសារអំឡុងពេលនោះ ចំនួនប្រជាពលរដ្ឋដែលទទួលបានប្រាក់បៀវត្សរ៍នៅជនបទកើនឡើងមិនដល់មួយភាគរយផង។

**ពេលយើងពិនិត្យកម្រិតចំណាយលើការប្រើប្រាស់ទៅតាមប្រភេទរបស់មុខរបរមេគ្រួសារ យើងរកឃើញថា កំណើនមេគ្រួសារដែលប្រកបរបរមានប្រាក់បៀវត្សរ៍ទៀងទាត់ជាកត្តាចម្បង ដែលជួយកាត់បន្ថយភាពក្រីក្រ** (មានពន្យល់ក្នុងផ្នែក ស្តីពីពលកម្មនៅទីប្រជុំជន ក្នុងរបាយការណ៍នេះ)។ ការកាត់បន្ថយភាពក្រីក្រ ក្នុងអំឡុងឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៧ បានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រទូទាំងប្រទេសចំនួន ១,៤ ភាគរយ។

## ចំណូលរបស់ក្រុមគ្រួសារពលរដ្ឋនៅតាមទីជនបទពីឆ្នាំ២០០៤ ទៅឆ្នាំ២០០៩

**កត្តាចម្បងទី១ ដែលធ្វើឲ្យការចំណាយរបស់ប្រជាពលរដ្ឋនៅតាមទីជនបទកើនឡើងពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩ គឺថ្លៃស្រូវអង្ករឡើងខ្ពស់។** គ្រួសារពលរដ្ឋជាច្រើននៅតាមទីជនបទបានលើកកម្ពស់ជីវភាពរបស់ខ្លួនដោយសារតម្លៃអង្ករបានកើនឡើងពីឆ្នាំ ២០០៤ ដល់ ២០០៩។ ក្រៅពីឥទ្ធិពលផ្ទាល់ តម្លៃស្រូវអង្ករខ្ពស់មានឥទ្ធិពលប្រយោលពីរទៅលើគ្រួសារពលរដ្ឋ៖ ឥទ្ធិពលប្រយោលទី១ បរិមាណស្រូវអង្ករដែលគ្រួសារនីមួយៗបានប្រើប្រាស់នឹងមានតម្លៃខ្ពស់ ពេលគិតជាប្រាក់។ ឥទ្ធិពលប្រយោលទី២ ការដាំដុះត្រូវបានពង្រីក ហើយទិន្នផលក៏ត្រូវបានបង្កើនដែរ។

ដើម្បីប៉ាន់ស្មានផលប៉ះពាល់នៃការកើនឡើងថ្លៃស្រូវអង្ករទៅលើជីវភាពរបស់ប្រជាពលរដ្ឋ យើងបានធ្វើការនិម្មិតកម្មមួយ ដោយប្រើព័ត៌មានពីការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា និងស្ថិតិផ្លូវការផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ហើយវិធីសាស្រ្តនៃការវិភាគត្រូវបានពន្យល់លម្អិតនៅឧបសម្ព័ន្ធទីបី។ ក្នុងការវិភាគនេះ យើងពិនិត្យមើលលើគ្រួសារមួយក្រុម ដែលត្រូវបានចាត់ទុកជាប្រជាពលរដ្ឋក្រីក្រនៅឆ្នាំ ២០០៧ ប៉ុន្តែមិនត្រូវបានចាត់ទុកជាប្រជាពលរដ្ឋក្រីក្រទេនៅឆ្នាំ២០០៩ តាមបន្ទាត់ភាពក្រីក្រឆ្នាំនីមួយៗ ហើយតាមរយៈក្រុមពលរដ្ឋនេះ យើងពិនិត្យមើលកម្រិតចំណាយប្រចាំថ្ងៃរបស់ពួកគេបានវិវត្តន៍យ៉ាងដូចម្តេច ពេលស្រូវអង្ករឡើងថ្លៃខ្ពស់។ លទ្ធផលនៃការវិភាគបានបង្ហាញថា ថ្លៃស្រូវអង្ករមានតម្លៃខ្ពស់បានជួយឲ្យការចំណាយក្នុងម្នាក់ៗក្នុងគ្រួសារទាំងនោះ កើនឡើងចំនួន ៦៨៣.៧២ រៀលក្នុងមួយថ្ងៃ។ ចំណែកឯការកើនឡើងនៃទិន្នផលស្រូវ និងផ្ទៃដីដាំដុះបានធ្វើឲ្យការចំណាយក្នុងម្នាក់ៗក្នុងគ្រួសារទាំងនោះកើនឡើង ៦.៦១៤ រៀលក្នុងមួយថ្ងៃ។

**កត្តាចម្បងទីពីរ ដែលជួយឲ្យការចំណាយរបស់ប្រជាពលរដ្ឋមានការកើនឡើងគឺកំណើនពីការលក់កម្លាំងពលកម្ម និងអត្រាថ្លៃឈ្នួលពលកម្ម។** ដោយសារតែទិន្នន័យមានកម្រិត យើងមិនអាចកំណត់ថា តើការលក់

កម្លាំងពលកម្មនៅតាមទីជនបទភាគច្រើនបានមកពីការងារកសិកម្មមួយណាទេ ប៉ុន្តែយើងអាចសន្មត់ថាចំណូលពីការលក់កម្លាំងពលកម្មភាគច្រើននៅតាមទីជនបទពាក់ព័ន្ធនឹងស្រូវអង្ករ។ ឧទាហរណ៍៖ ៨០ ភាគរយ នៃផ្ទៃដីដាំដុះនៅកម្ពុជាដាំដំណាំស្រូវ ហើយប្រជាពលរដ្ឋនៅជនបទ ៨០ ភាគរយជាកសិករ។ លើសពីនេះទៀតតម្លៃអង្ករបានកើនឡើងខ្ពស់ជាងគេបើធៀបនឹងមុខទំនិញអាហារផ្សេងៗដែលផលិតក្នុងស្រុក នេះបើយោងតាមសន្ទស្សន៍ថ្លៃទំនិញរបស់រាជរដ្ឋាភិបាល។ ឧទាហរណ៍៖ ថ្លៃអង្ករកើនឡើង ៣៩ ភាគរយ ចំណែកឯថ្លៃទំនិញផ្សេងទៀតដូចជាសាច់គោកើនឡើង ២៥ ភាគរយ, សាច់មាន់កើនឡើង ២៤ ភាគរយ, ត្រី និងគ្រឿងសមុទ្រកើនឡើង ២៤ភាគរយ, ស៊ុតកើនឡើង ១៤ ភាគរយ, ផ្លែឈើកើនឡើង ២៧ ភាគរយ, និងបន្លែកើនឡើង ២២ ភាគរយ។

ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៩ ចំណូលដែលបានមកពីការលក់កម្លាំងពលកម្មរបស់ប្រជាពលរដ្ឋ នៅតាមទីជនបទបានកើនឡើង ៤៩ ភាគរយ គឺប្រមាណជា ៤៥០ រៀល ក្នុងមួយថ្ងៃក្នុងម្នាក់ៗ។ ប៉ុន្តែចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ ចំណូលដែលបានមកពីការលក់កម្លាំងពលកម្មមិនបានកើនឡើងទេ (**ក្រាហ្វិកទី ២៧**)។

**កត្តាចម្បងទីបី ដែលជួយឲ្យការចំណាយរបស់ប្រជាពលរដ្ឋ មានការកើនឡើង គឺចំណូល ដែលបានមកពីអាជីវកម្មតូចតាច។** ការអង្កេតសេដ្ឋកិច្ចកម្ពុជាពីឆ្នាំ២០០៤ ដល់ឆ្នាំ ២០១១ បានសួរសំណួរអំពីការប្រកបមុខរបរជំនួញដោយខ្លួនឯង។ យើងបានប្រើព័ត៌មានទាំងនេះដើម្បីគណនាចំណូលរបស់គ្រួសារនីមួយៗដែលមានប្រភពពីការប្រកបជំនួញតូចតាចនេះ ហើយលទ្ធផលបានបង្ហាញថា ចំណូលបានមកពីប្រភពនេះបានកើនឡើងចំនួន ៥៤២ រៀល ក្នុងមួយថ្ងៃក្នុងម្នាក់ៗ ពីឆ្នាំ ២០០៤ ទៅឆ្នាំ ២០០៩ (ប៉ុន្តែពីឆ្នាំ ២០០៩ ដល់ ២០១១ មានការធ្លាក់ចុះ)។ ផ្នែកនៃរបាយការណ៍នេះដែលពន្យល់ពីតួនាទីរបស់ជនបទ បានបង្ហាញពីបម្រែបម្រួលចំណូលពីការប្រកបជំនួញតូចតាចពីឆ្នាំ ២០០៤ ដល់ឆ្នាំ២០១១។ (**ក្រាហ្វិក ២៧**)

## កត្តាចម្បងៗក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១

ដើម្បីប៉ាន់ស្មានឥទ្ធិពលនៃកត្តាចម្បងលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១១ យើងបានសន្មត់ថា ការកើនឡើងនៃប្រាក់ចំណូលរបស់គ្រួសារនានានៅ **ក្រាហ្វទី២៧** ស្មើល្បឿនការកាត់បន្ថយភាពក្រីក្រ។

ការកាត់បន្ថយភាពក្រីក្រនៅភ្នំពេញកើតមានពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៧ ហើយកត្តាចម្បងនេះគឺចំនួនកម្មករដែលប្រកបការងារ មានប្រាក់បៀវត្សរ៍ទៀងទាត់បានកើនឡើង។ ចំណែកឯការកាត់បន្ថយភាពក្រីក្រនៅតំបន់ផ្សេងទៀតក្រៅពីភ្នំពេញ ដោយសារកត្តារួមផ្សំគ្នារវាងការងារនៅតាមទីប្រជុំជន និងការងារនៅតាមទីជនបទ ហើយកត្តាចម្បងៗនោះ បានចំណែកផ្សេងៗគ្នា។ ពាក់កណ្តាលនៃការកាត់បន្ថយភាពក្រីក្ររបស់ក្រុមគ្រួសារដែលរស់នៅទីប្រជុំជនផ្សេងៗ ក្រៅពីទីក្រុងភ្នំពេញ ដោយសារតែកំណើននៃការងារធ្វើការទទួលបានប្រាក់បៀវត្សរ៍ទៀងទាត់ ហើយពាក់កណ្តាលទៀត ដោយសារតែកត្តាចម្បងដែលកើតមានដូចនៅតាមទីជនបទដែរ។

ការកាត់បន្ថយភាពក្រីក្ររបស់កម្ពុជាទាំងមូលមានកត្តាមួយចំនួនដូចជា ៖ ថ្លៃស្រូវអង្ករខ្ពស់ (៧,៨ភាគរយ)

**ក្រាហ្វិក ២៧៖** បម្រែបម្រួលចំណូលនៃក្រុមផ្សៀងផ្ទាត់ ឆ្នាំ២០០៤-២០០៩



កំណើនផលិតស្រូវ (៧,៦ភាគរយ) កំណើនចំណូលបានមកពីការលក់កម្លាំងពលកម្ម (៥,២ភាគរយ) និងកំណើនចំណូលពីរបរជំនួញតូចតាច (៦,២ភាគរយ) ចំណែកឯអត្រាភាពក្រីក្រ ៤,៤ភាគរយ ទៀតដោយសារកត្តាផ្សេងៗទៀត (**ក្រាហ្វទី២៨**)។

**វិស័យកសិកម្មដែលក្នុងនេះមានតម្លៃស្រូវអង្ករខ្ពស់ និង កំណើនទិន្នផលស្រូវបានធ្វើឲ្យការកាត់បន្ថយភាពក្រីក្រធ្លាក់ចុះជិតពាក់កណ្តាល។** អត្រាកម្លាំងពលកម្មជាពិសេសទាក់ទងនឹងការធ្វើស្រែបានចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ ១៦ ភាគរយ។ ទន្ទឹមនឹងនេះដែរ កំណើនចំណូលពីការប្រកបជំនួញតូចតាចបានជួយកាត់បន្ថយភាពក្រីក្រប្រហែលជាមួយភាគប្រាំ ហើយកំណើនការងារមានប្រាក់បៀវត្សរ៍ទៀងទាត់នៅតាមទីប្រជុំជនបានចូលរួមឲ្យការកាត់បន្ថយភាពក្រីក្រចំនួន ៤ ភាគរយ។ ចំណែកឯការកាត់បន្ថយភាពក្រីក្រ ១៤ ភាគរយទៀត ដោយសារ កត្តាមួយចំនួន កើតឡើងអំឡុង ឆ្នាំ ២០០៩-២០១១។ (**ក្រាហ្វិក ២៨**)

## អនុសាសន៍នានាពាក់ព័ន្ធនឹងគោលនយោបាយ

**គេត្រូវរក្សាគោលនយោបាយរបស់រដ្ឋ ដែលមិនចូលអន្តរាគមន៍ត្រួតត្រាតម្លៃកសិផល។** មូលហេតុមួយក្នុងចំណោមមូលហេតុសំខាន់ៗដែលកសិករកម្ពុជាទទួលអត្ថប្រយោជន៍យ៉ាងច្រើនពីការកើនឡើងនៃថ្លៃស្រូវអង្ករដោយសារតែនៅកម្ពុជាពុំមានគោលនយោបាយត្រួតត្រាតម្លៃដែលអាចធ្វើឲ្យប៉ះពាល់ដល់ការឡើងចុះនៃតម្លៃទីផ្សារ។ លើសពីនេះទៀត ប្រការដែលរដ្ឋាភិបាលមិនបានយកពន្ធលើការដាំដុះដំណាំស្រូវ បានជួយឲ្យកសិករជាច្រើនបានទទួលផលចំណេញ។ ទៅអនាគត រដ្ឋគួរតែរក្សាគោលនយោបាយនេះ ដើម្បីឲ្យធនធាននានាបានដោះដូរដោយសេរី ក្នុងវិស័យកសិកម្ម ឬ វិស័យក្រៅពីកសិកម្ម។ គោលនយោបាយនេះដែរនឹងឲ្យកសិករបែងចែកទ្រព្យ និងមធ្យោបាយរបស់ពួកគាត់ប្រកបដោយប្រសិទ្ធិភាព។

**បន្តកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ ដោយប្រើអត្រាភាពក្រីក្រសម្រាប់កំណត់អទិភាពគម្រោងនានា។** ការស្តារហេដ្ឋារចនាសម្ព័ន្ធជនបទ ផ្លូវទូរគមនាគមន៍ និងអគ្គិសនីបានជួយប្រជាពលរដ្ឋក្រីក្រជាច្រើនឲ្យទាញយកផលនានាពីកំណើនសេដ្ឋកិច្ចពីឆ្នាំ ២០០4 ដល់ ២០១១។ ដូច្នេះហើយ យើងសូមផ្តល់អនុសាសន៍ឲ្យបន្តពង្រីកការស្តារហេដ្ឋារចនាសម្ព័ន្ធជនបទទាំងនោះ ហើយអាទិភាពនានាគួរធ្វើទៅតាមតំបន់ខ្ពង់រាប និង តំបន់ភ្នំដែលតំបន់ទាំងនោះនៅមានអត្រាភាពក្រីក្រខ្ពស់នៅឡើយ។ ចំពោះការអនុវត្តន៍គម្រោងមួយចំនួនទៀត គេគួរជ្រើសរើសគម្រោងណាដែលមានផលប៉ះពាល់ជាវិជ្ជមានដល់ប្រជាពលរដ្ឋ

**ក្រាហ្វិក ២៨៖** កត្តាសំខាន់ៗដែលចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ឆ្នាំ២០០៤-២០១១




**សម្គាល់៖** លេខទី១ ជាអត្រាភាពក្រីក្រ ដែលត្រូវបានកាត់បន្ថយ (សរុប ៣២,៧ ភាគរយ), លេខទី២ ជា អត្រាភាពក្រីក្រសរុប (សរុប=១០០ ភាគរយ)។

ក្រីក្រ។

**ទិន្នផលកាន់តែប្រសើរក្នុងការផលិតស្រូវ និងជំរុញឲ្យកសិករបានប្រាក់ចំណេញទៀត។** ដោយសារតែប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះមួយភាគធំជាអ្នកផលិតស្រូវនោះ គោលនយោបាយទាំងឡាយណាដែលជំរុញទិន្នផលស្រូវឲ្យបានខ្ពស់ នឹងជួយដល់ប្រជាពលរដ្ឋទាំងនោះ។ គេមិនមែនផ្តោតលើការបង្កើនផលិតកម្មតែឯងនោះទេ ប៉ុន្តែ ត្រូវបង្កើនប្រាក់ចំណេញរបស់កសិករដោយមិនចាំបាច់បង្កហានិភ័យបន្ថែម។ គេអាចធ្វើបានដូចជាៈ ទី១ ជំរុញឲ្យប្រើប្រាស់ពូជស្រូវដែលមានគុណភាពប្រសើរជាងមុន។ ទី២ បន្តវិនិយោគលើប្រព័ន្ធស្រោចស្រព ដើម្បីជំរុញឲ្យការដាំដុះ ធ្វើឲ្យបានច្រើនជាងមួយដងក្នុងមួយឆ្នាំ និងកាត់បន្ថយហានិភ័យនានា ដែលបណ្តាលមកពីទឹកជំនន់ ឬគ្រោះរាំងស្ងួត។ ទី៣ រៀបចំបង្កើតសេវាបច្ចេកទេស និង សេវាស្រាវជ្រាវ ដើម្បីលើកកម្ពស់ផលិតកម្មដំណាំស្រូវសម្រាប់កសិករណាដែលមានផ្ទៃដីតិចជាង ២ ហិកតា ព្រមទាំងជំរុញឲ្យមានការផ្តល់ប្រាក់កម្ចីដល់កសិករឲ្យបានច្រើនជាងមុន។

**ជំរុញឲ្យមានពិពិធកម្ម វិស័យកសិកម្មនៅកម្ពុជា។** បើទោះបីជាការផលិតស្រូវជាកត្តាចម្បងមួយដែលជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតាមជនបទក៏ដោយក៏ប្រជាពលរដ្ឋទាំងនោះ ជាពិសេសប្រជាពលរដ្ឋក្រីក្រនឹងទទួលបានផលបន្ថែមទៀត ប្រសិនការងារកសិកម្មរបស់ពួកគាត់អាចពង្រីកទៅដាំដំណាំកសិកម្មផ្សេងទៀត។ ប៉ុន្តែដើម្បីធ្វើការពង្រីកធ្វើការដាំដុះនេះ គេចាំបាច់ត្រូវសិក្សាថាតើស្ថានភាពផ្ទៃដីប្រភេទណា សមស្របទៅនឹងដំណាំអ្វីខ្លះ? តើត្រូវដាំដំណាំផ្សេងៗ ឬក៏ចិញ្ចឹមសត្វ? ឧទាហរណ៍ដីនៅតំបន់ខ្ពង់រាបភាគច្រើនសមស្របសម្រាប់ដំណាំពោតសណ្តែក។ ការពង្រីកការដាំដំណាំដែលរួមមានបន្លែផ្សេងៗនឹងជំរុញឲ្យមានម្ហូបអាហារគ្រប់ប្រភេទសម្រាប់បំពេញជីវជាតិ និងសុខភាព។ ពិពិធកម្មកសិកម្មនឹងជួយឲ្យកសិករមិនសូវងាយរងគ្រោះ ប្រសិនបើដំណាំណាមួយរបស់ពួកគាត់ជួបហានិភ័យ។

**គេត្រូវបង្កើនតម្លៃបន្ថែម លើកសិផលទាំងឡាយណាដែលកម្ពុជាផលិតបាន។** ការលក់កម្លាំងពលកម្ម ជាកត្តាចម្បងទីពីរដែលបានជួយកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ប្រជាពលរដ្ឋនៅតាមទីជនបទមានសក្តានុពលដើម្បីបង្កើនតម្លៃបន្ថែមទៅលើកសិផលទាំងនោះ ក្នុងសង្វាក់ផ្សេងៗ។ តម្លៃបន្ថែមទាំងនោះមានដូចជា ការកែច្នៃ ការវេចខ្ចប់ ការចែកចាយ និង ការធ្វើទីផ្សារ។ ការបង្កើនសមត្ថភាពរបស់រោងម៉ាស៊ីនកិនស្រូវរបស់កម្ពុជាជាឧទាហរណ៍មួយដែលបញ្ជាក់ថាតម្លៃបន្ថែមផ្សេងៗ ត្រូវបានគេធ្វើឡើងនៅក្នុងប្រទេស ប៉ុន្តែគេគួរតែធ្វើនៅក្នុងផលិតផលផ្សេងៗទៀត។ ឧទាហរណ៍មួយទៀតម្រេចនៅខេត្តកំពតដែលត្រូវបានដាំដុះ កែច្នៃ វិចខ្ចប់ និងធ្វើពាណិជ្ជកម្មទាំងក្នុងស្រុកនិងក្រៅស្រុក ហើយវាត្រូវបានគេទទួលស្គាល់ម៉ាកជាអន្តរជាតិថា «ម្រេចកំពត» ។ គ្រប់ដំណាក់កាលទាំងអស់នៃខ្សែសង្វាក់ផលិតកម្មសុទ្ធតែបង្កើតការងារ និងឱកាសវិនិយោគដល់ប្រជាពលរដ្ឋកម្ពុជា និងប្រជាពលរដ្ឋដទៃ។

**វិស័យកសិកម្មបានជួយឲ្យប្រជាពលរដ្ឋតាមជនបទជាច្រើនបានចាកចេញពីភាពក្រីក្រ ប៉ុន្តែគេមិនអាចពឹងផ្អែកលើវិស័យនេះទាំងស្រុងដើម្បីកាត់បន្ថយភាពក្រីក្រនាអនាគតនោះឲ្យលឿនដូចប៉ុន្មានឆ្នាំមុននេះទេ។** សម្រាប់រយៈពេលមធ្យមទៅរយៈពេលវែង សកម្មភាពសេដ្ឋកិច្ចដែលមិនមានកសិកម្មនឹងដើរតួនាទីយ៉ាងសំខាន់ដើម្បីរក្សាកំណើនសេដ្ឋកិច្ច និង លើកកម្ពស់ជីវភាពប្រជាពលរដ្ឋកម្ពុជា។ គេគួររៀបចំឲ្យមានកិច្ចខិតខំប្រឹងប្រែងឲ្យវិស័យឧស្សាហកម្មនៅតាមទីប្រជុំជន និងការងារមិនមែនកសិកម្មនៅតាមទីជនបទកាន់តែមានសន្ទុះលឿនថែមទៀត។ ដើម្បីឲ្យសម្រេចបានគោលដៅសេដ្ឋកិច្ច និងសង្គម គោលនយោបាយនានានៅជនបទ គេត្រូវពង្រីកវិស័យកសិកម្ម ក្នុងរយៈពេលខ្លី និងមធ្យម ហើយបន្ទាប់មកពង្រីកវិស័យឧស្សាហកម្ម និងសេវាកម្មក្នុងរយៈពេលមធ្យម និងរយៈពេលវែង។

# ផ្តោតការយកចិត្តទុកដាក់បន្ថែម ចំពោះ ជនក្រីក្រ និងជនងាយរងគ្រោះ

# ជំពូក ៣

ប្រទេសកម្ពុជាបានបោះជំហានដ៏សំខាន់ ទាំងក្នុងការវិនិយោគលើវិស័យអប់រំកម្រិតបឋមសិក្សា និងលទ្ធភាពនៃការទទួលបានការអប់រំនៅកម្រិតនេះ។ ការអប់រំកម្រិតបឋមសិក្សាក្នុងពេលបច្ចុប្បន្ន គឺមានស្ទើរគ្រប់ទីកន្លែង ទោះបីនៅតាមតំបន់ជនបទដាច់ស្រយាលក៏ដោយ។ ប៉ុន្តែក៏មានបញ្ហាប្រឈមមួយចំនួនផងដែរ។ បញ្ហាទាំងនេះមានដូចជា ការចុះឈ្មោះចូលរៀនយឺតពេលការបោះបង់ចោលការសិក្សា (ជាពិសេសនៅកម្រិតមធ្យមសិក្សា) និងគុណភាពនៃការអប់រំនៅមានកម្រិតនៅឡើយ ដែលទាំងនេះជាបញ្ហាថ្មីៗរបស់រាជរដ្ឋាភិបាល។ ការផ្តល់សេវាអប់រំកម្រិតមធ្យមសិក្សា និងសេវាសុខាភិបាលនៅមិនទាន់មានវិសាលភាពធំ ដូចសេវាអប់រំកម្រិតបឋមសិក្សានៅឡើយទេ។ វិសាលភាពតូចនេះ រួមផ្សំនឹងកង្វះលទ្ធភាពដោយអន្លើផងនោះ បានកាត់បន្ថយការទទួលបាននូវសេវាទាំងពីរនេះ ដែលការណ៍នេះជាសូចនាករបង្ហាញអំពីលទ្ធផលមិនទាន់ល្អប្រសើរ។ ប៉ុន្តែការរីកចម្រើនក៏ត្រូវបានមើលឃើញគ្រប់ផ្នែកផងដែរ លើកលែងតែករណីកង្វះអាហារូបត្ថម្ភដែលមិនបានបង្ហាញវឌ្ឍនភាពគួរឲ្យកត់សម្គាល់សោះ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ។

កិច្ចគាំពារសង្គមដែលជាទស្សនទានថ្មីមួយនៅប្រទេសកម្ពុជា រីតតែមិនសូវមានការរីកចម្រើននៅឡើយ។ គេឃើញថា រដ្ឋាភិបាលបានចូលរួមចំណែក ឬ គ្រប់គ្រង ឬមួយផ្តល់ហិរញ្ញប្បទានតែចំពោះកម្មវិធីសង្គមទ្រង់ទ្រាយតូចៗមួយចំនួនដូចជា ជំនួយផ្នែកអាហារ និង ជំនួយខាងទឹកជំនន់ ប៉ុណ្ណោះ។ ពោលគឺ ពុំបានធ្វើសកម្មភាពពាក់ព័ន្ធទៅនឹងកម្មវិធីអាហាររូបករណ៍ ដែលផ្តោតលើស្ត្រី និងកម្មវិធីឧបត្ថម្ភធនខាងថៃទាំសុខភាពសម្រាប់ជនក្រីក្រនៅឡើយទេ(**ប្រអប់ ៥**)។ ដើម្បីបំពេញតម្រូវការថ្មីៗ និងដោះស្រាយបញ្ហាប្រឈម រដ្ឋាភិបាលត្រូវបន្តវិនិយោគក្នុងវិស័យគោលក្នុងសង្គមចំនួនបីគឺៈ វិស័យសុខាភិបាល វិស័យអប់រំ និងវិស័យគាំពារសង្គម។

## វិស័យអប់រំ

### សាវតារនៃវិស័យអប់រំ

ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជាភាគច្រើនជាសេវាសាធារណៈដែលគ្រប់គ្រងដោយស្ថាប័នរដ្ឋចំនួន ៦។ ទី១ គឺក្រសួងអប់រំ យុវជន និងកីឡាដែលជាស្ថាប័នជាតិទទួលបន្ទុកខាងវិស័យអប់រំទាំងមូល។ ស្ថាប័ននេះផ្តល់

សេវាអប់រំឃ្លាំមើលគុណភាព និងលទ្ធភាពនៃការទទួលបានការអប់រំគ្រប់កម្រិតទាំងអស់ និងធានាឲ្យបានថា រាល់លក្ខខណ្ឌជាមូលដ្ឋាននៃការអប់រំទាំងអស់ គឺត្រូវបានបំពេញ។ ទី២ គឺវិទ្យាស្ថានអប់រំថ្នាក់ឧត្តមសិក្សារបស់រដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់ក្រសួង និងអង្គភាពទាំង ១៤។[4] ស្ថាប័ននេះផ្ដល់នូវសេវាអប់រំថ្នាក់ឧត្តមសិក្សាមានដូចជា ថ្នាក់បរិញ្ញាបត្រ ថ្នាក់អនុបណ្ឌិត និងថ្នាក់បណ្ឌិត។ ទី៣ គឺស្ថាប័នឯកជននានា ដែលមិនទទួលបាននូវការឧបត្ថម្ភធនពីសំណាក់រដ្ឋាភិបាល។ ទី៤ គឺ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលមាននាទីផ្ដល់សេវាបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅគ្រប់កម្រិតមធ្យមសិក្សា និងឧត្តមសិក្សា។ ទី៥ គឺគណៈកម្មាធិការអភិវឌ្ឍន៍កុមារថ្នាក់ជាតិ ដែលដើរនាទីក្នុងការសម្របសម្រួលវិស័យអប់រំសម្រាប់កុមារតូចៗ ដែលមានមូលដ្ឋាននៅតាមទីសាធារណៈ និងនៅតាមសហគមន៍ក្រោមកិច្ចសហការជាមួយៈ ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងមហាផ្ទៃ, ក្រសួងសុខាភិបាល, និងក្រសួងកិច្ចការនារី។ ទី៦ គឺ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៅក្នុងប្រទេសកម្ពុជា ដែលធ្វើប្រតិបត្តិការនៅក្រោមទីស្ដីការគណៈរដ្ឋមន្ត្រី ហើយត្រូវបានត្រួតពិនិត្យដោយផ្ទាល់ពីខុទ្ទកាល័យរបស់នាយករដ្ឋមន្ត្រី។ ស្ថាប័ននេះទទួលខុសត្រូវចំពោះការទទួលស្គាល់គុណភាពនៃការអប់រំទាំងនៅគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន។

កម្រិតផ្សេងៗគ្នានៃការអប់រំនៅកម្ពុជាត្រូវបានរៀបចំទៅជាដំណាក់កាលដូចតទៅះ (១) ការថែទាំកុមារអាយុក្រោម ៦ ឆ្នាំនៅតាមផ្ទះ (២) ការអប់រំកុមារកម្រិតមុនចូលសាលារៀនចាប់ពីអាយុ ៣ឆ្នាំទៅ ៥ឆ្នាំ (៣) ការអប់រំថ្នាក់បឋមសិក្សាសម្រាប់កុមារអាយុពី ៦ ឆ្នាំ ទៅ ១១ ឆ្នាំ (៤) ការអប់រំថ្នាក់មធ្យមសិក្សា ដែលត្រូវបានបែងចែកជាពីរផ្នែក គឺមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិសម្រាប់សិស្សអាយុចាប់ពី ១២ ឆ្នាំទៅ ១៧ ឆ្នាំនិង (៥) ការអប់រំថ្នាក់ឧត្តមសិក្សាទាំង ៣ កម្រិត សម្រាប់និស្សិតចាប់ពីអាយុ ១៧ ឆ្នាំឡើងទៅ។ ស្របទៅនឹងរបត់ទូទៅនេះ សិស្សអាចជ្រើសរើសវគ្គបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិបាន។ វគ្គបណ្ដុះបណ្ដាលនេះ គឺអាចជ្រើសរើសបានចំពោះសិស្សចាប់ពីអាយុ ១៥ ឆ្នាំទៅ ១៧ ឆ្នាំ និស្សិតថ្នាក់ឧត្តមសិក្សា និងសិស្សទាំងអស់ដែលមានអាយុចាប់ពី ១៧ ឆ្នាំ ឡើងទៅ( **តារាង ១៨** )។ ក្រសួងអប់រំ យុវជន និងកីឡាមិនត្រឹមតែទទួលខុសត្រូវលើការអប់រំក្រៅប្រព័ន្ធ (កម្មវិធីអប់រំដែលមានតម្លៃប្រហាក់ប្រហែលនឹងការអប់រំផ្លូវការកម្មវិធីអប់រំអក្ខរកម្ម និងមជ្ឈមណ្ឌលបង្រៀនតាមសហគមន៍) ប៉ុណ្ណោះទេ តែថែមទាំងទទួលខុសត្រូវលើការបណ្ដុះបណ្ដាលគ្រូបង្រៀនផងដែរ។

## គោលនយោបាយអប់រំរបស់រដ្ឋាភិបាល

ចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៩០ មកគោលនយោបាយអភិវឌ្ឍន៍នៅកម្ពុជាត្រូវបានយកតាមផែនការ ៥ ឆ្នាំដែលមានឈ្មោះដើមថា «ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច (Economic Development Plans)» ហើយក្រោយមកត្រូវបានគេហៅថា«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(Naitonal Strategic Development Plans)»។ នៅឆ្នាំ២០០១ ដើម្បីឆ្លើយតបទៅនឹងផែនការជាតិទាំងនេះ ក្រសួងអប់រំយុវជន និងកីឡាបានតាក់តែង

**តារាង ១៨៖** អាយុ កម្រិត និងថ្នាក់នៃការអប់រំជាផ្លូវការនៅក្នុងប្រទេសកម្ពុជា

| អាយុកុមារ | ០ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០+ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្រិតនៃការអប់រំ | មុនចូលសាលារៀន | | | | | | បឋមសិក្សា | | | | | | មធ្យមសិក្សាៈ បឋមភូមិ | | | មធ្យមសិក្សាៈ ទុតិយភូមិ និងបណ្ដុះបណ្ដាល | | | ឧត្តមសិក្សា ឬកម្មវិធីអប់រំឧត្តមសិក្សាជាន់ខ្ពស់ | | |
| ថ្នាក់នៃការអប់រំ | ការថែទាំកុមារ | | | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ១ | ២ | ៣ | ៤ | ៥ | ៦ | ១ | ២ | ៣+ |

«ផែនការយុទ្ធសាស្ត្រអប់រំ (Education Strategic Plan)» រយៈពេល ៥ ឆ្នាំជាលើកដំបូងរបស់ខ្លួន។ រហូតមកដល់បច្ចុប្បន្ននេះ ផែនការនេះត្រូវបានកែសម្រួល២ដង (ESP ២០០៦-២០១០ និង ESP ២០០៩-២០១៣)។[5]

ដំណើការនៃការអភិវឌ្ឍគោលនយោបាយនេះត្រូវបានចាប់ផ្តើមនៅ ឆ្នាំ២០០១ ដោយមានការអនុម័តចេញនូវផែនការយុទ្ធសាស្ត្រអប់រំ ឆ្នាំ ២០០១ ដល់ឆ្នាំ ២០១៥ កម្មវិធីផ្តត់ផ្គង់វិស័យអប់រំ ឆ្នាំ ២០០១ ដល់ឆ្នាំ២០១៥ និងការអភិវឌ្ឍផែនការសកម្មភាពដែលមានឈ្មោះថា «ការអប់រំថ្នាក់ជាតិ ដើម្បីទាំងអស់គ្នា» នៅឆ្នាំ២០០៣។ កម្មវិធីទាំងបីនេះបានកំណត់គោលដៅនៃការអប់រំមួយចំនួនសម្រាប់កុមារកម្ពុជាទាំងអស់ ឲ្យសម្រេចបានត្រឹមឆ្នាំ ២០១៥។ ផែនការអប់រំជាយុទ្ធសាស្ត្រដំបូង(ESP)បានកំណត់គោលដៅរបស់រដ្ឋាភិបាល និងចក្ខុវិស័យពាក់កណ្តាលសម្រាប់ឆ្នាំ២០០១ ដល់ឆ្នាំ ២០០៥ ដូចតទៅ «...ដើម្បីអភិវឌ្ឍឲ្យបាននូវសេវាកម្មដែលមានគុណភាពខ្ពស់ និងងាយស្រួលទទួលយកបានសម្រាប់ទាំងអស់គ្នា ដោយមិនរើសអើងទ្រព្យសម្បត្តិ ភេទ ពូជសាសន៍ រូបរាង និងអត្តចរិតឡើយ» (ទំព័រទី៧, ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០១)។ ជាងនេះទៀត ផែនការសកម្មភាពជាក់ស្តែងត្រូវបានតាក់តែងឡើងដើម្បីបង្ហាញផ្នែកជាក់-លាក់មួយចំនួនដែលត្រូវអនុវត្តបន្ត។

ចក្ខុវិស័យទី២ (ផែនការយុទ្ធសាស្ត្រអប់រំ ឆ្នាំ២០០៦ ដល់ឆ្នាំ២០១០) ត្រូវបានបង្កើតឡើង ដើម្បីសម្រេចបានគោលដៅដែលបានកំណត់តាមរយៈការអនុវត្តគោល-នយោបាយជាតិចំនួន ៣ គឺ៖ (១) ការទទួលបានសេវាអប់រំប្រកបដោយសមធម៌ (២) ការធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការអប់រំ និង (៣) ការពង្រឹងសមត្ថភាពស្ថាប័នដែលផ្តល់សេវាអប់រំ។ បន្ទាប់មក ចក្ខុ-វិស័យទី៣ (ផែនការយុទ្ធសាស្ត្រអប់រំ ឆ្នាំ២០០៩ ដល់ឆ្នាំ ២០១៣) មានបំណងពន្លឿនកិច្ចខិតខំប្រឹងប្រែងក្នុងវិស័យនេះ ដើម្បីសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) និងផែនការជាតិនៃការអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ២០០៣ ដល់ ឆ្នាំ២០១៥។ ផ្នែកជាអាទិភាពទាំងបីរបស់ផែនការអប់រំទីពីរ ដែលនៅផ្នែកចុងក្រោយនៃផែនការយុទ្ធសាស្ត្រអប់រំ ឆ្នាំ២០០៩ ដល់ឆ្នាំ ២០១៣ គឺនៅដដែល ប៉ុន្តែផែនការនេះផ្តោតសំខាន់ទៅលើការពង្រីក ជាពិសេសលើវិស័យអប់រំសម្រាប់កុមារតូចៗ ការអប់រំថ្នាក់មធ្យមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសក្រៅប្រព័ន្ធ។

## វិស័យអប់រំឯកជននៅកម្ពុជា

វិស័យឯកជនកំពុងបង្កើនតួនាទីរបស់ខ្លួន នៅក្នុងការអប់រំកុមារក្នុងវ័យមុនចូលសាលា ខណៈដែលវិស័យនេះក៏កំពុងគ្របដណ្តប់យ៉ាងខ្លាំងក្នុងវិស័យឧត្តមសិក្សាផងដែរ។ កន្លងមក វិស័យអប់រំរបស់រដ្ឋឈានមុខគេនៅក្នុងប្រព័ន្ធអប់រំនៅកម្ពុជា។ ប៉ុន្តែ វិស័យអប់រំឯកជនក៏កំពុងរីកចម្រើន និងដើរតួយ៉ាងសំខាន់ ជាពិសេសក្នុងផ្នែកមត្តេយ្យសិក្សា (តួលេខបានកើនទ្វេរដង ច្រើនជាងមុន ពោលគឺពី៧,៧% ក្នុងឆ្នាំ២០០៤ ទៅ ១៩,១% ក្នុងឆ្នាំ២០១១)។ មកទល់នឹងបច្ចុប្បន្ននេះ វិស័យអប់រំថ្នាក់ឧត្តមសិក្សារបស់ឯកជនបានគ្របដណ្តប់លើសលុប គឺទទួលបានសិស្សរហូតដល់ ៧១,៩% ក្នុងចំណោមសិស្សសរុបនៅឆ្នាំ ២០១១ (**ក្រាហ្វិក ២៩**)។ ជាងមួយទសវត្សរ៍កន្លងទៅនេះ ចំនួននិស្សិតដែលចុះឈ្មោះចូលរៀននៅថ្នាក់ឧត្តមសិក្សាបានកើនឡើង ១០ ដង ពោលគឺពីចំនួន ៨.៤១៩នាក់ អំឡុងឆ្នាំ២០០១ ដល់ឆ្នាំ២០០២ ទៅដល់ចំនួន ១៤៦.៨៣៤ នាក់នៅអំឡុងឆ្នាំ ២០១១ ដល់ឆ្នាំ ២០១២។ ការអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សា (ដែលគ្របដណ្តប់ជាង ៩២% នៃចំនួនសិស្សទាំងអស់នៅ ឆ្នាំ២០១១) គឺសុទ្ធ-សឹងជាការអប់រំតាមគ្រឹះស្ថានរដ្ឋទាំងអស់ រីឯការចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានឯកជនបានកើនតិចតួច។ (**ក្រាហ្វិក ២៩**)

## លទ្ធផលនៃការអប់រំ

### អក្ខរកម្ម

**អក្ខរកម្មរបស់ប្រជាជនកម្ពុជាបានកើនឡើងមិនថាគិតតាម អាយុ ភេទ ទីតាំង ឬទីកន្លែងស្នាក់នៅនោះឡើយ។** អត្រានៃអ្នកដែលអាចអាន និងសសេរបានកើន

**ក្រាហ្វិក ២៩៖** បំណែងចែកនៃការចុះឈ្មោះចូលរៀនតាមសាលារដ្ឋ និងឯកជននៅកម្ពុជា ឆ្នាំ២០០៤-២០១១




**ប្រភព៖** អ.ស.ស.ក ឆ្នាំ២០០៤ និង២០១១។

ឡើងចាប់ពី ៦៤,២% ក្នុងឆ្នាំ២០០៤ ទៅ ៧០,៦% ក្នុងឆ្នាំ២០១១។ អត្រានៃអ្នកចេះអាននិងសរសេរចំពោះគ្រប់ក្រុមអាយុទាំងអស់មិនថា នៅទីប្រជុំជនឬជនបទបានកើនឡើងចំនួនពី ១០% ទៅ ១២%។ ការកើនឡើងនេះរួមបញ្ចូលទាំងបុរស និងស្ត្រី ព្រមទាំងអ្នកនៅក្រុមបញ្ចភាគអ្នកមានបំផុត និងអ្នកក្រីក្របំផុត(**តារាង ១៩**)។ ការកើនឡើងដ៏ធំបំផុតនៃអត្រាអ្នកចេះអាននិងសរសេរ គឺស្ថិតនៅក្នុងចំណោមមនុស្សនៅក្នុងក្រុមបញ្ចភាគមនុស្សចាស់នៅទីក្រុង និងអ្នកមានបំផុត(ដែលក្នុងនោះ មានភាគរយរៀងគ្នាគឺ ២៥,៦% និង ១៧,១%)។ ចំណែកឯក្រុមមនុស្សវ័យក្មេងវិញការកើនឡើងខ្លាំងជាងគេបំផុត គឺក្នុងចំណោមស្ត្រី និងនិងអ្នកដែលស្ថិតនៅក្នុងក្រុមបញ្ចភាគក្រីក្របំផុត (ប្រមាណជា ១៥%)។ ការបង្កើនកម្រិតនៃការអប់រំ (រួមបញ្ចូលទាំងអក្ខរកម្ម) គឺមានទំនាក់ទំនងខ្លាំងទៅនឹងការកាត់បន្ថយកម្រិតនៃភាពក្រីក្រ (ធនាគារពិភពលោកឆ្នាំ ២០០៧)។

**គិតមកដល់ឆ្នាំ២០១១ គេឃើញថា ពុំមានគម្លាតអក្ខរកម្មរវាងប្រភេទយេនឌ័រនៃក្រុមមនុស្សអាយុចាប់ពី ១៥ ដល់ ២៤ ឆ្នាំនោះឡើយ។** ជាការពិតណាស់ អត្រាស្ត្រីដែលអាចអាននិងសសេរបាន មិនត្រឹមតែបានប្រសើរឡើងពី ៧៦,៨% នៅក្នុង ឆ្នាំ២០០៤ ដល់ ៩១,៣% ក្នុងឆ្នាំ២០១១ នោះទេ តែថែមទាំងបានកាត់បន្ថយគម្លាតនៃយេនឌ័រនេះដល់ទៅតិចជាង ១% ទៀតផង បើធៀបនឹងគម្លាតដើមដែលមានដល់ទៅ ៧,៤%។គម្លាតអក្ខរកម្មសម្រាប់យុវវ័យ (ក្រុមដែលបានឆ្លុះបញ្ចាំងពីគោលនយោបាយនៃការអប់រំថ្មីៗជាច្រើន) ក៏បានកាត់បន្ថយផងដែរ ទាំងនៅទីក្រុង និងជនបទ និងទាំងអ្នកមានបំផុតនិងអ្នកក្រីក្របំផុត (**តារាង ១៩**)។

## ការសម្រេចបាននូវការអប់រំ

**ថ្វីបើការសម្រេចបាននូវការអប់រំរបស់ពលរដ្ឋកម្ពុជាដែលមានអាយុពី ២៥ ឆ្នាំឡើងទៅបានប្រសើរឡើងក្តី បញ្ហាទាក់ទងនឹងគម្លាតអប់រំនៅតែបន្តកើតមាន។** ការសម្រេចបាននូវការអប់រំរបស់មនុស្សពេញវ័យនេះ ជាសមិទ្ធិផលដែលកើតចេញពីកត្តាពីរយ៉ាងគឺ ការអនុវត្តគោលនយោបាយកន្លងមក និងការកែលម្អជាបន្តបន្ទាប់។ គេត្រូវការរយៈពេលយូរទើបអាចមើលឃើញអំពីសមិទ្ធិផលបែបនេះ។ ដោយហេតុនេះ នៅពេលវាយតម្លៃសក្តានុពលធនធានមនុស្សកម្ពុជា គេដឹងថា ផលិតភាពការងារគឺពាក់ព័ន្ធនឹងសន្និធិ (ស្តុក) ធនធានមនុស្សបច្ចុប្បន្ន។ ដូច្នេះ ជាការសំខាន់ណាស់ដែលត្រូវកត់សម្គាល់ចំពោះការទទួលបានការអប់រំទាបរបស់ក្រុមស្ត្រី អ្នករស់នៅតាមជនបទ និងជនក្រីក្រ (**ក្រាហ្វិក ៣០**)។ ក្នុងចំណោមគ្រួសារនៅជនបទ និងអ្នកក្រីក្រ គម្លាតនៃការអប់រំមានការកើន

ឡើងសម្រាប់ ថ្នាក់ទី៣ ឡើងទៅ។ ជាឧទាហរណ៍ ស្ថានភាពពលរដ្ឋនៅតាមជនបទអាចរៀនដល់ថ្នាក់ទី៦ គឺមានចំនួនតិចជាងពាក់កណ្តាល បើប្រៀបធៀបនឹងអ្នកនៅទីក្រុង ហើយក្នុងចំណោមក្រុមបញ្ចភាគក្រីក្រការដែលពលរដ្ឋរៀនបញ្ចប់ដល់ថ្នាក់ទី ៦ នោះ គឺមានចំនួនតិចជាងមួយភាគបី បើប្រៀបធៀបនិងអ្នកមាន។[6]

**គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់កម្រិតសិក្សារបស់កុមារីបានសម្រេចនូវសមភាពដោយជោគជ័យ បើប្រៀបធៀបជាមួយនឹងកម្រិតសិក្សារបស់កុមារា។** កម្មវិធីអាហារូបករណ៍ និងកម្មវិធីអប់រំផ្សេងៗទៀតដែលផ្តោតសំខាន់ទៅលើក្រុមគោលដៅដែលជាកុមារីអំឡុងប៉ុន្មានឆ្នាំកន្លងមកនេះ បានធ្វើឲ្យការចុះឈ្មោះចូលរៀនរបស់កុមារីមានលក្ខណៈល្អប្រសើរជាងមុន និងបានបំពេញតាមគោលដៅដែលលើកឡើងថា មុនឆ្នាំ ២០១១ នឹងគ្មានភាពខុសគ្នាទៀតឡើយនូវកម្រិតនៃការអប់រំរវាងបុរស និងស្ត្រីចន្លោះពីអាយុ ១៥ ឆ្នាំទៅ ២០ ឆ្នាំ(**ក្រាហ្វិក ៣១**)។

**ការសម្រេចបាននូវការអប់រំសម្រាប់មនុស្សវ័យជំទង់ត្រូវបានធ្វើឱ្យប្រសើរឡើងសម្រាប់ក្រុមទាំងអស់ និងវិសមភាពត្រូវបានកាត់បន្ថយ។** មនុស្សវ័យជំទង់ដែលមានអាយុចន្លោះពី ១៥ ឆ្នាំទៅ ២០ ឆ្នាំត្រូវបានបង្ហាញថាមានភាពប្រសើរឡើងគួរឲ្យកត់សម្គាល់នៅក្នុងវិស័យអប់រំ។ ជាឧទហរណ៍ ៩៦ ភាគរយបានបញ្ចប់ថ្នាក់ដំបូង (៧៦ ភាគរយ សម្រាប់ក្រុមក្មេងជំទង់ដែលមានវ័យចំណាស់ជាង) និង ៧៥ ភាគរយបានបញ្ចប់ថ្នាក់ទី៦ (៣៨ ភាគរយសម្រាប់ក្រុមក្មេងជំទង់ដែលមានវ័យចំណាស់ជាង) និង ៣៦ ភាគរយបានបញ្ចប់មធ្យមសិក្សាបឋមភូមិ (១៧ ភាគរយសម្រាប់ក្រុមក្មេងជំទង់ដែលមានវ័យចំណាស់

**តារាង ១៩៖** អត្រាអក្ខរកម្មតាមក្រុមអាយុ ទីក្រុង-ជនបទ យេនឌ័រ និងស្ថានភាពក្រីក្រនៅកម្ពុជា ឆ្នាំ២០០៤-២០១១

| ក្រុម | យុវជន (១៥ ដល់ ២៤ ឆ្នាំ) | | | មនុស្សពេញវ័យ (១៥ ឆ្នាំ ឡើងទៅ) | | | មនុស្សវ័យចំណាស់ (៦៥ ឆ្នាំ ឡើងទៅ) | | |
|---|---|---|---|---|---|---|---|---|---|
| | ២០០៤ | ២០១១ | បម្រែបម្រួល | ២០០៤ | ២០១១ | បម្រែបម្រួល | ២០០៤ | ២០១១ | បម្រែបម្រួល |
| ទីក្រុង | ៨៩,៧% | ៩៦,៩% | ៧,២% | ៨១,៧% | ៩២,៣% | ១០,៦% | ៤៥,៥% | ៧១,០% | ២៥,៦% |
| ជនបទ | ៧៨,៥% | ៩០,២% | ១១,៦% | ៦៦,៥% | ៧៥,៧% | ៩,២% | ៣១,៧% | ៤១,៨% | ១០,០% |
| **គម្លាត** | **១១,២%** | **៦,៨%** | **-៤,៤%** | **១៥,២%** | **១៦,៥%** | **១,៤%** | **១៣,៧%** | **២៩,២%** | **១៥,៥%** |
| បុរស | ៨៤,២% | ៩១,៩% | ៧,៧% | ៨០,២% | ៨៧,៦% | ៧,៤% | ៦៣,៧% | ៧៥,៨% | ១២,១% |
| ស្ត្រី | ៧៦,៨% | ៩១,៣% | ១៤,៥% | ៥៩,៤% | ៧២,១% | ១២,៧% | ១៣,១% | ២៦,០% | ១២,៩% |
| **គម្លាត** | **៧,៤%** | **០,៦%** | **-៦,៨%** | **២០,៩%** | **១៥,៥%** | **-៥,៣%** | **៥០,៦%** | **៤៩,៨%** | **-០,៨%** |
| អ្នកមានបំផុត | ៩៣,៨% | ៩៧,៥% | ៣,៧% | ៨៤,៥% | ៩០,៣% | ៥,៨% | ៤៤,៤% | ៦១,៥% | ១៧,១% |
| អ្នកក្របំផុត | ៦៥,៥% | ៨០,៦% | ១៥,២% | ៥៣,៦% | ៦៤,៦% | ១១,០% | ២២,៤% | ៣២,២% | ៩,៨% |
| **គម្លាត** | **២៨,៣%** | **១៦,៩%** | **-១១,៤%** | **៣០,៨%** | **២៥,៧%** | **-៥,១%** | **២២,០%** | **២៩,៣%** | **៧,៣%** |
| **សរុប** | **៨០,៥%** | **៩១,៦%** | **១១,១%** | **៦៩,០%** | **៧៩,៣%** | **១០,៣%** | **៣៣,៨%** | **៤៥,៩%** | **១២,១%** |

**ប្រភព៖** ការប៉ាន់ស្មានរបស់បុគ្គលិកនៃធនាគារពិភពលោក ដោយផ្អែកតាម អ.ស.ស.កឆ្នាំ២០០៤ និងឆ្នាំ២០១១។

**ក្រាហ្វិក ៣០៖** ការសម្រេចបាននូវការអប់រំ ដោយក្រុមអ្នកដែលមានអាយុចាប់ពី២៥ ឆ្នាំឡើងទៅ




**ប្រភព៖** ការប៉ាន់ស្មានរបស់បុគ្គលិកនៃធនាគារពិភពលោក ផ្អែកតាម អ.ស.ស.ក ឆ្នាំ២០០៤ និង២០១១។

ជាង)។ ឥទ្ធិពលដែលបណ្តាលមកពីភាពខុសគ្នានៃទីតាំងស្នាក់នៅរបស់ពលរដ្ឋ (ដែលច្រើនកើតមានចំពោះតំបន់ទីប្រជុំជននិងជនបទ) បានថមថយ ជាមធ្យមចំនួន ១៧ ពិន្ទុភាគរយ ចំពោះការអប់រំក្នុងរយៈពេល ៧ ឆ្នាំដំបូង ប៉ុន្តែពុំប្រែប្រួលទេ ចំពោះថ្នាក់ក្រោយៗទៀត។ គម្លាតនៃការអប់រំរវាងអ្នកក្រីក្របំផុត និងអ្នកមានបំផុតក៏ត្រូវបានកាត់បន្ថយផងដែរ គឺបាន១៧ពិន្ទុភាគរយ ប៉ុន្តែបានតែសម្រាប់រយៈពេល ៥ ឆ្នាំដំបូងនៃការអប់រំប៉ុណ្ណោះ។ សិស្សដែលមានជីវភាពធូធារបំផុតបានទទួលការអប់រំច្រើនជាងសិស្សក្រីក្រចាប់ពីថ្នាក់ទី ៦ដល់ថ្នាក់ទី ១២។ ជាការពិតគម្លាតនេះបានកើនឡើងជាមធ្យម ១៤ ពិន្ទុភាគរយ (**ក្រាហ្វិក ៣១**)។

**កុមារវ័យក្មេងដែលមកពីក្រុមជនជាតិភាគតិច តាមមូលដ្ឋានបានទទួលការអប់រំទាបនៅគ្រប់កម្រិត គិតចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២។** ភាពមិនអំណោយផលជាក់លាក់មួយចំនួនបានដាក់បន្ទុកចំពោះកុមារជនជាតិភាគតិចក្នុងប្រទេសកម្ពុជា។ ភាពមិនអំណោយផលនេះត្រូវបានកត់សម្គាល់ថា ចាប់ផ្តើមមានតាំងពីថ្នាក់ទី ១ ដោយកម្រិតនៃការអប់រំសម្រេចបានត្រឹមតែ ៧៥,៥ភាគរយតែប៉ុណ្ណោះ ដែលនេះជាកម្រិតទាបខ្លាំង គឺទាបជាងសូម្បីតែកុមារដែលមកពីគ្រួសារក្រីក្របំផុតទៅទៀត (ដែលតួលេខមានដល់ទៅ ៩០,៨ ភាគរយ)។ បញ្ហានេះបានបន្តទៅលើគ្រប់កម្រិតទាំងអស់នៃការអប់រំនៅថ្នាក់បឋមសិក្សាសម្រាប់កុមារជនជាតិភាគតិច។ ពួកគេទទួលបានការអប់រំទាបជាងកុមារដែលក្រីក្របំផុតនៅគ្រប់កម្រិតទាំង

អស់រហូតដល់ថ្នាក់ទី ៦ (គឺទាបជាងអត្រាទទួលបានការអប់រំរបស់កុមារដែលក្រីក្របំផុតនៅកម្ពុជា ក្នុងចំនួនជាមធ្យម១៤,២ពិន្ទុភាគរយ)។ ស្ថានភាពទទួលបានការអប់រំថ្នាក់បឋមសិក្សារបស់កុមារមកពីក្រុមជនជាតិភាគតិចផ្សេងៗទៀត ជាមធ្យមពុំសូវមានភាពខុសគ្នាជាងកុមារកម្ពុជាឡើយ ប៉ុន្តែស្ថានភាពនៃការទទួលបាននូវការអប់រំថ្នាក់មធ្យមសិក្សារបស់ពួកគេ គឺមានចំនួនទាបជាងច្រើន។

## អត្រាចុះឈ្មោះចូលរៀន

វិធីសាស្ត្រនៃការគណនាអត្រាចុះឈ្មោះចូលរៀនជាធម្មតាមានពីរបៀប គឺតាមរយៈការគណនាលើការចុះឈ្មោះចូលរៀនដុល និងអត្រាចុះឈ្មោះចូលរៀនសុទ្ធ។ អត្រាចុះឈ្មោះចូលរៀនដុលគឺត្រូវបានកំណត់ដោយយកចំនួនសិស្សដែលចូលរៀនទាំងអស់ (ដោយមិនគិតពីអាយុ) ចែកនឹងចំនួនអ្នកដែលគួរតែចូលរៀន ដោយយោងទៅតាមអាយុ។ អត្រាចុះឈ្មោះចូលរៀនសុទ្ធ គឺត្រូវបានកំណត់ដោយយកចំនួនសិស្ស ដែលមានអាយុសមល្មមក្នុងការចូលរៀន (មិនមែនសិស្សទាំងអស់នោះទេ) ចែកនឹងចំនួនអ្នកដែលគួរតែចូលរៀនដោយយោងទៅតាមអាយុ។ អត្រាចុះឈ្មោះចូលរៀនដុលអាចត្រូវបានបកស្រាយថា ជាចំនួនសរុបរបស់អ្នកដែលចូលរៀន។ រីឯអត្រាចុះឈ្មោះចូលរៀនសុទ្ធ គឺជាចំនួនសិស្សដែលចូលរៀននៅកម្រិតថ្នាក់ដែលសាកសមនឹងអាយុរបស់ពួកគេ។[7] លើសពីនេះទៅទៀត មានវិធីសាស្ត្រពីរយ៉ាងដែលអាចធ្វើបានដើម្បីឲ្យនិយមន័យទៅលើអត្រាចុះឈ្មោះចូលរៀនសុទ្ធសម្រាប់កម្រិតបឋមសិក្សា ឬមធ្យមសិក្សាទាំងមូល។ សម្រាប់ការសិក្សានេះ និយមន័យជាក់លាក់មួយនៃអត្រាចុះឈ្មោះចូលរៀនសុទ្ធ (**ប្រអប់ ៤**) ត្រូវបានជ្រើសរើសដោយសារតែវាអាចវាងឥទ្ធិពលពីការចូលរៀនយឺត និងការរៀនត្រួត-

**ក្រាហ្វិក ៣១៖** ការសម្រេចបានការអប់រំ ដោយក្រុមអ្នកដែលមានអាយុចាប់ពី ២៥ ឆ្នាំឡើងទៅ នៅកម្ពុជាក្នុងឆ្នាំ២០១១




**ប្រភព៖** ការប៉ាន់ស្មានរបស់បុគ្គលិកនៃធនាគារពិភពលោក។

ថ្នាក់ដែលជាបញ្ហាប្រឈមពីរនៅក្នុងវិស័យអប់រំនៅកម្ពុជា។

**អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅក្នុងប្រទេសកម្ពុជា (ដោយប្រើនិយមន័យជាក់លាក់ខាងលើ) មានកម្រិតប្រសើរឡើងខ្លាំងនៅគ្រប់កម្រិតសិក្សាទាំងអស់។** ចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ២០១១ អត្រាចុះឈ្មោះចូលរៀនសុទ្ធសម្រាប់សិស្សបឋមសិក្សាបានកើនឡើងជាងពាក់កណ្តាល (ពោលគឺពី ៣០,៦ ភាគរយទៅ ៤៨,៨ ភាគរយ) អត្រាចុះឈ្មោះចូលរៀនថ្នាក់មធ្យមសិក្សាក៏មានការកើនឡើងលើសពីពីរដង (ពោលគឺពី ៨,១ ភាគរយ ទៅ២០ ភាគរយ) ផងដែរ។ ខណៈពេលស្ថានភាពអត្រានេះមានលក្ខណៈល្អប្រសើរឡើងគ្រប់កម្រិតបែបនេះ ការបោះបង់ចោលសាលាពីថ្នាក់ទី ៤ ទៅថ្នាក់ទី៥ និងទី៦ ក៏ស្ទើរតែគ្មានផងដែរ។ ស្រដៀងគ្នាទៅនឹងបណ្តាប្រទេសទាំងអស់លើសកលលោកដែលបានពង្រីកការគ្របដណ្តប់នៃវិស័យអប់រំរបស់ពួកគេ អត្រាចុះឈ្មោះចូលរៀនដុលនៅក្នុងប្រទេសកម្ពុជា គឺមានការលំបាកក្នុងការបកស្រាយឬឲ្យនិយមន័យ។ ជាឧទាហរណ៍ ចំនួនកុមារដែលនៅមានវត្តមានក្នុងសាលារៀនជាកត្តាដែលធ្វើឲ្យអត្រាចុះឈ្មោះចូលរៀនកើនឡើង ប៉ុន្តែចំនួនអ្នកដែលត្រួតថ្នាក់ និងអ្នកដែលចុះឈ្មោះចូលរៀនយឺត ក៏ធ្វើឲ្យអត្រាចុះឈ្មោះចូលរៀនដុលមានការកើនឡើងផងដែរ។ ប៉ុន្តែចំនួនកុមារដែលចាប់ផ្តើមចូលរៀនថ្នាក់ដំបូងនៅអាយុសមរម្យណាមួយ ក៏អាចបន្ថយចំនួននៃការចុះឈ្មោះចូលរៀនដុលសម្រាប់ថ្នាក់ដំបូងផងដែរ។

**ដោយសារតែអត្រាចុះឈ្មោះចូលរៀននៅមានកម្រិតទាបនៅឡើយក្នុងពេលកន្លងមក ដូចនេះហើយស្ថានភាពដែលបានរៀបរាប់ខាងលើថា បានប្រសើរឡើងនោះគឺនៅមិនគ្រប់គ្រាន់នោះទេ ហើយអត្រាចុះឈ្មោះចូលរៀនសុទ្ធក៏នៅទាបផងដែរ។** ប្រទេសកម្ពុជាបាននិងកំពុងធ្វើឲ្យអត្រាចុះឈ្មោះចូលរៀនសុទ្ធបានប្រសើរឡើងយ៉ាងឆាប់រហ័ស នៅក្នុងការអប់រំទាំងថ្នាក់បឋមសិក្សានិងមធ្យមសិក្សា ក្នុងរយៈពេលជាង ៧ ឆ្នាំចុងក្រោយនេះ (ចំពោះថ្នាក់បឋម ជាមធ្យម មានការកើនឡើង ២,៧ ភាគរយជារៀងរាល់ឆ្នាំ និងថ្នាក់មធ្យមសិក្សាមានការកើនឡើង ១,៧ ភាគរយជារៀងរាល់ឆ្នាំ)។ ទោះជាយ៉ាងណាក៏ដោយ អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅតែមានកម្រិតទាប នៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ ២០១១ ដោយអាត្រានេះបិតក្រោម ៤០ ភាគរយ បន្ទាប់ពីថ្នាក់ទី៣ និងក្រោម ២៥ ភាគរយ បន្ទាប់ពីថ្នាក់ទី ៦ (**ក្រាហ្វិក ៣២**)។

**កុមារដែលគ្រប់អាយុជាង ៣០ ភាគរយមិនបានចូលរៀនថ្នាក់ទី ១ នោះទេ លើសពីនេះទៀត អត្រាអ្នក**

**ក្រាហ្វិក ៣២៖** អត្រាចុះឈ្មោះចូលរៀនសុទ្ធ និងអត្រាចុះឈ្មោះចូលរៀនដុល នៅក្នុងប្រទេសកម្ពុជាឆ្នាំ ២០០៤ និងឆ្នាំ២០១១




**ប្រភព៖** ការប៉ាន់ស្មានរបស់បុគ្គលិកនៃធនាគារពិភពលោកផ្អែកលើអ.ស.ស.ក។

## ប្រអប់ ៤៖ ការគណនាអត្រាចុះឈ្មោះចូលរៀនសុទ្ធ

អត្រាចុះឈ្មោះចូលរៀនសុទ្ធ (Net Enrollment Rate ឬ NER) អាចមានការប្រែប្រួលយ៉ាងខ្លាំង ទៅតាមនិយមន័យដែលយកមកប្រើ។ និយមន័យចង្អៀតនៃអត្រាចុះឈ្មោះចូលរៀនសុទ្ធគឺ៖ ចំនួនសិស្សចូលរៀនតាមកម្រិតថ្នាក់ ដែលសមស្របនឹងអាយុចូលរៀនរបស់សិស្ស។[ក]

$$NER^{ទី១} = \frac{\text{ចំនួនសិស្សអាយុ ៦ ឆ្នាំ ដែលរៀនថ្នាក់ទី១}}{\text{ចំនួនកុមារអាយុ ៦ ឆ្នាំ ដែលចុះឈ្មោះកាលពីដើមឆ្នាំ}} \times ១០០$$

មធ្យមទម្ងន់តាមថ្នាក់ ពីទី ១ ដល់ទី ៦ ត្រូវបានគណនា ដើម្បីប៉ាន់ស្មានអត្រាចុះឈ្មោះចូលរៀនសុទ្ធនៅកម្រិតបឋម។[ខ]

**អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅកម្រិតបឋម (ជាក់លាក់) = មធ្យម($NER^{ទី១}$, $NER^{ទី២}$, $NER^{ទី៣}$, $NER^{ទី៤}$, $NER^{ទី៥}$, $NER^{ទី៦}$)**

គេក៏ប្រើប្រាស់និយមន័យបែបធូរលុងជាងនេះ (ដោយប្រើប្រាស់កម្រិតអប់រំ (បឋមឬទុតិយភូមិ) សម្រាប់ជាឯកតាវាស់ស្ទង់) ផងដែរនៅពេលខ្លះ៖

$$\text{អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅកម្រិតបឋម (ងាយ)} = \frac{\text{ចំនួនសិស្សអាយុ ៦ ដល់ ១១ ឆ្នាំ ដែលរៀនថ្នាក់ទី១}}{\text{ចំនួនកុមារអាយុ ៦ ដល់ ១១ ឆ្នាំ ដែលចុះឈ្មោះកាលពីដើមឆ្នាំ}} \times ១០០$$

អត្រាចុះឈ្មោះចូលរៀនសុទ្ធ "ជាក់លាក់" ប្រើកម្រិតថ្នាក់ជាខ្នាតក្នុងការវាស់ការរៀនត្រួតថ្នាក់ និងការចុះឈ្មោះចូលរៀនយឺត គឺមានភាពត្រឹមត្រូវជាង។ អត្រាចុះឈ្មោះចូលរៀនសុទ្ធ ដោយប្រើកម្រិតបឋមសិក្សា ឬមធ្យមសិក្សាដែលជាខ្នាត ក្នុងការវាស់មិនបានចាប់យកអត្រារៀនត្រួតថ្នាក់រហូតទាល់តែសិស្សមានអាយុ ១២ ឆ្នាំ (សំរាប់បឋមសិក្សា)។ លើសពីនេះទៅទៀត មធ្យោបាយនេះមិនអាចកំណត់អត្តសញ្ញាណសិស្ស ដែលចុះឈ្មោះចូលរៀនយឺតបានទេ។

រដ្ឋាភិបាលប្រើនិយមន័យ "ងាយ" ដើម្បីរាយការណ៍អំពីអត្រាចុះឈ្មោះចូលរៀនសុទ្ធ។ អត្រារាយការណ៍ដោយស្ថាប័នអន្តរជាតិស្នើឱ្យប្រើប្រាស់ការអប់រំកម្រិតជាជាងថ្នាក់ជាឯកតា នៃការវាស់វែង។ វិធានគណនាទាំងពីរនេះត្រូវបានគេរាយការណ៍សម្រាប់ធ្វើការប្រៀបធៀប និងធ្វើឲ្យមានទំនាក់ទំនងនឹងស្ថិតិជាផ្លូវការរបស់រដ្ឋាភិបាល។ រាល់អត្រាចុះឈ្មោះចូលរៀនសុទ្ធទាំងអស់ ដែលមានក្នុងរបាយការណ៍នេះ គឺត្រូវបានប្រើដោយនិយមន័យ "ជាក់-លាក់" ។

**អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅបឋមសិក្សានិងមធ្យមសិក្សាដោយប្រើនិយមន័យ "ជាក់លាក់" និង "ងាយ" កម្ពុជា ឆ្នាំ២០០៤-២០១១**




ក អាយុចាប់ផ្តើមនៃឆ្នាំសិក្សា ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា

ខ ចែកនឹងចំនួននៃកុមារ។

**ឡើងថ្នាក់ក៏មានកម្រិតទាបនៅឡើយ សម្រាប់កម្រិតបឋមសិក្សាដែលកត្តាទាំងពីរនេះធ្វើឲ្យអត្រាចុះឈ្មោះចូលរៀនសុទ្ធសម្រាប់ថ្នាក់ទី ៦ នៅមានកម្រិតទាប (៣៧,៤ ភាគរយ )** (**ក្រាហ្វិក ៣២**)។ ការឡើងថ្នាក់ពីថ្នាក់ទី ៦ ទៅថ្នាក់ទី ៧ បង្កើតឲ្យមានបញ្ហាប្រឈមមុខពីរសម្រាប់សិស្ស ៖ ទីមួយ គឺតម្រូវការនៃការប្រលងថ្នាក់ជាតិឲ្យជាប់នៅចុងបញ្ចប់នៃថ្នាក់ទី៦នោះ ទីពីរគឺថា សម្ភារៈបរិក្ខារនៃការអប់រំសម្រាប់ថ្នាក់មធ្យមសិក្សា គឺមានតិចជាងនៅកម្រិតបឋមសិក្សា។ ដូច្នេះការធ្លាក់ចុះនៃការចុះឈ្មោះចូលរៀនរវាងថ្នាក់ទី ៦ និងថ្នាក់ទី ៧ (ម្នាក់ក្នុងចំណោមសិស្សបីនាក់) គឺជាលទ្ធផលនៃកត្តាផ្គត់ផ្គង់ និងតម្រូវការ។ ប៉ុន្តែ បញ្ហានេះមិនកើតមានសម្រាប់ការអប់រំកម្រិតបឋមសិក្សានោះទេព្រោះថា ៖ មិនមានតម្រូវការជាក់លាក់ណាមួយដើម្បីឡើងពីថ្នាក់ទីមួយទៅថ្នាក់បន្ទាប់នោះឡើយ ហើយជាធម្មតា លទ្ធភាពនៃការចូលរៀនគ្រប់កម្រិតទាំងអស់នៃកម្រិតបឋមសិក្សា គឺដូចៗគ្នាទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងឆ្នាំ២០១១ មានសិស្សចំនួន ៤ នាក់ក្នុងចំណោមសិស្សចំនួន១០នាក់ រៀននៅថ្នាក់ទីមួយ មិនបានចូលរៀននៅថ្នាក់ទី ៤ ទេ។ កត្តាដែលរួមចំណែកដល់ស្ថិតិនេះ រួមមាន ការត្រួតថ្នាក់ និងការបោះបង់ចោលសាលា បន្ទាប់ពីសិស្សអាចអាន និងសរសេរនៅកម្រិតមូលដ្ឋានបានហើយនោះ។ ទោះជាយ៉ាងនេះក្តី ពុំមានហេតុផលណាមួយច្បាស់លាស់សម្រាប់ពន្យល់អំពីអត្រាធ្លាក់ចុះនេះឡើយ។ អត្រាបោះបង់ចោលសាលា និងនិន្នាការរៀនត្រួតថ្នាក់មិនត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មាននៃវិស័យអប់រំ (EMIS) ឡើយ។[8]

**អត្រាចុះឈ្មោះចូលរៀនសម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សាគ្រប់កម្រិតទាំងអស់មានលក្ខណៈល្អប្រសើរជាងមុន** ដោយមិនគិតពីទីកន្លែងស្នាក់នៅ យេនឌ័រ ឬស្ថានភាពទ្រព្យសម្បត្តិឡើយ។ ហើយអត្រាចុះឈ្មោះចូលរៀនសុទ្ធរបស់កុមារី គឺមានកម្រិតខ្ពស់ជាងកុមារាបន្តិចចាប់តាំងពីឆ្នាំ២០០៧ ទាំងនៅក្នុងកម្រិតអប់រំថ្នាក់បឋមសិក្សានិងមធ្យមសិក្សា។

**កុមារដែលមកពីគ្រួសារក្រីក្របំផុតកំពុងត្រូវបានគេមិនរវីរវល់ ក្នុងការឲ្យចុះឈ្មោះចូលរៀននៅថ្នាក់ដំបូង។** កត្តាទ្រព្យសម្បត្តិ និងការអប់រំនៅក្នុងប្រទេសកម្ពុជា ត្រូវបានគេមើលឃើញថា មានទំនាក់ទំនងគ្នាយ៉ាងច្បាស់ ហើយភាពខុសគ្នាដ៏ធំបំផុតនៃអត្រាចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សា គឺកើតមានក្នុងចំណោមកុមារដែលក្រីក្របំផុត។ ជាមួយនឹងអត្រាតែ ៣៤,៤ ភាគរយនៃអត្រាចុះឈ្មោះចូលរៀនសុទ្ធ កុមារក្រីក្របំផុតគឺជាក្រុមតែមួយគត់ដែលស្ថិតនៅខាងក្រោមកម្រិតមធ្យមថ្នាក់ជាតិ។ សូម្បីតែកុមារនៅក្នុងក្រុមដែលមានទ្រព្យសម្បត្តិបន្ទាប់ ក៏អត្រាចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សាសុទ្ធរបស់ពួកគេលើសពីកម្រិតមធ្យមថ្នាក់ជាតិផងដែរ (**សូមមើលតារាងទី ២០**)។

**លើកលែងស្ថានភាពយេនឌ័រចេញ អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅកម្រិតមធ្យមសិក្សាបានបង្ហាញពីគម្លាត**

**តារាង ២០៖ អត្រាចុះឈ្មោះចូលរៀនសុទ្ធសម្រាប់កម្រិតបឋមសិក្សា និងមធ្យមសិក្សាក្នុងប្រទេសកម្ពុជាឆ្នាំ២០១១**

| | ទីកន្លែងស្នាក់អាស្រ័យ | | | យេនឌ័រ | | ស្ថានភាពទ្រព្យសម្បត្តិទៅតាមក្រុមបញ្ចភាគ | | | | | ជាតិ |
|---|---|---|---|---|---|---|---|---|---|---|---|
| | ភ្នំពេញ | ទីក្រុង | ជនបទ | ប្រុស | ស្រី | អ្នកក្របំផុត | ក្រុមបញ្ចភាគទី២ | ក្រុមបញ្ចភាគទី៣ | ក្រុមបញ្ចភាគទី៤ | អ្នកមានបំផុត | |
| បឋមសិក្សា | ៦៧,៣% | ៥៨,០% | ៤៨,៨% | ៤៧,៣% | ៥០,៤% | ៣៤,៤% | ៤៩,៦% | ៥០,៤% | ៥៨,៣% | ៦២,៩% | ៤៨,៨% |
| មធ្យមសិក្សា (គ្រប់កម្រិត) | ៥០,២% | ២៨,៣% | ១៥,៤% | ១៨,៨% | ២១,២% | ៥,៦% | ១៣,៧% | ១៤,៨% | ២៧,៧% | ៤៥,៤% | ២០,០% |
| ថ្នាក់ទី៩ | ៦០,០% | ៣០,៦ % | ១៧,៤ % | ១៧,៧ % | ២៥,៥% | ៤,២% | ១៥,៧ % | ២០,១% | ២៦,៧ % | ៥១,៥% | ២១,៥% |
| ថ្នាក់ទី១២ | ៤៣,៦ % | ១៦,៦ % | ៩,១% | ១៣,៩% | ១៤,០% | ៥,៣% | ៥,៧ % | ៩,៤ % | ១១,១% | ៣៥,៥ % | ១៤,០ % |

**ប្រភព៖** ការប៉ាន់ស្មានរបស់បុគ្គលិកនៃធនាគារពិភពលោកផ្អែកលើអ.ស.ស.ក។

ដ៏គួរឲ្យកត់សម្គាល់។ អត្រារៀនធ្លាក់ និងរៀនត្រួតថ្នាក់ គឺកើតឡើងច្រើន ក្នុងចំណោមអ្នកដែលរស់នៅតាមជនបទ អ្នកក្រីក្រ និងអ្នកមានជីវភាពមធ្យម។ នៅក្នុងឆ្នាំ ២០១១ អត្រាចុះឈ្មោះចូលរៀនសុទ្ធ នៅថ្នាក់មធ្យមសិក្សា ក្នុងរាជធានីភ្នំពេញ គឺមានចំនួនបីដងខ្ពស់ជាងអ្នកដែលនៅជនបទ (បើប្រៀបធៀបទៅនឹងកម្រិតបឋមសិក្សា ដែលមានតែមួយភាគបីតែប៉ុណ្ណោះ)។ លើសពីនេះទៀត កុមារនៅក្រុមបញ្ចភាគមានជាងគេបំផុត មានអត្រាចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សាលើសពី ៨ ដងនៃអ្នកដែលស្ថិតនៅក្រុមបញ្ចភាគក្រីក្របំផុត (ប៉ុន្តែ តិចជាង ២ដងក្នុងកម្រិតបឋមសិក្សា) និងជាង ៣ ដងនៃអ្នកដែលស្ថិតនៅក្រុមបញ្ចភាគកណ្តាល (ប៉ុន្តែមានតែមួយភាគបួននៅក្នុងកម្រិតបឋមសិក្សា)។

## លក្ខណៈនៃការអប់រំ

### ការចុះឈ្មោះចូលរៀនតាមអាយុ

**ការចុះឈ្មោះចូលរៀន និងទ្រព្យសម្បត្តិគឺមានទំនាក់ទំនងដ៏រឹងមាំរវាងគ្នា ដែលនេះអាចមើលឃើញថា ចាប់ផ្តើមសម្រាប់សិស្សមានអាយុ១១ ឆ្នាំឡើងទៅ។** បើទោះបីជាគម្លាតនៃការចុះឈ្មោះចូលរៀនរវាងកុមារក្រីក្របំផុត និងកុមារមានបំផុតចាប់ពីអាយុ ៧ ឆ្នាំ ទៅ អាយុ ១១ឆ្នាំ មានអត្រាតិចជាង ១០ ភាគរយក៏ដោយ ក៏សម្រាប់កុមារនៅអាយុ១២ឆ្នាំ គម្លាតត្រូវបានគេមើលឃើញថា បានកើនឡើងដល់ទៅ ១៨ ភាគរយ។ នៅអាយុ ១៨ ឆ្នាំ គម្លាតបានកើនឡើងដល់ទៅ ៥៧ ភាគរយ (**ក្រាហ្វិក ៣៣d**)។ (និន្នាការស្រដៀងគ្នានេះដែរ ក៏ត្រូវបានរកឃើញនៅគ្រប់ក្រុមបញ្ចភាគអ្នកមានទ្រព្យសម្បត្តិទាំងអស់ផងដែរ)។ ស្ថានភាពអត្រាវត្តមានក្នុងចំណោមសិស្សប្រុស និងសិស្សស្រី គឺមិនមានសភាពខុសគ្នានោះទេ។ភាពខុសគ្នារវាងគ្រួសារនៅទីក្រុង និងគ្រួសារនៅជនបទ គឺមានតិចតួច បើគិតចាប់ពីសិស្សចូលរៀនដល់អាយុ ១៣ ឆ្នាំ (តិចជាង ៨ ភាគរយ)។ ភាពខុសគ្នាកើនឡើងយ៉ាងខ្លាំងសម្រាប់សិស្សអាយុ ១៥ ឆ្នាំ គឺអត្រាឡើងដល់ទៅជិត ២០ ភាគរយ ជាមួយនឹងការផ្លាស់ប្តូរតិចតួចសម្រាប់សិស្សដែលមានអាយុលើសពីនេះ (**ក្រាហ្វិក ៣៣b និង ៣៣c**)។

**ស្ថានភាពប្រសើរឡើងនៃការមានវត្តមានចូលរៀនគឺឃើញមានភាគច្រើន ក្នុងចំណោមសិស្ស ដែលជាកុមារវ័យ។** អត្រាវត្តមានជារួមមានការប្រសើរឡើងសម្រាប់កុមារអាយុពី ៦ ឆ្នាំ ទៅ៧ ឆ្នាំ គឺប្រហាក់ប្រហែលជា ១៣ ភាគរយ និងសម្រាប់កុមារអាយុ ៨ ឆ្នាំទៅ ១០ ឆ្នាំមានការប្រសើរឡើងជាមធ្យម គឺ ៤ ភាគរយ ។ ប៉ុន្តែ សម្រាប់សិស្សអាយុចាប់ពី ១១ ឆ្នាំទៅ ១៥ ឆ្នាំវិញ គឺស្ថានភាពវត្តមានមិនមានភាពប្រសើរឡើងឲ្យពិតប្រាកណាមួយទេ។

### ការបោះបង់ចោលសាលា និងកុមារដែលពុំធ្លាប់ចូលសាលារៀនសោះ

**អត្រានៃកុមារដែលមិនដែលបានទៅសាលារៀនមានសភាពប្រសើរជាងមុននៅក្នុងប្រទេសកម្ពុជា។** អត្រាកុមារអាយុចាប់ពី ១១ ឆ្នាំទៅ ១៨ ឆ្នាំដែលមិនបានចូលរៀនមានការថយចុះពី ៨,៥ ភាគរយនៅក្នុងឆ្នាំ ២០០៤ ដល់ ៣,៦ ភាគរយ នៅក្នុងឆ្នាំ ២០១១ ហើយស្ថានភាពនេះគឺស្ទើរតែគ្មានសោះក្នុងរាជធានីភ្នំពេញ (០,៨ ភាគរយ) ឬតំបន់ជាយទីក្រុងផ្សេងៗ (១,៧ ភាគរយ )។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អាត្រាកុមារដែលមកពីគ្រួសារក្រីក្របំផុតមិនដែលបានចូលរៀនសោះ គឺមានចំនួន ៩,៧ ភាគរយដែលចំនួននេះ គឺប្រហាក់ប្រហែលនឹងចំនួនជាមធ្យមថ្នាក់ជាតិ កាលពី ៧ ឆ្នាំកន្លងទៅ (**សូមមើលតារាងទី ២១**)។[9] ការពិចារណាអំពីសេដ្ឋកិច្ច (តម្រូវការក្នុងការធ្វើការងារ ឬថ្លៃចំណាយក្នុងការអប់រំ) បានក្លាយជាមូលហេតុចម្បងសម្រាប់កុមារដែលមិនដែលបានចុះឈ្មោះចូលរៀនសោះ។ មូលហេតុនេះ ត្រូវបានលើកឡើងជាងពាក់កណ្តាលនៃករណីទាំងអស់ (បើប្រៀបធៀបនឹងឆ្នាំ២០០៤

**មូលហេតុដែលមិនចូលសាលារៀន**

| មូលហេតុ | ២០០៤ | ២០១១ |
|---|---|---|
| ចំណាយ/ការងារ | ៣១,៦% | ៥៧,១% |
| កិច្ចការផ្ទះ | ៣៥,៤% | ១៣,៥% |
| ការលើកទឹកចិត្ត/កម្រិតថ្នាក់ | ២៦,១% | ២២,២% |
| ដទៃផ្សេងទៀត | ៦,៨% | ៧,២% |

**ក្រាហ្វិក ៣៣៖** អត្រាវត្តមាននៅសាលា (មិនគិតពីថ្នាក់) តាមអាយុ នៅក្នុងប្រទេសកម្ពុជា




**ប្រភព៖** ការប៉ាន់ស្មានរបស់បុគ្គលិកនៃធនាគារពិភពលោកផ្អែកលើអ.ស.ស.ក។

ដែលមានតិចជាងមួយភាគបី)។ ការងារនៅផ្ទះលែងជាមូលហេតុចម្បងសម្រាប់ការដែលកុមារមិនបានចូលរៀនទៀត ហើយ ដោយភាគរយនៃមូលហេតុនេះបានធ្លាក់ចុះយ៉ាងខ្លាំងពី ៣៥,៤ ភាគរយ នៅក្នុងឆ្នាំ ២០០៤ មកនៅត្រឹមតែ ១៣,៥ ភាគរយនៅក្នុងឆ្នាំ២០១១។

**មូលហេតុនៃការបោះបង់ចោលការសិក្សា គឺស្រដៀងគ្នាទៅនឹងមូលហេតុនៃការមិនបានចូលសាលាដែរ។** នេះគឺជាការពិតសម្រាប់ការអប់រំទាំងក្នុងកម្រិតបឋមសិក្សានិងមធ្យមសិក្សា។ ក្នុងចំណោមសិស្សបឋមសិក្សា និងមធ្យមសិក្សាទាំងអស់ ហេតុផលសេដ្ឋកិច្ចបានកើនឡើងពីប្រហែលមួយភាគបីទៅជាងពាក់កណ្តាលនៃអត្រាអ្នកដែលបោះបង់ចោលការសិក្សាទាំងអស់។ ការអប់រំថ្នាក់មធ្យមសិក្សាតម្រូវឱ្យមានការចំណាយច្រើន ជាបន្ទុកសម្រាប់គ្រួសារ ដូចជាមធ្យោបាយធ្វើដំណើរ សម្ភារៈ សិក្សា ។ល។ ទន្ទឹមនឹងនោះដែរ សិស្សថ្នាក់មធ្យមសិក្សា គឺមានអាយុគ្រប់គ្រាន់នឹងអាចរកប្រាក់ចំណូលបាន។ ដូច្នេះ នេះមិនគួរឱ្យភ្ញាក់ផ្អើលទេ ដែលថាហេតុផលសេដ្ឋកិច្ចត្រូវបានលើកឡើងជាញឹកញាប់សម្រាប់ពន្យល់ពីការបោះបង់ចោលការសិក្សានៅថ្នាក់មធ្យមសិក្សា (៦១,១ ភាគរយ)ជាងនៅថ្នាក់បឋមសិក្សា (៥៣,៣ ភាគរយ)។

**ការងារផ្ទះ លែងជាមូលហេតុចម្បងសម្រាប់ការបោះ-បង់ចោលការសិក្សានៅថ្នាក់បឋមសិក្សា ឬមធ្យមសិក្សាទៀតហើយ។** មូលហេតុនៃការឈប់រៀនដោយសារតែការងារផ្ទះសម្បែង ត្រូវបានកាត់បន្ថយពីជាង ៣០ភាគរយ ក្នុងឆ្នាំ២០០៤ ដល់ប្រហែលជា ១៣ ភាគរយ នៅក្នុងឆ្នាំ ២០១១។ កង្វះចំណាប់អារម្មណ៍ក្នុងការសិក្សា និងការបានពិន្ទុទាបត្រូវបានលើកឡើង ដើម្បីពន្យល់ពីមូលហេតុនៃការបោះបង់ចោលការសិក្សានៅថ្នាក់បឋមសិក្សា

(២៨,១ ភាគរយ) ជាងថ្នាក់មធ្យមសិក្សា (១៨,០ ភាគរយ) ក្នុងឆ្នាំ២០១១ (**តារាង ២២**)។

**ចំពោះហេតុផលដែលថាការងារផ្ទះសម្បែងមានសារៈសំខាន់ដែលឈានដល់ការបោះបង់ចោលការសិក្សា គឺមានលក្ខណៈស្រដៀងគ្នាសម្រាប់សិស្សប្រុស និងសិស្សស្រី។** ការងារផ្ទះសម្បែងត្រូវបានគេលើកឡើងស្មើរតែ ១៤ ភាគរយថាជាមូលហេតុនៃការបោះបង់ចោលការសិក្សា សម្រាប់ទាំងសិស្សប្រុស និងសិស្សស្រី។ ដោយសារតែការងារផ្ទះសម្បែងមិនត្រូវបានគេមើលបំណាំបែបប្រពៃណីថា ជាកិច្ចការងារប្រុស ឬស្រីនោះ សិស្សប្រុស និងសិស្សស្រីត្រូវបានគេលើកឡើងថា បានធ្វើការងារផ្ទះក្នុងអត្រាដូចគ្នា។ កត្តាចម្បងដែលប៉ះពាល់ដល់ការបោះបង់ចោលការសិក្សានាពេលបច្ចុប្បន្ននេះ ដោយមិនគិតអំពីទីតាំង

**តារាង ២១៖** ភាគរយនៃកុមារអាយុ ១២ ដល់១៧ ឆ្នាំដែលពុំធ្លាប់ចុះឈ្មោះចូលរៀន នៅប្រទេសកម្ពុជា ឆ្នាំ២០០៤ ដល់ឆ្នាំ ២០១១

| | ទីស្នាក់អាស្រ័យ | | | យេនឌ័រ | | ស្ថានភាពទ្រព្យសម្បត្តិ តាមក្រុមបញ្ចភាគ | | | | | ជាតិ |
|---|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ | ភ្នំពេញ | ទីក្រុង | ជនបទ | ប្រុស | ស្រី | អ្នកក្របំផុត | ក្រុមបញ្ចភាគទី២ | ក្រុមបញ្ចភាគទី៣ | ក្រុមបញ្ចភាគទី៤ | អ្នកមានបំផុត | |
| ២០០៤ | ១,៨% | ៦,១% | ៨,៣% | ៧,២% | ៧,៩% | ១៤,៩% | ៨,៦% | ៦,៨% | ៤,១% | ២,០% | ៧,៥% |
| ២០១១ | ០,៤% | ១,៣% | ៣,៦% | ៣,៧% | ២,៤% | ៧,៧% | ១,៧% | ៣,១% | ១,២% | ០,៤% | ៣,១% |

**ប្រភព៖** ការប៉ាន់ស្មានរបស់បុគ្គលិកនៃធនាគារពិភពលោកផ្អែកលើអ.ស.ស.ក។

**តារាង ២២៖** ការបោះបង់ចោលការសិក្សារបស់ក្មេងអាយុចាប់ពី ១២ ទៅ ១៧ ឆ្នាំតាមក្រុមឆ្នាំ និងក្រុម, នៅប្រទេសកម្ពុជាឆ្នាំ២០១១

| | | ឆ្នាំ | | ឆ្នាំ២០១១[10] | | | |
|---|---|---|---|---|---|---|---|
| | មូលហេតុ | ២០០៤ | ២០១១ | ជនបទ | ប្រុស | ស្រី | Q១ និង Q២ |
| បឋមសិក្សា | ចំណាយ/ការងារ | ៣០.២% | ៥៣.៣% | ៥២.៨% | ៤៨.៨% | ៥៨.០% | ៦០.៤% |
| | កិច្ចការផ្ទះ | ៣៤.៥% | ១២.៥% | ១២.២% | ១១.៤% | ១៣.៥% | ១៣.២% |
| | ការលើកទឹកចិត្ត/កម្រិតថ្នាក់ | ២៧.៧% | ២៨.១% | ២៩.០% | ៣៣.៦% | ២២.៤% | ២២.៥% |
| | ដទៃផ្សេងទៀត | ៧.៧ % | ៦.១ % | ៦.០% | ៦.២% | ៦.១% | ៣.៨% |
| មធ្យមសិក្សា | ចំណាយ/ការងារ | ៣៤.៨% | ៦១.១% | ៦១.៣% | ៤៨.៧% | ៦៨.៨% | ៦៤.៩% |
| | កិច្ចការផ្ទះ | ៣៩.៥% | ១៣.២% | ១៣.១% | ១៧.៤% | ១០.៦% | ១២.៦% |
| | ការលើកទឹកចិត្ត/កម្រិតថ្នាក់ | ២២.៧% | ១៨.០% | ១៦.៩% | ២៣.៤% | ១៤.៧% | ១៣.៩% |
| | ដទៃផ្សេងទៀត | ៣.១% | ៧.៧% | ៨.៧% | ១០.៥% | ៥.៩% | ៨.៦% |
| សរុប | ចំណាយ/ការងារ | ៣១.៤% | ៥៦.៤% | ៥៦.២% | ៤៩.២% | ៦២.៤% | ៦១.១% |
| | កិច្ចការផ្ទះ | ៣៥.៦% | ១៣.៧% | ១៣.៤% | ១៣.៨% | ១៣.៦% | ១៤.១% |
| | ការលើកទឹកចិត្ត/កម្រិតថ្នាក់ | ២៦.០% | ២៣.០% | ២៣.១% | ២៩.១% | ១៧.៩% | ១៩.៥% |
| | ដទៃផ្សេងទៀត | ៦.៩% | ៦.៩% | ៧.៣% | ៧.៩% | ៦.១% | ៥.២% |

**ប្រភព៖** ការប៉ាន់ស្មានរបស់បុគ្គលិកនៃធនាគារពិភពលោក ដោយផ្អែកតាមអ.ស.ស.ក។

លំនៅដ្ឋាន យេនឌ័រ ឬស្ថានភាពទ្រព្យសម្បត្តិនោះគឺហេតុផលសេដ្ឋកិច្ច។ ហេតុផលបន្តបន្ទាប់ទៀតមានដូចជាកង្វះការលើកទឹកចិត្ត ការបានពិន្ទុទាប និងការងារផ្ទះសម្បែង។ ហេតុផលផ្សេងៗទៀត រាប់បញ្ចូលទាំងការផ្គត់ផ្គង់ផ្នែកសិក្សាផងដែរនោះ គឺតែងតែជាកត្តាបន្ទាប់បន្សំជំរុញឲ្យមានការបោះបង់ចោលការសិក្សា។

## ការចូលរៀនយឺតជាងអាយុ

ការចូលរៀនយឺតជាងអាយុត្រូវបានគេឲ្យនិយមន័យថា ជាការចូលរៀននៅកម្រិតអប់រំទាបជាងអាយុ ដែលត្រូវចូលរៀនដោយមិនគិតអំពីការរៀនត្រួតថ្នាក់។ ការចុះឈ្មោះចូលរៀនយឺត និងការរៀនត្រួតថ្នាក់ជាកត្តាដ៏សំខាន់ពីរដែលរួមចំណែកដល់ការរៀនយឺតជាងអាយុនៅក្នុងសាលារៀន។ ផលប៉ះពាល់ពីរយ៉ាងដែលបង្កមកពីការចុះឈ្មោះចូលរៀនយឺតគឺ៖ ដំបូងចាប់ផ្តើមពីការមិនបានរៀនពីក្មេងដែលធ្វើឲ្យរយៈពេលដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍ខួរក្បាលរបស់កុមារត្រូវកន្លងផុតទៅ និងធ្វើឱ្យមានការលំបាកក្នុងការរៀននៅពេលអនាគត។ ទីពីរ គឺជាការចូលរៀនយឺតក្នុងថ្នាក់ដំបូង ក៏ដូចជាការរៀនត្រួតថ្នាក់។ ប្រការនេះនឹងបង្កើនអាយុរបស់កុមារនៅក្នុងថ្នាក់ក្រោយៗទៀតដែលអាចជាសំពាធឱ្យពួកគេឈប់រៀន ដើម្បីទៅធ្វើការដែលអាចជាការងារផ្ទះ ឬការងារខាងក្រៅដើម្បីរកប្រាក់ចំនូល។ បើទោះបីជាមិនសំអាងលើហេតុផលនេះ ការចូលរៀនយឺតនឹងបង្កឲ្យមានការចុះថយនៃសមត្ថភាពក្នុងការសិក្សា និងធ្វើឲ្យអត្រាបោះបង់ចោលការសិក្សាមានកម្រិតខ្ពស់នៅក្នុងការអប់រំកម្រិតមធ្យមសិក្សា។

**ជាមធ្យម ការចូលរៀនយឺត (ការចូលរៀនយឺតជាងអាយុនៅថ្នាក់ដំបូង) ហាក់ដូចជាមិនមែនជាបញ្ហាចោទខ្លាំងក្នុងឆ្នាំ២០១១ ដូចធ្លាប់មានកាលពី ៧ ឆ្នាំមុននោះទេ។** តាមការប៉ាន់ស្មាន អាត្រាការចូលរៀនថ្នាក់ដំបូងយឺតបានថយចុះយ៉ាងខ្លាំង ពីការយឺតក្នុងរយៈពេល ១,៣ ឆ្នាំនៅក្នុងឆ្នាំ ២00៤ មកនៅត្រឹម ០,៤ ឆ្នាំ ក្នុងឆ្នាំ ២០១១។ ប៉ុន្តែ ជាការចាំបាច់ត្រូវយល់ថា អត្រាអ្នកចូលរៀនយឺតជាងអាយុសរុប អាចកើនឡើងដោយសារការរៀនត្រួតថ្នាក់។ នៅក្នុងឆ្នាំ ២០១១ការចូលរៀនយឺតជាងអាយុគឺមានអាត្រា ០,៨ ឆ្នាំសម្រាប់សិស្សថ្នាក់ទី ៣ និង ១,១ ឆ្នាំសម្រាប់សិស្សថ្នាក់ទី ៦ (បើប្រៀបធៀបទៅនឹង ២,២ ឆ្នាំនៅក្នុងឆ្នាំ២០០៤)។ ការកាត់បន្ថយជាមធ្យមសម្រាប់ការចូលរៀនយឺតជាងអាយុសម្រាប់កម្រិតទាំង ៦ ថ្នាក់នៅកម្រិតបឋមសិក្សា គឺ ១ ឆ្នាំពេញ។ ប៉ុន្តែ ការចូលរៀនយឺតជាងអាយុនៅក្នុងប្រទេសកម្ពុជាមានការខុសប្លែកគ្នាខ្លាំង ៖ សិស្សមួយភាគធំត្រូវបានគេបានរាយការណ៍នូវតួលេខនៃការចូលរៀនយឺតជាងអាយុក្នុងកម្រិតខ្ពស់ខ្លាំង។ ក្នុងចំណោម ៤០ ភាគរយនៃសិស្សដែលចូលរៀនយឺតជាងអាយុខ្លាំង គឺមានអ្នកដែលចូលរៀនយឺតនៅក្នុងឆ្នាំ ២០១១ រយៈពេល ២ឆ្នាំពេញ ហើយសម្រាប់សិស្សថ្នាក់ទី៣វិញ មានកម្រិតចូលរៀនយឺត ២,៧ ឆ្នាំ និង ៣,១ឆ្នាំសម្រាប់សិស្សថ្នាក់ទី៦(**សូមមើលក្រាហ្វិក ៣៤**)។[11]

**ការចូលរៀនយឺតជាងអាយុមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងអត្រាបោះបង់ចោលការសិក្សារបស់សិស្សនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងថ្នាក់បន្ទាប់ៗទៀត។** ឧទាហរណ៍ សិស្ស ៤ នាក់ក្នុងចំណោមសិស្ស ១០ នាក់អាចរៀនដល់បញ្ចប់ថ្នាក់ទី ៦ របស់ពួកគេនៅពេលពួកគេមានអាយុ ១៥ ឆ្នាំទៅហើយ ដែលក្នុងករណីនេះពួកគេគួតែបានបញ្ចប់ថ្នាក់នោះនៅអាយុ ១២ ឆ្នាំ ដែលនេះជាកត្តាជំរុញឲ្យពួកគេបោះបង់ចោលការសិក្សា ដើម្បីអាចទៅធ្វើការខាងក្រៅ ឬជួយការងារក្នុងគ្រួសារ។ បច្ចុប្បន្ននេះ សិស្សចំនួន ៣៩,៥ ភាគរយ គឺមិនត្រូវបានទទួលបានការអប់រំជាផ្លូវការ រហូតដល់ពួកគេមានអាយុ ៨ឆ្នាំ (ជំនួសឲ្យការចូលរៀននៅអាយុ ៦ ឆ្នាំ)។

**គោលនយោបាយវិស័យអប់រំជាផ្លូវការនៅក្នុងប្រទេសកម្ពុជា ពោលគឺផែនការអប់រំជាយុទ្ធសាស្ត្រ ហាក់ដូចជាមិនសូវមានប្រសិទ្ធភាពក្នុងការឆ្លើយតបចំពោះបញ្ហាការចូលរៀនយឺតជាងអាយុនោះទេ បើទោះបីជាប្រទេសកម្ពុជាបាននឹងកំពុងប្រឈមមុខនឹងអត្រាមានអ្នកចូលរៀនយឺតច្រើនធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ដែលយ៉ាងហោចណាស់ គឺឋិតក្នុងអាត្រា ៤០ ភាគរយចំពោះសិស្សចាប់ពីថ្នាក់ទី ១ ដល់ថ្នាក់ទី ៦។** បើទោះបីជាមូលហេតុនៃការចូលរៀនយឺតជាងអាយុ គឺបណ្តាលមកពីការចុះឈ្មោះចូលរៀនយឺត ឬបណ្តាលមកពីការរៀនត្រួតថ្នាក់ក៏ដោយ

គោលនយោបាយនៃការអប់រំជាយុទ្ធសាស្ត្រនេះបានផ្តោតការយកចិត្តទុកដាក់ស្ទើរតែទាំងស្រុងទៅលើតែការរៀនត្រួតថ្នាក់ និងការបោះបង់ចោលការសិក្សាតែប៉ុណ្ណោះ។ ការវិភាគទៅលើការសិក្សានេះបានបង្ហាញថា ការចុះឈ្មោះចូលរៀននៅអាយុសមរម្យមានផលប៉ះពាល់ពិតប្រាកដដល់វត្តមាននៃការចូលរៀននាពេលអនាគត និងការវិវត្តនៃការសិក្សានៅថ្នាក់បន្ទាប់ៗទៀត។

## គុណភាពនិងថវិកានៃការអប់រំ

ដើម្បីស្វែងយល់ឲ្យបានច្បាស់នូវប្រព័ន្ធអប់រំសាធារណៈរបស់ប្រទេសកម្ពុជា ហើយនិងស្វែងយល់ពីលទ្ធភាពនៃប្រព័ន្ធនេះក្នុងការផ្តល់ឲ្យប្រជាពលរដ្ឋនូវជំនាញ ដែលពួកគេត្រូវការ ដើម្បីជានាឲ្យបាននូវការងារដែលមានលក្ខណៈអាជីព និងដើម្បីទាក់ទាញវិនិយោគទុនបរទេស។ ពិតជាចាំបាច់ណាស់ដែលយើងត្រូវមើលឲ្យឆ្ងាយលើសពីការដែលគ្រាន់តែឲ្យក្មេងៗចូលក្នុងថ្នាក់រៀន ហើយរក្សាពួកគេឲ្យនៅទីនោះ។ គុណភាពនៃការបង្រៀនត្រូវតែបានដោះស្រាយផងដែរ។ ប៉ុន្តែបច្ចុប្បន្ននេះ សូចនាករដើម្បីវាស់ស្ទង់ការរីកចម្រើនលើការសិក្សារបស់សិស្ស គឺនៅមិនទាន់មាននៅឡើយទេ។

**ការសិក្សាស្រាវជ្រាវមុនៗបានបញ្ជាក់ថា សមិទ្ធិផលនៃការសិក្សារៀនសូត្រ គឺជាកត្តាយ៉ាងសំខាន់ដើម្បីវាស់ស្ទង់គុណភាពនៃការអប់រំ។** ការសិក្សានាពេលថ្មីៗនេះបានបង្ហាញថា បណ្តាប្រទេសជាច្រើនដែលមានសិស្សមានសមត្ថភាពក្នុងការប្រឡងវិញ្ញាសារថ្នាក់អន្តរជាតិ ច្រើនតែជាប្រទេសដែលមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ផងដែរ (អ៊ី ហានុសែក វូស្មាន E. Hanushek Woessmann ឆ្នាំ២០០៩, ប្រ៊ីចិត្រ និងវ៉ាយ៉ារ៉ែនហ្គោ Pritchett & Viarengo ឆ្នាំ២០០៩)។ ការសិក្សាផ្សេងៗទៀត ក៏បានបង្ហាញបន្ថែមផងដែរថា ប្រទេសដែលមានសិស្សនិស្សិតដែលមានការយល់ដឹងខ្ពស់ភាគច្រើនគឺជាប្រទេសដែលមានលទ្ធិប្រជាធិបតេយ្យរឹងមាំ (បារ៉ូ Barro ឆ្នាំ ១៩៩៩, ខេមភេន និង ឃ្លាស់ស៊ែ Campante & Glaeser ឆ្នាំ២០០៩) ។ លទ្ធផលនៃការសិក្សាមុនៗនេះបានបង្ហាញយ៉ាងច្បាស់ពីសារៈសំខាន់នៃការយកចិត្តទុកដាក់ដល់

**ក្រាហ្វិក ៣៤៖** ការចូលរៀនយឺតជាងអាយុ តាមថ្នាក់នីមួយៗនៅប្រទេសកម្ពុជា ឆ្នាំ២០០៤ ដល់ ២០១១




**ប្រភព៖** ធនាគារពិភពលោក, របាយការណ៍អភិវឌ្ឍន៍ពិភពលោក។

លទ្ធផលនៃការសិក្សារបស់សិស្ស ដែលជាសូចនាករគន្លឹះមួយសម្រាប់គុណភាពនៃការអប់រំ។ ជាក់ស្តែង ការវាយតម្លៃបទដ្ឋានថ្នាក់ជាតិ គឺជាគោលនយោបាយដ៏មានប្រសិទ្ធិភាពនិងជាឧបករណ៍ក្នុងការអនុវត្តជាក់ស្តែង ដើម្បីប្រមូលព័ត៌មាន និងវាយតម្លៃលើការសិក្សារបស់សិស្ស និងការអភិវឌ្ឍន៍នៃចំណេះដឹងរបស់ពួកគេ។ ជាការចាំបាច់ផងដែរក្នុងការសម្រេចចិត្តអំពីជំហានបន្ទាប់ក្នុងដំណើរការនៃការអប់រំ (ខ្លាក (Clarke) ឆ្នាំ២០១២)។

ស្ទើរតែ ៩០ ភាគរយនៃថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបម្រុងទុកសម្រាប់វិស័យអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា នៅពេលដែល ១០ ភាគរយដែលនៅសល់ ត្រូវប្រើប្រាស់សម្រាប់ផ្នែកផ្សេងៗមានដូចជា

ការអប់រំកុមារថ្នាក់ដំបូង (ECE) ការអប់រំថ្នាក់ឧត្តមសិក្សា និងការអប់រំក្រៅប្រព័ន្ធ (NFE) (**ក្រាហ្វិក ៣៥**)។

និន្នាការនៃថវិកាក្នុងវិស័យអប់រំត្រូវបានកើនឡើងដល់កម្រិតកំពូល គឺ ១៩,២ភាគរយនៃថវិកាសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ ២០០៧ ។ ប៉ុន្តែក្នុងពេលថ្មីៗនេះ មានការធ្លាក់ចុះជាលំដាប់ ចាប់តាំងអំពីការឡើងខ្ពស់បំផុតនៅឆ្នាំ ២០០៧ មក(**ក្រាហ្វិក ៣៦**)។ បើទោះបីជាភាគរយនៃការបែករំលែកថវិកាចរន្តនេះបង្ហាញពីនិន្នាការថយចុះមែន ប៉ុន្តែចំនួនទឹកប្រាក់ជាក់ស្តែងដែលទទួលបានមានការកើនឡើង។ ជាការពិតណាស់ដែលថា ឯកតានៃការចំណាយសម្រាប់វិស័យអប់រំបានកើនឡើងពី៤៦,១០ ដុល្លារសហរដ្ឋអាមេរិកសម្រាប់សិស្សម្នាក់ក្នុងឆ្នាំ ២០០៨ ទៅ ៧២,៤៣ ដុល្លារសហរដ្ឋអាមេរិកសម្រាប់សិស្សម្នាក់

**ក្រាហ្វិក ៣៥៖** ថវិកាអប់រំសរុប និងថវិកាកម្មវិធី តាមភូមិសិក្សាឆ្នាំ២០១០




**ប្រភព៖** ការប៉ាន់ស្មានរបស់បុគ្គលិកនៃធនាគារពិភពលោក។

តួលេខថវិកាក្រៅកម្មវិធី គឺយកផ្អែកតាមចំណាយសម្រាប់គ្រូ/បុគ្គលិកសិក្សារដ្ឋ និងតាមកម្រិតខុសៗគ្នានៃប្រាក់ខែទៅតាមភូមិសិក្សានីមួយៗ។ រីឯថវិកាកម្មវិធី គឺយកតាមទឹកប្រាក់ជាក់ស្តែង តែមិនរាប់បញ្ចូលទឹកប្រាក់សម្រាប់យុវជននិងកីឡា។

**ក្រាហ្វិក ៣៦៖** ចំណាយចរន្តដែលគ្រោងទុកនិងជាក់ស្តែងនៅប្រទេសកម្ពុជា




**ប្រភព៖** ការប៉ាន់ស្មានរបស់បុគ្គលិកនៃធនាគារពិភពលោក ផ្អែកលើតួលេខ

ក្នុងឆ្នាំ ២០១២។ ទោះបីជាយ៉ាងណាក៏ដោយ ភាគច្រើននៃការកើនឡើងនៅក្នុងការចំណាយសម្រាប់សិស្សម្នាក់ៗ គឺជាលទ្ធផលនៃការកើនឡើងនៃប្រាក់ខែគ្រូបង្រៀន ដែលត្រូវបង្កើនឡើងប្រមាណ ១០ ភាគរយជារៀងរាល់ឆ្នាំ។ ផ្ទុយទៅវិញ អត្រាកំណើននៃថវិកាកម្មវិធីសម្រាប់សិស្សម្នាក់ៗ គឺតិចជាងមុន (**តារាង ២៣**)។

**ការតាក់តែងគម្រោងថវិកា និងការប្រតិបត្តិចំណាយថវិកា គឺជាបញ្ហាសំខាន់មួយដែលជះឥទ្ធិពលលើសកម្មភាពផ្សេងៗក្នុងវិស័យអប់រំ។** អ្វីដែលគួរឲ្យព្រួយបារម្ភខ្លាំងនោះគឺការប្រើប្រាស់ថវិកាមិនគ្រប់គ្រាន់ក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ។ នៅក្នុងឆ្នាំ ២០១០ ថវិកាត្រូវបានប្រើប្រាស់មិនគ្រប់ គឺជាង ៣០ លានដុល្លារសហរដ្ឋអាមេរិកដែលជាចំនួនតួលេខដ៏ធំស្មើនឹងថវិកាសរុបសម្រាប់កម្មវិធីក្នុងឆ្នាំនោះ។ បើទោះបីជា ប្រាក់បៀវត្សរ៍របស់គ្រូបង្រៀននៅមានកម្រិតទាបជាបញ្ហាដដែលៗក៏ដោយ ក៏ផ្នែកដែលខ្វង់ចំណាយមានតិចជាងគេបំផុតនោះគឺប្រាក់ភាគលាភ (ប្រភេទនៃថវិកាក្រោមជំពូកទី៦៤)។ នៅក្នុងឆ្នាំ ២០១០ ថវិកាត្រូវបានចំណាយក្រោម ២០ លានដុល្លារសហរដ្ឋអាមេរិក ហើយនេះគឺគ្រាន់តែសម្រាប់ប្រភេទនៃការចំណាយដែលស្ថិតនៅក្រោមជំពូកទី ៦៤ តែប៉ុណ្ណោះ។ នេះបង្ហាញថា ទោះបីជាចំនួនទឹកប្រាក់សម្រាប់ការអប់រំបានកើនឡើងក៏ដោយការកើនឡើងទាំងនេះគឺមិនត្រូវបានគេ

**តារាង ២៣៖** ការចំណាយប្រចាំឆ្នាំរបស់ក្រសួងអប់រំក្នុងសម្រាប់សិស្សម្នាក់ៗ

| ឆ្នាំ | ថវិកាសម្រាប់កម្មវិធី | ថវិកាមិនមែនសម្រាប់កម្មវិធី | សរុប |
|---|---|---|---|
| ២០០៨ | $ ៧,០៧ | $ ៣៩,០៣ | $ ៤៦,១០ |
| ២០០៩ | $ ៨,៥៩ | $ ៤៦,០៦ | $ ៥៤,៦៥ |
| ២០១០ | $ ៨,៩៣ | $ ៤៧,៤១ | $ ៥៦,៣៤ |
| ២០១១ | $ ៩,៨៩ | $ ៥២,៩៤ | $ ៦២,៨៣ |
| ២០១២ | $ ៩,៨២ | $ ៦២,៦១ | $ ៧២,៤៣ |

**ប្រភព៖** ការប៉ាន់ស្មានរបស់បុគ្គលិកនៃធនាគារពិភពលោកផ្អែកលើទិន្នន័យ EMIS របស់ក្រសួងអប់រំ យុវជន និងកីឡា។

យកមកចំណាយឲ្យមានប្រសិទ្ធិភាពនៅឡើយ ដែលជាលទ្ធផលធ្វើឲ្យសមាមាត្រថវិកាសម្រាប់ការអប់រំមានកម្រិតតិចតួច ប្រៀបធៀបនឹងថវិកាជាតិសរុបសម្រាប់ឆ្នាំសារពើពន្ធក្រោយៗទៀត។

## អនុសាសន៍គោលនយោបាយ

**ការពង្រីកវិស័យអប់រំក្រៅប្រព័ន្ធបន្ថែមទៀត (យុទ្ធនាការអប់រំលំដាប់អក្សរពី ក ដល់ អ) ដែលផ្តោតសំខាន់ទៅលើមនុស្សពេញវ័យដែលក្រីក្រ គឺមានភាពចាំបាច់ដើម្បីគ្របដណ្តប់ចំនួនដែលនៅសល់ ៨,៤ ភាគរយនៃយុវជនដែលមិនចេះអក្សរ និង ២០,៧ ភាគរយនៃមនុស្សពេញវ័យដែលមិនចេះអក្សរ។** ការធ្វើឱ្យប្រសើរឡើងនូវការគ្របដណ្តប់ការអប់រំកម្រិតបឋមសិក្សា និងការលើកកម្ពស់វិស័យអប់រំក្រៅប្រព័ន្ធបានកាត់បន្ថយអត្រាអនក្ខរភាពក្នុងប្រទេសកម្ពុជា។ ប៉ុន្តែអត្រាអនក្ខរភាពនៅតែមានកម្រិតខ្ពស់ ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាដែលក្រីក្របំផុត (១៩,៤ ភាគរយ) និងសម្រាប់មនុស្សពេញវ័យចាប់ពីអាយុ ១៥ឆ្នាំ ទៅ អាយុ ៦៤ឆ្នាំ (២០,៧ ភាគរយ)។ យុទ្ធនាការអប់រំតាមលំដាប់អក្សរពី ក ទៅ អ អាចជាជម្រើសសម្រាប់ពួកគេ។ កម្មវិធីបែបនេះគួរតែផ្តោតកិច្ចខិតខំប្រឹងប្រែងទៅក្នុងតំបន់ជនបទក្នុងគ្រួសារក្រីក្របំផុត និងផ្តោតទៅលើយុវតីដែលពេញវ័យ។

**អនុសាសន៍ដ៏មានសារៈសំខាន់បំផុត ដើម្បីធ្វើឲ្យប្រសើរឡើងនូវលទ្ធផលនៃការអប់រំថ្នាក់បឋមសិក្សា គឺត្រូវជំរុញឲ្យមានការចុះឈ្មោះចូលរៀននៅថ្នាក់ដំបូងសម្រាប់កុមារទាំងអស់ដែលមានអាយុចាប់ពី ៥ ឆ្នាំឡើងទៅ ជាពិសេសក្នុងចំណោមជនក្រីក្រនៅតាមតំបន់ជនបទ។** ខណៈពេលដែលការចូលរៀនយឺតជាងអាយុ ជាមធ្យមសម្រាប់សិស្សថ្នាក់ទី ១ (ការចុះឈ្មោះចូលរៀនយឺតជាងអាយុ) ឈរនៅកម្រិតមួយដែលអាចទទួលយកបាន ពោលគឺ ០,៤ ឆ្នាំនៅក្នុងឆ្នាំ២០១១ សិស្សចំនួន ៣៨ ភាគរយជាមធ្យម គឺមានកម្រិតអាត្រានៃការចូលរៀនយឺតជាងអាយុរយៈពេល ២ ឆ្នាំ។ ការខាតបង់ពេលវេលាដ៏មានសារៈសំខាន់នៅក្នុងការអភិវឌ្ឍន៍ការយល់ដឹងរបស់កុមារគឺជាឧបសគ្គសម្រាប់ការសិក្សារបស់ពួកគេនាពេលអនាគត ដែលអាចកាត់បន្ថយអត្ថប្រយោជន៍នៃការអប់រំ និងអាចបង្កើននូវឱកាសនៃការបោះបង់ចោលការសិក្សានៅឆ្នាំក្រោយៗទៀត។

**ជម្រើសដ៏មានសារៈសំខាន់បំផុតទីពីរដើម្បីធ្វើឱ្យលទ្ធផលនៃការអប់រំថ្នាក់បឋមសិក្សាបានប្រសើរឡើងគឺត្រូវកាត់បន្ថយអត្រាអ្នករៀនត្រួតថ្នាក់។** ការរៀនត្រួតថ្នាក់ពីថ្នាក់ទី ១ ដល់ថ្នាក់ទី ៦ អាចធ្វើឲ្យអត្រានៃការចូលរៀនយឺតជាងអាយុកើនឡើង ០,៧ ឆ្នាំនៅថ្នាក់ទី ៦។ ស្រដៀងគ្នាទៅនឹងការចូលរៀនយឺតជាងអាយុ ការត្រួតថ្នាក់បានបន្ថែម ១,១ ឆ្នាំនៃការរៀនយឺត ដល់សិស្ស នៅក្នុងថ្នាក់ទី ៦ (៤ នាក់ក្នុងចំណោម ១០នាក់)។ នៅពេលដែលបញ្ចូលគ្នាជាមួយការចូលរៀនយឺតជាងអាយុនោះ វាបានបន្ថែមចំនួនសរុប ៣,១ ឆ្នាំនៃអត្រាចូលរៀនយឺតជាងអាយុនៅថ្នាក់ទី ៦។

**កិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាទាំងពីរនេះត្រូវផ្តោតទៅលើបញ្ហាពីរ ៖ ការកំណត់អត្តសញ្ញាណក្រុមកុមារដែលចូលរៀនថ្នាក់ដំបូងយឺត ឬរៀនធ្លាក់ និងផ្តល់នូវការលើកទឹកចិត្តដោយត្រឹមត្រូវ ដើម្បីផ្លាស់ប្តូរឥរិយាបទនិងការអនុវត្តការសិក្សារបស់ពួកគេ។** ការផ្តល់អាហារូបករណ៍ និងកម្មវិធីអប់រំបន្ថែមពីលើការសិក្សានៅសាលាត្រូវបានគេរកឃើញថា ជាមធ្យោបាយដ៏មានប្រសិទ្ធិភាពដើម្បីដោះស្រាយបញ្ហានេះ មិនត្រឹមតែសម្រាប់នៅក្នុងប្រទេសកម្ពុជានោះទេ ប៉ុន្តែគឺសម្រាប់ទូទាំងពិភពលោកផងដែរ។ កម្មវិធីអប់រំទាំងនេះ គួរតែត្រូវបានពង្រីកបន្ថែម។

**កម្មវិធីដូចជាការចំណាយប្រាក់ទៅលើគោលដៅណាមួយ និងកម្មវិធីផ្សេងទៀតដែលមានគោលដៅផ្សេងៗគឺសាកសមក្នុងការលើកកម្ពស់វិស័យអប់រំកម្រិតមធ្យមសិក្សានៅក្នុងប្រទេសកម្ពុជា។** ការកែលម្អលទ្ធផលនៅកម្រិតមធ្យមសិក្សា នឹងធ្វើឲ្យមានភាពប្រសើរឡើងនូវអត្រាការបោះបង់ចោលការសិក្សានៅថ្នាក់បឋមសិក្សា។ មូលហេតុដ៏សំខាន់បំផុតដែលនាំឲ្យមានកំណើនអត្រាបោះបង់ចោលការសិក្សា គឺបញ្ហាសេដ្ឋកិច្ច ដូច្នេះកម្មវិធីផ្សេងៗដែលមានគោលដៅរក្សាចំនួនសិស្សបន្ថែមទៀតឲ្យនៅបន្តការសិក្សាក្នុងកម្រិតមធ្យមសិក្សា ត្រូវតែយកបញ្ហា

នេះមកពិចារណាផងដែរ។ ហេតុផលសេដ្ឋកិច្ចសម្រាប់អ្នករៀនត្រួតថ្នាក់ និងអ្នកបោះបង់ចោលការសិក្សាត្រូវបានលើកឡើងដោយសិស្សជានារី និងសិស្សក្រីក្របំផុតចំនួន ៤០ ភាគរយ។ ការវាយតម្លៃយ៉ាងម៉ត់ចត់នៃកម្មវិធីអាហារូបករណ៍របស់គម្រោងគាំទ្រវិស័យអប់រំនៅកម្ពុជា (CESSP) បានបង្ហាញថា កម្មវិធីនេះបានបង្កើននូវអត្រាចុះឈ្មោះចូលរៀនក្នុងចំណោមកុមារពីគ្រួសារក្រីក្រ ជាពិសេសកុមារី (ហ្វិមមើ Filmer និង ស្កាឌី Schady ឆ្នាំ២០០៩)។ កម្មវិធីបែបនេះ គួរតែត្រូវបានពង្រីកបន្ថែម។ បទពិសោធន៍ពីអន្តរជាតិបានបញ្ជាក់យ៉ាងច្បាស់ថា ការវាយតម្លៃដែលមានស្តង់ដាថ្នាក់ជាតិ គឺជាឧបករណ៍ដ៏មានប្រសិទ្ធិភាពដើម្បីធ្វើឱ្យមានការសម្រេចចិត្តមួយច្បាស់លាស់អំពីដំណើរការនៃការអប់រំ។ នាយកដ្ឋានធានាគុណភាពនៃការអប់រំរបស់ក្រសួងបាននិងកំពុងធ្វើការសាកល្បងបង្កើតការវាយតម្លៃជាផ្លូវការថ្នាក់ជាតិមួយសម្រាប់ថ្នាក់ទី ៣ លើកដំបូងដែលជានិន្នាការវិជ្ជមានមួយ។ ប៉ុន្តែ ដើម្បីអាចធ្វើឲ្យឱ្យប្រសើរឡើងនូវគុណភាព លុះត្រាតែការងារនេះត្រូវបានធ្វើឲ្យទៅជាប្រព័ន្ធ និងជាទម្លាប់។

**ជាចំណែកមួយនៃថវិកាសរុបនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ការចំណាយលើការអប់រំបានធ្លាក់ចុះ ហើយការចំណាយក្នុងវិស័យនេះ គឺមិនគ្រប់គ្រាន់ទេក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ។** ថវិកាសម្រាប់វិស័យអប់រំនេះមាននិន្នាការកើនឡើងនៅទសវត្សរ៍កន្លងទៅ ដែលកើនដល់ ១៩,២ ភាគរយនៅក្នុងឆ្នាំ២០០៧ ។ ប៉ុន្តែ ខ្ទង់ថវិកានេះបានធ្លាក់ចុះភ្លាមៗ ចាប់តាំងពីឆ្នាំ២០០៧ មក គឺធ្លាក់ដល់ ១៥,៩ ភាគរយនៅក្នុងឆ្នាំ ២០១២។ ទោះជាយ៉ាងណាក៏ដោយ ក្តីបារម្ភកាន់តែខ្លាំងនោះគឺថា ការចំណាយថវិកាគឺមិនគ្រប់គ្រាន់អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ដូច្នេះ ការតាក់តែងថវិកានិងការប្រតិបត្តិចំណាយថវិកានេះត្រូវចាត់ជាបញ្ហាបន្ទាន់មួយ ដែលចាំបាច់សម្រាប់ការកែលម្អការផ្តល់ហិរញ្ញប្បទានជារួម និងការបង្កើនសមត្ថភាពនៅគ្រប់សកម្មភាពនៃវិស័យអប់រំទាំងអស់។

**ធនធានបន្ថែមទៀតគួរតែត្រូវបានបម្រុងទុកសម្រាប់ការអប់រំកុមារថ្នាក់ក្រោម ដើម្បីបំពេញតាមតម្រូវការដែលកើនឡើង។** ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងនៃថវិកាសម្រាប់ការអប់រំកុមារថ្នាក់ដំបូង គួរត្រូវបានសម្រេចដោយការបង្កើនថវិកាទៅក្នុងវិស័យអប់រំទាំងមូល ជាជាងដោយការកាត់បន្ថយថវិកានៅក្នុងអនុវិស័យផ្សេងៗ។ ស្ទើរតែ ៩០ ភាគរយនៃថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា គឺត្រូវបានបម្រុងទុកសម្រាប់កម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សា ហើយថវិកាដែលនៅសល់ ១០ ភាគរយ គឺត្រូវបានបែងចែកទៅអនុវិស័យដូចជាៈ ការអប់រំកុមារថ្នាក់ដំបូង (ECE) ថ្នាក់ឧត្តមសិក្សា និងការអប់រំក្រៅប្រព័ន្ធ (NFE) (**ក្រាហ្វិក ៣៥**)។

## សុខភាព

ប្រទេសកម្ពុជាបានអភិវឌ្ឍគួរឲ្យកត់សម្គាល់ក្នុងការស្តាបនាឡើងវិញនូវប្រព័ន្ធសុខាភិបាលក្នុងប៉ុន្មានទសវត្សរ៍បន្ទាប់ពីរបបប្រល័យពូជសាសន៍ និងជម្លោះផ្ទៃក្នុងមក។ ប្រទេសកម្ពុជាបានបាត់បង់នូវបុគ្គលិកជំនាញខាងវិស័យសុខាភិបាលរបស់ខ្លួនប្រមាណជា ៩០ ភាគរយក្នុងអំឡុងរបបខ្មែរក្រហម។ ជាងនេះទៀត ជម្លោះផ្ទៃក្នុងដែលបានបន្តរហូតដល់ឆ្នាំ១៩៩៨បានបង្កផលលំបាកក្នុងការផ្តល់សេវាសុខាភិបាល។ បន្ទាប់មក ប្រទេសកម្ពុជាបានស្តាបនាឡើងវិញនូវប្រព័ន្ធសុខាភិបាលរបស់ខ្លួន។ ប្រព័ន្ធសុខាភិបាលសាធារណៈនាពេលបច្ចុប្បន្ននេះ គឺមានសមាសភាពរបស់ក្រសួងសុខាភិបាល មន្ទីរសុខាភិបាលប្រចាំខេត្តចំនួន ២៦ និងឃុំប្រតិបត្តិការសុខាភិបាលចំនួន ៧៧ ដែលជាទូទៅក្នុងមួយឃុំមានមួយ ឬមន្ទីរពេទ្យខេត្ត ព្រមទាំងមជ្ឈមណ្ឌលសុខភាពចំនួន ១០ ទៅ ១៥។ នាពេលបច្ចុប្បន្ននេះ មានមន្ទីរពេទ្យរដ្ឋចំនួន ៦ ពេទ្យបង្អែកចំនួន ៨៣ និងមជ្ឈមណ្ឌលសុខភាព ចំនួន ១.០២៤ ព្រមទាំងប៉ុស្តិ៍សុខភាពចំនួន ១២១ ប៉ុស្តិ៍នៅទូទាំងប្រទេស។ ក្រសួងសុខាភិបាលមានបុគ្គលិកចំនួន ១៩.៧០០ នាក់ រាប់បញ្ចូលទាំងវេជ្ជបណ្ឌិតចំនួន៣.២០០ នាក់ គិលានុបដ្ឋាកចំនួន ៩.០០០ នាក់ និង ឆ្មបចំនួន ៤.៦០០ នាក់។ កម្ពុជាបានសម្រេចនូវវត្ថុបំណងរបស់ខ្លួនក្នុងការធានាឲ្យបានយ៉ាងហោចណាស់ ក្នុងមជ្ឈមណ្ឌលសុខភាពនីមួយៗ មានឆ្មបបង្គោលមួយ ហើយនាពេលបច្ចុប្បន្ននេះ កម្ពុជាកំពុងព្យាយាមបង្កើននូវចំនួនឆ្មបជំនួយឲ្យបានច្រើនថែមទៀត។

### ប្រអប់ ៥៖ ប្រព័ន្ធគាំពារសង្គម នៅក្នុងប្រទេសកម្ពុជា

សមិទ្ធិផលថ្មីៗរបស់ប្រទេសកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ គឺមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ទោះជាយ៉ាងណាក៏ដោយមនុស្សម្នាក់ក្នុងចំណោមមនុស្ស ៥ នាក់នៅតែជាជនក្រីក្រ ហើយមនុស្សម្នាក់ក្នុងចំណោមមនុស្ស ៥ នាក់ដដែល គឺប្រឈមនឹងហានិភ័យក្នុងការធ្លាក់ចូលទៅក្នុងភាពក្រីក្រក្នុងរយៈពេលដ៏ខ្លីបំផុត។ ដូច្នេះល្បឿនយ៉ាងលឿននៃការកាត់បន្ថយភាពក្រីក្រកន្លងមក ប្រហែលជាមិនអាចបន្តទៅក្នុងពេលអនាគតបានទេ ដោយសារតែប្រជាពលរដ្ឋដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រមានការលំបាកខ្លាំង ក្នុងការងើបឲ្យផុតពីភាពក្រីក្រនេះ ហើយកំណើនសេដ្ឋកិច្ចអាចថយចុះ ខណៈពេលដែលការអភិវឌ្ឍបានកើនឡើង។

សម្រាប់ភាពក្រីក្រនិងភាពងាយរងគ្រោះ គឺទាមទារឲ្យមានប្រព័ន្ធគាំពារសង្គមមួយ ដែលជួយឱ្យគ្រួសារទាំងអស់អាចចាកចេញពីភាពក្រីក្រ និងវិបត្តិផ្សេងៗ ហើយនិងចូលរួមវិនិយោគនៅក្នុងវិស័យអភិវឌ្ឍន៍ធនធានមនុស្ស។ ការអភិវឌ្ឍន៍ និងនគរូបនីយកម្មបាននាំឲ្យមានការបាត់បង់ជាបណ្តើរៗនូវប្រព័ន្ធសំណាញ់សុវត្ថិភាពរបស់គ្រួសារតាមបែបប្រពៃណី ដែលតាមប្រវត្តិសាស្ត្រអាចជួយឲ្យប្រជាពលរដ្ឋ អាចដោះស្រាយជាមួយនឹងការខ្វះខាត និងហានិភ័យបាន។[12] ការបាត់បង់បន្តិចម្តងៗនៃសំណាញ់សុវត្ថិភាពនេះធ្វើឲ្យគ្រួសារទាំងអស់ងាយនឹងទទួលរងគ្រោះ។ លើសពីនេះទៀត បញ្ហានេះធ្វើឱ្យពួកគាត់ពិបាកក្នុងការចាកចេញពីភាពក្រីក្រ។ នៅក្នុង អ.ស.ស.ក ឆ្នាំ ២០១១ ចំនួន ៩៨ ភាគរយនៃចំនួនប្រជាពលរដ្ឋដែលបានស្ទង់មតិបានរាយការណ៍ថា មិនបានទទួលប្រាក់សោធននិវត្ត ឬអាហារូបករណ៍ណាមួយពីរដ្ឋាភិបាលនោះទេ។ លើសពីនេះទៅទៀត ៨០ ភាគរយនៃជនក្រីក្រមិនមានលទ្ធភាពទទួលបានការព្យាបាលសុខភាពដោយឥតគិតថ្លៃ ឬដោយការជួយឧបត្ថម្ភពីរដ្ឋាភិបាលទេ សូម្បីតែនៅក្នុងកម្រិតថ្នាក់បឋមសិក្សាក្តី។ នោះមានន័យថា ពួកគេត្រូវការខ្ចីប្រាក់ពីគេ (២៨ភាគរយ) ឬលក់ទ្រព្យសម្បត្តិ (៩ ភាគរយ) ដើម្បីចំណាយសម្រាប់ការថែទាំសុខភាព។ កម្រិតខ្ពស់នៃកង្វះអាហារូបត្ថម្ភរបស់កុមារក្នុងចំណោមជនក្រីក្រក៏ជាកង្វល់ដ៏ខ្លាំងផងដែរ ដោយសារតែកង្វះអាហារូបត្ថម្ភនេះធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់ការអភិវឌ្ឍន៍នៃចំណេះ ក៏ដូចជាការចំណាយដ៏ធំលើវិស័យធនធានមនុស្ស និងសេដ្ឋកិច្ច ទាំងនៅកម្រិតបុគ្គល និងកម្រិតជាតិ។

ថ្មីៗនេះរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានទទួលស្គាល់ពីភាពចាំបាច់ ក្នុងការបង្កើតឡើងនូវប្រព័ន្ធគាំពារសង្គមរួមមួយ។ រាជរដ្ឋាភិបាលបានបង្កើតនូវយុទ្ធសាស្ត្រជាតិគាំពារសង្គម (NSPS) សម្រាប់ឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ ដែលត្រូវបានចុះហត្ថលេខា ដោយលោកនាយករដ្ឋមន្ត្រី នៅឆ្នាំ២០១១។ យុទ្ធសាស្ត្រនេះមានគោលបំណងសម្រេចបានគោលដៅមួយចំនួនដូចជា (ក) ការពារជនក្រីក្របំផុត និងអ្នកជួបការលំបាកខ្លាំងបំផុតដែលមិនអាចជួយខ្លួនឯង (ខ) កាត់បន្ថយហានិភ័យដែលអាចនាំឱ្យមានផលលំបាកជាអវិជ្ជមាន និងបង្កឲ្យមានភាពក្រីក្របន្ថែមទៀត និង (គ) ការលើកកម្ពស់ដល់ជនក្រីក្រឲ្យរួចផុតពីភាពក្រីក្រ ដោយកសាងធនធានមនុស្ស និងបង្កើនឱកាសឲ្យបានច្រើនសម្រាប់ពួកគេ។ ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ ២០១៣ រដ្ឋាភិបាលបានធ្វើការជាមួយអង្គការអភិវឌ្ឍន៍លើការរៀបចំនៃការសាកល្បងកម្មវិធីចំនួនបី ដើម្បីដកយកបទពិសោធន៍ពីការរៀបចំកម្មវិធី និងយន្តការសម្រាប់ការផ្តល់សំណាញ់សុវត្ថិភាព។ ការអនុវត្តន៍នៃការសាកល្បងទាំងនេះត្រូវបានចាប់ផ្តើមនៅឆ្នាំ២០១៣។

គួរឱ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ ២០០៧ មក រដ្ឋាភិបាលបានរៀបចំបង្កើត និងបានអនុវត្ត (ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីអង្គការ GIZ និងAusAID) ប្រព័ន្ធកំណត់គោលដៅនៃភាពក្រីក្រជាផ្លូវការដែលហៅថា អត្តសញ្ញាណជាអ្នកក្រីក្រ (IDPoor) ដែលអាចអនុវត្តបានគ្រប់កម្មវិធីទាំងអស់។ យន្តការនេះផ្តោតសំខាន់លើការវាយតម្លៃតាមគ្រួសារតាមរយៈការសួរតាមកម្រងសំណួរស្ទង់មតិមួយដែលបានរួមបញ្ចូលជាមួយនឹងការពិភាក្សានៅថ្នាក់ភូមិ។ គ្រួសារដែលត្រូវបានកំណត់ថា ជាគ្រួសារក្រីក្របំផុត ឬក្រីក្រ ត្រូវបានចាត់ថ្នាក់ថាជា IDPoor ១ និង ២ រៀងគ្នា និងការទទួលបានកាតអត្តសញ្ញាណជាអ្នកក្រីក្រ (IDPoor) មួយ។ នៅឆ្នាំ២០១២ កម្មវិធីអត្តសញ្ញាណជាអ្នកក្រីក្រ IDPoor បានគ្របដណ្តប់ស្ទើរតែគ្រប់តំបន់ជនបទទាំងអស់ ដែលមានការស្ទង់មតិយ៉ាងហោច

ណាស់មួយដងៗ ការស្ទង់មតិត្រូវបានធ្វើឡើងម្តងទៀត នៅក្នុងខេត្តនីមួយៗ ជារៀងរាល់ ៣ ឆ្នាំម្តងៗ ការអភិវឌ្ឍនៃប្រព័ន្ធកំណត់គោលដៅនៃភាពក្រីក្រនៅតាមជាយក្រុងត្រូវបានគេគ្រោងធ្វើឡើងនៅឆ្នាំ២០១៣ៗ ជាអកុសល ប្រព័ន្ធអត្តសញ្ញាណជាអ្នកក្រីក្រ (IDPoor) នេះ មិនអនុញ្ញាតឱ្យមានការបញ្ជាក់អត្តសញ្ញាណឡើងវិញបាន ដូចនេះ តម្រូវឱ្យមានកម្មវិធីដើម្បីបង្កើតយន្តការដោះស្រាយ ក្នុងការកំណត់គោលដៅ (ដែលគួរកត់សម្គាល់ជាងគេនោះគឺមូលនិធិសមធម៌សម្រាប់សុខភាព)ៗ

បើទោះបីជាមានការប្តេជ្ញាចិត្តពីសំណាក់រដ្ឋាភិបាល និងការអាចរកបាននូវយន្តការកំណត់គោលដៅជនក្រីក្រក៏ដោយ ក៏ការគ្របដណ្តប់នៃសំណាញ់សុវត្ថិភាព គឺមានតែ ២ ភាគរយនៃក្រុមបញ្ចភាគភាពក្រីក្របំផុតនៃចំនួនប្រជាជន បើប្រៀបធៀបទៅនឹងមធ្យមភាគ ៥៣ ភាគរយ នៅក្នុងតំបន់អាស៊ីបូព៌ា និង ៤៩,៣ ភាគរយក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតៗ រហូតមកដល់ឆ្នាំ២០១៣ រដ្ឋាភិបាលបានផ្តល់មូលនិធិទៅឲ្យកម្មវិធីសំណាញ់សុវត្ថិភាពដ៏សំខាន់ចំនួន ៣ ៖ ការជួយទូទាត់ថ្លៃសុខុមាលភាពសម្រាប់ក្រុមជនងាយរងគ្រោះមួយចំនួន (មនុស្សចាស់, កុមារកំព្រា, អតីតយុទ្ធជន) តាមរយៈក្រសួងកិច្ចការសង្គម, អាហារូបករណ៍សម្រាប់កុមារក្រីក្រនៅតាមសាលាមធ្យមសិក្សាបឋមភូមិ តាមរយៈក្រសួងអប់រំ និងមូលនិធិសមធម៌សុខាភិបាល (HEFs) តាមរយៈក្រសួងសុខាភិបាល ដែលថវិកាទាំងអស់នេះក៏ជាហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍នានាផងដែរៗ ជាអកុសល គ្មានព័ត៌មានណាដែលអាចរកបានទាក់ទងទៅនឹងអ្នកដែលបានទទួលផលពីតំបន់សេវាកម្ម ឬចំនួននៃថវិកាដែលបានទូទាត់ថ្លៃសុខុមាលភាព ដែលធ្វើឡើងដោយក្រសួងសង្គមកិច្ច ដូច្នេះការវិភាគវិសាលភាពនៃអត្ថប្រយោជន៍ដែលអាចទទួលបាន គឺមិនអាចត្រូវបានធ្វើរួចឡើយ (អង្គការពលកម្មអន្តរជាតិ ILO ឆ្នាំ២០១២)ៗ ការវាយតម្លៃផលប៉ះពាល់ដោយធនាគារពិភពលោកបានរកឃើញថា កម្មវិធីអាហារូបករណ៍បានបង្កើនការចុះឈ្មោះចូលរៀនគួរឲ្យចាប់អារម្មណ៍ នៅក្នុងចំណោមអ្នកដែលបានទទួលផល ទោះបីជាមិនមានព័ត៌មានពាក់ព័ន្ធទៅនឹងភាពប្រព័ន្ធដែលផ្តោតសំខាន់ទៅលើជនក្រីក្រដែលត្រូវបានប្រើសំរាប់កម្មវិធីអាហារូបករណ៍ទាំងនោះក៏ដោយ (ហ្វីមមើ Filmer និង ស្កាឌី Schady, ឆ្នាំ២០០៩)ៗ ផ្នែកសុខភាពនៅក្នុងជំពូកនេះបានរកឃើញថា ភាពត្រឹមត្រូវនៃការកំណត់គោលដៅជនក្រីក្រសម្រាប់មូលនិធិសមធម៌ក្នុងការទទួលបានការព្យាបាលដោយឥតគិតថ្លៃ គឺមិនសូវមានទេ ដោយសារតែប្រហែល ៨០ ភាគរយនៃជនក្រីក្រ គឺពុំបានទទួលនូវមូលនិធិសមធម៌ ឬកាតអត្តសញ្ញាណប័ណ្ណជាអ្នកក្រីក្រ (IDPoor) ទេៗ កម្មវិធីសំណាញ់សុវត្ថិភាពផ្សេងៗទៀតដែលមានស្រាប់ គឺត្រូវបានទទួលការឧបត្ថម្ភថវិកា និងអនុវត្តដោយផ្ទាល់ពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលហើយតំបន់សេវាកម្មរបស់ពួកគេ គឺមានកំណត់ (អង្គការពលកម្មអន្តរជាតិ ILO ឆ្នាំ២០១២ និងរាជរដ្ឋាភិបាល ឆ្នាំ២០១០)ៗ អន្តរាគមន៍គួរឱ្យកត់សម្គាល់ភាគច្រើនក្នុងចំណោមកម្មវិធីទាំងនេះ គឺកម្មវិធីការងារសាធារណៈដែលប្រើកម្លាំងពលកម្ម ដែលបានអនុវត្តនៅក្នុងខេត្តមួយចំនួន ដែលស្ថិតនៅក្រោមកម្មវិធីដាច់ដោយឡែកពីគ្នាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ទោះបីជាកម្មវិធីនោះទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី និងកម្មវិធីស្បៀងអាហារពិភពលោក ឬ ជំនួយរបស់ប្រទេសអូស្ត្រាលីក៏ដោយៗ លើកលែងមូលនិធិសមធម៌សុខុមាលភាពចេញ យន្តការជានារ៉ាប់រងសង្គមមិនបានគ្របដណ្តប់ទៅលើជនក្រីក្រទេ ដោយសារតែយន្តការទាំងនោះ ត្រូវបានកំណត់ទៅឱ្យមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងនិយោជិតផ្លូវការ តាមរយៈមូលនិធិសន្តិសុខសង្គមថ្នាក់ជាតិសម្រាប់មន្ត្រីរាជការ ស៊ីវិល (NSSFC) មូលនិធិជាតិសម្រាប់អតីតយុទ្ធជន (NFV ) និងមូលនិធិសន្តិសុខសង្គមថ្នាក់ជាតិសម្រាប់និយោជិតវិស័យឯកជន (មូលនិធិសន្តិសុខសង្គម) តាមលំដាប់ (អង្គការពលកម្មពិភពលោក ILO, ឆ្នាំ២០១២)ៗ

ស្របពេលនៃការចាប់ផ្តើមនៃវិស័យគាំពារសង្គមនៅក្នុងប្រទេសកម្ពុជាថ្មីៗ ដែលមានតំបន់សេវាកម្មទាបខាងក្រោមនេះ គឺជាអនុសាសន៍គន្លឹះដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ និងដើម្បីជំរុញការវិនិយោគនៅក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងចំណោមជនក្រីក្រ៖

១). បង្កើនបរិមាណធនធានរបស់រដ្ឋាភិបាល ដើម្បីត្រៀមបម្រុងទុកសម្រាប់ការការពារសង្គមៗ ប្រការនេះនឹងធានាបាននូវនិរន្តរភាពរបស់ស្ថាប័ន និងហិរញ្ញវត្ថុ និងសម្រាប់កម្មវិធីទាំងនេះៗ ខណៈពេលដែលប្រទេសកម្ពុជាមានការរីកចម្រើនឆ្ពោះទៅរកស្ថានភាពប្រទេសដែលមានចំណូល

មធ្យម ការផ្តល់មូលនិធិពីម្ចាស់ជំនួយនឹងថយចុះ។ ដូច្នេះ ធនធានរបស់រដ្ឋាភិបាល គឺមានភាពចាំបាច់ខ្លាំងក្នុងការ បង្កើតប្រព័ន្ធគាំពារសង្គម។

២). ពង្រឹងយន្តការកំណត់គោលដៅអត្តសញ្ញាណប័ណ្ណជាអ្នកក្រីក្រ (IDPoor) ឲ្យបានខ្លាំង។ ប្រការនេះអាចត្រូវបានសម្រេចដោយធ្វើឱ្យប្រសើរឡើងនូវភាពត្រឹមត្រូវ និងការអនុញ្ញាតឱ្យមានការវាយតម្លៃ និងកំណត់អត្តសញ្ញាណឡើងវិញបាន បន្ទាប់ពីផ្តល់ជំនួយ ក៏ដូចជាការអភិវឌ្ឍន៍វិធីសាស្ត្រ ដើម្បីកំណត់អត្តសញ្ញាណប្រជាពលរដ្ឋមានហានិភ័យខ្ពស់ ក្នុងការធ្លាក់ចូលទៅក្នុងភាពក្រីក្រ (ការផ្តោតសំខាន់ទៅលើភាពងាយរងគ្រោះ)។

៣). ពង្រីកតំបន់សេវាកម្ម និងការធ្វើឲ្យប្រសើរឡើងនូវការកំណត់គោលដៅនៃតម្រូវការ។ ប្រការនេះនឹងជំរុញឲ្យមានការប្រើនូវសេវាកម្មសំខាន់ៗសម្រាប់ជនក្រីក្រ។ នេះរួមបញ្ចូលទាំងការបង្កើននូវកម្មវិធីអាហារូបករណ៍សម្រាប់កុមារមកពីគ្រួសារក្រីក្រ និងការកែលម្អការកំណត់អត្តសញ្ញាណ ព្រមទាំងការជំរុញឲ្យមានការប្រើប្រាស់នូវមូលនិធិសមធម៌សុខាភិបាល (HEFs) សម្រាប់ជនក្រីក្រ ក៏ដូចជាការធ្វើតេស្តអន្តរាគមន៍ថ្មីមួយដើម្បីគ្របដណ្តប់ចំណុចខ្វះខាតនៅក្នុងការផ្តល់សេវាសំខាន់ៗ (ដូចជា នៅក្នុងសេវាអាហាររូបត្ថម្ភ និងអនាម័យ)។

លើកកម្ពស់កម្មវិធីបើកចំហរចំពោះជនដែលងាយរងគ្រោះ។ កម្មវិធីទាំងឡាយមិនអាចត្រូវបានបើកចំហរសម្រាប់តែជនក្រីក្រមួយគត់ប៉ុណ្ណោះទេ ៖ ភាពងាយរងគ្រោះក៏ត្រូវតែកាត់បន្ថយផងដែរសម្រាប់ប្រជាពលរដ្ឋទាំងអស់។ កម្មវិធីបែបនេះមានដូចជាកម្មវិធីផ្តល់ការងារឲ្យសាធារណៈជនធ្វើការដើម្បីទទួលបានប្រាក់ចំណូល នៅពេលដែលពួកគាត់គ្មានការងារធ្វើ ក៏ដូចជាកម្មវិធីធានារ៉ាប់រងសុខភាពសង្គមនៅតាមសហគមន៍នានាដែលក្នុងនោះ អ្នកដែលងាយរងគ្រោះអាចចូលរួមផងដែរ។

សុខាភិបាលជាវិស័យអាទិភាពរបស់រដ្ឋាភិបាល។ យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល គឺផ្តល់អាទិភាពដល់ការកសាងពេទ្យបង្អែក និងមជ្ឈមណ្ឌលសុខភាពការផ្តល់សេវាថែទាំសុខភាពដោយមិនគិតថ្លៃដល់ពលរដ្ឋក្រីក្រ និងកម្មវិធីបន្តទប់ស្កាត់ និងព្យាបាលជំងឺឆ្លង។ អន្តរាគមន៍ផ្សេងៗទៀតនោះ រាប់បញ្ចូលទាំងការលើកកម្ពស់សុខភាពមាតានិងទារក និងការអនុម័ត ព្រមទាំងការអនុវត្តន៍និងពង្រឹងដល់ការគោរពច្បាប់ និងបទបញ្ញាពាក់ព័ន្ធនឹងសុខាភិបាលជាដើម។ សេចក្តីថ្លែងការណ៍គោលនយោបាយនៃយុទ្ធសាស្ត្រនេះត្រូវបានបញ្ជាក់បន្ថែមនៅក្នុងផែនការយុទ្ធសាស្ត្រសុខាភិបាលលើកទីពីរសម្រាប់ឆ្នាំ២០០៨ ដល់ឆ្នាំ ២០១៥។ ផែនការនេះផ្តោតលើការអភិវឌ្ឍន៍ប្រព័ន្ធសុខាភិបាល ដើម្បីឲ្យលទ្ធផលនៃវិស័យនេះមានភាពប្រសើរឡើង តាមរយៈការបង្កើតយុទ្ធសាស្ត្រចំនួន៥ ក្នុងការធ្វើឲ្យសម្រេចបាននូវគោលបំណងនេះ៖ (១) ការផ្តល់សេវាថែទាំសុខភាព (២) ការផ្តល់ហិរញ្ញទានដល់ការថែទាំសុខភាព (៣) ធនធានមនុស្សសម្រាប់វិស័យសុខាភិបាល (៤) ប្រព័ន្ធព័ត៌មានសុខភាព និង (៥) អភិបាលកិច្ច ប្រព័ន្ធសុខាភិបាល។ យុទ្ធសាស្ត្រ និង គោលការណ៍ផ្តល់ហិរញ្ញប្បទានដល់ការថែទាំសុខភាពថ្នាក់ជាតិត្រូវបានបញ្ជាក់បន្ថែមក្នុងធម្មនុញ្ញជាតិស្តីពីហិរញ្ញប្បទានសុខាភិបាល (ឆ្នាំ១៩៩៦) និងបែបផែនយុទ្ធសាស្ត្រសម្រាប់ហិរញ្ញទានសុខាភិបាល (២០០៨-២០១៥)។

**ប្រទេសកម្ពុជាបានអភិវឌ្ឍគួរឲ្យកត់សម្គាល់ ក្នុងការឆ្ពោះទៅរកការសម្រេចឲ្យបានគោលដៅអភិវឌ្ឍន៍សហ-**

**សហស្សវត្សរ៍ខាងវិស័យសុខាភិបាល។** ស្របពេលដែលសេដ្ឋកិច្ចកំពុងកើនឡើងសូចនាករសុខាភិបាលសំខាន់ៗក៏មានលក្ខណៈប្រសើរផងដែរ។ ចាប់តាំងពីឆ្នាំ២០០០ ដល់ឆ្នាំ ២០១០ អាត្រាមរណមាតា[13] បានធ្លាក់ចុះពី ៤៣៧ នាក់ មកនៅត្រឹម ២៨៨ នាក់ (ក្នុង ១០០.០០០ ករណីនៃកំណើតរស់) និងអាត្រាមរណកុមារ អាយុក្រោម ៥ឆ្នាំ[14] បានធ្លាក់ចុះពី ១២៤ នាក់មកនៅត្រឹម ៥៤ នាក់ (ក្នុងចំណោម ១០.០០០ ករណីនៃកំណើតរស់) (**ក្រាហ្វិក ៣៧**)។ ជាទូទៅ អាត្រាមរណកុមារអាយុក្រោម ៥ឆ្នាំបានធ្លាក់ចុះ បើធៀបនឹងឆ្នាំ ២០០០ ដែលមានក្មេង ១ នាក់ក្នុង ចំណោម ៨នាក់ បានកើតមកហើយស្លាប់ក្រោមអាយុ ៥ ឆ្នាំ។ មកដល់ឆ្នាំ ២០១០ អាត្រានេះមានលក្ខណៈប្រសើរជាងមុន ដោយមានក្មេង ១នាក់ក្នុងចំណោម ១៩ នាក់វិញ។ នាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងតែសំដៅឆ្ពោះដើម្បីសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទាំងពីរនេះ។

## មរណកុមារ

មរណកុមារមានទំនាក់ទំនងយ៉ាងខ្លាំងនឹងធនធានទ្រព្យសម្បត្តិ ជាពិសេសសម្រាប់កុមារអាយុចាប់ពី ១ ទៅ ១២ ខែ។ វិសមភាពជាបញ្ហាសំខាន់របស់ប្រទេសកំពុងអភិវឌ្ឍ ហើយប្រទេសកម្ពុជាក៏ដូច្នោះដែរ។ ក្រៅពីទ្វេគ្រោះដែលបានប្រឈមវិសមភាព ក៏បណ្ដាលឲ្យខ្វះប្រសិទ្ធិភាព និងយឺតយ៉ាវដល់ការអភិវឌ្ឍន៍ផងដែរ។ ថ្វីបើអាត្រាមរណកុមារបានធ្លាក់ចុះគួរឲ្យកត់សម្គាល់ (កុមារអាយុក្រោម ៥ ឆ្នាំ)ចាប់ពីឆ្នាំ២០០៥មក ការធ្លាក់ចុះនៃអាត្រាមរណកុមារនៅតំបន់ទីក្រុងមានសភាពខ្ពស់ជាងតំបន់ជនបទពីរដង និងសម្រាប់ក្រុមមញ្ជូភាគអ្នកមានគឺខ្ពស់ជាងក្រុមបញ្ចូភាគក្រីក្រ។ អត្រាមរណកុមារនៅតែមិនផ្លាស់ប្ដូរច្រើននោះទេ ដោយនៅតែខ្ពស់ជាង ៣.៣ ដង សម្រាប់ក្រុមបញ្ចូភាគអ្នកក្រីក្រធៀបនឹងក្រុមបញ្ចូភាគអ្នកមាន ចាប់ពីឆ្នាំ២០០៥មក (**ក្រាហ្វិក ៣៨**) ហើយខ្ពស់ជាង ៣ ដង សម្រាប់កុមារទីក្រុង ធៀបនឹងកុមារជនបទ។ ការអប់រំដល់មាតាក៏ជាកត្តាកំណត់ដល់មរណកុមារអាយុក្រោម ៥ ឆ្នាំផងដែរ។ កុមារដែលចាប់កំណើតពីមាតាដែលមិនបានទទួលការអប់រំអាចប្រឈមមុខនឹងការស្លាប់ក្នុងអាត្រាពីរដងខ្ពស់ជាងកុមារដែលចាប់កំណើតពីមាតាដែលទទួលបានការអប់រំត្រឹមមធ្យមសិក្សា ឬខ្ពស់ជាង នេះ។ ទោះជាយ៉ាងនេះក្ដី ស្ថានភាពដែលកុមារីមកពីគ្រួសារក្រីក្រមិនបានចូលរៀននៅថ្នាក់បឋមសិក្សា និងថ្នាក់មធ្យមសិក្សាអាចកើតមានឡើងច្រើនជាង ក្នុងអាត្រារៀង គ្នាចំនួន ២ដង និង ៥ដង ធៀបនឹងករណីនៃកុមារីមកពីគ្រួសារអ្នកមាន។

វិសមភាពបានធ្វើឲ្យមរណកុមារចាប់ពីអាយុ ១ ខែដល់ ១ ឆ្នាំ និងទារកដែលទើបចាប់កំណើតមានការវិវត្តន៍តិច

**ក្រាហ្វិក ៣៧៖** ប្រទេសកម្ពុជា កំពុងសំដៅទិសដើម្បីសម្រេចបាននូវអាត្រាមរណមាតា និងកុមារអាយុក្រោម ៥ ឆ្នាំ តាមផែនការអភិវឌ្ឍន៍សហស្សវត្សរ៍




**ប្រភព៖** CDHS ឆ្នាំ២០០០, ឆ្នាំ២០០៥ និងឆ្នាំ ២០១០។

តួច ជាពិសេសសម្រាប់ពលរដ្ឋក្រីក្រនិងនៅជនបទ។ មរណកុមារអាយុក្រោម ៥ ឆ្នាំ អាចចែកច្រើនប្រភេទ៖ ការស្លាប់របស់ទារក (ការស្លាប់របស់ទារកចាប់ពីកំណើតរហូតដល់អាយុ ១ខែ) មរណបន្ទាប់ពីអាយុទារក (មរណទារកអាយុចាប់ពី ១ ខែ ដល់ ១២ ខែ) និងមរណកុមារ (មរណកុមារចាប់ពីអាយុ ១ ឆ្នាំ ដល់ ៥ ឆ្នាំ)។ ការត្រួតពិនិត្យលើប្រភេទនៃមរណកុមារអាចឆ្លុះបញ្ចាំងឲ្យឃើញរបត់ជាច្រើន៖ ទីមួយ មរណកុមារអាយុពី ១ ឆ្នាំ ដល់ ៥ ឆ្នាំបានធ្លាក់ចុះយ៉ាងខ្លាំងនៅគ្រប់បណ្តាសហគមន៍ ហើយស្ថានភាពនេះបានធ្លាក់ចុះស្ទើរតែពាក់កណ្តាលសម្រាប់ក្រុមបញ្ចភាគក្រីក្រចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ ថ្វីបើស្ថានភាពកុមារមកពីក្រុមបញ្ចភាគក្រីក្របិតក្នុងអាយុទាំងនេះ ទំនងនឹងស្លាប់ក្នុងអាត្រាខ្ពស់ជាង៣ដងធៀបនឹងស្ថានភាពកុមារមកពីក្រុមបញ្ចភាគអ្នកមានក៏ដោយ។ ទីពីរ មរណបន្ទាប់ពីអាយុទារក គឺមានកម្រិតវិសមភាពខ្ពស់ជាងគេបង្អស់។ ខណៈដែលស្ថានភាពមរណបន្ទាប់ពីអាយុទារកសម្រាប់កុមារក្រីក្របានធ្លាក់ចុះពាក់កណ្តាលក្នុងអំឡុងចុងទសវត្សរ៍នេះអាត្រាមរណសម្រាប់កុមារក្រីក្រមានកម្រិតខ្ពស់ជាង ៦ ដង បើធៀបនឹងស្ថានភាពកុមារមកពីគ្រួសារអ្នកមាន។ ទីបី មរណទារកបានធ្លាក់ចុះតិចតួចបំផុត ក្នុងបណ្តាក្រុមបញ្ចភាគទាំងអស់ ពោលគឺធ្លាក់ចុះពី ៣៧ ក្នុងចំណោម ១.០០០ ករណីកំណើតរស់ក្នុងឆ្នាំ២០០០ មកនៅត្រឹម ២៨ សម្រាប់ឆ្នាំ២០០៥ ហើយមកនៅត្រឹម ២៧ សម្រាប់ឆ្នាំ២០១០៖ មរណទារកជាប្រភពស្នូលនៃមរណកុមារសម្រាប់ទាំងកុមារមកពីគ្រួសារក្រីក្រ និងកុមារមកពីគ្រួសារអ្នកមាន (**ក្រាហ្វិក ៣៨**)។ ខណៈដែលស្ថានភាពមរណទារកបានធ្លាក់ចុះសម្រាប់តំបន់ទីក្រុង ក្នុងអំឡុងឆ្នាំ២០០៥ ដល់ ២០១០ ក៏ដោយ ស្ថានភាពនេះមិនមានអ្វីប្រសើរសម្រាប់ទារកចាប់កំណើតនៅទីជនបទ ឬក្នុងគ្រួសារក្រីក្រនោះទេ (**ក្រាហ្វិក ៤២**)។

**ការធ្លាក់ចុះនៃអាត្រាមរណកុមារឆ្លុះបញ្ចាំងពីភាពប្រសើរឡើងនៃសេវាបង្កា និងស្ថានភាពសេដ្ឋកិច្ចសង្គម ដោយសារថា គុណភាពសេវាថែទាំមានឥទ្ធិពលខ្លាំងទៅលើការស្លាប់របស់ទារក។** ការធ្លាក់ចុះខ្លាំងនៃអាត្រាមរណកុមារទំនងឆ្លុះបញ្ចាំងពីភាពប្រសើរឡើងនៃស្ថានភាពសេដ្ឋកិច្ចសង្គមទូទៅ និងការគ្របដណ្តប់នៃយន្តការទប់ស្កាត់ ដូចជាការចាក់វ៉ាក់សាំងការពារជំងឺជាដើម។ ស្ថានភាពខុសគ្នាដែលនឹងបន្តរីកដុះដាលចំពោះអាត្រាមរណកុមារអាយុបន្ទាប់ពីទារក អាចបង្ហាញពីកត្តាជាច្រើនដែលរាប់បញ្ចូលទាំងស្ថានភាពខុសគ្នាដាច់នៃស្ថានភាពសេដ្ឋកិច្ចសង្គម ការអប់រំរបស់មាតា សុខភាពបរិស្ថាន និងអនាម័យ អាហារូបត្ថម្ភ និងការខ្វះលទ្ធភាពទទួលបានសេវាទប់ស្កាត់ និងព្យាបាលសុខភាពប្រកបដោយគុណភាព។ គុណភាពនៃការថែទាំមាតា និងទារករាប់បញ្ចូលទាំងពេលទង្ងន់ ពេលសម្រាល និងបន្ទាប់ពីសម្រាល គឺមានឥទ្ធិពល

**ក្រាហ្វិក ៣៨៖ អត្រាមរណកុមារអាយុចាប់ពី ០ ដល់ ៥ ឆ្នាំ តាមប្រភេទឆ្នាំ នៅប្រទេសកម្ពុជា**




**ប្រភព៖** CDHS ឆ្នាំ២០០០, ឆ្នាំ២០០៥ និងឆ្នាំ ២០១០។

ខ្លាំងដល់ស្ថានភាពការស្លាប់របស់ទារក។

**ការគ្របបណ្តប់មិនគ្រប់គ្រាន់ និងវិសមភាពនៃការទប់ស្កាត់ការពារសុខភាពបឋមជាកត្តាប៉ះពាល់ដល់មរណ-កុមារនៅប្រទេសកម្ពុជា។** នៅឆ្នាំ២០១០ កត្តា១០យ៉ាងដែលបណ្តាលឲ្យមានមរណកុមារក្រោមអាយុ ៥ ឆ្នាំក្នុងនោះ គឺផលលំបាកក្នុងពេលសម្រាល (ការស្ទះដង្ហើម ការសម្រាលមុនកំណត់ និងជំងឺបៅ), ជំងឺដែលអាចទប់ស្កាត់បានតាមរយៈការចាក់វ៉ាក់សាំងការពារ (រោគរលាកសួត និងជំងឺកញ្ជ្រិល), ឬបណ្តាលមកពីកង្វះលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យល្អ (រាគរូស) (**ក្រាហ្វិក ៣៩**)។ ការគ្របដណ្តប់មិនគ្រប់គ្រាន់ និងវិសមភាពក្នុងការទទួលបានការថែទាំសុខភាពដ៏ល្អនៅតែកើតមាន (ឧទាហរណ៍ ការថែទាំសុខភាពមុនពេលសម្រាល និងគុណភាពនៃការសម្រាលបុត្រ និងការថែទាំបន្ទាប់ពីសម្រាលបុត្ររួច), ជាងនេះទៅទៀត ការមិនបានចាក់វ៉ាក់សាំងគ្រប់គ្រាន់ និងកង្វះលទ្ធភាពក្នុងការទទួលបានទឹកស្អាតសម្រាប់បរិភោគ និងអនាម័យស្អាតល្អនៅតែជាកត្តាបណ្តាលឲ្យស្ថានភាពមរណកុមារក្រោមអាយុ ៥ ឆ្នាំ បន្តកើតមាន។

ជំងឺឆ្លងដូចជាជំងឺគ្រុនចាញ់បានធ្លាក់ចុះគួរឲ្យកត់សម្គាល់ ហើយនេះមិនត្រឹមតែដោយសារការកើនឡើងនូវការប្រើប្រាស់មុងជ្រលក់ទឹកថ្នាំនោះទេតែក៏ដោយសារការលើកកម្ពស់នូវលទ្ធភាព ដែលអាចទទួលបានការថែទាំព្យាបាលផងដែរ។ នាពេលបច្ចុប្បន្ន ប្រទេសនេះកំពុងឈានទៅរកដំណាក់កាលមុនកាលលុបបំបាត់ទាំងស្រុង ថ្វីបើការគំរាមកំហែងនៃភាពធន់នឹងថ្នាំអាចជាបញ្ហាបារម្ភក៏ដោយ។

**សូចនាករបានបង្ហាញនូវគ្រោះថ្នាក់កាន់តែច្រើនដល់ជីវិត នៅពេលដែលសម្រាលទារកដោយបុគ្គលិកជួបមិនមានជំនាញ។** តើអ្វីដែលអាចពន្យល់ដល់ការវិវត្តន៍ដ៏យឺត-យ៉ាវចំពោះមរណទារក? អង្គហេតុដែលថា អាត្រារៀងគ្នា ២៣ ភាគរយ និង១៧ ភាគរយនៃអាត្រាមរណកុមារក្រោមអាយុ ៥ ឆ្នាំ (**ក្រាហ្វិក ៣៩**) បណ្តាលមកពីការសម្រាលមុនកំណត់ និងជំងឺបៅពេលទើបសម្រាល ឬស្ទះដង្ហើមពេលសម្រាលរួច ជាសូចនាករបង្ហាញពីបរាជ័យនៃប្រព័ន្ធសុខាភិបាល និងសេវាថែទាំសុខភាពស្ត្រីមានផ្ទៃ-ពោះ (ការថែទាំ ពេលទម្ងន់, សម្រាល, និងបន្ទាប់ពីសម្រាល)។ អាត្រាមរណទារកបានធ្លាក់ចុះតិចតួចសម្រាប់

**ក្រាហ្វិក ៣៩៖** មូលហេតុភាគច្រើនដែលបណ្តាលឲ្យមានមរណកុមារអាយុក្រោម ៥ ឆ្នាំនៅប្រទេសកម្ពុជា ឆ្នាំ២០១០




**សម្គាល់៖** ជំងឺគ្រុនចាញ់ រោគអេដស៍ហ៊ីវ និងកញ្ជ្រិល នីមួយៗ គឺមានអាត្រា ≤ ២ ភាគរយ។
**ប្រភព៖** ក្រុមយោងជំងឺសើស្បែកសុខភាពកុមារ (CHERG) ឆ្នាំ២០១២។

តំបន់ជនបទ ដែលមានចំនួនប្រជាពលរដ្ឋច្រើនបំផុត ព្រមទាំងសម្រាប់សហគមន៍ក្រីក្រ (**ក្រាហ្វិក ៤០**)។ ការវិភាគតាមរ៉េហ្គ្រេស្សុងលើទិន្នន័យនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពបានគាំទ្រដល់របកគំហើញខាងលើ ដែលនេះឆ្លុះបញ្ចាំងថា ស្ថានភាពប្រថុយប្រថានដល់ជីវិតនឹងកើនឡើងចំពោះករណីដែលទារកត្រូវបានជួយសម្រាលពីសំណាក់ឆ្មបបុរាណ គិលានុបដ្ឋាការ និង ឆ្មប បើធៀបនឹងការជួយសម្រាលបុត្រដោយវេជ្ជបណ្ឌិតជំនាញ។ ស្រដៀងគ្នានោះដែរ ការវិភាគតាមរ៉េហ្គ្រេស្សុងដោយរក្សាអញ្ញាតិផ្សេងៗទៀតនៅថេរនោះ បានបង្ហាញនូវឱកាសដែលអាចស្លាប់កាន់តែធំ ប្រសិនបើការសម្រាលបុត្រត្រូវបានធ្វើឡើងតាមមន្ទីរពេទ្យរដ្ឋ បើធៀបនឹងការសម្រាលបុត្រនៅតាមផ្ទះ ហើយភាពប្រថុយប្រថានក៏នឹងអាចកាត់បន្ថយក្នុងករណីដែលការសម្រាលបុត្រត្រូវបានធ្វើឡើងនៅតាមមន្ទីរពេទ្យឯកជន។ លទ្ធផលទាំងនេះមិនអាចចាត់ទុកថា ត្រឹមត្រូវតាមស្តង់ដាស្ថិតិនោះឡើយដោយសារថា ទំហំនៃទិន្នន័យវិភាគគឺមានចំនួនតិចតួចពេក។

ភាពប្រថុយប្រថានខ្ពស់កើតឡើងនៅតាមបណ្តាមន្ទីរពេទ្យរដ្ឋ ភាគខ្លះអាចបណ្តាលឲ្យការសម្រាលបុត្រមានភាពប្រថុយប្រថានខ្ពស់ដែរ ប៉ុន្តែកង្វះគុណភាពនៃសេវាថែទាំក៏អាចជាកត្តាផងដែរ។

**បន្ទុកខាងជំងឺមិនឆ្លងដែលកំពុងរីកដុះដាលក៏អាចប៉ះពាល់ខ្លាំងដល់អ្នកក្រីក្រ ព្រមទាំងអ្នកដែលធូរធារផងដែរ។** ប្រទេសកម្ពុជាប្រឈមនឹងបន្ទុកទ្វេរដងនៃជំងឺឆ្លង និងជំងឺមិនឆ្លង។ ស្ថានភាពបន្ទុកជំងឺមិនឆ្លងមានលើសលុបលើជំងឺឆ្លង។ យោងតាមអង្គការសុខភាពពិភពលោក នៅឆ្នាំ២០០៤ ចំនួនអ្នកស្លាប់ ៨៣២ នាក់ ក្នុងចំណោម ១០០.០០០នាក់គឺបណ្តាលមកពីជំងឺមិនឆ្លង ខណៈដែលចំនួនអ្នកស្លាប់ ៦៦០ នាក់ គឺបណ្តាលមកពីជំងឺឆ្លង។ ខណៈដែលប្រទេសនេះកំពុងធ្វើការអភិវឌ្ឍន៍ និងបង្កើននូវការរំពឹងទុកនៃអាយុរស់រានមានជីវិតឲ្យបានវែងជាងមុន គេក៏បានរំពឹងថា ជំងឺមិនឆ្លងនឹងរាលដាលខ្លាំង ដែលនេះនឹងក្លាយជាបន្ទុករួមនៃជំងឺសម្រាប់ឆ្នាំបន្ទាប់ៗទៀត។ ជំងឺរ៉ាំរ៉ៃ និងស្ថានភាពជំងឺដូចជា សំពាធឈាមឡើងខ្ពស់ ទឹកនោមផ្អែម និងមហារីកនឹងប៉ះពាល់ខ្លាំងដល់អ្នកក្រីក្រ ហើយដោយសារតែលក្ខខណ្ឌសុខភាព ស្ថានការណ៍នេះរឹតតែធ្វើឲ្យពលរដ្ឋរឹតតែប្រឈមភាពប្រថុយប្រថានក្រីក្រថែមទៀត ដោយសារតែត្រូវចំណាយលើសុខភាព។ ការផ្តោតលើវិធានការបង្ការ និងព្យាបាល តាមរយៈសេវាត្រឹមត្រូវ និងរក្សាកញ្ចប់ហិរញ្ញប្បទានសម្រាប់ករណីជំងឺធ្ងន់ធ្ងរជាដើម គឺជាការចាំបាច់ក្នុងការកាត់បន្ថយបន្ទុកដែលបណ្តាលពីជំងឺនានា និងកាត់បន្ថយការចំណាយដែលនេះមិនត្រឹមតែសម្រាប់ពលរដ្ឋនោះទេ តែចំពោះប្រព័ន្ធសុខាភិបាលផងដែរ។ (**ក្រាហ្វិក ៤០**)

## សមភាពក្នុងការផ្តល់និងការប្រើប្រាស់សេវាកម្មសុខភាព

**ទោះបីជាចំនួនគ្របដណ្តប់នៃអន្តរាគមន៍ ដើម្បីបង្ការ និងអាកប្បកិរិយាផ្នែកសុខភាពអាចទទួលជោគជ័យក្នុងកម្រិតសមភាពបានល្អប្រសើរហើយនោះ ចំនួនគ្របដណ្តប់ផ្នែកផ្សេងនៅមានលក្ខណៈវិសមភាពខ្លាំងនៅឡើយ** (**រូបភាព ៤១**)។ ជាទូទៅ សមភាពគឺមានលក្ខណៈល្អប្រសើរចំពោះសេវាកម្ម ដែលតម្រូវឲ្យមានការជួបតែមួយដងជាជាងសេវាកម្មទាំងឡាយដែលតម្រូវឲ្យមានការព្យាបាលពេលក្រោយទៀត និងសេវាកម្មបន្តបន្ទាប់។ ឧទាហរណ៍

**ក្រាហ្វិក ៤០៖** អត្រាការស្លាប់ទារក តាមប្រភេទទីស្នាក់អាស្រ័យ និងស្ថានភាពទ្រព្យសម្បត្តិ នៅប្រទេសកម្ពុជា ឆ្នាំ ២០០០ និង ២០១០




**ប្រភព៖** CDHS ឆ្នាំ ២០០០, ឆ្នាំ២០០៥ និង ឆ្នាំ២០១០។

ខណៈពេលដែល ៨៩ ភាគរយ នៃចំនួនស្ត្រីក្រីក្របំផុត អាចទៅពិនិត្យផ្ទៃពោះមុនសម្រាលកូនយ៉ាងហោចណាស់ម្តង ក្នុងឆ្នាំ ២០១០ មានស្ត្រីក្រីក្រជាម្តាយ តែ ៤០ ភាគរយបានទទួលការត្រួតពិនិត្យមុនពេលមានផ្ទៃពោះចំនួន ៤ ដង ដែលជាចំនួនណែនាំ ប្រសិនបើប្រៀបធៀបនឹង ៨០ ភាគរយ ក្នុងចំណោមអ្នកមានបំផុត។ ចំណុចនេះបណ្តាលឲ្យមានលទ្ធភាពទទួលបានការគាំទ្រផ្នែកអាហារបំប៉នតិចតួច (ឧទាហរណ៍ អាស៊ីដហ្វូលិក និងការបន្ថែមជាតិដែក) ហើយលទ្ធភាពដែលអាចឲ្យការសម្រាលកូនមានគុណភាពក៏តិចតួចផងដែរ។ ដូច្នេះនាំឲ្យមានកើតមានភាពប្រឈមកម្រិតខ្ពស់នៃមរណភាពទារកនិងមាតា។ ការចូលរួមក្នុងការសម្រាលកូនដោយអ្នកមានជំនាញបានកើនឡើងជាខ្លាំងក្នុងទសវត្សរ៍ចុងក្រោយ ប៉ុន្តែនៅតែបង្ហាញចន្លោះធំរវាងអ្នកមានបំផុត និងអ្នកក្របំផុត។ ស្ត្រីនៅក្នុងតំបន់ជនបទមានទំនោរបង្កើតកូននៅផ្ទះច្រើនជាងស្ត្រីនៅក្នុងទីប្រជុំជន ៣ ដង (CDHS ឆ្នាំ២០១០)។ អ្នកក្រីក្រទំនងជារស់នៅឆ្ងាយពីមណ្ឌលសុខភាពសាធារណៈ និងប្រឈមនឹងការចំណាយប្រាក់ និងឱកាសខ្ពស់ជាងដើម្បីអាចមកត្រួតពិនិត្យជាបន្តបន្ទាប់ ឬសម្រាប់យានជំនិះពេលសម្រាលកូន។ ផ្ទុយមកវិញសេវាកម្មដែលផ្តល់តាមរយៈសកម្មភាពចុះមូលដ្ឋាន (ដូចជាការចែកចាយវីតាមីន) អាចធ្វើឲ្យមានចំនួនគ្របដណ្តប់មានសមភាពបានខ្លះ តែចំណុចនេះគួរតែត្រូវអភិវឌ្ឍន៍បន្ថែមទៀត។

**ទោះបីជាមានការប្រសើរឡើងគួរឲ្យកត់សម្គាល់ក្នុងផ្នែកការចាក់ថ្នាំបង្ការ អ្នកក្រីក្របំផុតនៅតែរងគ្រោះពីអត្រានៃចំនួនគ្របដណ្តប់ដ៏ទាបដដែល។** ចំនួនគ្របដណ្តប់នៃការចាក់វ៉ាក់សាំងការពារជំងឺជាច្រើនបានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេល ២ ឆ្នាំ ចាប់ពី ៤០ ភាគរយនៃចំនួនកុមារដែលទទួលបានការចាក់វ៉ាក់សាំងបង្ការជំងឺកញ្ជ្រិល ខាន់ស្លាក់ ក្អកមាន់ និង តេតាណុស (DTP) និង Bacillus Calmette–Guerin (BCG) ក្នុងឆ្នាំ១៩៩០ ទៅ ៩០ ភាគរយ ក្នុង ឆ្នាំ២០១០។ អត្រាដ៏ខ្ពស់នៃការគ្របដណ្តប់នេះ បានរួមចំណែកកាត់បន្ថយជំងឺ និងការស្លាប់របស់កុមារ។ ប៉ុន្តែ មានត្រឹមតែ ៦៥ភាគរយនៃចំនួនជនក្រីក្រសរុបប៉ុណ្ណោះ ដែលទទួលបានការចាក់ថ្នាំបង្ការបានពេញលេញបើធៀបទៅនឹង ៨៨ ភាគរយ នៃចំនួនក្រុមបញ្ចភាគអ្នកមានបំផុត។ ការធានានូវចំនួនគ្របដណ្តប់នៃការចាក់ថ្នាំបង្ការមេរោគសម្រាប់ជនក្រីក្រ និងសហគមន៍ដាច់ស្រយាលឲ្យបានខ្ពស់នឹងអាចជួយកាត់បន្ថយការឈឺ

**ក្រាហ្វិក ៤១៖** លទ្ធភាពទទួលបានការអន្តរាគមន៍ផ្នែកសុខភាពសំខាន់ៗ Q1 និងចន្លោះជាមួយ Q5 ប្រទេសកម្ពុជា ២០១០




**កំណត់សម្គាល់៖** ORT + ការបំបៅសូមមើលការព្យាបាលជំងឺរាគ

**ប្រភព៖** ធនាគារពិភពលោក, របាយការណ៍អភិវឌ្ឍន៍ពិភពលោក។

ថ្នាក់ និងអត្រាមរណភាពពីជំងឺដូចជា រោគរលាកសួត និងកញ្ជ្រិល ដែលស្ថិតក្នុងចំណាត់ថ្នាក់ទីបី និងទី១០ ដោយឡែកពីគ្នានៃមូលហេតុចម្បងៗបំផុត បណ្តាលឲ្យមានមរណភាពសម្រាប់កុមារក្រោមប្រាំឆ្នាំ។ ផលវិបាកចុងក្រោយនៃចំនួនគ្របដណ្តប់ខុសៗគ្នាក្នុងវិធានការការពារជំងឺ និងទម្លាប់ការថែរក្សាសុខភាព គឺមានភាពមិនស្របស៊ីគ្នាជាមួយនឹងអត្រាមរណភាពនៃក្រុមមនុស្សប្រាំនាក់ដែលជាអ្នកមាន។

**អ្នកក្រីក្រច្រើនជាង ៩០ ភាគរយទៅរកសេវាកម្មថែរក្សាសុខភាពពេលមានជំងឺ ប៉ុន្តែភាគច្រើនទៅរកសេវាកម្មពីឱសថដ្ឋាន និងទីផ្សារលក់ឱសថគ្មានអាជ្ញាប័ណ្ណ។** ភាគរយនៃជនក្រីក្រទៅរកសេវាកម្មថែរក្សាសុខភាពនៅពេលមានជំងឺ កើនឡើងពី ៦២ ភាគរយ ក្នុងឆ្នាំ២០០៤ ទៅ ៩២ ភាគរយ ក្នុងឆ្នាំ២០១១។ នេះជានិន្នាការគួរឲ្យលើកសរសើរ។ ភាគរយនៃជនក្រីក្រស្វែងរកការថែទាំសុខភាពក្នុងវិស័យសាធារណៈ កើនឡើងក្នុងកម្រិតថេរចាប់ពីឆ្នាំ២០០៤ ទៅ ឆ្នាំ២០០៩ ប៉ុន្តែ ក្រោយមកបានធ្លាក់ចុះពី ២៦ ភាគរយ ក្នុងឆ្នាំ២០០៩ ទៅ ១៦ភាគរយ ក្នុងឆ្នាំ២០១១ ដោយ ៣៥ ភាគរយស្វែងរកការថែទាំសុខភាពក្នុងវិស័យឯកជន និង ៤៨ ភាគរយស្វែងរកការថែទាំសុខភាព តាមរយៈហាងលក់ឱសថ និងក្រៅវិស័យសុខាភិបាល។ ក្នុងឆ្នាំ ២០១១ ប្រភពដែលជនក្រីក្រទទួលការព្យាបាល គឺហាងនិងទីផ្សារលក់ឱសថដែលគ្មានអាជ្ញាប័ណ្ណ (៤៧ ភាគរយ) មណ្ឌលសុខភាព (១៣ ភាគរយ)

ឱសថស្ថានឯកជន (១៣ ភាគរយ) និងអ្នកផ្តល់សេវាផ្នែកវេជ្ជសាស្ត្រឯកជនដទៃទៀត (៩ ភាគរយ)។ បន្ថែមពីលើនោះ ចំនួនការប្រើប្រាស់មន្ទីរពេទ្យថ្នាក់ខេត្ត និងថ្នាក់ស្រុករបស់អ្នកក្រីក្រធ្លាក់ចុះពាក់កណ្តាលពីឆ្នាំ ២០០៧ ដល់ ឆ្នាំ២០១១ (ទៅត្រឹមតែ ១,៤ ភាគរយ និង ០,៦ ភាគរយដោយឡែកពីគ្នា)។ អ្នកមានបំផុតស្វែងរកសេវាកម្មប្រហែលជា ៣ភាគ៤ដងពីវិស័យឯកជន ប៉ុន្តែពួកគេមានទំនោរក្នុងការប្រើប្រាស់មន្ទីរពេទ្យថ្នាក់ ស្រុក ថ្នាក់ខេត្ត ឬថ្នាក់ជាតិច្រើនជាងអ្នកក្រីក្រចំនួនពីរដង (**តារាង ២៤**)។ ប្រជាពលរដ្ឋរស់នៅទីក្រុងភ្នំពេញគឺជាអ្នកដែលប្រើប្រាស់មន្ទីរពេទ្យថ្នាក់ជាតិញឹកញាប់បំផុត (៥ ភាគរយនៃពេលវេលាសរុប) ប៉ុន្តែប្រហែលជា ៧០ ភាគរយនៃប្រជាពលរដ្ឋរស់នៅក្នុងទីក្រុងភ្នំពេញ ទិញថ្នាំដោយផ្ទាល់ពីឱសថស្ថានឯកជន ពេលដែលពួកគេឈឺ។ ភាគរយនៃប្រជាពលរដ្ឋក្រីក្រស្វែងរកសេវាថែទាំសុខភាពតាមរយៈការព្យាបាលដល់ផ្ទះ ឬបុគ្គលិកផ្នែកសុខាភិបាលទទួលបានការបណ្តុះបណ្តាល គឺមានចំនួនដូចគ្នានឹងការទៅមណ្ឌលសុខភាព (៩ ភាគរយ) ដែលនេះបញ្ជាក់ពីការរាលដាលនៃការអនុវត្តពីរបៀបក្នុងតំបន់ជនបទជាបន្តបន្ទាប់។

**អាកប្បកិរិយាស្វែងរកការព្យាបាលសុខភាពរងឥទ្ធិពលពីថ្លៃចំណាយធៀបនឹងទ្រព្យសម្បត្តិដែលមានទស្សនៈចំពោះគុណភាព ភាពអាចរកបាន និងការយល់ឃើញពីភាពធ្ងន់ធ្ងរនៃជំងឺ។** អ្វីដែលសំខាន់គឺត្រូវបែងចែករវាងការស្វែងរកសេវាថែទាំសុខភាពសម្រាប់ការថែទាំកម្រិតចម្បង និងកម្រិតបន្ទាប់បន្សំ។ អ្នកក្រីក្រមានចំណូលចិត្តទៅរកអ្នកលក់ឱសថ និងអ្នកផ្តល់សេវាឯកជនដែលមានជំនាញព្យាបាលក្នុងកម្រិតបឋម ហើយមានតម្លៃសេវាទាប៖ ចំណុចនេះបង្ហាញឲ្យឃើញថា ដោយសារតែភាពងាយស្រួល (ឧទាហរណ៍ ភាពញឹកញាប់ រយៈពេលនៃការរង់ចាំ និង ផ្សេងៗ)។ ចាប់ពីឆ្នាំ២០០៩ ដល់ ២០១១ ការចំណាយជាមធ្យមរបស់អ្នកក្រីក្រនៅហាងលក់ឱសថគឺប្រហែលជា ២ ដុល្លារ ចំណែកឱសថស្ថានឯកជនមានតម្លៃលើសតែបន្តិច គឺជាមធ្យម ៥ដុល្លារ (**តារាង ២៤**)។ ប៉ុន្តែ ហាងលក់ឱសថនិងឱសថស្ថានហាក់ដូចជានៅជិតជាង និង រយៈពេលនៃការរង់ចាំតិចជាង។ ទោះបីជាយ៉ាងណាក៏ដោយ ក៏សម្រាប់ការព្យាបាលបន្ទាប់បន្សំ (គេងពេទ្យ) ថ្លៃចំណាយមានកម្រិតខ្ពស់ជាងអ្នកក្រីក្រ ក៏ដូចជាប្រជាពលរដ្ឋជាមធ្យមចូលចិត្តផ្នែកសាធារណៈ និងគម្រោងសង្គមក្នុងគោលបំណងកាត់បន្ថយចំណាយ ដូចជាមូលនិធិសមភាពសុខភាព (HEF) ដែលបានបង្កើនតម្រូវការសេវាថែទាំសុខភាពក្នុងចំណោមអ្នកក្រីក្រ។

## សមភាពនៃការចំណាយលើសុខភាព

**ការចំណាយលើសុខភាព** (ភាគរយនៃប្រាក់ចំណូល) **និងការចំណាយលើសុខភាពដ៏ហួសហេតុបានធ្លាក់ចុះ**

**តារាង ២៤៖** អ្នកផ្តល់សេវាសុខាភិបាលដែលត្រូវបានប្រើប្រាស់ និងតម្លៃជាមធ្យម ប្រទេសកម្ពុជា ឆ្នាំ២០០៧ ដល់ ២០១១

| | % ស្វែងរក ឆ្នាំ២០០៧ | % ស្វែងរកការថែទាំសុខភាព ក្នុងឆ្នាំ២០១១ | | | | ចំណាយជាមធ្យមឆ្នាំ ០៩ - ១១ | |
|---|---|---|---|---|---|---|---|
| | ក្រីក្របំផុត | ក្រីក្របំផុត | មានបំផុត | ជនបទ | ភ្នំពេញ | ទាំងអស់ | ក្រីក្របំផុត |
| មន្ទីរពេទ្យថ្នាក់ជាតិ | ០,៧% | ០,៩% | ២,២% | ១,៣% | ៥,០% | $៨៤ | $៤ |
| មន្ទីរពេទ្យថ្នាក់ខេត្ត | ៣,៤% | ១,៤% | ២,៩% | ១,៦% | ០,៨% | $៦៣ | $៩ |
| មន្ទីរពេទ្យថ្នាក់ស្រុក | ១,៩% | ០,៦% | ៣,៣% | ២,៥% | ០,០% | $៣៤ | $៨ |
| មណ្ឌលសុខភាព /ប៉ុស្តិ៍សុខភាព | ១៩,៦% | ១៣,៤% | ៣,៥% | ៨,៨% | ០,៥% | $៧១ | $១១ |
| សរុបសាធារណៈ: | ២៥,៦% | ១៦,៣% | ១១,៩% | ១៤,២% | ៦,៣% | $៣៩ | $៦ |
| មន្ទីរពេទ្យឯកជន | ១,៥% | ០,៧% | ២,៨% | ១,៦% | ១,៥% | $៥១ | $១៨ |
| គ្លីនិកឯកជន | ៩,០% | ៦,៩% | ១៩,៤% | ១៣,៣% | ១១,១% | $៤៣ | $១០ |
| បុគ្គលិកផ្នែកសុខភាពដែលបានបណ្តុះបណ្តាលនៅគ្រប់ទីកន្លែង | ១៩,៩% | ៥,៨% | ៨,៤% | ៩,១% | ៤,៣% | $១៨ | $១៧ |
| ឱសថស្ថានឯកជន | ៦,៩% | ១២,៧% | ៣៩,២% | ១៦,២% | ៦៨,២% | $៨ | $៥ |
| សរុបផ្នែកវេជ្ជសាស្ត្រឯកជន | ៣៧,៣% | ២៦,១% | ៦៩,៨% | ៤០,២% | ៨៥,១% | $២០ | $៧ |
| ហាង/ទីផ្សារលក់ឱសថ | ៣៧,៤% | ៤៦,៩% | ១៤,១% | ៣៥,៩% | ៧,៦% | $៤ | $២ |
| ឯកជនដទៃទៀត | ២,៦% | ៩,៣% | ៣,០% | ៧,៩% | ០,០% | $១៦ | $៥ |
| គ្រូខ្មែរ/លោកសង្ឃ | ០,៤% | ០,៩% | ០,៨% | ១,០% | ០,៦% | $២៦ | $២៤ |
| សរុបផ្នែកមិនមែនវេជ្ជសាស្ត្រឯកជន | ៤០,៤% | ៥៧,១% | ១៧,៩% | ៤៤,៨% | ៨,២% | $៧ | $៣ |
| សរុបរួម | **១០០ %** | **៩៩%** | **១០០%** | **៩៩%** | **៩៩%** | **$១៨** | **$៥** |

* **កំណត់សម្គាល់៖** តម្លៃឆ្លើយតបសម្រាប់តែអ្នកដែលស្វែងរកការថែទាំសុខភាពក្នុងប្រភេទអ្នកផ្តល់សេវាកម្មនីមួយៗ។ ចំនួនសរុបត្រូវបានវិនិច្ឆ័យតាមរយៈ ការប្រើប្រាស់ជាញឹកញាប់។ តារាងរាយការណ៍ពីទីកន្លែងដំបូងដែលប្រជាពលរដ្ឋទៅស្វែងរកសេវាថែទាំសុខភាព ក្នុងចំណោមចំនួនមនុស្សដែលមកទទួលសេវាថែទាំសុខភាព។ ថ្លៃចំណាយជាមធ្យមក្នុងរយៈពេល ៣០ឆ្នាំកន្លងមកនេះ ប្រហែលជារួមបញ្ចូលការទៅកាន់កន្លែងផ្តល់សេវាដទៃទៀត និងបានបង្ហាញជាប្រាក់ដុល្លារដែលមានតម្លៃថេរក្នុងទីក្រុងភ្នំពេញ (១ ដុល្លារអាមេរិក = ៤,០៤៤ រៀល)

**ប្រភព៖** ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ផ្អែកលើអ.ស.ស.ក ឆ្នាំ ២០០៧ ឆ្នាំ២០០៩ ឆ្នាំ២០១០ ឆ្នាំ២០១១។

**ចាប់តាំងពី ឆ្នាំ២០០៩ ដោយសារតែប្រាក់ចំណូលកើន និងការកើនឡើងនៃការប្រើប្រាស់សេវាកម្ម ដែលមានតម្លៃទាប។** ការចំណាយទៅលើសុខភាពអាចជាប្រភពចម្បងនៃការធ្វើឲ្យកាន់តែក្រីក្រ។ បើគិតជាភាគរយនៃប្រាក់ចំណូលសរុប ការចំណាយទៅលើសុខភាពបានធ្លាក់ចុះពី ៣,៣ ភាគរយក្នុងឆ្នាំ២០០៧ ទៅ ២,៥ភាគរយ ក្នុងឆ្នាំ ២០១១ សម្រាប់ប្រជាពលរដ្ឋកម្ពុជា និង ចាប់ពី ២ ភាគរយ ទៅ ១,៥ ភាគរយ សម្រាប់អ្នកក្រីក្រ (**រូបភាព ៤២**)។ ប៉ុន្តែ ប្រជាពលរដ្ឋនៅជនបទបច្ចុប្បន្នចំណាយ ២,៨ ភាគរយនៃប្រាក់ចំណូលរបស់ខ្លួនលើសុខភាពធៀបទៅនឹងចំនួន ១ ភាគរយ សម្រាប់ពលរដ្ឋនៅភ្នំពេញ។ ការចំណាយលើសុខភាពដ៏ហួសហេតុ (ត្រូវបានកំណត់និយមន័យថា ជាការចំណាយក្នុងគ្រួសារច្រើនជាង ៤០ ភាគរយនៃការចំណាយប្រចាំឆ្នាំលើវត្ថុមិនមែនជាចំណីអាហារទៅលើសុខភាព) ជាមធ្យមស្មើរតែ ៥ ភាគរយ

ក្នុងឆ្នាំ ២០០៤ ឆ្នាំ ២០០៧ និងឆ្នាំ ២០០៩។ ការចំណាយនេះបានធ្លាក់ចុះពី ៣,៦ ភាគរយ ក្នុងឆ្នាំ ២០១០ និងធ្លាក់ម្តងទៀតទៅ ២,៨ ក្នុងឆ្នាំ ២០១១។ ការធ្លាក់ចុះជាទូទៅនៃការចំណាយលើសុខភាពជាភាគ-រយនៃប្រាក់ចំណូល និងការចំណាយហួសហេតុប្រហែលដោយសារតែការបញ្ចូលគ្នារវាងការកើនឡើងប្រាក់ចំណូល និងការផ្លាស់ប្តូរទៅប្រើសេវាកម្មដែលចំណាយតិច តាមរយៈឱសថស្ថានឯកជន និងហាងលក់ឱសថ។ នៅកម្ពុជា ដូចជាបណ្តាប្រទេសដទៃ ការចំណាយលើសុខភាពហាក់កើនឡើងមិនសមាមាត្រនឹងប្រាក់ចំណូលឆ្លុះបញ្ចាំងពីការប្រើប្រាស់ប្រាក់ចំណូលយ៉ាងច្រើន និងលទ្ធភាពទទួលបានសេវាសន្សំ។

**...ប៉ុន្តែ ការចំណាយលើសុខភាពនៅតែជាប្រភពដ៏សំខាន់នៃការបង្កើតឲ្យមានបំណុលរបស់អ្នកក្រីក្រ និងអ្នកជិតក្រ និងអ្នកជំងឺរ៉ាំរ៉ៃ។** ទោះបីជាមានភាពប្រសើរឡើង ចំនួនប្រជាពលរដ្ឋកម្ពុជាដែលបានប៉ាន់ស្មានចំនួន ២ ភាគរយ ធ្លាក់ទៅក្នុងភាពក្រីក្រក្នុង ឆ្នាំ២០១១ ដោយសារតែការចំណាយលើសុខភាព ដែលជាការធ្លាក់ចុះបន្តិចពី ៣ ភាគរយ ក្នុងឆ្នាំ ២០០៤។ ការចំណាយលើសុខភាពនៅតែជាបន្ទុកដ៏ធ្ងន់ធ្ងរសម្រាប់អ្នកក្រីក្រ ដោយមាន ១៨ ភាគរយនៃអ្នកក្រីក្របង្កើតបំណុល ដោយសារតែការចំណាយលើសុខភាព។ ការចំណាយលើសុខភាពក៏ជាបន្ទុកដ៏ធ្ងន់ធ្ងរសម្រាប់ក្រុមគ្រួសាររបស់ប្រជាពលរដ្ឋកម្ពុជាចំនួន ៩,៤ ភាគរយ ដែលបានរាយការណ៍ថា យ៉ាងហោចណាស់មានសមាជិកក្នុងគ្រួសារម្នាក់ធ្លាក់ខ្លួនឈឺក្នុងឆ្នាំ ២០១១ (ដោយសារជំងឺរ៉ាំរ៉ៃ ឬរបួស)។ ក្រុមគ្រួសារក្រីក្រចំណាយ ២៥ ភាគរយនៃប្រាក់ចំណូលប្រចាំខែក្នុងម្នាក់សម្រាប់ជំងឺដែលមានរយៈពេលយូរអង្វែង។ ប៉ុន្តែនៅជនបទ ការចំណាយលើសុខភាពជាមធ្យមសម្រាប់ជំងឺរ៉ាំរ៉ៃ គឺ ១២៥ ភាគរយនៃប្រាក់ចំណូលក្នុងម្នាក់ ដែលនាំឲ្យក្លាយជាបន្ទុកដ៏ធ្ងន់ធ្ងរ និងបង្កើតឲ្យមានបំណុលសម្រាប់គ្រួសារទាំងមូល។

**មូលនិធិសមភាពសុខភាព (HEFs) និងគម្រោងឧបត្ថម្ភដទៃទៀតបានកាត់បន្ថយចំណាយ និងបំណុលរបស់អ្នកក្រីក្រ ហើយស្របពេលជាមួយគ្នាបង្កើនការប្រើប្រាស់សេវាកម្មសាធារណៈ។** មូលនិធិសមភាពសុខភាព (HEFs) ត្រូវបានបង្កើតឡើងដំបូង ដោយអង្គការមិនមែនរដ្ឋាភិបាល ក្នុងចុងទសវត្សរ៍ទី ៩០ ដើម្បីបង់ប្រាក់ថ្លៃគេងពេទ្យឲ្យអ្នកក្រីក្រ។ ក្រោយមកមូលនិធិនេះត្រូវបានពង្រីកទៅដល់ស្រុកប្រតិបត្តិ ចំនួន ៤៤ ក្នុងចំណោមស្រុកប្រតិបត្តិសរុប៧៧ របស់កម្ពុជាក្នុងឆ្នាំ២០១៣។ ប្រហែលជាពីរភាគបីនៃចំនួនអ្នកក្រីក្រត្រូវបានគ្របដណ្តប់ បើគិតតាមភូមិសាស្ត្រ ហើយរដ្ឋាភិបាលប្តេជ្ញាដើម្បីសម្រេចបាននូវចំនួនគ្របដណ្តប់ថ្នាក់ជាតិ ក្នុងឆ្នាំ ២០១៥។ ការគ្របដណ្តប់ក៏ត្រូវបានពង្រីកពីការថែរក្សាសម្រាប់អ្នកគេងពេទ្យទៅសេវាកម្មអ្នកជំងឺធម្មតាដែលមានមណ្ឌលសុខភាព

**រូបភាព ៤២៖** ការចំណាយលើសុខភាព គិតជាភាគរយនៃប្រាក់ចំណូលសរុប




ការចាយវាយដ៏ខ្លាំងក្លា ត្រូវបានកំណត់ថា ជាការចាយវាយក្នុងចំនួនច្រើនជាង ៤០ ភាគរយនៃការចំណាយក្រៅពីចំណីអាហារ ទៅលើសុខភាព។

**ប្រភព៖** ធនាគារពិភពលោក, របាយការណ៍អភិវឌ្ឍន៍ពិភពលោក។

ចំនួន ៣០០ ក្នុងចំណោម ១,១០០ នៅកម្ពុជាមានលក្ខណៈគ្រប់គ្រាន់ក្នុងការទទួលបានមូលនិធិសមភាពសុខភាព (HEFs) នេះ។ មូលនិធិទាំងនេះបានក្លាយទៅជាប្រភពសំខាន់នៃប្រាក់ចំណូល ដែលអាចបត់បែនបានសម្រាប់សេវាកម្មសាធារណៈ ដោយ ៦០ ភាគរយនៃប្រាក់ចំណូលត្រូវបានប្រើប្រាស់សម្រាប់ចំណាយទៅលើបុគ្គលិក និងប្រាក់ចំណូលដែលនៅសល់សម្រាប់ថ្លៃប្រតិបត្តិការ។ ជនក្រីក្រត្រូវកំណត់ដោយប្រព័ន្ធអត្តសញ្ញាណប័ណ្ណជនក្រីក្រដែលគ្រប់គ្រងដោយក្រសួងផែនការ ដោយការចេញកាតសម្រាប់ប្រើមូលនិធិ។ ប៉ុន្តែ ប្រតិបត្តិករមូលនិធិសមភាពសុខភាព (HEFOs ជាទូទៅគឺអង្គការមិនមែនរដ្ឋាភិបាល) ក៏បានប្រើប្រព័ន្ធ "បន្ទាប់ពីអត្តសញ្ញាណប័ណ្ណ" ដើម្បីផ្តល់សេវាកម្មដោយឥតគិតថ្លៃទៅដល់ជនក្រីក្រដែលមិនមានកាតផងដែរ។ ប្រតិបត្តិករមូលនិធិក៏ត្រូវទទួលខុសត្រូវក្នុងការតាមដានគុណភាពនៃសេវាកម្មថែរក្សាសុខភាពសម្រាប់ជនក្រីក្រ និងធានាថាពួកគេនឹងមិនត្រូវបង់ប្រាក់បន្ថែម។ ការវាយតម្លៃផលប៉ះពាល់នាពេលថ្មីៗនេះបានរកឃើញថា គម្រោងមូលនិធិសមភាពសុខភាព (HEFs)ដែលគ្រប់គ្រងដោយប្រតិបត្តិករ ដែលជាបុគ្គលទីបីត្រូវបានកាត់បន្ថយ ប៉ុន្តែមិនទាន់បានលុបបំបាត់ការចំណាយលើសុខភាពដ៏ច្រើនលើសលប់របស់អ្នកក្រីក្រ និងកាត់បន្ថយភាពជាប់បំណុលនោះទេ។ ការវាយតម្លៃក៏បានរកឃើញពីការធ្វើការរួមគ្នាជាវិជ្ជមានរវាងមូលនិធិសមភាពសុខភាព (HEFs) និងអន្តរាគមន៍ ខាងផ្នែកផ្គត់ផ្គង់ ដូចជាកិច្ចសន្យាផ្តល់សេវាសុខភាព (Flores, et.al, ឆ្នាំ ២០១១) ។

**ប៉ុន្តែ ចំនួនគ្របដណ្តប់ និងការប្រើប្រាស់មូលនិធិសមភាពសុខភាពនៅតែមានកម្រិតទាបនៅឡើយ ដោយសារតែចំនួនគ្របដណ្តប់នៃប្រព័ន្ធអត្តសញ្ញាណប័ណ្ណជនក្រីក្រមានមិនទាន់ពេញលេញ និងចន្លោះដែលអាចកើតមានក្នុងការចែកចាយកាត ក៏ដូចជាការប្រើប្រាស់សេវាសាធារណៈកម្រិតទាប។** ទោះបីជាចំនួនគ្របដណ្តប់ជាលក្ខណៈទ្រឹស្តីរបស់មូលនិធិសមភាពសុខភាព (HEFs) មានកម្រិតខ្ពស់ និងគម្រោងសំបុត្រជានាដែលជនក្រីក្រភាគច្រើនមិនមានកាតមូលនិធិ និងអ្នកដែលមានកាតពេលខ្លះមិនបានប្រើ។ ក្នុង អ.ស.ស.ក ឆ្នាំ២០១១ ប្រហែល ត្រឹមតែ ១០ ភាគរយនៃជនក្រីក្រដែលត្រូវវាយការណ៍ថាបានប្រើប្រាស់មូលនិធិសមភាពសុខភាព (HEFs) ឬកាតផ្សេងៗដើម្បីទទួលបានការព្យាបាលដោយឥតគិតថ្លៃ ឬដោយមានឧបត្ថម្ភធនប្រហែល ១០ ភាគរយទៀតត្រូវវាយការណ៍ថា បានប្រើប្រាស់អត្តសញ្ញាណប័ណ្ណជនក្រីក្ររបស់ខ្លួន ប៉ុន្តែមាន ៤ ភាគរយ ដែលមានកាត មូលនិធិប៉ុន្តែមិនបានប្រើ។ ដូច្នេះ ប្រហែលជា ៨០ ភាគរយនៃជនក្រីក្រមិនមានលទ្ធភាពទទួលបានការព្យាបាលដោយឥតគិតថ្លៃ ឬដោយមានឧបត្ថម្ភធន។ ប្រហែលជា ៥ ភាគរយនៃក្រុមគ្រួសារកម្រិតទី ៣ និង ទី ៤ ក្នុងចំណោមក្រុមមនុស្សប្រាំនាក់ដែលមានបំផុតត្រូវបានរាយការណ៍ថាបានប្រើអត្តសញ្ញាប័ណ្ណជនក្រីក្ររបស់ខ្លួន ឬកាតឧបត្ថម្ភធនដទៃទៀត ដើម្បីទទួលការព្យាបាល ដែលនេះដោយសារតែកំហុសក្នុងប្រព័ន្ធអត្តសញ្ញាប័ណ្ណជនក្រីក្រ (**រូបភាព ៤៣**)។

ការស្ទង់មតិពីសុខភាព និងភូមិសាស្រ្តរបស់ប្រទេសកម្ពុជា (CDHS) ក្នុងឆ្នាំ២០១០ ក៏បានរកឃើញអត្រាការប្រើប្រាស់ទាបមិនមែនមានតែចំពោះមូលនិធិសមភាពសុខភាពនោះទេ ប៉ុន្តែក៏មានការប្រើប្រាស់ចំពោះការធានារ៉ាប់រងសុខភាពក្នុងថ្នាក់មូលដ្ឋានរបស់អ្នកក្រីក្រផងដែរ៖ ត្រឹមតែ ៤ ភាគរយ នៃក្រុមមនុស្សប្រាំនាក់ដែលក្រីក្របំផុតត្រូវវាយការណ៍ថា មូលនិធិសមភាពសុខភាព (HEFs) ជាអ្នកចំណាយលើសេវាកម្មសុខភាព (និង១ ភាគរយតាមរយៈការធានារ៉ាប់រងសុខភាពក្នុងថ្នាក់មូលដ្ឋាន)។ មិនត្រឹមតែប៉ុណ្ណោះ ១៨ ភាគរយនៃអ្នកក្រីក្រខ្ចីលុយដោយមានការប្រាក់ ១០ ភាគរយខ្ចីលុយដោយគ្មានការប្រាក់ និង ៩ ភាគរយលក់ទ្រព្យសម្បត្តិដើម្បីចំណាយលើសេវាថែទាំសុខភាព (**រូបភាព ៤៤**)។ ផ្ទុយមកវិញ ក្រុមមនុស្សប្រាំនាក់ដែលមានបំផុតកម្រខ្ចីឬលក់ទ្រព្យសម្បត្តិដើម្បីចំណាយលើសេវាកម្មសុខភាពណាស់។ មួយវិញទៀត ការសិក្សាថ្មីៗ (GIZ ឆ្នាំ ២០១១ និង Ir ឆ្នាំ ២០០៨) បានបង្ហាញថា រវាង ៣០ និង ៥០ ភាគរយនៃក្រុមគ្រួសារអ្នកក្រីក្រ ឬក្រីក្របំផុតបន្តប្រឈមមុខនឹងរនាំងហិរញ្ញវត្ថុក្នុងការទទួលបានការព្យាបាលជំងឺ។

### ការចំណាយលើសេវាសុខាភិបាលរបស់រដ្ឋាភិបាល

**ជាទូទៅជួយដល់ជនក្រីក្រ ប៉ុន្តែសមភាព និងប្រសិទ្ធភាពនៃការចំណាយសាធារណៈអាចនឹងកើនឡើង និងសង្ឃឹមថាថ្លៃចំណាយដ៏លើសលប់ត្រូវបានកាត់បន្ថយ។** ការចំណាយដ៏លើសលប់គឺជាប្រភពសំខាន់បំផុតសម្រាប់ហិរញ្ញប្បទានលើសេវាសុខភាពនៅកម្ពុជា។ ការចំណាយរបស់រដ្ឋាភិបាលទៅលើសុខភាពកើនឡើងពីប្រហែល ០,៨ ភាគរយនៃ ផ.ស.ស (GDP) ក្នុងឆ្នាំ ២០០០ ទៅប្រហែល ១,៤ ភាគរយនៃ ផ.ស.ស ក្នុងឆ្នាំ ២០១០ (ប្រហែល ១១ ភាគរយនៃថវិកាជាតិ) ស្មើនឹងមួយភាគប្រាំនៃចំនួនការចាយវាយលើសុខភាពនៅកម្ពុជា។ ការផ្តល់ហិរញ្ញប្បទានរបស់ម្ចាស់ជំនួយមកពីខាងក្រៅស្មើនឹងប្រហែល ០,៨ ភាគរយ នៃ ផ.ស.ស ប៉ុន្តែបានផ្តល់ការគាំទ្រជាច្រើនសម្រាប់កម្មវិធី និងអន្តរាគមន៍ផ្នែកសុខភាពសំខាន់ៗសម្រាប់ជនក្រីក្ររួមបញ្ចូលទាំងមូលនិធិសមភាពសុខភាព (HEFs) ផងដែរ។ ការពិនិត្យមើលឡើងវិញលើចំណាយសាធារណៈក្នុងពេលថ្មីៗបានគូសបញ្ជាក់ពីការរកឃើញដែលពាក់ព័ន្ធមួយចំនួន (ធនាគារពិភពលោក ឆ្នាំ២០១១)។ ទីមួយ ការចំណាយលើការថែទាំចម្បង និងសេវាកម្មបង្ការគឺសម្រាប់ជួយដល់អ្នកក្រីក្រ ដោយសារតែអ្នកក្រីក្រអាចទទួលបានប្រយោជន៍មិនសមាមាត្រពីសេវាកម្មទាំងនេះ។ ផ្ទុយមកវិញ អ្នកដែលមានជីវភាពធូរធារហាក់ដូចជាអាចទទួលបានការឧបត្ថម្ភធនរបស់រដ្ឋាភិបាលទៅរកមន្ទីរពេទ្យថ្នាក់ជាតិ ឬថ្នាក់ខេត្ត។ ទីពីរ គុណភាព និងប្រសិទ្ធភាពនៃការបែងចែកធនធានក្នុងចំណោមថ្នាក់ខេត្តអាចនឹងត្រូវបានធ្វើឡើងដោយមានតម្លាភាពជាងនេះ រួមទាំងការយកភាពក្រីក្រមកធ្វើជាគុណសម្បត្តិនៃការបែងចែកផងដែរ។ ទីបី ៧០ ភាគរយនៃធនធានទាំងអស់របស់ក្រសួងសុខាភិបាលត្រូវបានគ្រប់គ្រងដោយថ្នាក់កណ្តាល (រួមទាំងការទិញថ្នាំ និងឧបករណ៍) ដែលធនធានបន្ថែមទៀតនឹងត្រូវបញ្ជូនទៅមណ្ឌលសុខភាព និងមន្ទីរពេទ្យ។ ចុងក្រោយក្រសួងសុខាភិបាលចាយវាយប្រហែលជាពាក់កណ្តាលនៃថវិកាសរុបរបស់ខ្លួនទៅលើឱសថ (ការសន្សំយ៉ាងច្រើនសន្ទឹកសន្ធាប់អាចកើតឡើងតាមរយៈការទិញឱសថ និងសម្ភារៈដែលមានប្រសិទ្ធភាពជាងមុន)។ ការសន្សំទាំង នេះអាចត្រូវបានប្រើប្រាស់ដើម្បីបង្កើន និងធ្វើឲ្យស៊ីជម្រៅចំពោះចំនួនគ្របដណ្តប់នៃសមភាពដែលជាអាទិភាពក្នុងការបង្កើនប្រសិទ្ធភាពផ្នែកអន្តរាគមន៍ រួមទាំងមូលនិធិសមភាពសុខភាព (HEFs) ផងដែរ។

**រូបភាព ៤៣៖** ការប្រើប្រាស់ការព្យាបាលឧត្ថម្ភធន ឆ្នាំ២០១១




**ប្រភព៖** អ.ស.ស.កឆ្នាំ២០១១។

**រូបភាព ៤៤៖** ប្រភពហិរញ្ញវត្ថុសម្រាប់សេវាថែទាំសុខភាព ២០១១




**ប្រភព៖** អ.ស.ស.កឆ្នាំ២០១១។

## អាហារបំប៉នម្តាយ និងកុមារ

**ស្ត្រីដែលខ្វះជីវជាតិបំប៉ន និងខ្វះគ្រាប់ឈាមក្រហម នៅតែមានកម្រិតខ្ពស់។ ក្នុងចំណោមស្ត្រីអាយុចន្លោះពី ១៥ ទៅ ៤៩ ឆ្នាំ ការប្រឈមមួយដែលនៅដដែលគឺការរាតត្បាតកម្រិតខ្ពស់នៃសន្ទស្សន៍ម៉ាស់ខ្លួន (BMI) ទាប ដែលនៅថេរ មិនប្រែប្រួល ពីឆ្នាំ២០០០ ទៅ ឆ្នាំ២០១០ នៅប្រហែលជា ២០ ភាគរយ** (**រូបភាព ៤៥**)។ នេះជាចំណុចគួរឲ្យព្រួយបារម្ភបំផុត ដោយសារតែវានឹងបណ្តាលឲ្យមានផលវិបាកអវិជ្ជមានសម្រាប់កូនៗរបស់ពួកគេ ដូចជា ទម្ងន់ពេលសម្រាលកូនស្រាលជាងធម្មតា។ ចំណែកចំណុចវិជ្ជមាន គឺមានការប្រសើរឡើងគួរឲ្យចាប់អារម្មណ៍ ដែលត្រូវបានរកឃើញក្នុងផ្នែកការរាលដាលនៃជំងឺខ្វះគ្រាប់ឈាមក្រហមរបស់មាតា។ ប៉ុន្តែ ជំងឺខ្វះគ្រាប់ឈាមក្រហមនៅតែរាតត្បាតខ្លាំងក្នុងចំណោមស្ត្រីដែលមានកូនច្រើន (ច្រើនជាងបួននាក់) មិនមានការអប់រំ ឬការអប់រំមានកម្រិត ដែលមានផ្ទៃពោះ និងរស់នៅក្នុងក្រុមគ្រួសារក្រីក្រក្នុងតំបន់ជនបទ។

**ការគាំទ្រដល់មាតាឲ្យបានគ្រប់គ្រាន់ តាមរយៈអាហារបំប៉ន និងការអប់រំមានប្រយោជន៍យ៉ាងខ្លាំងសម្រាប់មាតា និងកូនរបស់គេ។** ឧទាហរណ៍ ការផ្តល់ថ្នាំគ្រាប់ជាតិដែកបន្ថែមទៅដល់ស្ត្រីក្នុងអំឡុងពេលមានផ្ទៃពោះ មិនមែនអាចការពារបានត្រឹមតែម្តាយនោះទេ តែក៏ការពារទារកពីជំងឺខ្វះគ្រាប់ឈាមក្រហមផងដែរ ហើយមានការប៉ាន់ស្មានថា ប្រហែលជាមួយភាគប្រាំនៃអត្រាមរណភាពរបស់ស្ត្រីជិតគ្រប់ខែ និងមួយភាគដប់នៃអត្រាមរណភាពមាតានៅជុំវិញពិភពលោកមានមូលហេតុដោយសារតែជំងឺខ្វះគ្រាប់ឈាមក្រហម ខ្វះជាតិដែក (Brabin ឆ្នាំ២០០១) ។ បន្ថែមពីលើនោះ ជំងឺខ្វះគ្រាប់ឈាមក្រហមបណ្តាលឲ្យមានភាពប្រថុយប្រថានកើនឡើងថា អាចនឹងសម្រាលកូនមុនពេលកំណត់ និងទម្ងន់ស្រាលពេលសម្រាលកូន (**រូបភាព ៤៥**)។ ក្នុងឆ្នាំ២០១០ មានត្រឹមតែ ៤៥ ភាគរយ នៃចំនួនស្ត្រីសរុបដែលត្រូវរាយការណ៍ថា បានទទួលវីតាមីនអា ជាតិដែក និងអាស៊ីដហ្វូលិកបន្ថែមក្នុងរយៈពេល ៦ខែ បន្ទាប់ពីការសម្រាលកូនចុងក្រោយរបស់ពួកគេដែលប្រហែលជាឆ្លុះបញ្ចាំងការពិតដែលថា មានត្រឹមតែ ៦០ ភាគរយនៃចំនួនស្ត្រីសរុបទទួលបានការថែរក្សាសុខភាពមុនពេលសម្រាលកូន និងក្រោយពេលសម្រាលកូនយ៉ាងជិតដល់។ ដូច្នេះ ទើបមានសក្តានុពលភាពក្នុងការកាត់បន្ថយកង្វះអាហារូបត្ថម្ភរបស់មាតា (និងកុមារ) តាមរយៈការពង្រឹងយន្តការសម្រាលកូន ដែលមានស្រាប់ទាំងនេះ និងដើម្បីបញ្ចូលនូវយុទ្ធសាស្ត្របន្ថែមទៀត។ ចំណុចនេះអាចរាប់បញ្ចូលទាំងការផ្ទេរប្រាក់ទៅអ្នកក្រីក្រ ស្ត្រីមានផ្ទៃពោះ ត្រូវបានលើកទឹកចិត្តឲ្យទទួលការថែរក្សាសុខភាពមុន និងក្រោយពេលសម្រាល និងការលើកកម្ពស់នូវការអប់រំ និងលទ្ធភាពស្វែងរកអាហារមានជីវជាតិ។

**រូបភាព ៤៥៖** បញ្ហាអាហារូបត្ថម្ភរបស់មាតា និងកុមារ ប្រទេសកម្ពុជា ឆ្នាំ២០០០ ២០០៥ និង ២០១០




**ប្រភព៖** CDHS ឆ្នាំ២០០០, ២០០៥, ២០១០។

ទោះបីជាមានការកើនឡើងពីឆ្នាំ២០០០ការអភិវឌ្ឍន៍នៃកង្វះអាហារូបត្ថម្ភរបស់កុមារនៅនឹងថ្កល់ ហើយការបាក់កម្លាំងបានកើនឡើងចាប់ពី ឆ្នាំ២០០៥ ជាមួយនឹងការជាប់ទាក់ទងដ៏សំខាន់ក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស និងសុខមាលភាព (**រូបភាព ៤៥**)។ ក្នុងឆ្នាំ ២០១០ ការរាតត្បាតនៃជំងឺគមខ្វង កុមារខ្វះទម្ងន់ និងការបាក់កម្លាំង គឺ ប្រហែល ៤០ ភាគរយ ២៨ ភាគរយ និង ១១ភាគរយ ដោយឡែកពីគ្នា និងជំងឺខ្វះគ្រាប់ឈាមក្រហមគឺស្ថិតនៅក្នុងកម្រិតរាលដាលត្រង់ ៥៥ ភាគរយនៃចំនួនកុមារក្រោមអាយុប្រាំឆ្នាំ។ កង្វះអាហារូបត្ថម្ភរបស់កុមារជាមូលហេតុមួយបណ្តាលឲ្យកុមារស្លាប់ប្រហែល ៦.៤០០ នាក់ក្នុងមួយឆ្នាំ។ ប្រទេសកម្ពុជាត្រូវបានប៉ាន់ស្មានថា បានបាត់បង់ថវិកា ១៤៦ លានដុល្លារ (គិតជាទឹកប្រាក់ ផ.ស.ស) ដោយសារកង្វះជាតិវីតាមីន និងជាតិរ៉ែជារៀងរាល់ឆ្នាំ។ ផលវិបាករយៈពេលយូរនៃកង្វះអាហារូបត្ថម្ភរបស់កុមារ គឺមានសភាពធ្ងន់ធ្ងរ បណ្តាលឲ្យមានការអភិវឌ្ឍផ្នែកកម្រិតយល់ដឹងរបស់អ្នកក្រីក្រ ដែលប៉ះពាល់ដល់ការបង្កើតធនធានមនុស្ស និងកំណើនសេដ្ឋកិច្ច។ មនុស្សពេញវ័យដែលខ្វះអាហារូបត្ថម្ភតាំងពីកុមារភាពមិនត្រឹមតែស្លាប់នៅអាយុតិចនោះទេ តែថែមទាំងមានអត្រាមានជំងឺរ៉ាំរ៉ៃខ្ពស់ទៀតផង។ បន្ថែមពីលើនោះ ក្មេងស្រីដែលមិនទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់ក្នុងរយៈពេលពីរឬបីឆ្នាំ ក្នុងរយៈពេលដំបូងៗនៃជីវិតរបស់ពួកគេ ទំនងអាចមានកូនដែលអាចស្លាប់ក្នុងវ័យក្មេង ដូច្នេះបានបង្កើតជាវដ្តជីវិតដ៏កាចសាហាវ (Barker, ឆ្នាំ១៩៩៣)។

**កង្វះអាហារូបត្ថម្ភរបស់កុមារពាក់ព័ន្ធនឹងស្ថានភាពសង្គមសេដ្ឋកិច្ច ប៉ុន្តែកត្តាសំខាន់មួយទៀត គឺកង្វះអាហារូបត្ថម្ភរបស់មាតាទម្លាប់បំបៅដោះ និងការចិញ្ចឹមកូន និងលទ្ធភាពទទួលបានអនាម័យ។** ការវិភាគត្រលប់ក្រោយដោយប្រើទិន្នន័យ ការស្ទង់មតិសុខភាព និងភូមិសាស្រ្តរបស់កម្ពុជា (CDHS) បង្ហាញថា កុមារទំនងជាគមខ្វង ឬខ្វះទម្ងន់ ប្រសិនបើក្រុមគ្រួសាររបស់គេក្រីក្រ ប្រសិនបើការបន្ទោរបង់ក្នុងទីចំហជាទម្លាប់ធម្មតា ក្នុងសហគមន៍របស់ពួកគេ ប្រសិនបើម្តាយរបស់ពួកគេមិនមានចំណេះដឹង ហើយបើពួកគេមិនត្រូវបានបំបៅដោះម្តាយ (**រូបភាព ៤៦**)។ ការវិភាគនេះបានបង្ហាញបន្ថែមទៀតថា ស្រ្តីគមខ្វងទំនងជានឹងមានកូនដែលខ្វះអាហារូបត្ថម្ភ បន្ទាប់ពីត្រូវបានគ្រប់គ្រង ដោយស្ថានភាពសង្គមសេដ្ឋកិច្ច ការអប់រំរបស់ម្តាយ ការបន្ទោរបង់ក្នុងទីចំហ និងទម្លាប់ការបំបៅដោះ។ ចំណុចនេះបញ្ជាក់ថា កង្វះអាហារូបត្ថម្ភមានផលប៉ះពាល់មកលើជំនាន់មួយទៅជំនាន់មួយផងដែរ និងកំណត់ពីសារៈសំខាន់នៃការដាក់ទុនផ្នែកអាហារបំប៉នសម្រាប់កុមារក្នុងដំណាក់កាលដំបូង ជាពិសេសក្មេងស្រី។ ការបំបៅដោះបន្ថែមនឹងល្អប្រសើរជាងមុន បន្ទាប់ពីអាយុបាន ៦ ខែ បានជួយកាត់បន្ថយការរាតត្បាតនៃចំនួនកុមារខ្វះទម្ងន់។ ចំណុចនេះគូសបញ្ជាក់ពីសារៈសំខាន់ ដែលមិនត្រឹមតែភាពចម្រុះនៃចំណីអាហារ ប៉ុន្តែថែមទាំងពេលវេលា

**រូបភាព ៤៦៖** កុមារគមខ្វងដោយសារ កម្រិតទ្រព្យសម្បត្តិ ការអប់រំ និងការបំបៅដោះរបស់កុមារ និងការបន្ទោរបង់ក្នុងទីចំហ




**ប្រភព៖** CDHS ឆ្នាំ២០០០, ២០០៥, ២០១០។

ដ៏ត្រឹមត្រូវក្នុងការផ្តាច់ដោះផងដែរ។[15] (Caulfield ឆ្នាំ ១៩៩៦) លទ្ធផលនេះមានភាពស៊ីសង្វាក់នឹងអនក្ខរកម្ម អន្តរជាតិ (Bhutta ឆ្នាំ២០០៨) និងកំណត់សម្គាល់ពីសារៈសំខាន់នៃការថែទាំសុខភាពម្តាយ និងកុមារក្នុងលក្ខណៈរួមគ្នា។

**ប្រទេសកម្ពុជាមានបទពិសោធន៍នៃដំណើរការដ៏សំខាន់ ក្នុងការលើកកម្ពស់ការបំបៅដោះតែមួយមុខ និងកាត់បន្ថយការបន្ទោរបង់ក្នុងទីចំហ ក្នុងចំណោមការអភិវឌ្ឍន៍ដទៃទៀត ប៉ុន្តែការយកចិត្តទុកដាក់បន្ថែមគឺចាំបាច់។** ក្នុងឆ្នាំ២០១០ ចំនួន ៧០ ភាគរយនៃសហគមន៍នៅតែបន្ទោរបង់ក្នុងទីចំហ។ មានតែ ៥០ ភាគរយនៃក្រុមគ្រួសារនៅកម្ពុជាមានលទ្ធភាពប្រើប្រាស់ទឹកស្អាត។ ក្នុងឆ្នាំដដែលមានក្មេងស្រីតែ ១ នាក់ក្នុងចំណោម ៤នាក់ បានចុះឈ្មោះចូលរៀនសាលាមធ្យមសិក្សា ដែលជាកត្តាប្រថុយប្រថានសម្រាប់ក្មេងជំនាន់ថ្មីដែលកើតចេញពីពួកគេទាំងនេះ ដែលធ្វើឲ្យបញ្ហាកើតមានជាបន្ត។ មាតាចំនួន ៣០ ភាគរយ មិនបានបំបៅដោះតែមួយមុខ មាន ២០ ភាគរយ ខ្វះទម្ងន់ និង ៤៥ ភាគរយមានជំងឺខ្វះគ្រាប់ឈាមក្រហម ដែលនេះគូសបញ្ជាក់ពីតម្រូវការក្នុងការធ្វើឲ្យសុខភាពមាតាមានការប្រសើរឡើង និងកាត់បន្ថយទម្ងន់ស្រាលក្នុងពេលកើត (**តារាង ២៥**)។ បន្ថែមពីលើនោះមាន ៧៦ ភាគរយនៃកុមារមិនបានទទួលរបបអាហារជាអប្បបរិមា ហើយចំពោះផ្នែកព្យាបាលមានត្រឹមតែ ១ ភាគរយនៃកុមារដែលខ្វះខាតអាហារូបត្ថម្ភធ្ងន់ធ្ងរ ចំនួនប៉ាន់ស្មានប្រហែល ៨០,០០០នាក់ទទួលបានការព្យាបាលពិសេសដោយ ចំណីអាហារសង្គ្រោះបន្ទាន់ (UNICEF)។ការអន្តរាគមន៍មួយចំនួន ដើម្បីកាត់បន្ថយកង្វះអាហារូបត្ថម្ភត្រូវបានធ្វើការសាកល្បងបានជោគជ័យនៅគ្រប់ទីកន្លែងទាំងអស់និងមានការទទួលស្គាល់ថា ការអន្តរាគមន៍ទាំងនោះមានដូចជា ការបង្កើនជីវជាតិក្នុងចំណីអាហារអាចដោះស្រាយនូវកង្វះអាហារបំប៉នបន្ទាប់បន្សំបាន។ការកំណត់របស់សហគមន៍ចំពោះកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ ឬការលើកកម្ពស់ការចិញ្ចឹមបន្ថែម និងចម្រុះតាមរយៈកម្មវិធីពហុវិស័យរបស់មូលដ្ឋានបង្ហាញឲ្យឃើញពីយុទ្ធសាស្រ្តប្រើប្រាស់ថ្លៃដើមយ៉ាងមានប្រសិទ្ធភាព ក្នុងការកាត់បន្ថយកង្វះអាហារូបត្ថម្ភ។ ប៉ុន្តែ នៅកម្ពុជា អំបិលអ៊ីយ៉ូត (ដែលបច្ចុប្បន្នទៅដល់ ៨៣ ភាគរយនៃក្រុមគ្រួសារទាំងអស់) គឺជាអាហារបង្កើនជីវជាតិមួយមុខ ដែលត្រូវបានផលិតក្នុងទ្រង់ទ្រាយធំ (UNICEF)។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍គោលនយោបាយ

**សមិទ្ធិផលខាងវិស័យសុខភាពបានកើនឡើងគួរឲ្យកត់សម្គាល់។ ក៏ប៉ុន្តែ គម្លាតរវាងអ្នកក្រនិងអ្នកធូរធារជាងមុន នៅតែមានទំហំធំក្នុងវិស័យមួយនេះ។ គម្លាតធំនេះឆ្លុះឲ្យឃើញនូវកង្វះខាតនៃវិសាលភាពរបស់កម្មវិធីឧបត្ថម្ភសង្គ្រោះជីវិតនានា និងគម្លាតនៃគុណភាពសេវាថែទាំសុខភាព។ ឧបសគ្គចម្បងដែលរាំងខ្ទប់ពលរដ្ឋងាយ**

**តារាង ២៥៖** អន្តរាគមន៍អាទិភាពដែលមានសក្តានុពលក្នុងការកាត់បន្ថយកង្វះអាហារូបត្ថម្ភបន្ថែមទៀត

| **កត្តាដែលអាចបង្កឲ្យខ្វះអាហារូបត្ថម្ភដល់កុមារ** | **គម្លាត** |
|---|---|
| ការបន្ទោរបង់ក្នុងទីចំហ | ៧០% នៃប្រជាជនសរុប បន្ទោរបង់ក្នុងទីចំហ |
| គ្មានលទ្ធភាពប្រើប្រាស់ទឹកស្អាត | ៥០% នៃគ្រួសារទាំងអស់ គ្មានទឹកស្អាតប្រើប្រាស់ |
| ការអប់រំរបស់មាតាមានកម្រិតទាប | ៣០% នៃម្តាយ ពុំទទួលបានការអប់រំ |
| ពុំបំបៅទឹកដោះម្តាយតែមួយមុខ អំឡុង ៦ ខែដំបូង | ៣០% ពុំបំបៅទឹកដោះម្តាយតែមួយមុខ អំឡុង ៦ ខែដំបូង |
| កម្រិតទាបនៃសន្ទស្សន៍ម៉ាសខ្លួន(BMI)របស់ម្តាយ | **២០% នៃម្តាយមានសន្ទស្សន៍ម៉ាសខ្លួនទាប** |
| **ម្តាយខ្វះឈាមក្រហម** | ៤៥% នៃម្តាយខ្វះឈាមក្រហម |

**ប្រភព៖** CHDS ឆ្នាំ២០១០។

**រងគ្រោះបំផុតពីការទទួលបានផលប្រយោជន៍នៃកម្មវិធីទាំងនេះគឺការទាត់ចោលរបស់សង្គម។ កត្តាចន្លោះប្រហោងជាច្រើនក្នុងទ្រង់ទ្រាយជាប្រព័ន្ធបានបង្កលក្ខណៈឲ្យជនងាយរងគ្រោះទាំងនោះ ពុំមានលទ្ធភាពទទួលប្រយោជន៍ពីបណ្តាកម្មវិធីឧបត្ថម្ភជាច្រើន។**

រដ្ឋាភិបាលគួរតែផ្តល់អាទិភាពក្នុងការបំបាត់ចន្លោះសមភាព ក្នុងសូចនាករគ្របដណ្តប់ដើម្បីជួយសង្គ្រោះជីវិតដែលរួមមានទាំងការថែរក្សាសុខភាពមុន និងក្រោយពេលសម្រាលកូន ការចាក់ថ្នាំបង្ការ និងឧបករណ៍សម្រាប់សម្រាលកូន។ ចំណុចនេះមានន័យថា បង្វែរធនធានជាច្រើនទៅរកផ្នែកការថែរក្សាសុខភាពចម្បង ជានារកហិរញ្ញប្បទានឲ្យបានគ្រប់គ្រាន់សម្រាប់ចុះមូលដ្ឋានទៅកាន់សហគមន៍ដាច់ស្រយាល និងបង្កើនសេវាកម្មគ្របដណ្តប់ក្នុងតំបន់ដាច់ស្រយាល។ ខាងអន្តរាគមន៍ផ្នែកតម្រូវការដូចជា មូលនិធិសមភាពសុខភាព សំបុត្រជានា ឬការផ្ទេរប្រាក់អាចត្រូវបានប្រើប្រាស់ ដើម្បីបង្កើនលទ្ធភាពប្រើប្រាស់ការអន្តរាគមន៍សំខាន់ៗទាំងនេះ។

ការពិតដែលអ្នកក្រីក្រភាគច្រើនទៅប្រើប្រាស់សេវាកម្មក្នុងវិស័យឯកជនហាក់បង្ហាញពីកម្រិតគុណភាពទាបនៃវិស័យសាធារណៈ។ គុណភាពនៃការថែរក្សាសុខភាពក្នុងវិស័យសាធារណៈតម្រូវឲ្យមានការវាយតម្លៃនិងបង្កើនឡើងជាបន្តបន្ទាប់ ទាំងគុណភាពផ្នែកគ្លីនិក និងការឆ្លើយតបទៅនឹងអតិថិជនដែលក្រីក្រ។ ចំណុចនេះនឹងតម្រូវឲ្យមានការរួមបញ្ចូលនូវ៖ ការវិនិយោគខាងការបណ្តុះបណ្តាល និងបរិក្ខា, ការពង្រឹងការតាមដាន និងពិនិត្យមើលគុណភាពផ្នែកគ្លីនិកដោយក្រសួងសុខាភិបាល, ការពង្រឹងការពិនិត្យ និងការគ្រប់គ្រងលើអ្នកផ្តល់សេវាសុខភាពឯកជន និងមិនផ្លូវការ, និងគណនេយ្យភាពសង្គមដែលប្រសើរជាងនេះទៅដល់ពលរដ្ឋនិងរដ្ឋអំណាចមូលដ្ឋានក្នុងបរិបទនៃដំណើរការវិសហមជ្ឈការ។

**ការការពារផ្នែកហិរញ្ញវត្ថុសម្រាប់អ្នកក្រីក្រ និងអ្នកជិតក្រត្រូវធ្វើឲ្យកាន់តែប្រសើរឡើង តាមរយៈការបង្កើនចំនួនគ្របដណ្តប់នៃអត្តសញ្ញាណរបស់អ្នកក្រីក្រ និងមូលនិធិសមភាពសុខភាព ស្របពេលជាមួយនោះ ត្រូវរក្សាតម្លៃប្រើប្រាស់ដ៏ទាបក្នុងវិស័យសាធារណៈ ដើម្បីចៀសវាងបន្ទុកធ្ងន់ធ្ងរខ្លាំងដល់អ្នកជិតក្រ។ ការប្រើប្រាស់មូលនិធិសមភាពសុខភាព (HEFs) ទាបដែលបានរាយការណ៍ និងគម្រោងឧបត្ថម្ភធនដទៃទៀតកំពុងតែមានការគួរឲ្យព្រួយបារម្ភ ដោយសារតែមានកំហុសជាក់លាក់ក្នុងការដកចេញ និងការបញ្ចូលឈ្មោះក្នុងប្រព័ន្ធអត្តសញ្ញាណរបស់អ្នកក្រីក្រ។**

ការអនុវត្ត និងតាមដាន ប្រព័ន្ធអត្តសញ្ញាណរបស់អ្នកក្រីក្រ និងមូលនិធិសមភាពសុខភាព បន្ទាប់ពីប្រព័ន្ធអត្តសញ្ញាណអ្នកក្រីក្រ គួរតែត្រូវបានពង្រឹង ដើម្បីធានាថាជនក្រីក្រពិតប្រាកដទទួលបានជំនួយ។ បន្ថែមពីលើនោះ អ្នកក្រីក្រដែលបានកំណត់ ទទួលបានកាតមូលនិធិ និងត្រូវតែបានដឹងអំពីអត្ថប្រយោជន៍នៃកាតនេះ។ មូលនិធិសមភាពសុខភាព (HEFs)ក៏ត្រូវតម្រូវឲ្យមានការបង្កើនឲ្យដល់ថ្នាក់ជាតិដោយពង្រីកការគ្របដណ្តប់ទៅមណ្ឌលសុខភាព ដើម្បីអនុញ្ញាតឲ្យមូលនិធិសមភាពសុខភាព (HEFs) ផ្តល់ថវិកាឧបត្ថម្ភដល់អ្នកជំងឺធម្មតា ក៏ដូចជាសេវាកម្មសម្រាប់អ្នកជំងឺដែលត្រូវគេងពេទ្យ។ យន្តការត្រួតពិនិត្យមូលនិធិសមភាពសុខភាព (HEFs) ក៏ត្រូវតែពង្រឹង ដើម្បីធានាគុណភាពរបស់សេវាកម្ម និងកាត់បន្ថយការបង់ប្រាក់បន្ថែម។

តម្លៃប្រើប្រាស់ទាបត្រូវតែរក្សាទុកក្នុងវិស័យសាធារណៈ ឲ្យស្របគ្នាជាមួយនឹងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការសម្រេចបាននូវចំនួនគ្របដណ្តប់សេវាសុខភាពពេញពិភពលោក ជាពិសេសក្នុងកម្រិតការថែទាំសុខភាពចម្បងផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ការបង្កើតការត្រួតពិនិត្យ និងការគ្រប់គ្រងដ៏ខ្លាំងក្លាលើថ្លៃចំណាយរបស់អ្នកជំងឺដែលមិនត្រូវបានធានានៅក្នុងមន្ទីរពេទ្យសាធារណៈក៏ត្រូវធ្វើឡើងដើម្បីចៀសវាងការចំណាយលើស និងហួសហេតុ។ ថ្លៃចំណាយ និងជម្រើសគួរតែត្រូវបានពិចារណាដើម្បីពង្រីកការការពារសុខភាពសង្គមសម្រាប់អ្នកជិតក្រ និងវិស័យមិនផ្លូវការក្នុងឆ្នាំបន្តបន្ទាប់ ដែលយ៉ាងហោចណាស់ផ្តល់ការឧបត្ថម្ភធនមួយផ្នែកពីរដ្ឋាភិបាល។

**ការបង្ការ និងការលើកកម្ពស់សុខភាពនៃជំងឺរ៉ាំរ៉ៃ និងមិនឆ្លងក៏គួរតែត្រូវបានពង្រឹងផងដែរ ហើយយន្តការ**

**ការពារសង្គមសម្រាប់ជំងឺរុំារ៉ៃក៏គួរតែត្រូវចាប់ផ្តើមអភិវឌ្ឍន៍។** ជាមួយនឹងការកើនឡើងនៃអាយុរស់នៅជាមធ្យម និងការគ្រប់គ្រងជំងឺឆ្លងដែលប្រសើរជាងមុន បន្ទុកនៃជំងឺនឹងងាកឆ្ពោះទៅជំងឺមិនឆ្លងក្នុងឆ្នាំបន្ទាប់ៗ។ ជំងឺរុំារ៉ៃដូចជាជំងឺឈាមរត់ខ្លាំង និងការព្យាបាលជំងឺទឹកនោមផ្អែមនឹងក្លាយទៅជាបន្ទុកបន្ថែមសម្រាប់អ្នកក្រីក្រ ក៏ដូចជាអ្នកមានផងដែរ។ ជំងឺបេះដូងនិងសរសៃឈាម និងជំងឺមហារីកនឹងបណ្តាលឲ្យមានការស្លាប់កាន់តែច្រើន និងធ្វើឲ្យមានការចាយវាយកាន់តែច្រើន។

អាទិភាពដំបូងរបស់ការចំណាយរបស់រដ្ឋាភិបាល គឺកម្មវិធីបង្ការ និងលើកកម្ពស់ រួមទាំងយុទ្ធនាការប្រឆាំងការជក់បារី និងការយកពន្ធ និងកម្មវិធីការរស់នៅមានសុខភាពល្អ រួមជាមួយនឹងការពង្រឹងការថែទាំសុខភាពក្នុងកម្រិតចម្បង ដើម្បីគ្រប់គ្រងមើលស្ថានភាពនៃជំងឺរុំារ៉ៃតែចំណាយទាប។

បញ្ញត្តិនៃសេវាកម្មជំងឺមិនឆ្លងគួរតែមានក្នុងមណ្ឌលសុខភាពសាធារណៈ និងមន្ទីរពេទ្យ ដោយមានគោលនយោបាយបង់ប្រាក់ដ៏សមស្របសម្រាប់អ្នកមាន (ការគ្របដណ្តប់នៃមូលនិធិសមភាពសុខភាព (HEFs) និងការធានារ៉ាប់រងសុខភាពសង្គម គួរតែត្រូវបានវាយតម្លៃដោយផ្អែកលើលទ្ធភាពចំណាយ)។

**វិធានការពហុវិស័យត្រូវតែអនុម័ត ដើម្បីកាត់បន្ថយកង្វះខាតអាហារូបត្ថម្ភរបស់មាតានិងកុមារ ដោយផ្តោតលើការដៅមុខសញ្ញាទៅតំបន់ដែលមានជនក្រីក្រ និងតំបន់ជនបទ ។** ម្តាយដែលមានជំងឺគមខ្វង ខ្វះទម្ងន់ និងមានជំងឺខ្វះគ្រាប់ឈាមក្រហមទំនងជាបង្កើតកូនដែលមានសុខភាពខ្សោយ ហើយហាក់ដូចជាខ្វះអាហារូបត្ថម្ភ និងប្រឈមខ្លាំងនឹងការស្លាប់។

ក្នុងវិស័យសុខភាព ត្រូវតែពង្រឹងការតាមដានការរីកលូតលាស់របស់កុមារក្នុងមន្ទីរសុខភាពធ្វើឲ្យប្រសើរឡើងនៃការពិភាក្សាយោបល់ផ្នែកអាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះ លើកកម្ពស់ទម្លាប់នៃការបំបៅដោះម្តាយ និងចិញ្ចឹមកូន បង្កើនការព្យាបាលចំពោះកង្វះអាហារូបត្ថម្ភរបស់កុមារក្នុងមន្ទីរសុខភាពសាធារណៈ និងធ្វើឲ្យប្រសើរឡើងនូវការចែកចាយអាហារបំប៉នកម្រិតតូច និងចំនួនគ្របដណ្តប់ទៅលើស្ត្រីមានផ្ទៃពោះ និងកុមារ។

កម្មវិធីនៅក្នុងមូលដ្ឋានគួរតែបង្កើតឡើង មិនមែនត្រឹមតែជំរុញឲ្យមានរបបអាហារចម្រុះ និងទម្លាប់ល្អក្នុងការចិញ្ចឹមកូននោះទេ ប៉ុន្តែក៏គួរតែធ្វើឲ្យប្រសើរឡើងផ្នែកអនាម័យ និងកាត់បន្ថយការបន្ទោរបង់ក្នុងទីចំហ។ ចំណុចនេះត្រូវការបំពេញបន្ថែម ដោយការធ្វើឲ្យម្ហូបអាហារមានជីវជាតិជាងមុន និងយុទ្ធនាការបន្ថែមអាហារបំប៉នកម្រិតតូច ដែលដៅមុខសញ្ញាទៅកុមារ ក្នុងដំណាក់កាលដំបូងក្នុងជីវិតរបស់ពួកគេ។

## ចំណាំជើងទំព័រ

4. ក្រសួងទាំង ១៤ នេះ មាន ក្រសួងអប់រំ, ក្រសួងសុខាភិបាល, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងការពារជាតិ, ក្រសួងធម្មការ និងសាសនា, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងមហាផ្ទៃ, ក្រសួងសាធារណៈការនិងដឹកជញ្ជូន, ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ក្រសួងសង្គមកិច្ច, ទីស្តីការគណៈរដ្ឋមន្ត្រី និងធនាគារជាតិនៃកម្ពុជា។
5. ESP ត្រូវបានកែសម្រួលនៅឆ្នាំ២០០៤ ហើយ ESP ២០០៤-២០០៨ ត្រូវបានបង្កើតឡើង។ គ្មានការកែប្រែធំដុំឡើយចំពោះ ESP ២០០១ ដល់២០០៥។
6. ទ្រព្យសម្បត្តិត្រូវបានកំណត់ដោយក្រុមបញ្ចភាគ បើយោងតាមការប្រើប្រាស់ ២០ ភាគរយ នៃចំនួនប្រជាពលរដ្ឋ នៅក្នុងក្រុមបញ្ចភាគនីមួយៗ។
7. ពីព្រោះថា អត្រាចុះឈ្មោះចូលរៀនដុលក៏នឹងរាប់បញ្ចូលនូវមនុស្សជំទង់ផងដែរ ដូចនេះ អត្រានេះអាចមានតម្លៃលេខលើសពី ១០០ ភាគរយ។ ក៏ប៉ុន្តែ អាត្រាចុះឈ្មោះសុទ្ធវិញ ត្រូវតែស្ថិតក្នុងចន្លោះ ០ និង ១០០ ភាគរយ។
8. EMIS មិនប្រើទិន្នន័យអាយុជាក់លាក់សម្រាប់ការ

ចុះឈ្មោះចូលរៀនទេ (អាយុ ៦-១១ ឆ្នាំ សម្រាប់ការចុះឈ្មោះចូលរៀនសុទ្ធ ថ្នាក់បឋមជាការកំណត់របស់ពួកគេ)។

**9.** កុមារអាយុចាប់ពី ១២ ឆ្នាំ ដល់ ១៧ ឆ្នាំ ត្រូវបានគេជ្រើសរើស ព្រោះពួកគេជាតំណាង ឬនិន្នាការវិស័យអប់រំដ៏ល្អ។ បញ្ហាអវត្តមាន និងអត្រាបោះបង់ចោលការសិក្សាសម្រាប់កុមារ គឺមានតិចតួចពេកក្នុងឆ្នាំ ២០១១ ក្នុងការទទួលបានលទ្ធផលស្ថិតិ គួរឱ្យកត់សម្គាល់។ ចំពោះមនុស្សពេញវ័យ ការបោះបង់ចោលការសិក្សាគឺមិនត្រូវបានសួរទេ នៅមុនឆ្នាំ២០០៩។

**10.** ក្រុមផ្សេងទៀតមិនមានការសង្កេតគ្រប់គ្រាន់ដើម្បីធ្វើការសន្និដ្ឋានទេ។

**11.** សិស្សក្នុងចំណោម ក្រុម ៤០ ភាគរយ គឺស្របគ្នានឹងតួលេខនៃសិស្ស ដែលចូលរៀនយឺតជាងអាយុក្នុងអាត្រាធំជាងមធ្យមភាគជាមធ្យម បើគិតទាំងឆ្នាំសិក្សា និងថ្នាក់។

**12.** រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាឆ្នាំ២០០៩។

**13.** ត្រូវបានគេគណនាសម្រាប់ ៦ ឆ្នាំ មុនពេលការស្ទង់មតិនីមួយៗ។

**14.** មរណកុមារ ត្រូវបានគេគណនាសម្រាប់ ១០ ឆ្នាំម្តងមុនពេលការស្ទង់មតិនីមួយៗ (ឧ. ឆ្នាំ២០០៥ គឺសម្រាប់ឆ្នាំ ១៩៩៦ ដល់ឆ្នាំ២០០៥)។

**15.** ការវិភាគត្រលប់ក្រោយ បង្ហាញពីទំនាក់ទំនងវិជ្ជមាន និងសំខាន់រវាងការកាត់បន្ថយកុមារដែលខ្វះទម្ងន់ និងពេលវេលាក្នុងមួយសប្តាហ៍ដែលកុមារទទួលទានសាច់ បបរ ត្រី ខ្ចង ឬស៊ុត។ កម្រិតទាបនៃពិន្ទុហ្សិត ( Z-score) កើនឡើងចំនួន 0,0៤ ក្នុងពេលមួយដងក្នុងមួយសប្តាហ៍នៅពេលដែលចំណីអាហារមួយត្រូវបានផ្តល់ឲ្យ។

# សូចនាករប៉ាន់ស្មានថ្មី នៃភាពក្រីក្រ នៅកម្ពុជា ក្នុងឆ្នាំ២០០៩

# ឧបសម្ព័ន្ធ ១

## អញ្ញាតថ្មីនៃចំណាយលើការប្រើប្រាស់សរុប

### អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា (អ.ស.ស.ក)

ចាប់តាំងពីអំឡុងឆ្នាំ១៩៩៣/៩៤មក ប្រទេសកម្ពុជាបាននិងកំពុងធ្វើអង្កេតសេដ្ឋកិច្ចសង្គមមួយចំនួន ដោយប្រមូលយកនូវព័ត៌មាននានា ទាំងពីសំណាក់គ្រួសារនិងពីសមាជិកនីមួយៗនៃគ្រួសារ។ វិសាលភាពគ្របដណ្ដប់នៃអង្កេតនេះបានកើនឡើងចំនួនពី ៥៩ ភាគរយ នៃចំនួនភូមិសរុប ក្នុងឆ្នាំ ១៩៩៣/៩៤ រហូតដល់ ចំនួន ១០០ ភាគរយ ក្នុងឆ្នាំ២០០៤។ ចាប់ផ្ដើមតាំងពី ឆ្នាំ២០០៤មក ទាំងការរៀបចំអង្កេតការធ្វើកម្រងសំណួរ ការចុះធ្វើអង្កេត និងវិធីសាស្ត្រស្រាវជ្រាវរួមសម្រាប់ការប្រមូល និងកែច្នៃព័ត៌មានត្រូវបានរចនាឡើង តាមបទដ្ឋានតែមួយ និងត្រូវបានយកជាគំរូអនុវត្តន៍នៅក្នុងបណ្ដាអង្កេតពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១១ រួមទាំងអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា (អ.ស.ស.ក) ឆ្នាំ ២០១២ ផងដែរ។

កម្រិតភាពក្រីក្រត្រូវបានប៉ាន់ស្មានមុនគេ ដោយប្រើប្រាស់អ.ស.ស.កឆ្នាំ១៩៩៣/៩៤។ ចំណាយលើការប្រើប្រាស់របស់មនុស្សម្នាក់ៗត្រូវបានជ្រើសរើសជាសូចនាករមួយ ដែលតាងឲ្យសុខុមាលភាពរបស់គ្រួសារនីមួយៗ។ បណ្ដាបន្ទាត់ភាពក្រីក្រកម្រិតខ្លាំង (ម្ហូបអាហារ) ត្រូវបានប៉ាន់ស្មាន ដោយផ្អែកតាមចំណាយលើម្ហូបអាហាររបស់គ្រួសារក្រីក្រទាំងឡាយ នៅក្នុងអំឡុងឆ្នាំ ១៩៩៣/៩៤។ ចំណែកឯបណ្ដាបន្ទាត់ភាពក្រីក្ររួមត្រូវបានប៉ាន់ស្មាន ដោយផ្អែកតាមចំណាយលើទំនិញនានាក្រៅអំពីម្ហូបអាហាររបស់បណ្ដាគ្រួសារក្រីក្រ។ ប្រភពចម្បងនៃព័ត៌មានគឺសុទ្ធសឹងជាទិន្នន័យដែលបានមកពីការរំឭកឡើងវិញឬតាមការចងចាំរបស់អ្នកតបចម្លើយ។ ករណីពុំមានទិន្នន័យពីការរំឭកឡើងវិញឬតាមការចងចាំបែបនេះ (ជាអាទិ៍ ពាក់ព័ន្ធនឹងគមនាគមន៍ ការទំនាក់ទំនងការថែទាំសុខភាពផ្ទាល់ខ្លួន និងការស្នាក់នៅសណ្ឋាគារ[16]) គេប្រើប្រាស់នូវព័ត៌មានទទួលបានពីកំណត់ត្រានានា ជាជំនួសវិញ។[17]

កន្លងមកគេឃើញថា មានការកែលម្អនូវចំណុចមួយចំនួន នៅក្នុងកម្រងសំណួរ។ ក៏ប៉ុន្តែ ចំណុចដែលត្រូវបានកែលម្អទាំងនោះ ត្រូវបានសម្រេចថា ពុំដាក់បញ្ចូលក្នុងការប៉ាន់ស្មានកម្រិតភាពក្រីក្រនោះឡើយ។ ការសម្រេចធ្វើបែបនេះ គឺចង់រក្សាឲ្យបានថាចំណាយលើការប្រើប្រាស់ត្រូវបានប៉ាន់ស្មាន តាមរយៈវិធីសាស្ត្រដដែល ក្នុងគោល-

បំណងជានាឲ្យបាន មិនត្រឹមតែសង្គតិភាពក្នុងការប្រៀប-ធៀបតាមកាលនីមួយៗប៉ុណ្ណោះទេ តែថែមទាំង "ភាពត្រឹមត្រូវ" នៃការប្រៀបធៀបផងដែរ។ ទោះជាយ៉ាងនេះក្តី ចំណង់ចំណូលចិត្ត និងទម្លាប់របស់មនុស្សបានប្រែប្រួល ឬផ្លាស់ប្តូរទៅតាមពេលវេលា។ បម្រែបម្រួលនេះពិតកើតមានឡើង នៅក្នុងប្រទេសជាច្រើន ពិសេសដូចករណីនៃប្រទេសកម្ពុជា ដែលបានឆ្លងកាត់បន្លាស់ប្តូរសំខាន់ៗជាច្រើន ចាប់តាំងពីការប៉ាន់ស្មានកម្រិតភាពក្រីក្រលើកដំបូង បន្ទាប់ពីឆ្លងកាត់រយៈកាលនៃការកើតមានជម្លោះជាច្រើនទសវត្សរ៍រួចមក។ ដោយហេតុនេះហើយ ដើម្បីទទួលបាននូវលទ្ធផលសុក្រឹត ដែលឆ្លុះបញ្ចាំងតថាភាពកម្ពុជានាពេលនេះ ជាការចាំបាច់ណាស់ដែលគេត្រូវធ្វើបច្ចុប្បន្នកម្មនៃការប៉ាន់ស្មាន ដូចបានបរិយាយពីខាងដើម។[18]

អ.ស.ស.ក ឆ្នាំ២០០៩ ត្រូវបានជ្រើសរើសសម្រាប់ធ្វើបច្ចុប្បន្នកម្ម និងកែលម្អនូវរបៀបវាស់ស្ទង់កម្រិតភាពក្រីក្រនៅកម្ពុជា ("ថ្មី" សំដៅដល់លទ្ធផលដែលបានមកពីការវាស់ស្ទង់បែបនេះ)។[19] ឯកសារមួយនេះរាប់បញ្ចូលនូវសេចក្តីបរិយាយអំពីវិធីសាស្ត្រ "ថ្មី" និងវែកញែកអំពីភាពខុសគ្នា រវាងបណ្តាសូចនាករប៉ាន់ស្មានចាស់ ("ចាស់" សំដៅដល់វិធីសាស្ត្រ ដែលត្រូវបានប្រើប្រាស់កាលពីមុន)។[20] ជាការសំខាន់ណាស់ ដែលគេគួរកត់សម្គាល់ថា ទាំងគោលការណ៍ និងគោលបំណងនៃវិធីសាស្ត្រទាំងពីរ (ទាំងចាស់ និង ថ្មី) មានលក្ខណៈដូចគ្នាគឺៈ វាស់ស្ទង់សុខុមាលភាព ដោយប្រើប្រាស់ចំណាយប្រើ-ប្រាស់របស់ មនុស្ស ម្នាក់ៗ។[21]

## សមាសធាតុនៃចំណាយលើការប្រើប្រាស់សរុបតាមវិធីសាស្ត្រថ្មី

ផ្នែករំឭកឡើងវិញនៃអ.ស.ស.ក ឆ្នាំ២០០៩ រួមមានសមាសធាតុទាំងអស់ ដែលចាំបាច់សម្រាប់ផ្តុំចេញជាចំណាយសរុប និងចំណាយក្នុងម្នាក់ៗសម្រាប់គ្រប់គ្រួសារ។ សមាសធាតុទាំងអស់នេះរាប់បញ្ចូលនូវបណ្តាចំណាយសម្រាប់ៈ ម្ហូបអាហារទាំងអស់ដែលបរិភោគនៅក្នុងផ្ទះ ឬនៅក្រៅផ្ទះ (ដែលបានមកដោយការទិញការផលិតអំណោយ ឬប្រភពផ្សេងៗទៀត), ការស្នាក់-នៅ (ជួលឬកម្មសិទ្ធិ), សេវាកម្មសម្រាប់លំនៅដ្ឋាន (ឧសអគ្គិសនី ហ្គាស ទឹក ជាដើម។ ល។ ), គមនាគមន៍និងទំនាក់ទំនង, តម្លៃទិញនូវទំនិញអចិន្ត្រៃយ៍មួយចំនួន, ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន, សកម្មភាពកម្សាន្តនិងលម្ហែ, ការអប់រំនិងសុខភាព, និងសកម្មភាពដូចគ្នាឯទៀត (សេចក្តីបរិយាយលម្អិតនៃសមាសធាតុនីមួយៗត្រូវបានដាក់បញ្ចូលក្នុង «**ប្រអប់ ១**»)។ សន្ទស្សន៍តម្លៃសម្រាប់តំបន់ ៣ សំខាន់ៗ (ភ្នំពេញ ទីប្រជុំជនឯទៀត និងទីជនបទ) ត្រូវបានបង្កើតឡើង ដើម្បីចាប់យកឲ្យបាននូវរបាយតម្លៃដែលមានលក្ខណៈខុសៗគ្នា ទៅតាមតំបន់នានានៅក្នុងប្រទេស។ ចំណាយលើការប្រើប្រាស់សរុបប្រចាំខែត្រូវបានប៉ាន់ស្មាន ដោយបូកសរុបនូវគ្រប់សមាសធាតុនីមួយៗទាំងអស់នេះ ហើយត្រូវបានបំប្លែងជាខ្នាតមួយសម្រាប់វាស់ស្ទង់លើសុខុមាលភាពក្នុងម្នាក់ៗ (បុគ្គល) សម្រាប់ថ្ងៃនីមួយៗ ដោយប្រើប្រាស់ទំហំគ្រួសារ។ (**ប្រអប់ ៦**)

**ប្រអប់ ៦៖ សមាសធាតុប្រើសម្រាប់បង្កើតអញ្ញាតថ្មី នៃចំណាយលើការប្រើប្រាស់សរុបនៅកម្ពុជាក្នុងឆ្នាំ២០០៩**

គ្រប់ម្ហូបអាហារ ដែលបរិភោគនៅក្នុងផ្ទះឬក្រៅផ្ទះ
(ទទួលបានដោយសារការទិញ
ការផលិត ឬប្រភពផ្សេងឯទៀត)
តម្លៃប្រចាំខែរបស់ផ្ទះ
សេវាកម្មសម្រាប់លំនៅដ្ឋាន (អគ្គិសនី ទឹក ហ្គាស។ល។)
គមនាគមន៍ និងទំនាក់ទំនង
តម្លៃទិញរបស់ទំនិញអចិន្ត្រៃយ៍មួយចំនួន
ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន
ចំណាយលើសកម្មភាពកម្សាន្ត និងលម្ហែ
ចំណាយលើការអប់រំ
ចំណាយលើសុខភាព
ផ្សេងៗទៀត (រាប់បញ្ចូលទាំងអំណោយ)

### តួលេខដែលបាត់បង់ និងតួលេខក្រៅចំណោម (outlier)

ស្រដៀងគ្នានឹងបណ្តាអង្កេតគ្រួសារដទៃទៀតដែរនោះ គឺថា សំណុំទិន្នន័យនៃ អ.ស.ស.ក ឆ្នាំ២០០៩មានផ្ទុកនូវបណ្តាករណី ដែលមានការបាត់បង់ព័ត៌មាន ឬព័ត៌មានដែលត្រូវបានផ្តល់ឲ្យមានលក្ខណៈខុសប្លែកពីគេខ្លាំងពេក ឬក្រៅចំណោម (outlier)។ ការធ្វើចំណាត់ថ្នាក់ ចំពោះករណីអង្កេតណាមួយថា ជាករណីក្រៅចំណោម ពុំមែនជាដំណើរការច្បាស់លាស់នោះឡើយ ហើយតម្រូវឲ្យមានការយកចិត្តទុកដាក់ ដោយអនុវត្តតាមលក្ខខណ្ឌដូចៗគ្នាសម្រាប់គ្រប់ករណីអង្កេត ដែលរួមមាន៖ (ក)ការចាត់ថ្នាក់ថាក្រៅចំណោម ឬយ៉ាងណានោះ ត្រូវធ្វើឡើងនៅកម្រិតអញ្ញាតរាយនីមួយៗ ពោលគឺមុនពេលចងជាក្រុមទិន្នន័យ, (ខ) បើមានការសង្ស័យលើករណីអង្កេតណាមួយនោះមិនត្រូវធ្វើការចាត់ថ្នាក់ថា ជាករណីក្រៅចំណោមនោះឡើយ, (គ) ប្រើប្រាស់ចំណេះដឹងផ្ទាល់ខ្លួន បូករួមនឹងការប្រៀបធៀបជាមួយលក្ខណៈស្ថិតិ[22] និងបុគ្គលិកលក្ខណៈគ្រួសារផ្សេងដទៃទៀត ដើម្បីធ្វើចំណាត់ថ្នាក់លើករណីក្រៅចំណោម, (ឃ)ត្រូវរក្សាទុកនូវកំណត់ត្រានៃករណីនីមួយៗនៅគ្រប់ដំណាក់កាល ដោយផ្តល់ព័ត៌មានជារួមសម្រាប់ករណីគ្រួសារនីមួយៗ, និង (ង) ត្រូវជួសតួលេខសម្រាប់ករណីក្រៅចំណោមនិងបាត់បង់ព័ត៌មាន ដោយប្រើប្រាស់មធ្យមភាគដែលត្រូវបានរាយការណ៍ ដោយបណ្តាគ្រួសារដែលមានបុគ្គលិកលក្ខណៈស្រដៀងគ្នា។

### ចំណាយលើម្ហូបអាហារ

ចំណាយលើម្ហូបអាហារត្រូវបានប៉ាន់ស្មានដោយប្រើប្រាស់ផ្នែក «០.១.B» នៃកម្រងសំណួរ។ អញ្ញាតទាំងអស់រាប់ទាំងចំណាយសរុបសម្រាប់មុខទំនិញនីមួយៗ (Q០១BC០៥) ត្រូវបានប្រើប្រាស់។ តម្លៃសរុបរបស់ម្ហូបអាហារដែលបានទទួលទាន ត្រូវបានរាយការណ៍អំឡុង ៧ ថ្ងៃចុងក្រោយ មកទល់នឹងថ្ងៃដែលអង្កេតប្រព្រឹត្តឡើង។ ដើម្បីប៉ាន់ស្មានចំណាយលើម្ហូបអាហារប្រចាំខែ គេត្រូវយកតម្លៃតួលេខដែលត្រូវបានរាយការណ៍ ចែកនឹង ៧ រួចគុណនឹង ៣៦៥ និងបន្ទាប់មកចែកនឹង ១២។

### តម្លៃប្រចាំខែរបស់ផ្ទះ

តម្លៃប្រចាំខែនៃការប្រើប្រាស់ផ្ទះ គឺជាផ្នែកមួយនៃចំណាយប្រើប្រាស់សរុបរបស់គ្រួសារនីមួយៗ។ ដោយហេតុនេះហើយ គេត្រូវរាប់បញ្ចូលតម្លៃនេះទៅក្នុងចំណាយប្រើប្រាស់សរុប (consumption aggregate)។ ព័ត៌មាននេះត្រូវបានដាក់បញ្ចូលនៅក្នុងផ្នែក ០៤ នៃកម្រងសំណួរ។ សម្រាប់ករណីជួលផ្ទះ តម្លៃឈ្នួលផ្ទះត្រូវបានចាត់ទុកថា ជាសូចនាករប៉ាន់ស្មានដ៏ល្អមួយសម្រាប់វាស់ស្ទង់តម្លៃនៃការប្រើប្រាស់ផ្ទះ។ ចំពោះបណ្តាគ្រួសារក្នុងករណីជួលផ្ទះនេះ គេប្រើប្រាស់ទំហំចំណាយប្រចាំខែដែលត្រូវបានរាយការណ៍នៅក្នុងសំណួរលេខ Q០៤_២៥A។ ចំណែកឯបណ្តាគ្រួសារ ដែលមានកម្មសិទ្ធិលើផ្ទះផ្ទាល់ខ្លួន ឬក៏មិនបង់ថ្លៃឈ្នួល គេប្រើប្រាស់តម្លៃនៃការប្រើប្រាស់ផ្ទះប្រចាំខែ ដែលត្រូវបានរាយការណ៍នៅក្នុងសំណួរលេខ Q០៤_២៥B។

ទិន្នន័យរបស់គ្រួសារចំនួន ២៥ គ្រួសារ (០,២១ ភាគរយនៃសំណាក) បានបាត់បង់ ឬមានលក្ខណៈក្រៅចំណោម។ ដោយហេតុថា តម្លៃនៃការប្រើប្រាស់ផ្ទះគឺជាភាគដ៏សំខាន់មួយនៃបរិការរបស់គ្រួសារ គេត្រូវយកចិត្តទុកដាក់ ដោយធ្វើការជួសតួលេខសម្រាប់ករណី២៥ គ្រួសារនេះ។ ការប៉ាន់ស្មានត្រូវបានធ្វើឡើងតាមរយៈការធ្វើរ៉េហ្គ្រេស្យុងប្រភេទពហុអញ្ញាត (multivariate regression)៖ ជាតុច្ចូលសម្រាប់ការគណនាបានមកតាមរយៈ ការប្រើប្រាស់ព័ត៌មាន អំពីគ្រួសារដែលមានកម្មសិទ្ធិលើផ្ទះរបស់ខ្លួន។ ពោលគឺថា គេត្រូវភ្ជាប់ទំនាក់ទំនងរវាងតម្លៃឈ្នួលផ្ទះ (ប្រើឡូការីតធម្មជាតិ ឬ ឡូការីតណេពែរ) ទៅនឹងបុគ្គលិកលក្ខណៈគ្រួសារចំនួន ៧ ប្រភេទ៖ ទំហំគ្រួសារ, គ្រួសារនៅភ្នំពេញ, គ្រួសារនៅទីប្រជុំជនផ្សេងទៀត, គុណភាពដំបូល, ប្រភពទឹក, លទ្ធភាពទទួលបានការប្រើប្រាស់បង្គន់, និងលទ្ធភាពទទួលបានអគ្គិសនីប្រើប្រាស់ (**តារាង ២៦**)។

**តារាង ២៦៖ រ៉េហ្គ្រេស្យុងលីណេអ៊ែរ នៃតម្លៃប៉ាន់ស្មាន លើការប្រើប្រាស់ផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន**[23]

| អញ្ញាតក្នុងបន្ទុក (Dependent Variable)៖ LN (តម្លៃឈ្នួលប៉ាន់ស្មាន) | β ប៉ាន់ស្មាន | តម្លៃ t | តម្លៃ p |
|---|---|---|---|
| កុងស្តង់(Constant) | ៩,៩៣៨ | ៤៧៩,៩ | ០,០០០ |
| ទំហំផ្ទះ (ប្រភេទ១៖ 0-២០ ម២; ២៖ ២១-៤០ ម២; ៣៖ > ៤០ ម២) | ០,៣៨៦ | ៤៤,៦ | ០,០០០ |
| ភ្នំពេញ (តំបន់ = ១) | ១,២៤៣ | ៤៦,៦ | ០,០០០ |
| ទីប្រជុំជនផ្សេងទៀត (តំបន់ = ២) | ០,៤៧១ | ២១,២ | ០,០០០ |
| មានដំបូលល្អ (Q0៤_0៥ = ២, ៣, ៤, ៦ ឬ ៨) | ០,៣៥៣ | ១៨,៩ | ០,០០០ |
| មានប្រព័ន្ធទឹកស្អាត (Q0៤_១២ = ១, ២, ៣, ៤ ឬ ៥) | ០,០០៤ | ០,៣ | ០,៧៦១ |
| មានបង្គន់ត្រឹមត្រូវ (Q0៤_១៩a = ១, ២ ឬ ៣) | ០,៣៩៩ | ២៤,៣ | ០,០០០ |
| មានអគ្គិសនី (Q0៤_២២a = ៥) | ០,៥៦៨ | ៤,៥ | ០,០០០ |

Adjusted $R^2$ = ០,៥១៧ និងប្រូបាប៊ីលីតេ F (ANOVA) < ០,០០១។

**ប្រភព៖** សូចនាករប៉ាន់ស្មាន របស់ធនាគារពិភពលោក ដោយផ្អែកលើអ.ស.ស.កឆ្នាំ២០០៩ របស់វ.ជ.ស។

## សេវាកម្មសម្រាប់លំនៅដ្ឋាន

ព័ត៌មានទាក់ទងនឹងសេវាកម្មសម្រាប់លំនៅដ្ឋានត្រូវបានដាក់បញ្ចូល នៅក្នុងផ្នែក ០៤ នៃកម្រងសំណួរ។ គ្រប់ព័ត៌មានទាំងអស់ត្រូវបានផ្តល់ឲ្យជាប្រចាំខែ។ ដូច្នេះ ពុំចាំបាច់ធ្វើការបំប្លែងទម្រង់នៃទិន្នន័យនោះឡើយ។ សមាសធាតុទាំងនោះរួមមាន៖ ចំណាយទឹក (Q០៤_១៦), ទឹកស្អុយ ឬទឹកសំណល់ (Q០៤_២០), សេវាប្រមូលសំរាម (Q០៤_២១), អគ្គិសនី (Q០៤_២៣A), ហ្គាស (សម្រាប់ចម្អិនម្ហូប) (Q០៤_២៣B), ប្រេងកាត (Q០៤_២៣C), ឧស (Q០៤_២៣D), ធ្យូង (Q០៤_២៣E), អាគុយ (Q០៤_២៣F), និងប្រភពថាមពលផ្សេងទៀត (Q០៤_២៣G)។

## គមនាគមន៍ និងទំនាក់ទំនង

ចំណាយសរុបលើគមនាគមន៍និងទំនាក់ទំនងត្រូវបានរាយការណ៍នៅក្នុងផ្នែក ០១.C នៃកម្រងសំណួរ។ ចំណាយសរុបលើគមនាគមន៍ (Q០១CC០៦ & Q០១C០១ = ២) និងចំណាយលើទំនាក់ទំនង (Q០១CC០៦ & Q០១C០១=៣) ត្រូវបានរាយការណ៍អំឡុងខែចុងក្រោយនៃអង្កេត។ ហេតុនេះ ពុំចាំបាច់ធ្វើការបំប្លែងទម្រង់នៃទិន្នន័យនោះឡើយ។

## តម្លៃប្រចាំខែនៃការប្រើប្រាស់ទំនិញអចិន្ត្រៃយ៍

ព័ត៌មានអំពីទំនិញអចិន្ត្រៃយ៍ត្រូវបានដាក់បញ្ចូល នៅក្នុងផ្នែក ០៩ នៃកម្រងសំណួរ។ អាយុកាលពិតរបស់មុខទំនិញ ដែលបានប្រើប្រាស់ច្រើនជាង ១ ឆ្នាំពុំត្រូវបានសាកសួរឡើយហើយវិធីសាស្ត្ររួម ដែលត្រូវបានប្រើប្រាស់នៅក្នុងការសិក្សាស្រាវជ្រាវដទៃទៀត ពុំអាចយកមកអនុវត្តបានឡើយ។ ដើមឡើយ យើងចង់ប៉ាន់ស្មានតម្លៃប្រើប្រាស់នៃគ្រប់ទំនិញអចិន្ត្រៃយ៍ទាំងអស់ ក៏ប៉ុន្តែត្រូវបានលុបចោលទៅវិញ បន្ទាប់ពីបានពិភាក្សាជាមួយមន្ត្រីរដ្ឋាភិបាលរួចមក។ តម្លៃទិញត្រូវបានប្រើប្រាស់ជាជំនួសវិញ សម្រាប់មុខទំនិញមួយចំនួន ដែលត្រូវបានជាវអំឡុង ១២ ខែចុងក្រោយ។ មុខទំនិញមួយចំនួនទាំងនោះរួមមាន៖ វិទ្យុ ទូរទស្សន៍ កង់ ម៉ាស៊ីនដេរ ម៉ាស៊ីនចាក់វីដេអូ បាស់កង្ហារអគ្គិសនី ចង្ក្រាន សម្ភារៈផ្ទះបាយ ទូរស័ព្ទដៃ ឆ្នាំងអ៊ុតអគ្គិសនី កាបូប អាគុយ សម្ភារៈបន្ទប់ដេក ទូសម្លៀកបំពាក់ និងទូ។ លើសពីនេះទៀតនោះ ដោយហេតុថាម៉ូតូបានក្លាយជារបស់សំខាន់ (ទាំងនៅក្នុងគ្រួសារ

ក្រីក្រផងដែរ) ការចំណាយលើម៉ូតូនេះត្រូវបានប្រើប្រាស់។ តម្លៃទិញ នៃបណ្ណមុខទំនិញទាំងអម្បាលម៉ាននេះ ឬតម្លៃជំនួស (imputed value) របស់មុខទំនិញទាំងនោះ ត្រូវបានប្រើសម្រាប់តែបណ្ណមុខទំនិញដែលត្រូវបានទិញអំឡុង ១២ខែចុងក្រោយប៉ុណ្ណោះ (Q០៩_C០៧) ហើយត្រូវបានយកទៅចែកនឹង ១២ ដើម្បីរកតម្លៃប្រចាំខែរបស់វា។[24]

## ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន

ព័ត៌មានអំពីទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនត្រូវបានរាយការណ៍ នៅក្នុងផ្នែក ០១.C នៃកម្រងសំណួរ។ តម្លៃសរុប (រាប់ទាំងចំណាយជាសាច់ប្រាក់ និងជាវត្ថុ) ត្រូវបានដាក់បញ្ចូលក្នុងសំណួរ Q០១CC០៦ និងត្រូវបានចងជាក្រុម ផ្អែកតាមអញ្ញាត Q០១C០១។ សមាសជាតុនៃក្រុមទិន្នន័យ ដែលបានចងនេះរួមមាន៖ ការថែរទាំសុខភាព (Q០១C០១=៤), សម្លៀកបំពាក់(Q០១C០១=៥), និងរបស់របរសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន(Q០១C០១=១១)។ ការថែទាំសុខភាពត្រូវបានរាយការណ៍អំឡុងខែចុងក្រោយនៃអង្កេត ហើយតម្លៃលេខដែលបានរាយការណ៍មកនេះត្រូវបានប្រើប្រាស់តែម្តង ដោយគ្មានធ្វើការបំប្លែងទិន្នន័យឡើយ ពីព្រោះជាទិន្នន័យប្រចាំស្រាប់។ រីឯសំណួរទាក់ទងនឹងផ្នែកសម្លៀកបំពាក់ត្រូវបានរាយការណ៍អំឡុង ៦ ខែចុងក្រោយ ហើយតម្លៃលេខត្រូវបានយកទៅចែកនឹង ៦។ ចំណែកឯចំណាយលើរបស់របរសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនវិញ ត្រូវបានរាយការណ៍ អំឡុង ១២ ខែ ចុងក្រោយ ហើយតម្លៃលេខត្រូវបានយកទៅចែកនឹង ១២។

## ចំណាយលើសកម្មភាពកម្សាន្តនិងលម្ហែ

ព័ត៌មានអំពីសកម្មភាពកម្សាន្តនិងលម្ហែ ត្រូវបានរាយ-ការណ៍ នៅក្នុងផ្នែក ០១.C នៃកម្រងសំណួរ។ តម្លៃសរុប (រាប់ទាំងចំណាយជាសាច់ប្រាក់ និងជាវត្ថុ) ត្រូវបានស្រង់យកដោយសំណួរ Q០១CC០៦ និងត្រូវបានចងជាក្រុមមួយចំនួន ផ្អែកតាមអញ្ញាត Q០១C០១។ សមាសជាតុនៃក្រុមទិន្នន័យដែលបានចងនេះរួមមាន៖ សកម្មភាពកម្សាន្តនៅក្នុងប្រទេសកម្ពុជា (Q០១C០១=៨), សកម្ម-ភាពលម្ហែនៅបរទេស (Q០១C០១=៩), និងការលេងល្បែងផ្សេងៗ (Q០១C០១=១២)។ គ្រប់អ្នកតបចម្លើយទាំងអស់ត្រូវបានសាកសួរអំពីចំណាយទាំងអម្បាលម៉ាននេះ ប្រព្រឹត្តិឡើងអំឡុង ១២ ចុងក្រោយ ហើយតម្លៃលេខនៃចំណាយនេះ ត្រូវបានយកមកចែកនឹង ១២។

## ចំណាយលើការអប់រំ

ផ្នែក ០២ នៃកម្រងសំណួរគ្រួសារមានផ្ទុកនូវគ្រប់ព័ត៌មានអំពីចំណាយលើការអប់រំ។ ចំណាយលើការអប់រំសរុបរបស់បុគ្គលម្នាក់ រាប់ទាំងការអប់រំប្រភេទផ្លូវការក្រៅប្រព័ន្ធ សាធារណៈ និងឯកជន។ ទំហំសាច់ប្រាក់ប៉ាន់ស្មាននៃចំណាយលើការអប់រំ ត្រូវបានទាញយកចេញពីសំណួរចំនួន ៦៖ តម្លៃឈ្នួលសាលា(Q០២C១៦a), តម្លៃឈ្នួលគ្រូ (Q០២C១៦b),សៀវភៅសិក្សា(Q០២C១៦c), ចំណាយសិក្សាផ្សេងទៀត(Q០២C១៦d), គមនាគមន៍ (Q០២C១៦f)[25], អំណោយសម្រាប់គ្រូបង្រៀន, មូលនិធិសាងសង់សាលា, និងចំណាយឯទៀតប្រភេទដូចគ្នានេះ (Q០២C១៦g)។ គ្រួសារចំនួន ៥ ពុំបានផ្តល់ព័ត៌មានអំពីចំណាយរបស់ខ្លួននីមួយៗឡើយ។ ក្នុងករណីនេះចំណាយសរុបត្រូវបានយកមកប្រើប្រាស់(Q០២C១៦h)។ គ្រប់អ្នកតបចម្លើយទាំងអស់ ត្រូវបានសាកសួរ អំពីចំណាយសិក្សាអំឡុង ១ ឆ្នាំកន្លងទៅ។ តម្លៃលេខ ដែលបានមក ត្រូវយកទៅចែកនឹង ១២។ តម្លៃនៃចំណាយលើការអប់រំសរុបរបស់គ្រួសារនីមួយៗ គឺស្មើនឹងផលបូកនៃចំណាយលើការអប់រំរបស់សមាជិកនីមួយៗនៃគ្រួសារ។

## ចំណាយលើសុខភាព

ព័ត៌មានអំពីចំណាយលើសុខភាព ត្រូវបានរាយការណ៍ នៅក្នុងផ្នែក ១៣ នៃកម្រងសំណួរ។ សមាជិកគ្រួសារនីមួយៗ ត្រូវបានសាកសួរក្នុងលក្ខណៈឯកជនដាច់ៗពីគ្នា ដែលការធ្វើបែបនេះ គេគិតថា អាចទទួលបានសុក្រឹតភាពល្អជាងការសាកសួរសំណួរតែមួយសម្រាប់គ្រួសារទាំង-មូលតែម្តង។ សំណួរអំពីចំណាយលើសុខភាពបានតម្រូវឲ្យអ្នកតបចម្លើយផ្តល់តួលេខទាក់ទងនឹងទំហំសាច់ប្រាក់ដែលត្រូវបានចំណាយទៅលើការព្យាបាលទាំងអស់ដោយ

មិនគិតអំពីប្រភេទនៃស្ថាប័នផ្តល់សេវាសុខភាពឡើយ (Q១៣BC១១)។ សមាជិកនីមួយៗនៃគ្រួសារត្រូវបានស្នើឲ្យផ្តល់ព័ត៌មានអំពីចំណាយបែបនេះ អំឡុង ៣០ ថ្ងៃចុងក្រោយ។ ចំណាយសរុបលើសុខភាពអាចគណនាបានតាមរយៈ ផលបូកនៃចំណាយរបស់គ្រប់សមាជិកទាំងអស់នៃគ្រួសារ។

## ចំណាយលើការប្រើប្រាស់ផ្សេងទៀត

ក្រុមទិន្នន័យចុងក្រោយរាប់បញ្ចូលនូវព័ត៌មានដែលបានមកពីផ្នែក ០១.C នៃកម្រងសំណួរ។ នៅក្នុងផ្នែក ០១.C នេះ សំណួរ Q០១CC០៦ ត្រូវបានប្រើប្រាស់សម្រាប់ចាប់យកព័ត៌មានទាក់ទងនឹងប្រាក់ខែក្នុងស្រុក (Q០១CC០១=៧) និងមុខចំណាយផ្សេងទៀត (Q០១CC០១=១៣)។ រីឯនៅក្នុងផ្នែក ០៧ វិញ តម្លៃលេខជំនួសសរុប(total imputed values)ដែលផ្តល់ដោយអ្នកតបចម្លើយគន្លឹះ(key informant)ត្រូវបានប្រើប្រាស់ (Q០៧_C០៥) សម្រាប់ទំនិញ ដែលទទួលបានពីក្នុងប្រទេសកម្ពុជា ឬបានជាអំណោយ ឬរង្វាន់ពីក្រៅប្រទេស (Q០៧_C០១=១០) ឬក៏ទទួលបានពីការធ្វើពាណិជ្ជកម្ម (Q០៧_C០១=១១)។ គ្រប់សំណួរទាំងបួននេះត្រូវបានសាកសួរ ដោយផ្តោតយក អំឡុង ១២ ខែ ចុងក្រោយ។ តម្លៃលេខទាំងនេះ ត្រូវបានយកទៅចែកនឹង ១២ ដើម្បីឲ្យចេញជាតម្លៃលេខប៉ាន់ស្មានប្រចាំខែ។

## តម្លៃលេខនៃអញ្ញាតចំណាយលើការប្រើប្រាស់សរុបនិងលើការប្រើប្រាស់ប្រចាំថ្ងៃក្នុងម្នាក់ៗ

អញ្ញាតចំណាយលើការប្រើប្រាស់សរុបត្រូវបានប៉ាន់ស្មាន ដោយផលបូកនៃគ្រប់សមាសធាតុនីមួយៗទាំងអស់របស់គ្រួសារនីមួយៗ។ អញ្ញាតចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃក្នុងម្នាក់ៗត្រូវបានគណនាដោយយកអញ្ញាតចំណាយលើការប្រើប្រាស់របស់គ្រួសារនីមួយៗទៅចែកនឹងទំហំគ្រួសារ រួចចែកនឹង ៣០,៤១៦៧។

## គណនាមធ្យមទម្ងន់នៃអញ្ញាតចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗ ដោយប្រើសន្ទស្សន៍តម្លៃប្រចាំតំបន់

សន្ទស្សន៍តម្លៃប្រចាំតំបន់ត្រូវបានប៉ាន់ស្មាន ដើម្បីប្រៀបធៀបស្ថានភាពសុខុមាលភាពរបស់គ្រួសារ ដែលរស់នៅក្នុងតំបន់ទីទៃពីគ្នានៃប្រទេស។ សន្ទស្សន៍តម្លៃប្រចាំតំបន់នេះត្រូវបានគណនា ដោយផ្អែកលើតួលេខនៃបន្ទាត់ភាពក្រីក្រនីមួយៗរបស់តំបន់ ៣សំខាន់ៗ៖ ភ្នំពេញ ទីប្រជុំជនផ្សេងទៀត និងទីជនបទ។[26] ភ្នំពេញត្រូវបានជ្រើសរើសធ្វើជាគោលសម្រាប់គណនាសន្ទស្សន៍តម្លៃ ហើយត្រូវបានតាងដោយលេខ ១។ ចំពោះបណ្តាគ្រួសារនៃតំបន់ទីប្រជុំជនផ្សេងទៀត ក្រៅពីភ្នំពេញ លេខប៉ាន់ស្មាននៃសន្ទស្សន៍តម្លៃគឺ ០,៨០២២។ រីឯគ្រួសារស្ថិតក្រៅភ្នំពេញ លេខប៉ាន់ស្មាននៃសន្ទស្សន៍តម្លៃគឺ ០,៧៣៤៨។

## លទ្ធផល

តម្លៃលេខជំនួស (imputed values)

ការជួសតម្លៃលេខដែលបាត់ និងតម្លៃលេខក្រៅចំណោម (outlier) តែងតែជួបនូវបញ្ហាស្មុគស្មាញខ្លាំង។ ដើម្បីទទួលបានខ្នាតដ៏ល្អមួយ សម្រាប់វាស់ស្ទង់ឥទ្ធិពលដែលកើតចេញពីការជួសតម្លៃលេខនេះ គេត្រូវកត់ត្រានូវរាល់តម្លៃលេខប៉ាន់ស្មាននីមួយៗ (តម្លៃលេខជំនួសនីមួយៗ) ហើយប្រៀបធៀបទៅនឹងអញ្ញាតចំណាយលើការប្រើប្រាស់សរុប។ ក្នុងចំណោមករណីអង្កេតនៃគ្រួសារចំនួន ១១.៩៧០ នៃសំណាក គេឃើញថា ករណីចំនួន ១១.៥៧២ ពុំត្រូវការការជួសតម្លៃលេខសម្រាប់អញ្ញាតណាមួយឡើយ។ ពោលគឺ មានករណីចំនួនតែ ៣៩៨ គ្រួសារប៉ុណ្ណោះ (ស្មើនឹង ៣,៣ ភាគរយនៃសំណាក) ដែលត្រូវការតម្លៃលេខជំនួស៖ វត្តមាននៃប្រភេទលេខជំនួសមានចំនួន ៥ ភាគរយនៃអញ្ញាតចំណាយលើការប្រើប្រាស់សរុប ឬភាគរយតិចជាងនេះ សម្រាប់ករណីចំនួន ៣២៣ គ្រួសារ ហើយវត្តមាននេះមានចន្លោះពី ៥,១ ភាគរយ ទៅ ១៤,៩ ភាគរយ សម្រាប់ករណីចំនួន ៦៧ គ្រួសារ ផ្សេងទៀតដែលនៅសល់។ មានករណីចំនួនតែ ៨ គ្រួសារប៉ុណ្ណោះទេ ដែលវត្តមាននៃប្រភេទលេខជំនួសនេះឡើងខ្ពស់រហូតដល់ទៅ ១៥ ភាគរយនៃអញ្ញាតចំណាយលើការប្រើប្រាស់ ឬភាគរយច្រើនជាងនេះទៀតក៏មាន។

ករណីអង្កេតនៃគ្រួសារចំនួន ៨ នោះ (ដែលវត្ថុមាននៃប្រភេទលេខជំនួសកើនឡើងរហូតដល់ទៅ ១៥ ភាគរយនៃអញ្ញាតចំណាយលើការប្រើប្រាស់ ឬ ភាគរយច្រើនជាងនេះ) ត្រូវបានដកចេញពីសំណាក។ ព័ត៌មានដែលត្រូវបានផ្តល់ដោយគ្រួសារចំនួន ៨ នោះ ពុំមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់សម្រាប់ប្រើក្នុងការគណនាអញ្ញាតចំណាយលើការប្រើប្រាស់។ ដោយហេតុនេះ ការដកករណី ៨ នោះចេញពីសំណាក គឺជាជម្រើសល្អបំផុត។ ដើម្បីផាត់ទាត់ឥទ្ធិពលនៃការលុបចំនួនករណីអង្កេតនៃគ្រួសារទាំងនោះចេញពីសំណាក ខ្នាតទម្ងន់ស្ថិតិរបស់បណ្តាករណីអង្កេតទាំងនោះ ត្រូវបានបែងចែកឲ្យសមាមាត្រទៅនឹងបណ្តាករណីអង្កេតនៃគ្រួសារផ្សេងទៀត ដែលស្ថិតនៅក្នុង «បំណែងចែក សំណាកបឋម (Primary Sampling Unit)»[27] ដូចគ្នា។ និយាយមួយបែបទៀត គឺថា គ្រួសារដែលមានបុគ្គលិកលក្ខណៈស្រដៀងនឹងបណ្តាគ្រួសារដែលត្រូវបានដកចេញពីសំណាក ត្រូវបានប្រើប្រាស់ជាតំណាងសម្រាប់ជួសឲ្យលេខ ដែលមានលក្ខណៈមិនច្បាស់លាស់ទាំងអស់នោះ។ វិធីសាស្ត្រ "ចាស់" ពុំបានព្យាយាមរែករក និងជួសនូវបណ្តាតម្លៃលេខក្រៅចំណោមទាំងនេះនោះឡើយ។

### ការប្រៀបធៀបអញ្ញាត "ថ្មី" និង "ចាស់" នៃចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗ

វិធីសាស្ត្រល្អក្នុងការវាស់ស្ទង់ឥទ្ធិពលនៃការធ្វើបច្ចុប្បន្នកម្មទៅលើការប៉ាន់ស្មានអញ្ញាតចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗ គឺធ្វើការប្រៀបធៀបតម្លៃមធ្យមនៃបំណែងចែកតំបន់នីមួយៗ។ បើយកខ្នាតជាតម្លៃបច្ចុប្បន្ននៃលុយរៀល(៛)[28] គេឃើញថា តម្លៃលេខរបស់អញ្ញាត "ថ្មី" នៃចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗនៅកម្ពុជាគឺ ៧.៣២៥ ៛ ក្នុងមួយថ្ងៃ។ តម្លៃលេខនេះ គឺខិតជិតនឹងលទ្ធផលទទួលបានពីការប្រើវិធីសាស្ត្រ "ចាស់" ដែលមានចំនួន ៧.២១២ ៛។ តារាង ២៧ បង្ហាញថា ភាពខុសគ្នារវាងសូចនាករប៉ាន់ស្មានទាំងពីរនេះ មានទំហំធំជាងនៅភ្នំពេញ (៣,២ ភាគរយ) និងទំហំតូចជាង នៅបណ្តាតំបន់ពីរទៀត គឺទីប្រជុំជនផ្សេងទៀត(០,៩ភាគរយ) និងទីជនបទ(១,២ ភាគរយ)។ (**តារាង ២៧**)

### កម្រិតនៃចំណាយលើការប្រើប្រាស់គិតជាលុយរៀលតាមតម្លៃគោលឆ្នាំ២០០៩

ដើម្បីប្រៀបធៀបកម្រិតនៃចំណាយលើការប្រើប្រាស់រវាងតំបន់ផ្សេងៗគ្នា គេគួរស្វែងយល់អំពីភាពខុសគ្នានៃតម្លៃនៅក្នុងតំបន់ទាំងនោះ។ គេពិតជាត្រូវធ្វើបែបនេះ ប្រសិនបើធ្វើការវិភាគទាក់ទងនឹងសុខុមាលភាព (ហើយមិនចំពោះថា ជាការប្រៀបធៀបប្រភេទអ្វីផ្សេងទៀតឡើយ) ដែលតម្រូវឲ្យមានការធ្វើលំដាប់ថ្នាក់គ្រួសារទៅតាមសក្តានុពល ក្នុងការប្រើប្រាស់ទំនិញ និងសេវាកម្ម។ ដោយប្រើប្រាស់សន្ទស្សន៍តម្លៃ ដែលបង្កើតឡើងផ្អែកលើអ.ស.ស.ក ឆ្នាំ២០០៩ គេឃើញថាមធ្យមភាគនៃចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗ នៅប្រទេសកម្ពុជាគឺ ៩.៣២៥ ៛ ក្នុងមួយថ្ងៃ (ប្រែប្រួលក្នុងចន្លោះពីចំនួន ១៥.៧០៩ ៛ នៅភ្នំពេញទៅចំនួន ៨.១៨៣ ៛ នៅទីជនបទ) (**តារាង ២៨**)។ ហេតុនេះហើយ ជាការពុំភ្ញាក់ផ្អើលឡើយដែលថា តម្លៃលេខគោល (តម្លៃលេខសម្រួលជាមួយនឹងថ្លៃ ឬ price adjusted values) គឺធំជាងតម្លៃលេខបច្ចុប្បន្ន ពីព្រោះថាតម្លៃមធ្យមនៃទំនិញនិងសេវាកម្ម ដែលស្ថិតនៅក្រៅភ្នំពេញមានលក្ខណៈថោកជាង។ និយាយមួយបែបទៀត គឺថា ដោយប្រើប្រាស់ទំហំសាច់ប្រាក់ដូចគ្នា មនុស្សម្នាក់ ឬគ្រួសារមួយអាចទិញទំនិញឬសេវាកម្មនៅក្រៅភ្នំពេញបានចំនួនច្រើនជាងការទិញនៅក្នុងភ្នំពេញ។

វិធីសាស្ត្រមួយទៀតដើម្បីស្វែងយល់អំពីរបាយនៃចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗនៅទូទាំងប្រទេសកម្ពុជា គឺការគណនារកមធ្យមប្រចាំក្រុមបញ្ចភាគ (quantile)។[29] ចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗ គិតតាមតម្លៃគោល ឆ្នាំ ២០០៩ មានចំនួនចន្លោះ ពី ៣.៩៥៣ ៛ ក្នុងមួយថ្ងៃ សម្រាប់ក្រុមប្រជាជនក្រីក្របំផុត ដែលតាងឲ្យ ២០ ភាគរយនៃចំនួនប្រជាពលរដ្ឋសរុប។ បន្ទាប់មក ចំណាយនេះបានកើនឡើងបន្តិចដល់ ១០.២៣៦ ៛ សម្រាប់ក្រុមទីបួន។ រីឯក្រុមបញ្ចភាគចុងក្រោយវិញ ចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗ បានកើនឡើងគួរឲ្យកត់សម្គាល់ ដល់ទៅចំនួន ១៩.០០៩ ៛ ក្នុងមួយថ្ងៃ (**តារាង ២៩**)។

**តារាង ២៧៖** តម្លៃមធ្យមនៃចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗ (កម្ពុជា ឆ្នាំ២០០៩)

| | រ/ថ្ងៃ (តម្លៃបច្ចុប្បន្ន) | | ភាពខុសគ្នា | |
|---|---|---|---|---|
| | ចាស់ | ថ្មី | រ/ថ្ងៃ | ភាគរយ |
| ភ្នំពេញ | ១៥.២២៥ | ១៥.៧០៩ | ៤៨៤ | ៣,២% |
| ទីប្រជុំជនផ្សេងទៀត | ១០.០៩៦ | ១០.១៨៤ | ៨៨ | ០,៩% |
| ទីជនបទ | ៥.៩៤០ | ៦.០១៣ | ៧៣ | ១,២% |
| កម្ពុជា | ៧.២១២ | ៧.៣២៥ | ១១៣ | ១,៦% |

**ប្រភព៖** សូចនាករប៉ាន់ស្មាន របស់ធនាគារពិភពលោក ដោយផ្អែកលើអ.ស.ស.កឆ្នាំ២០០៩ របស់វ.ជ.ស។

**តារាង ២៨៖** ចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗ គិតជាលុយរៀលតាមតម្លៃគោលប្រចាំភ្នំពេញឆ្នាំ២០០៩ (កម្ពុជា ឆ្នាំ២០០៩)

| | ភ្នំពេញ | ទីប្រជុំជនផ្សេងទៀត | ទីជនបទផ្សេងទៀត | កម្ពុជា |
|---|---|---|---|---|
| ចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗ ក្នុងមួយថ្ងៃ (រៀល, ថ្លៃគោល) | ១៥.៧០៩ | ១២.៦៩៤ | ៨.១៨៣ | ៩.៣២៥ |

**ប្រភព៖** សូចនាករប៉ាន់ស្មាន របស់ធនាគារពិភពលោក ដោយផ្អែកលើអ.ស.ស.កឆ្នាំ២០០៩ របស់វ.ជ.ស។

**តារាង ២៩៖** ចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃក្នុងម្នាក់ៗ បែងចែកតាមក្រុមបញ្ចភាគ (កម្ពុជា ឆ្នាំ២០០៩)

| | ក្រុមបញ្ចភាគ | | | | | មធ្យមភាគ |
|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ | |
| គិតជារៀល (តម្លៃគោល) | ៣.៩៥៣ | ៥.៨១៨ | ៧.៦១០ | ១០.២៣៦ | ១៩.០០៩ | ៩.៣២៥ |
| គិតជារៀល (តម្លៃបច្ចុប្បន្ន) | ២.៩៣៧ | ៤.៣៤២ | ៥.៧៣៣ | ៧.៩២១ | ១៥.៦៩១ | ៧.៣២៥ |

## ចំណែកនៃចំណាយលើការប្រើប្រាស់ បែងចែកតាមសមាសធាតុ

ការប្រៀបធៀបសារៈសំខាន់នៃសមាសធាតុនីមួយៗទៅនឹងចំណាយលើការប្រើប្រាស់សរុប គឺជាវិធីសាស្ត្រមួយដ៏មានប្រយោជន៍។តម្លៃមធ្យមនៃចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗ គិតតាមថ្លៃបច្ចុប្បន្ន ត្រូវបានគណនាទាំងសម្រាប់តំបន់នីមួយៗ និងសម្រាប់ទូទាំងប្រទេស។ ចំណែកភាគរយនៃសមាសធាតុនីមួយៗត្រូវបានប៉ាន់ស្មាន និងត្រូវបានបង្ហាញនៅក្នុង **តារាង ៣០**។ ចំណាយលើម្ហូបអាហារតាងឲ្យចំណែកដ៏ធំជាងគេបំផុតនៃគ្រប់សមាសធាតុចំណាយទាំងអស់នៅកម្ពុជា គឺមានចំនួន ៥៣,២ ភាគរយនៃចំណាយលើការប្រើប្រាស់សរុប។ ប្រភេទចំណាយដែលជាប់លំដាប់ថ្នាក់លេខ ២ គឺទាក់ទងនឹងការស្នាក់នៅ និងសេវាកម្មទាក់ទងនឹងលំនៅដ្ឋាន (អគ្គិសនី ទឹក ជាដើម) ដែលតាងឲ្យ ១៩,២ ភាគរយនៃចំណូលមធ្យមរបស់ប្រជាជនកម្ពុជា។ ប្រភេទចំណាយដែលជាប់លំដាប់ថ្នាក់លេខ ៣ គឺពាក់ព័ន្ធនឹងគមនាគមន៍

និងទំនាក់ទំនង ដែលតាងឲ្យ ៦,៧ ភាគរយនៃចំណូល។ ប្រភេទចំណាយដែលមានចំណែកភាគរយតូចៗផ្សេងទៀត រួមមានសេវាសុខភាព (៣,៨ ភាគរយ) និងសេវាអប់រំ (២,៤ ភាគរយ)។

នៅភ្នំពេញ ចំណែករបស់ចំណាយលើម្ហូបអាហារធៀបនឹងចំណាយសរុបមានទំហំតូចជាង (គឺមានចំនួន ៤០,២ ភាគរយ) ពីព្រោះទំហំចំណាយលើការប្រើប្រាស់មានកម្រិតធំជាង (បើប្រៀបធៀបនឹងគ្រួសារនៅជនបទដែលមានចំនួន ៥៨,១ ភាគរយ) (**តារាង ៣០**)។ ម៉្យាងវិញទៀត តម្លៃប្រើប្រាស់របស់ផ្ទះ បែរជាមានលក្ខណៈផ្ទុយទៅវិញដោយហេតុថាគ្រួសារធូរធារចាយច្រើនជាងគ្រួសារក្រីក្រសម្រាប់មុខចំណាយមួយនេះ។ នៅក្នុងឆ្នាំ២០០៩ ចំណាយលើការស្នាក់នៅតាងឲ្យ ២៤,១ភាគរយ នៃថវិការបស់គ្រួសារ ដែលស្ថិតនៅភ្នំពេញ ហើយតាងឲ្យតែ ៩,៥ ភាគរយប៉ុណ្ណោះ សម្រាប់គ្រួសារនៅទីជនបទ។ គ្រួសារនៅភ្នំពេញក៏បានចាត់ចែងចំណែកនៃថវិកាគ្រួសារក្នុងទំហំធំជាងផងដែរ សម្រាប់ចំណាយទាក់ទងនឹងសកម្មភាពកម្សាន្តនិងលម្ហែ គមនាគមន៍និងទំនាក់ទំនង និងសេវាអប់រំ។ ក៏ប៉ុន្តែ គ្រួសារនៅភ្នំពេញចាត់ចែងចំណែកនៃថវិកាគ្រួសារ ក្នុងទំហំតូចជាងសម្រាប់ចំណាយទាក់ទងនឹងសេវាសុខភាព។

## បន្ទាត់ភាពក្រីក្រថ្មី

### ទស្សនទាននៃភាពក្រីក្រ

ទស្សនទាននៃភាពក្រីក្រត្រូវបានទទួលស្គាល់ថា ជាលក្ខខណ្ឌមួយដែលក្តោបយកនូវទិដ្ឋភាពច្រើនយ៉ាង។ ចំណុចសំខាន់នៃទិដ្ឋភាពទាំងនេះ គឺថាភាពក្រីក្រត្រូវបាន

**តារាង ៣០៖ ចំណែកនៃចំណាយលើការប្រើប្រាស់សរុប បែងចែកតាមសមាសធាតុនិងតាមតំបន់ នៅកម្ពុជាក្នុងឆ្នាំ២០០៩**

| សមាសធាតុនៃអញ្ញាតចំណាយលើការប្រើប្រាស់ | ភ្នំពេញ | ទីប្រជុំជនផ្សេងទៀត | ទីជនបទផ្សេងទៀត | កម្ពុជា |
|---|---|---|---|---|
| ម្ហូបអាហារទាំងអស់ ដែលទទួលទាននៅក្នុងនិងក្រៅផ្ទះ | ៤០,២% | ៤៨,៧% | ៥៨,១% | ៥៣,២% |
| តម្លៃប្រើប្រាស់ប្រចាំខែរបស់ផ្ទះ | ២៤,១% | ១៦,៦% | ៩,៥% | ១៣,៤% |
| សេវាកម្មផ្គត់ផ្គង់លំនៅដ្ឋាន (អគ្គិសនី ទឹក ហ្គាស ។ ល។ ) | ៦,៥% | ៦,០% | ៥,៥% | ៥,៨% |
| គមនាគមន៍ និងទំនាក់ទំនង | ៩,០% | ៧,៣% | ៥,៩% | ៦,៧% |
| តម្លៃប្រើប្រាស់ប្រចាំខែនៃទំនិញអចិន្ត្រៃយ៍ | ១,៨% | ២,០% | ១,៩% | ១,៩% |
| ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន | ៤,១% | ៤,៩% | ៥,៦% | ៥,២% |
| សកម្មភាពកម្សាន្ត និងលម្ហែ | ២,២% | ១,៨% | ០,៩% | ១,៣% |
| ការអប់រំ | ៥,២% | ៣,០% | ១,៤% | ២,៤% |
| ការថែទាំសុខភាព | ១,៨% | ២,៨% | ៤,៥% | ៣,៨% |
| ផ្សេងទៀត (រាប់ទាំងទំនិញទទួលបានជារបស់) | ៥,១% | ៧,០% | ៦,៧% | ៦,៤% |
| សរុប | ១០០,០% | ១០០,០% | ១០០,០% | ១០០,០% |
| ចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃក្នុងម្នាក់ៗ (រៀល, តម្លៃបច្ចុប្បន្ន) | **១៥.៧០៩** | **១០.១៨៤** | **៦.០១៣** | **៧.៣២៥** |

**សម្គាល់៖** តម្លៃលេខទាំងអស់ ត្រូវបានគិតជា ភាគរយនៃមធ្យមភាគរបស់តម្លៃបច្ចុប្បន្ន ដែលត្រូវបានរាយការណ៍ នៅក្នុងឆ្នាំ២០០៩។

**ប្រភព៖** សូចនាករប៉ាន់ស្មាន របស់ធនាគារពិភពលោក ដោយផ្អែកលើអ.ស.ស.កឆ្នាំ២០០៩ របស់វ.ជ.ស។

គេផ្តល់និយមន័យថា ជាកង្វះខាតនូវអ្វីដែលជាតម្រូវការអប្បបរមានិងសមរម្យសម្រាប់ជីវភាពរស់នៅ។ ក្នុងន័យនេះ មានកត្តាជាច្រើនដែលចូលរួមចំណែកបង្កើតឲ្យមានភាពក្រីក្រ (ប្រសិនបើយើងកុំប្រើនិយមន័យនៃភាពក្រីក្រវិញនោះ កត្តាទាំងនេះអាចធ្វើឲ្យកម្រិតជីវភាពរស់នៅធ្លាក់ចុះយ៉ាងខ្លាំង)។ ឧទាហរណ៍នៃកត្តាមួយចំនួន ក្នុងចំណោមកត្តាទាំងនេះមានដូចជា៖ លទ្ធភាពទាបក្នុងការទទួលបានយុត្តិធម៌ ការរើសអើងយេនឌ័រ ការរើសអើងក្រុមជនជាតិ ភាពងាយរងគ្រោះ បញ្ហាអសន្តិសុខ និងសុវត្ថិភាព បញ្ហាបំពុលបរិស្ថាន ពលកម្មកុមារ ការរំលោភបំពានក្នុងគ្រួសារ ពិការភាពខាងកាយសម្បទានិងសតិ, ភាពអត់ឃ្លាននិងកង្វះជីវជាតិ កង្វះកន្លែងស្នាក់នៅគ្រប់គ្រាន់ លទ្ធភាពទាបក្នុងការទទួលបានសេវាសុខភាពនិងអប់រំ និងកត្តាផ្សេងទៀតក្នុងប្រភេទដូចគ្នានេះ។ សំណុំទិដ្ឋភាពនៃភាពក្រីក្រមានលក្ខណៈប្រែប្រួលយ៉ាងខ្លាំងទៅតាមប្រទេសនីមួយៗ។ លើសពីនេះទៀតនោះ ទិដ្ឋភាពទាំងនេះអាចមានលក្ខណៈខុសៗគ្នា នៅក្នុងប្រទេសតែមួយផងដែរ មិនមែនដោយសារកត្តាតំបន់ខុសៗគ្នានោះទេ ក៏ប៉ុន្តែគឺដោយសារកត្តាពេលវេលា។

គេបានព្យាយាមបង្កើតខ្នាតសម្រាប់វាស់ស្ទង់ភាពក្រីក្រ ចំនួនប៉ុន្មានលើកប៉ុន្មានដងមកហើយ ដោយប្រចាប់បញ្ចូលគ្នានូវទិដ្ឋភាពមួយចំនួនព្រមៗគ្នា។ ខ្នាតទាំងនោះភាគច្រើនជាទម្រង់សន្ទស្សន៍ ប៉ុន្តែពុំផ្តល់ភាពជោគជ័យគួរឲ្យកត់សម្គាល់ឡើយ។ ឫសគល់នៃបញ្ហានេះកើតចេញពីការដាក់បញ្ចូលគ្នានូវគ្រប់ទិដ្ឋភាពទាំងអស់ទៅក្នុងខ្នាតវាស់ស្ទង់តែមួយ បំណងចង់ឲ្យមានភាពងាយស្រួលក្នុងការប្រៀបធៀប (សេដ្ឋវិទូហៅ បញ្ហានេះថាជា "បញ្ហាឯកតា")។ ជាឧទាហរណ៍ គេពុំអាចញែកឲ្យច្បាស់ថាទិដ្ឋភាពណាមួយមានសារៈសំខាន់ជាង ក្នុងការឆ្លុះបញ្ចាំងអំពីភាពក្រីក្រ៖ តើពិការភាពសំខាន់ជាង ឬស្ថានភាពដែលត្រូវបានគេរំលោភបំពានសំខាន់ជាង? ឧទាហរណ៍មួយទៀតនោះគឺថា៖ តើការដែលទៅរស់នៅតំបន់ជិតទន្លេ ដែលងាយរងគ្រោះពីទឹកជំនន់ និងរស់នៅតំបន់ដែលស្ថិតនៅក្បែរកន្លែង មានអគ្រោះឧក្រិដ្ឋកម្មខ្ពស់មួយណាមានគ្រោះថ្នាក់ជាង?

ពាក់ព័ន្ធនឹងកិច្ចការងារនេះ ចំណាយលើការប្រើប្រាស់ដែលរាយការណ៍ដោយគ្រួសារ ត្រូវបានប្រើប្រាស់សម្រាប់ជាខ្នាតវាស់ស្ទង់សុខុមាលភាព។ ពោលគឺថា ខ្នាតនេះនឹងត្រូវបានប្រើសម្រាប់ប្រៀបធៀបនូវចំនួនអប្បបរមា (បន្ទាត់ភាពក្រីក្រ) ដែលអាចឲ្យគេធ្វើបំណែងចែកគ្រួសារឬបុគ្គលថា ជាអ្នកមានឬអ្នកក្រីក្របាន។ គ្រួសារណាមួយនឹងត្រូវបានគេចាត់ថ្នាក់ថាជាគ្រួសារ "ក្រីក្រខ្លាំង" ប្រសិនបើចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗ ស្ថិតនៅក្រោម "បន្ទាត់ភាពក្រីក្រខាងស្បៀងអាហារ"។ គ្រួសារមួយនឹងត្រូវបានគេចាត់ថ្នាក់ថា ជាគ្រួសារ "ក្រីក្រ" ប្រសិនបើចំណាយលើការប្រើប្រាស់ក្នុងម្នាក់ៗ ស្ថិតនៅក្រោម "បន្ទាត់ភាពក្រីក្ររួម"។ អាស្រ័យហេតុនេះ គ្រួសារដែលត្រូវបានគេចាត់ថ្នាក់ថា ជាគ្រួសារ "ក្រីក្រខ្លាំង" ក៏ជាគ្រួសារ "ក្រីក្រ" ផងដែរ ប្រសិនបើយកតាមនិយមន័យ។[30]

គេអាចបន្ថែមទិដ្ឋភាពផ្សេងៗគ្នាជាច្រើនទៀត ដែលពាក់ព័ន្ធនឹងភាពក្រីក្រ តាមរយៈការវាស់ស្ទង់តម្លៃចំណាយលើការប្រើប្រាស់ ដោយតម្លៃបិយប័ណ្ណក្នុងស្រុក ជាអាទិ៍លុយរៀល(៛)។ ហេតុដូច្នេះ ទង្វើនេះបានដោះស្រាយបញ្ហាមួយចំនួន ដែលពាក់ព័ន្ធនឹង "បញ្ហាឯកតា" ដូចបានពោលមកក្នុងកថាខណ្ឌខាងដើម (វិធីសាស្ត្របែបនេះត្រូវបានប្រើសម្រាប់វាស់ស្ទង់ចំណាយទៅលើម្ហូបអាហារ សេវាអប់រំ សេវាសុខភាព សកម្មភាពកម្សាន្ត ជាដើម)។ ក៏ប៉ុន្តែ ការធ្វើបែបនេះពុំបានរាប់បញ្ចូល ឬព្យាយាមរាប់បញ្ចូលនូវគ្រប់ទិដ្ឋភាពនៃភាពក្រីក្រនោះឡើយ។ ដើម្បីរាប់បញ្ចូលនូវទិដ្ឋភាពផ្សេងទៀតរបស់ភាពក្រីក្រ គេគួរធ្វើការវិភាគបន្ថែម ដោយផ្តោតការយកចិត្តទុកដាក់ផ្ទាល់ទៅលើទិដ្ឋភាពជាក់លាក់នោះតែម្តង។ ជាឧទាហរណ៍ ប្រសិនបើគេជឿជាក់ថា មនុស្សចាស់ងាយនឹងរងគ្រោះជាងក្រុមមនុស្សផ្សេងដទៃទៀត គេគួរសិក្សាអំពីស្ថានភាពរបស់មនុស្សដែលមានវ័យ ៦០ ឆ្នាំឬចាស់ជាងនោះ ផ្ទាល់តែម្តង។ ជាការចាំបាច់ផងដែរ គឺថា គេគួរស្វែងយល់អំពី៖ បុគ្គលិកលក្ខណៈ, ទំនាក់ទំនង ជាមួយនឹងអញ្ញាតផ្សេងទៀត (រាប់ទាំងភាពក្រីក្រផងដែរ), ប្រភពនៃប្រាក់ចំណូល, ការឧបត្ថម្ភ, និងកត្តាផ្សេងៗទៀត។

ឯកសារមួយនេះប្រើប្រាស់វិធីសាស្ត្រ "ថ្មី" ដើម្បីវាស់ស្ទង់ចំណាយលើការប្រើប្រាស់ និងបន្ទាត់ភាពក្រីក្រដោយពឹងផ្អែកទៅលើលក្ខខណ្ឌនៅក្នុងអង្កេតខាងសង្គម និងសេដ្ឋកិច្ចកម្ពុជា (អ.ស.ស.ក) ឆ្នាំ២០០៩។ លទ្ធផលទទួលបានពីវិធីសាស្ត្រថ្មីនេះនឹងត្រូវបានយកមកធ្វើការប្រៀបធៀប ជាមួយនឹងវិធីសាស្ត្រដែលត្រូវបានគេប្រើកាលពីលើកមុន នៅក្នុង អ.ស.ស.ក ឆ្នាំ១៩៩៣/៩៤។ យើងហៅវិធីសាស្ត្រដែលត្រូវបានគេប្រើកាលពីលើកមុនមកនោះ ថាជាវិធីសាស្ត្រ "ចាស់"។

## បន្ទាត់ភាពក្រីក្រ

បន្ទាត់ភាពក្រីក្រចំនួនពីរត្រូវបានប៉ាន់ស្មាន។ បន្ទាត់ភាពក្រីក្រទី១ ទាក់ទងនឹងចំណាយទៅលើក្រុមអាហារដែលរួមមាននូវបរិមាណកាឡូរីអប្បបរមាសម្រាប់បំពេញតម្រូវការខាងមុខងារជីវសាស្ត្រក្នុងការទ្រទ្រង់រាងកាយមនុស្ស។បន្ទាត់នេះត្រូវបានឲ្យឈ្មោះថា"បន្ទាត់ភាពក្រីក្រម្ហូបអាហារ (កម្រិតខ្លាំង)"។ ចំណែកឯ បន្ទាត់ភាពក្រីក្រទី២ គឺជាការរួមផ្សំបន្ទាត់ភាពក្រីក្រ ទី១ ជាមួយនឹងការចាត់ចែងចំណាយអប្បបរមាសម្រាប់ទំនិញក្រៅអំពីម្ហូបអាហារ និងសម្រាប់សេវាកម្មនានាដែលក៏សុទ្ធសឹងជាតម្រូវការមូលដ្ឋានរបស់មនុស្ស។ បន្ទាត់ភាពក្រីក្រនីមួយៗត្រូវបានបង្កើតឡើងទៅតាមបំណែងចែកផ្សេងៗគ្នានៃសណ្ឋានប្រជាជនក្នុងគោលបំណងងាយស្រួលធ្វើចំណាត់ថ្នាក់លទ្ធផល។

## បន្ទាត់ភាពក្រីក្រម្ហូបអាហារ (កម្រិតខ្លាំង)

បន្ទាត់ភាពក្រីក្រម្ហូបអាហារគឺជាចំណាយទៅលើក្រុមម្ហូបអាហារ ដែលផ្តល់នូវបរិមាណកាឡូរីជាក់លាក់មួយ។ មានសមាសធាតុចំនួន ៣ ដែលចាំបាច់សម្រាប់ប៉ាន់ស្មានបន្ទាត់ភាពក្រីក្រម្ហូបអាហារៈ តម្រូវការកាឡូរីអប្បបរមារបស់មនុស្សម្នាក់ បរិមាណឬសមាសធាតុនៃក្រុមម្ហូបអាហារ និងតម្លៃដែលត្រូវបានប្រើដើម្បីប៉ាន់ស្មានចំណាយទៅលើក្រុមម្ហូបអាហារនោះ។

## តម្រូវការកាឡូរីអប្បបរមា

បរិមាណកាឡូរីសរុបរបស់ក្រុមម្ហូបអាហារ គឺអាស្រ័យទៅលើតម្រូវការកាឡូរីអប្បបរមា ដែលត្រូវបានប៉ាន់ស្មានសម្រាប់ប្រទេសកម្ពុជា ដោយពិចារណាទៅលើអាយុ និងយេនឌ័រ។ ការប៉ាន់ស្មានបែបនេះ គឺធ្វើតាមបែបបទដែលត្រូវបានស្នើឡើងដោយអង្គការស្បៀងអាហារនិងកសិកម្ម (FAO) អង្គការសុខភាពពិភពលោក (WHO) និងអង្គការសហប្រជាជាតិ (អ.ស.ប) នៅក្នុងឆ្នាំ២០០៤[31] (ដែលត្រូវបានសម្រួលឲ្យស៊ីនឹងស្ថានភាពប្រទេសកម្ពុជា)។ ដោយហេតុថា ប្រទេសកម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍដែលមានប្រជាជនខ្លួនប្រមាណ ៨០ ភាគរយពាក់ព័ន្ធនឹងសកម្មភាពកសិកម្មនោះ តម្រូវការត្រូវបានគេប៉ាន់ស្មានថាមានកម្រិតពីមធ្យមទៅមធ្យមខ្ពស់។ ចំពោះក្រុមអាយុនិងយេនឌ័រនីមួយៗវិញ តម្រូវការកាឡូរីអប្បបរមាសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ ក៏ត្រូវបានប៉ាន់ស្មានផងដែរ។ នៅចុងបញ្ចប់ គេត្រូវគិតអំពីតម្រូវការបន្ថែមសម្រាប់ករណីស្ត្រីមានគភ៌។ **តារាង ៣៥** រាប់បញ្ចូលនូវតម្រូវការទៅតាមអាយុនិងយេនឌ័រ និងទៅតាមបំណែងចែកប្រជាជន។ ទី១ តម្រូវការគីឡូកាឡូរី (Kcal) មធ្យមត្រូវបានប៉ាន់ស្មាន (ដោយប្រើមធ្យមទម្ងន់ជាមួយនឹងចំណែកភាគរយនៃបំណែងចែកប្រជាជន) ក្នុងចំនួន ២.១៩៤,៧៥ Kcal/ថ្ងៃ។ ទី២ បើចំណែកកាឡូរីបន្ថែមត្រូវបានរាប់បញ្ចូលសម្រាប់ករណីស្ត្រីមានគភ៌ (៥,២៥ Kcal/ថ្ងៃ)នោះ តម្រូវការកាឡូរីអប្បបរមាសម្រាប់មនុស្សម្នាក់មានចំនួន ២.២០០ Kcal/ថ្ងៃ។ ដើមឡើយ សូចនាករប៉ាន់ស្មានដែលមានកម្រិតនៃសកម្មភាពខ្ពស់ជាង និងកម្រិតនៃតម្រូវការកាឡូរីខ្ពស់ជាងត្រូវបានកែសម្រួល ដើម្បីឲ្យស៊ីនឹងសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា។

## សមាសធាតុនៃក្រុមម្ហូបអាហារ

ទិន្នន័យដែលទទួលបានពី សំណៅឯកសារ ឬកំណត់ត្រា ត្រូវបានប្រើប្រាស់ ដើម្បីសម្រេចថាមុខទំនិញណាខ្លះគួរដាក់បញ្ចូលនៅក្នុងក្រុមម្ហូបអាហារ និងក្នុងបរិមាណ

ប៉ុណ្ណោះ។ ព័ត៌មានទទួលបានពីកំណត់ត្រានេះមានលក្ខណៈលម្អិតគ្រប់គ្រាន់ ដែលអាចឲ្យគេកំណត់ទម្ងន់ (សម្រាប់គណនាមធ្យមទម្ងន់) តម្លៃឯកតា និងសមាសធាតុកាឡូរី។ ដើម្បីកំណត់ក្រុមម្ហូបអាហារឲ្យបានសមស្របសម្រាប់គ្រួសារក្រីក្រ បណ្តាគ្រួសារនៃក្រុមដែលមានចំណាយលើការប្រើប្រាស់ទាបចំនួនពី ៥ ភាគរយ ទៅ ២៥ ភាគរយ ត្រូវបានជ្រើសរើស។[32] ម្ហូបអាហារ ដែលត្រូវបានប្រើប្រាស់សម្រាប់ផលិតកម្មសប្បុរសធម៌ ឬការទូទាត់កម្ចី (សង) ពុំត្រូវបានរាប់បញ្ចូលឡើយ ពោលគឺមានតែប្រភេទម្ហូបអាហារប្រើសម្រាប់ផ្គត់ផ្គង់គ្រួសារប៉ុណ្ណោះ ដែលត្រូវបានរាប់បញ្ចូល។ ទិន្នន័យប្រភេទសំណៅនេះបានផ្តល់នូវព័ត៌មានអំពីប្រភេទម្ហូបអាហារខុសៗគ្នាចំនួន ១៩៣ មុខ។

បន្ទាប់ពីលុបចោលនូវមុខទំនិញ ដែលគ្មានព័ត៌មានអំពីបរិមាណកាឡូរីច្បាស់លាស់ មុខទំនិញដែលត្រូវបានរាយការណ៍ដោយគ្រួសារចំនួនតិចជាង ៥ ភាគរយ នៃចំនួនគ្រួសារសរុប ឬ មុខទំនិញ ដែលត្រូវបានរាយការណ៍ដោយពុំមានផ្តល់នូវឯកតាច្បាស់លាស់រួចមក ចំនួនមុខទំនិញដែលត្រូវបានរាប់បញ្ចូលនៅក្នុងក្រុមម្ហូបអាហារនៅសល់ត្រឹមតែ ១១១ មុខ ប៉ុណ្ណោះ។ ចំពោះម្ហូបអាហារទាំង ១១១ មុខនេះ តួលេខចំណាយលើការប្រើប្រាស់ដែលទទួលបាន ត្រូវបានបំប្លែងឲ្យទៅជាទម្ងន់ (សម្រាប់ប្រើក្នុងការគណនាមធ្យមទម្ងន់) ហើយតម្លៃមេដ្យានក៏ត្រូវបានគណនាផងដែរដោយគិតជាគីឡូក្រាម។ តម្លៃមេដ្យានចំពោះបណ្តាមុខម្ហូបអាហារទាំង ១១១ មុខនេះក៏ត្រូវបានគណនា ទៅតាមតំបន់សំខាន់ៗទាំងបី ផងដែរ។

បរិមាណកាឡូរីសរុប នៅក្នុងក្រុមម្ហូបអាហារមួយចំនួនត្រូវបានប៉ាន់ស្មានថា មានចំនួន ១.៤៨៤ Kcal/ថ្ងៃ។[33] បរិមាណម្ហូបអាហារដែលចាំបាច់សម្រាប់បំពេញតម្រូវការកាឡូរីអប្បបរមាចំនួន ២.២០០ ត្រូវបានគណនាដោយធ្វើប្រមាណវិធីគុណរវាងបរិមាណនឹងចំនួន ១,៤៨២៤ (២.២០០/១.៤៨៤)។ បញ្ជីមុខម្ហូបអាហារ បរិមាណចាំបាច់ សម្រាប់បំពេញតម្រូវការកាឡូរី ដែលមានចំនួន ២.២០០ Kcal/ថ្ងៃ ព្រមទាំងកម្រិតកាឡូរី របស់មុខទំនិញទាំងអស់នេះ ត្រូវបានរៀបរាប់នៅក្នុង **តារាង ៣៥**។

## តម្លៃចំណាយលើក្រុមម្ហូបអាហារ

តម្លៃចំណាយលើក្រុមម្ហូបអាហារត្រូវបានប៉ាន់ស្មានដោយការធ្វើប្រមាណវិធីគុណរវាងបរិមាណទៅនឹងថ្លៃនៃមុខទំនិញ ដែលស្ថិតនៅក្នុងតំបន់ទាំងបីនៃប្រទេស។ ចំណាយបន្ថែមចំនួន ១០ ភាគរយនៃចំណាយសរុបដើមឡើយត្រូវបានលៃលកទុកសម្រាប់ផាត់ទាត់នឹងការខាតបង់ ក៏ប៉ុន្តែក្រោយមក ត្រូវបានលុបចោលទៅវិញបន្ទាប់ពីកិច្ចសន្ទនាជាមួយមន្ត្រីរដ្ឋាភិបាល។ បណ្តាថ្លៃចំណាយលើមុខម្ហូបអាហារនីមួយៗ និងចំណាយសរុបទៅលើក្រុមម្ហូបអាហារ ត្រូវបានដាក់បញ្ចូលនៅក្នុង **តារាង ៣៧**។ ចំណាយសរុបនៃក្រុមម្ហូបអាហារ ដោយគិតជាលុយរៀលក្នុងតម្លៃបច្ចុប្បន្នមានចំនួន៣.៤១១ ៛ សម្រាប់គ្រួសារនៅភ្នំពេញ, ២.៧៩១ ៛ សម្រាប់គ្រួសារនៅទីប្រជុំជនផ្សេងទៀត, និងចំនួន ២.៥៧០ ៛ សម្រាប់គ្រួសារនៅទីជនបទ (**តារាង ៣១**)។

**តារាង ៣១៖ តម្លៃចំណាយរបស់ក្រុមម្ហូបអាហារដំបូង(១១១ មុខ) និងបង្រួម(២៩ មុខ) (កម្ពុជា ឆ្នាំ២០០៩)**

| | ភ្នំពេញ | ទីប្រជុំជនផ្សេងទៀត | ទីជនបទ |
|---|---|---|---|
| តម្លៃចំណាយរបស់ក្រុមម្ហូបអាហារដំបូង (គិតជា ៛/ថ្ងៃ, ថ្លៃបច្ចុប្បន្ន) | ៣.៤០៨,៨៧ | ២.៨២០,០៨ | ២.៥៨៣,១០ |
| តម្លៃចំណាយរបស់ក្រុមម្ហូបអាហារបង្រួម (គិតជា ៛/ថ្ងៃ, ថ្លៃបច្ចុប្បន្ន) | ៣.៤៤៨,០៥ | ២.៨១៥,៧០ | ២.៥៨៣,១០ |
| គម្លាតចំណាយគិតជា៖ លុយរៀលក្នុងមួយថ្ងៃ(៛/ថ្ងៃ)/ ភាគរយ | ៣៩,១៨/១,១% | -៤,៣៨/-០,២% | ០,០០/០,០% |

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់ «ក្រុមស្រាវជ្រាវខាងភាពក្រីក្រ» ដោយប្រើប្រាស់ទិន្នន័យអ.ស.ស.កឆ្នាំ២០០៩ របស់វ.ជ.សនៃប្រទេសកម្ពុជា។

## តម្លៃចំណាយលើក្រុមម្ហូបអាហារបង្រួម

ទៅថ្ងៃអនាគត ដើម្បីប៉ាន់ស្មានតម្លៃចំណាយទៅលើក្រុមម្ហូបអាហារ គេនឹងត្រូវធ្វើការគណនាថ្លៃរបស់ក្រុមម្ហូបអាហារដដែលនោះ ដោយប្រើប្រាស់ថ្លៃថ្មី។ បរិមាណនៃក្រុមម្ហូបអាហារពុំប្រែប្រួលឡើយ ក៏ប៉ុន្តែថ្លៃរបស់មុខម្ហូបអាហារនីមួយៗមានការប្រែប្រួលទៅតាមពេលវេលា។ ទោះបីជាយ៉ាងនេះក្តី គេមិនងាយទទួលបានថ្លៃរបស់ម្ហូបអាហារ ដែលមានកម្រិតជឿជាក់ល្អនោះឡើយ ដោយសារមូលហេតុមួយចំនួន។ មូលហេតុទី១៖ គេឃើញថាមុខម្ហូបអាហារនៅក្នុងក្រុមម្ហូបអាហារមានចំនួនច្រើន ក្នុងករណីដែលក្រុមម្ហូបអាហារមានចំនួន ១១១ មុខ។ មូលហេតុទី២៖ អំឡុងពេលនៃអត្រាអតិផរណាខ្ពស់ ថ្លៃប្រចាំខែរបស់ម្ហូបអាហារមានការប្រែប្រួលខ្លាំង ដែលទាមទារឲ្យមានការយកព័ត៌មានល្អជាងមុន។ មូលហេតុទី៣៖ ផ្នែកខ្លះរបស់ក្រុមម្ហូបអាហារមានរាប់បញ្ចូលនូវមុខម្ហូបអាហារមួយចំនួន ដែលអាចបង្កការលំបាកដល់ការធ្វើបច្ចុប្បន្នកម្មទៅតាមពេលវេលា។ មូលហេតុទី៤៖ ការរឹតត្បិតថវិកានៅពេលអនាគតអាចបង្ករការលំបាកក្នុងការប្រមូលយកនូវគ្រប់ព័ត៌មានចាំបាច់ទាំងអស់ ដើម្បីធ្វើការវាយតម្លៃឲ្យបានសុក្រឹត។

ដោយឃើញមានមូលហេតុទាំងអស់នេះ គេបានបង្កើតក្រុមម្ហូបអាហារ ទី២ ដែលគេហៅឈ្មោះថា "ក្រុមម្ហូបអាហារបង្រួម"។ គោលការណ៍បន្តបន្ទាប់នេះត្រូវបានប្រើប្រាស់ក្នុងការបង្កើតក្រុមទី២នេះ៖ រក្សាតម្លៃចំណាយសរុបសម្រាប់ក្រុមម្ហូបអាហារឲ្យខិតជិតទៅនឹងសូចនាករប៉ាន់ស្មានពីខាងដើម តាមដែលអាចធ្វើបាន, រក្សាទុកនូវមុខម្ហូបអាហារ ដែលមាននិយមន័យនិងខ្នាតឯកតាច្បាស់លាស់, និងរក្សាទុកបណ្តាមុខម្ហូបអាហារដែលផ្តល់នូវកម្រិតកាឡូរីខ្ពស់ និងដែលត្រូវបានគ្រួសារប្រើប្រាស់ជាទូទៅឬនិយមប្រើប្រាស់។បន្ទាប់ពីប្រកាន់យកនូវគោលការណ៍ទាំងអស់នេះរួចមក គេឃើញថា ចំនួនមុខម្ហូបអាហារនៅសល់ត្រឹមតែ ២៩ មុខប៉ុណ្ណោះ (ប្រៀបធៀបនឹង ១១១ មុខកាលពីដំបូង)។ ទន្ទឹមនឹងនេះដែរ ក្រុមម្ហូបអាហារទី២នេះរាប់បញ្ចូលនូវបរិមាណកាឡូរីចំនួនជាង ៩៦ ភាគរយ នៃបរិមាណកាឡូរីរបស់ក្រុមម្ហូបអាហារដំបូង (ដែលមានមុខម្ហូបអាហារចំនួន ១១១ មុខ)។ រីឯតម្លៃចំណាយរបស់ក្រុមម្ហូបអាហារបង្រួមនេះ មានតម្លៃស្មើនឹង ៩១,៥ ភាគរយ នៃតម្លៃចំណាយរបស់ក្រុមម្ហូបអាហារដំបូង។

ដើម្បីរក្សាតម្លៃចំណាយឲ្យស្រដៀងតាមដែលអាចធ្វើបានទៅនឹងចំណាយរបស់ក្រុមម្ហូបអាហារដំបូងគេបានបង្កើនបរិមាណសរុបរបស់ម្ហូបអាហារទាំង ២៩ មុខ។ បន្ទាប់ពីធ្វើការកែសម្រួលជាចុងក្រោយរួចមក តម្លៃចំណាយរបស់ក្រុមម្ហូបអាហារបង្រួមមានដូចតទៅ៖ ៣.៤០៨,៨៧៛សម្រាប់គ្រួសារនៅភ្នំពេញ,២.៨២០,០៨៛ សម្រាប់គ្រួសារនៅទីប្រជុំជនផ្សេងទៀត, និង ២.៥៨៣,១០៛ សម្រាប់គ្រួសារនៅទីជនបទ (**សូមមើល តារាង ៣១**)។ គម្លាតនៃទំហំចំណាយរវាងក្រុមម្ហូបអាហារទាំងពីរនេះមានចំនួន ១,១ ភាគរយ សម្រាប់ ភ្នំពេញ និងស្មើរតែសូន្យសម្រាប់តំបន់ពីរផ្សេងទៀត គឺទីប្រជុំជនផ្សេងទៀតក្រៅពីភ្នំពេញ និងទីជនបទ។ ដោយឃើញ សារៈប្រយោជន៍អំពីភាពងាយស្រួលក្នុងការតាមដានថ្លៃរបស់មុខម្ហូបអាហារនៅក្នុងក្រុមម្ហូបអាហារបង្រួម និងអំពីផលប៉ះពាល់តិចតួចដែលកើតចេញអំពីការបង្រួមចំនួនមុខម្ហូបអាហារនេះគេក៏ផ្តល់អនុសាសន៍ឲ្យប្រើប្រាស់ក្រុមម្ហូបអាហារបង្រួមនេះ។ មុខម្ហូបអាហារទាំងអស់នៅក្នុងក្រុមម្ហូបអាហារបង្រួមត្រូវបានបង្ហាញនៅក្នុង **តារាង ៣៧**។

## បន្ទាត់ភាពក្រីក្ររួម

បន្ទាត់ភាពក្រីក្ររួមគឺជាផលបូកនៃបន្ទាត់ភាពក្រីក្រ (កម្រិតខ្លាំង) ខាងស្បៀងអាហារជាមួយនឹងចំណែកនៃចំណាយអប្បបរមាទៅលើទំនិញក្រៅពីម្ហូបអាហារ និងសេវាកម្មនានា (កន្លែងស្នាក់នៅ សម្លៀកបំពាក់ ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ការកម្សាន្ត ជាដើម)។ គេបានកំណត់ទំហំចំណាយអប្បបរមា ដោយលក្ខណៈប្រយោលពីព្រោះថា ពុំមានការទទួលស្គាល់ជាទូទៅ ទាក់ទងនឹងទំហំចំណាយអប្បបរមាសម្រាប់ទំនិញក្រៅពីម្ហូបអាហារ និងសេវាកម្មនានានៅឡើយទេ។

បច្ចេកទេសក្នុងការប៉ាន់ស្មានទំហំចំណាយសម្រាប់ទំនិញក្រៅពីម្ហូបអាហារ ត្រូវបានធ្វើឡើងដោយផ្អែកតាមទស្សនទានដែលថា បន្ទាត់ភាពក្រីក្រផ្តល់នូវតម្រូវការម្ហូបអាហារអប្បបរមា ហើយចំណាយលើការប្រើប្រាស់សម្រាប់ទំនិញបែបនោះត្រូវបានចាត់ទុកថា "សំខាន់" ឬ "ចាំបាច់"។ ចំណែកឯ ទស្សនទានទី២វិញ គឺជាគោលការណ៍ដែលថា គ្រួសារមួយអាចនឹងជំនួសចំណាយលើម្ហូបអាហារ "មូលដ្ឋាន" មួយចំនួនរបស់ខ្លួន ដោយចាយវាយទៅលើសេវាកម្ម និងទំនិញផ្សេងដទៃទៀត ល្គឹកណាសេវាកម្មនិងទំនិញផ្សេងដទៃទៀតទាំងនោះមានសារៈសំខាន់ដូចម្ហូបអាហារនោះដែរ។ និយាយមួយបែបទៀតគឺថា គ្រួសារមួយអាចចំណាយថវិការបស់ខ្លួនទៅលើទំនិញក្រៅពីម្ហូបអាហារនិងសេវាកម្មនានា តែមិនចំណាយទៅលើម្ហូបអាហារទេ បើទោះបីជាខ្លួនស្រេកឃ្លានក៏ដោយ ពីព្រោះថាទំនិញក្រៅពីម្ហូបអាហារ និងសេវាកម្មនានាទាំងអស់នោះ ពិតមានសារៈសំខាន់ដូចម្ហូបអាហារផងដែរ។[34]

បណ្តាគ្រួសារដែលមានកម្រិតចំណាយលើការប្រើប្រាស់សរុបស្ថិតនៅជុំវិញបន្ទាត់ភាពក្រីក្រខាងស្បៀងអាហារ ពុំអាចបំពេញ ឬសឹងតែពុំអាចបំពេញនូវតម្រូវការម្ហូបអាហារអប្បបរមាបានផងទេ។ ថ្វីបើយ៉ាងនេះក្តី បណ្តាគ្រួសារទាំងនេះ នៅតែលៃលកចំណែកខ្លះនៃថវិការបស់ខ្លួនសម្រាប់ចំណាយលើទំនិញក្រៅពីម្ហូបអាហារ។ ចំណាយលើទំនិញក្រៅពីម្ហូបអាហារនេះ គឺពិតជាមានសារៈសំខាន់ ដូចនឹងចំណាយលើម្ហូបអាហារផងមិនខាន ដែលជាហេតុនាំឲ្យគេហៅថាជាចំណាយ "មូលដ្ឋាន"។ នៅក្នុងអង្កេតខាងសង្គមនិងសេដ្ឋកិច្ចកម្ពុជា(អ.ស.ស.ក) ឆ្នាំ២០០៩ បណ្តាគ្រួសារចំនួន ៤៩៨ គ្រួសារចាយវាយលើការប្រើប្រាស់សរុប ក្នុងចំនួនតែ ១០ ភាគរយនៃតម្លៃបន្ទាត់ភាពក្រីក្រខាងស្បៀងអាហារប៉ុណ្ណោះ។[35] សម្រាប់ក្រុមគ្រួសារទាំងនេះ ការប្រើប្រាស់ម្ហូបអាហារមានចំនួនស្មើនឹង ៦៤ ភាគរយ នៃចំណាយលើការប្រើប្រាស់សរុបសម្រាប់ភ្នំពេញ និងចំនួន ៦៦ ភាគរយនៃចំណាយលើការប្រើប្រាស់សរុបសម្រាប់តំបន់ពីរផ្សេងទៀត។ មានន័យថា ចំណាយលើទំនិញក្រៅពីម្ហូបអាហារមានចំនួន ៣៦ និង ៣៤ភាគរយនៃចំណាយលើការប្រើប្រាស់សរុបរៀងគ្នាសម្រាប់ភ្នំពេញនិងតំបន់ពីរផ្សេងទៀត។[36]

បន្ទាត់ភាពក្រីក្រខាងស្បៀងអាហារ គួរតែតាងឲ្យ៦៤ ឬ ៦៦ ភាគរយនៃបន្ទាត់ភាពក្រីក្ររួម។ ហើយទំហំចំណាយលើទំនិញក្រៅពីម្ហូបអាហារ គួរតែស្ថិតក្នុងរង្វង់ ៣៦ ឬ ៣៤ ភាគរយនៃបន្ទាត់ភាពក្រីក្ររួម។ បើយោងតាមតម្លៃលេខរបស់បន្ទាត់ភាពក្រីក្រខាងស្បៀងអាហារដែលត្រូវបានរាយការណ៍នៅក្នុង **តារាង ១** គេឃើញថា បណ្តាបន្ទាត់ភាពក្រីក្ររួមមានតម្លៃលេខរៀងគ្នា ដូចតទៅ៖ ៥.៣២៦,៣៦៛ (ភ្នំពេញ), ៤.២៧២,៨៥៛ (ទីប្រជុំជន ផ្សេងទៀត), និង ៣.៩១៣,៧៩ ៛ (ជនបទ) (**សូមមើលតារាង ៣២**)។

**តារាង ៣២៖** បន្ទាត់ភាពក្រីក្រប្រចាំតំបន់នីមួយៗ នៅកម្ពុជា ក្នុងឆ្នាំ២០០៩ (គិតជា ៛/ថ្ងៃ, ថ្លៃបច្ចុប្បន្ន)

| | បន្ទាត់ភាពក្រីក្ររួម [ក] | ចំណាយលើម្ហូបអាហារ [ខ] | ចំណាយលើទំនិញក្រៅពីម្ហូបអាហារ [គ] |
|---|---|---|---|
| ភ្នំពេញ | ៥.៣២៦,៣៦ | ៣.៤០៨,៨៧ | ១.៩១៧,៤៩ |
| ទីប្រជុំជនផ្សេងទៀត | ៤.២៧២,៨៥ | ២.៨២០,០៨ | ១.៤៥២,៧៧ |
| ទីជនបទ | ៣.៩១៣,៧៩ | ២.៥៨៣,១០ | ១.៣៣០,៦៩ |
| **កម្ពុជា** | **៤.០៨០,៧៥** | **២.៦៨៣,៣៣** | **១.៣៩៧,៤២** |

**សម្គាល់៖** [ក]បន្ទាត់ភាពក្រីក្រម្ហូបអាហារ/០,៦៤ ឬ ០,៦៦; [ខ]ដូចគ្នានឹងតម្លៃរបស់បន្ទាត់ភាពក្រីក្រម្ហូបអាហារដែរ; [គ]បន្ទាត់ភាពក្រីក្ររួម - ចំណាយលើទំនិញក្រៅពីម្ហូបអាហារ។ តម្លៃមសម្រាប់ប្រទេសកម្ពុជា គឺយកតាមមធ្យមភាគនៃសំណាកធំ។

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់ «ក្រុមស្រាវជ្រាវខាងភាពក្រីក្រ» ដោយប្រើទិន្នន័យអ.ស.ស.កឆ្នាំ២០០៩។

## ការប្រៀបធៀបបន្ទាត់ក្រីក្រ ដែលគណនាតាមវិធីសាស្ត្រ "ចាស់" និងវិធីសាស្ត្រ "ថ្មី"

តម្លៃលេខរបស់បន្ទាត់ភាពក្រីក្រម្ហូបអាហារ ដែលគណនាតាមវិធីសាស្ត្រ "ចាស់" និងវិធីសាស្ត្រ "ថ្មី" គឺស្រដៀងគ្នា។ ពោលគឺថា សូចនាករប៉ាន់ស្មានរបស់វិធីសាស្ត្រ "ថ្មី" មានតម្លៃខ្ពស់ជាងវិធីសាស្ត្រ "ចាស់" ក្នុងចំនួន ១៤ ៛ សម្រាប់តំបន់នៅភ្នំពេញ (+០,៤ ភាគរយ), មានតម្លៃទាបជាងក្នុងចំនួន ៨៧៛ សម្រាប់តំបន់នៅទីប្រជុំជនផ្សេងទៀត (-៣,០ ភាគរយ), និងមានតម្លៃទាបជាងក្នុងចំនួន ១៣៨ ៛ សម្រាប់តំបន់នៅទីជនបទ (-៥,១ ភាគរយ) (**តារាង ៣៣**)។ ភាពខុសគ្នារវាងបន្ទាត់ភាពក្រីក្រនៃវិធីសាស្ត្រ "ចាស់" និងវិធីសាស្ត្រ "ថ្មី" កើតឡើងដោយសារកត្តាចំនួនពីរ។ កត្តាទី១៖ ការកំណត់ឡើងវិញនូវក្រុមម្ហូបអាហារឆ្នាំ ២០០៩ជាកត្តាមួយដែលអនុញ្ញាតឲ្យគ្រួសារអាចងាកទៅប្រើប្រាស់ផលិតផលម្ហូបអាហារ ដែលមានថ្លៃទាប។ កត្តាទី២៖ នៅពេលទទួលបានចំណូលច្រើនជាងមុន បណ្តាគ្រួសារបានបង្កើនចំណាយទៅលើម្ហូបអាហារ ដែលមានកាឡូរីថ្លៃៗជាងមុន។ ដោយហេតុនេះ ឥទ្ធិពលសុទ្ធរបស់វាភាគច្រើនមានលក្ខណៈវិជ្ជមានពីព្រោះថា ការចំណេញខាងប្រសិទ្ធភាព (ក្នុងការបំពេញតម្រូវការរាងកាយ) មានលក្ខណៈធំជាងបរិមាណកាឡូរីថ្លៃៗ ដែលត្រូវបានប្រើប្រាស់។

ទោះជាយ៉ាងនេះក្តី វិធីសាស្ត្រទាំងពីរផ្តល់នូវគម្លាតខុសគ្នាខ្លាំង ចំពោះចំណាយលើទំនិញក្រៅពីម្ហូបអាហារ។ តម្លៃលេខដែលផ្តល់ដោយវិធីសាស្ត្រ "ថ្មី" មានចំនួនធំជាងដល់ទៅជាងពីរដងកន្លះ បើប្រៀបធៀបនឹងតម្លៃលេខដែលគណនាតាមវិធីសាស្ត្រ "ចាស់" (**សូមមើលតារាង ៣៣**)។ សូចនាករប៉ាន់ស្មានទាំងពីរ ត្រូវបានគណនាឡើង ដោយផ្អែកតាមបរិមាណម្ហូបអាហារ និងទំនិញក្រៅពីម្ហូបអាហារដែលបណ្តាគ្រួសារនៅក្នុងសំណាកបានប្រើប្រាស់ (មេគុណអេនដែល ឬ Engels coefficient)។ ហេតុអ្វីបានជាមេគុណនិម្មិតនេះប្រែប្រួលយ៉ាងគំហុកពីចំនួន ៨៤ ភាគរយ ទៅ ៦៤ ភាគរយ បន្ទាប់ពីប្រើប្រាស់វិធីសាស្ត្រ "ថ្មី"?

មានមូលហេតុចំនួនពីរដែលបណ្តាលឲ្យចំណាយលើម្ហូបអាហារគណនាដោយវិធីសាស្ត្រ "ថ្មី" មានទំហំធំជាងចំណាយប៉ាន់ស្មានដោយវិធីសាស្ត្រ "ចាស់" គឺ៖ ឆ្នាំគោល និងបម្រែបម្រួលថ្លៃ។ បញ្ហាទាក់ទងនឹងឆ្នាំគោលកើតចេញអំពីឆ្នាំដែលគេប្រើសម្រាប់បង្កើតវិធីសាស្ត្រ "ចាស់"។ គេប្រើប្រាស់ព័ត៌មានរបស់អង្កេតគ្រួសារឆ្នាំ១៩៩៣/៩៤។ ពេលនោះ គឺជាគ្រាដែលប្រទេសកម្ពុជាមានកម្រិតភាពក្រីក្រខ្ពស់ជាង ហើយបណ្តាគ្រួសារនានាលៃលកចំណែកធំជាងសម្រាប់ចំណាយលើម្ហូបអាហារ។[37] ជាឧទាហរណ៍ ចំណែកនៃចំណាយលើទំនិញក្រៅពីម្ហូបអាហាររបស់គ្រួសារនៅទីជនបទមានចំនួន ២១,១ ភាគរយ នៅក្នុងឆ្នាំ១៩៩៣/៩៤ ប្រៀបធៀបនឹង ៣៤ ភាគរយ នៅក្នុងឆ្នាំ២០០៩។[38] ដោយសារតែកើតមានបន្លាស់ប្តូរគួរឲ្យកត់សម្គាល់នៅក្នុងសង្គមកម្ពុជា បម្រែបម្រួលនៃការលៃលកថវិកាពុំមែនជាការគួរឲ្យភ្ញាក់ផ្អើលឡើយ។ អស់រយៈពេល ១៦ ឆ្នាំ កន្លងមកហើយតាំងពីឆ្នាំ១៩៩៣/៩៤ ហើយកម្រិតប្រាក់ចំណូលបានកើនឡើងជាងទ្វេដង។

**តារាង ៣៣៖ ការប្រៀបធៀបបន្ទាត់ភាពក្រីក្រ នៅកម្ពុជា ឆ្នាំ២០០៩ (គិតជា ៛/ថ្ងៃ, ថ្លៃបច្ចុប្បន្ន)**

| តំបន់ | បន្ទាត់ភាពក្រីក្រម្ហូបអាហារ (កម្រិតខ្លាំង) | | | ចំណាយលើទំនិញក្រៅពីម្ហូបអាហារ | | |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | គម្លាត | ចាស់ | ថ្មី | គម្លាត |
| ភ្នំពេញ | ៣.៣៩៥ | ៣.៤០៩ | ១៤ | ៧៩០ | ១.៩១៧ | ១.១២៧ |
| ទីប្រជុំជនផ្សេងទៀត | ២.៩០៧ | ២.៨២០ | -៨៧ | ៥៣១ | ១.៤៥៣ | ៩២២ |
| ទីជនបទ | ២.៧២១ | ២.៥៨៣ | -១៣៨ | ៤៩២ | ១.៣៣១ | ៨៣៩ |

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់ «ក្រុមស្រាវជ្រាវខាងភាពក្រីក្រ» ដោយប្រើប្រាស់ទិន្នន័យអ.ស.ស.កឆ្នាំ២០០៩ របស់វ.ជ.សនៃប្រទេសកម្ពុជា។

មូលហេតុទី២ គឺបម្រែបម្រួលថ្លៃអំឡុងជាង ១៦ ឆ្នាំកន្លងមកនេះ តាំងពីឆ្នាំ១៩៩៣ រហូតមកដល់ឆ្នាំ២០០៩ ដែលបង្កការលំបាក ក្នុងការវាស់ស្ទង់។ ឯកតានៅក្នុងកម្រងសំណួរប្រភេទជាសំណៅឯកសារ និងថ្លៃនៅក្នុងកម្រងសំណួរថ្លៃសុទ្ធសឹងបញ្ជាក់ថា អតិផរណាទាក់ទងនឹងថ្លៃទំនិញក្រៅពីម្ហូបអាហារមានកម្រិតទាបជាងអតិផរណាទាក់ទងនឹងថ្លៃម្ហូបអាហារ នៅគ្រប់តំបន់ទាំងបី និងនៅពេញមួយអំឡុងពេលនោះ។ នៅក្នុងឆ្នាំ ២០០៩ វិធីសាស្ត្រ "ចាស់" ថែមទាំងផ្ដល់នូវតម្លៃលេខ នៃចំណាយលើទំនិញក្រៅពីម្ហូបអាហារ ក្នុងទំហំតូចជាងឆ្នាំកន្លងទៅ។ ឧទាហរណ៍ ចំណែកនៃចំណាយលើទំនិញក្រៅពីម្ហូបអាហាររបស់គ្រួសារនៅទីជនបទមានចំនួន ១៥,៨ភាគរយ។

មូលហេតុដែលធ្វើឲ្យមានគម្លាតខុសគ្នានេះមានលក្ខណៈច្បាស់លាស់ហើយ ក៏ប៉ុន្តែ តើគេគួរប្រើប្រាស់វិធីសាស្ត្រណាមួយ? ចម្លើយនៃសំណួរមួយនេះត្រូវបានបកស្រាយដូចតទៅ។ បើឆ្នាំនៅក្នុងសំណួរកាន់តែខិតជិតឆ្នាំ ១៩៩៣/៩៤ នោះ ការគណនាតាមវិធីសាស្ត្រចាស់កាន់តែសុក្រឹត។ បើឆ្នាំនៅក្នុងសំណួរកាន់តែខិតជិតឆ្នាំ ២០០៩ នោះ ការគណនាតាមវិធីសាស្ត្រថ្មីកាន់តែសុក្រឹត។ លើសពីនេះទៀត តាមរយៈការប្រើប្រាស់សូចនាករប៉ាន់ស្មានដែលគណនាតាមវិធីសាស្ត្រទាំងពីរ ក្នុងចន្លោះគ្រាណាមួយ គេអាចប្រៀបធៀបនិន្នាការគន្លង និងកត្តានានាទាក់ទងនឹងភាពក្រីក្រ។ ប្រសិនបើគម្លាតខុសគ្នា គឺគ្រាន់តែជាបញ្ហានៃតម្លៃលេខនោះ ការវិភាគអំពីភាពក្រីក្រនិងចំណេះដឹងទទួលបានពីការវិភាគនេះភាគច្រើន នឹងមិនផ្លាស់ប្ដូរឡើយ។

## លទ្ធផលនៃការវិភាគភាពក្រីក្រឆ្នាំ២០០៩

ដោយប្រើប្រាស់វិធីសាស្ត្រ "ថ្មី" ភាពក្រីក្រកម្រិតខ្លាំងនៅកម្ពុជាត្រូវបានប៉ាន់ស្មានថា មានអត្រា ៥,៣ ភាគរយ ដែលអត្រានេះហាក់មានកម្រិតទាបជាងបន្តិច នៅក្នុងតំបន់ទីប្រជុំជន (០,៦ ភាគរយសម្រាប់ភ្នំពេញ និង២,០ ភាគរយសម្រាប់ទីប្រជុំជនផ្សេងទៀត) ប៉ុន្តែហាក់មានកម្រិតខ្ពស់ជាងបន្តិច នៅក្នុងតំបន់ទីជនបទ គឺ ៦,៣ ភាគរយ។ សូចនាករប៉ាន់ស្មានតាមវិធីសាស្ត្រ "ចាស់" ផ្ដល់នូវអត្រាភាពក្រីក្រ (កម្រិតខ្លាំង) ខាងស្បៀងអាហារ ដោយមានតម្លៃលេខចំនួន ២,៤ ពិន្ទុ ភាគរយសម្រាប់គ្រប់តំបន់ទាំងអស់ ឬតំបន់នីមួយៗ (**តារាង ៣៤**)។

អត្រាភាពក្រីក្ររួមដែលគណនាតាមវិធីសាស្ត្រ "ថ្មី" មានចំនួនខ្ពស់ជាងខ្លាំង ដោយសារតែចំណាយលើទំនិញក្រៅពីម្ហូបអាហារមានទំហំធំជាងខ្លាំង។ អត្រារួមនេះត្រូវបានប៉ាន់ស្មានថា មានចំនួន ២៣,៩ ភាគរយដោយ៤,៣ ភាគរយសម្រាប់តំបន់នៅភ្នំពេញ ១២,៧ភាគរយសម្រាប់តំបន់នៅទីប្រជុំជនផ្សេងទៀត និង ២៧,៥ ភាគរយសម្រាប់តំបន់នៅទីជនបទ (**តារាង ៣៤**)។ បើប្រើប្រាស់វិធីសាស្ត្រ "ចាស់" វិញនោះ អត្រាភាពក្រីក្ររួមនៅកម្ពុជាត្រូវបានប៉ាន់ស្មានថា មានចំនួន ១៤,៦ ភាគរយ។

**តារាង ៣៤៖ អត្រាភាពក្រីក្រនៅកម្ពុជា ក្នុងឆ្នាំ២០០៩**

| តំបន់ | បន្ទាត់ភាពក្រីក្រម្ហូបអាហារ (កម្រិតខ្លាំង) | | | អត្រាភាពក្រីក្ររួម | | |
|---|---|---|---|---|---|---|
| | ចាស់ | ថ្មី | គម្លាត | ចាស់ | ថ្មី | គម្លាត |
| ភ្នំពេញ | ៣.៣៩៥ | ៣.៤០៩ | ១៤ | ៧៩០ | ១.៩១៧ | ១.១២៧ |
| ទីប្រជុំជនផ្សេងទៀត | ២.៩០៧ | ២.៨២០ | -៨៧ | ៥៣១ | ១.៤៥៣ | ៩២២ |
| ទីជនបទ | ២.៧២១ | ២.៥៨៣ | -១៣៨ | ៤៩២ | ១.៣៣១ | ៨៣៩ |
| កម្ពុជា | ៧,៤% | ៥,៣% | -២,១% | ១៤,៦% | ២៣,៩% | ៩,៣% |

**ប្រភព៖** សូចនាករប៉ាន់ស្មានរបស់ «ក្រុមស្រាវជ្រាវខាងភាពក្រីក្រ» ដោយប្រើប្រាស់ទិន្នន័យអ.ស.ស.កឆ្នាំ២០០៩ របស់វ.ជ.សនៃប្រទេសកម្ពុជា។

## តារាង ៣៥៖ តម្រូវការកាឡូរី និងអត្រាប្រជាជន បែងចែកតាមអាយុនិងយេនឌ័រ នៅកម្ពុជា ឆ្នាំ២០០៩

| ប្រុស | | | | ស្រី | | | |
|---|---|---|---|---|---|---|---|
| អាយុ(ឆ្នាំ) | កាឡូរី/ថ្ងៃ | %ប្រជាជន | កាឡូរី*ភាគរយ | អាយុ(ឆ្នាំ) | កាឡូរី/ថ្ងៃ | %ប្រជាជន | កាឡូរី*ភាគរយ |
| < ១ | ៦៧១ | ១,២% | ៨,០ | < ១ | ៦១៥ | ១,១% | ៦,៥ |
| ១ - ១,៩ | ៩៤២ | ១,០% | ៩,២ | ១ - ១,៩ | ៨៤៣ | ០,៩% | ៧,៩ |
| ២ - ២,៩ | ១.១១៥ | ១,០% | ១០,៩ | ២ - ២,៩ | ១.០៤១ | ១,០% | ១០,០ |
| ៣ - ៣,៩ | ១.២៣៩ | ១,១% | ១៣,១ | ៣ - ៣,៩ | ១.១៤០ | ០,៩% | ១០,៣ |
| ៤ - ៤,៩ | ១.៣៣៨ | ១,០% | ១៣,០ | ៤ - ៤,៩ | ១.២៣៩ | ០,៩% | ១០,៩ |
| ៥ - ៥,៩ | ១.៤៦២ | ១,០% | ១៥,៣ | ៥ - ៥,៩ | ១.៣១៣ | ១,១% | ១៤,២ |
| ៦ - ៦,៩ | ១.៥៦១ | ១,២% | ១៨,៧ | ៦ - ៦,៩ | ១.៤១៣ | ១,១% | ១៥,២ |
| ៧ - ៧,៩ | ១.៦៨៥ | ១,១% | ១៨,៨ | ៧ - ៧,៩ | ១.៥៣៦ | ១,០% | ១៥,៩ |
| ៨ - ៨,៩ | ១.៨០៩ | ១,១% | ១៩,៣ | ៨ - ៨,៩ | ១.៦៨៥ | ១,០% | ១៧,៦ |
| ៩ - ៩,៩ | ១.៩៥៨ | ១,២% | ២២,៥ | ៩ - ៩,៩ | ១.៨៣៤ | ១,២% | ២១,២ |
| ១០ - ១០,៩ | ២.១៣១ | ១,២% | ២៥,១ | ១០ - ១០,៩ | ១.៩៨៣ | ១,១% | ២១,៩ |
| ១១ - ១១,៩ | ២.៣២៩ | ១,១% | ២៤,៧ | ១១ - ១១,៩ | ២.១៣១ | ១,១% | ២២,៥ |
| ១២ - ១២,៩ | ២.៥២៨ | ១,១% | ២៨,២ | ១២ - ១២,៩ | ២.២៥៥ | ១,១% | ២៤,៣ |
| ១៣ - ១៣,៩ | ២.៧៥១ | ១,៣% | ៣៤,៥ | ១៣ - ១៣,៩ | ២.៣៥៤ | ១,១% | ២៦,៩ |
| ១៤ - ១៤,៩ | ២.៩៧៤ | ១,២% | ៣៦,២ | ១៤ - ១៤,៩ | ២.៤២៩ | ១,១% | ២៦,៨ |
| ១៥ - ១៥,៩ | ៣.១៤៧ | ១,៤% | ៤២,៧ | ១៥ - ១៥,៩ | ២.៤៧៨ | ១,១% | ២៧,៨ |
| ១៦ - ១៦,៩ | ៣.២៩៦ | ១,៣% | ៤២,៤ | ១៦ - ១៦,៩ | ២.៤៧៨ | ១,២% | ២៩,១ |
| ១៧ - ១៧,៩ | ៣.៣៧០ | ១,២% | ៤០,២ | ១៧ - ១៧,៩ | ២.៤៧៨ | ១,១% | ២៨,៣ |
| ១៨ - ១៨,៩ | ២.៦៨១ | ១,៣% | ៣៣,៩ | ១៨ - ១៨,៩ | ២.០២០ | ១,២% | ២៤,៥ |
| ១៩ - ១៩,៩ | ២.៦៦៤ | ១,១% | ២៨,៥ | ១៩ - ១៩,៩ | ២.០០៤ | ១,១% | ២២,១ |
| ២០ - ២៤,៩ | ២.៧៣១ | ៥,១% | ១៣៨,៧ | ២០ - ២៤,៩ | ២.០៣៩ | ៥,២% | ១០៦,១ |
| ២៥ - ២៩,៩ | ២.៧៣៣ | ៤,៦% | ១២៦,២ | ២៥ - ២៩,៩ | ២.០៤០ | ៥,១% | ១០៣,៥ |
| ៣០ - ៣៤,៩ | ២.៧៣៧ | ២,៦% | ៧១,៥ | ៣០ - ៣៤,៩ | ២.២០៩ | ២,៨% | ៦២,៨ |
| ៣៥ - ៣៩,៩ | ២.៧៤២ | ២,៩% | ៧៩,៩ | ៣៥ - ៣៩,៩ | ២.២១២ | ៣,២% | ៦៩,៨ |
| ៤០ - ៤៤,៩ | ២.៧២៦ | ២,៤% | ៦៥,៤ | ៤០ - ៤៤,៩ | ២.២០២ | ២,៨% | ៦១,៤ |
| ៤៥ - ៤៩,៩ | ២.៧១១ | ២,៤% | ៦៤,៨ | ៤៥ - ៤៩,៩ | ២.១៩៣ | ២,៧% | ៦០,១ |
| ៥០ - ៥៤,៩ | ២.៧១៨ | ១,៦% | ៤៣,១ | ៥០ - ៥៤,៩ | ២.១៩៧ | ២,៤% | ៥២,០ |
| ៥៥ - ៥៩,៩ | ២.៧៣០ | ១,៣% | ៣៥,៨ | ៥៥ - ៥៩,៩ | ២.២០៥ | ១,៩% | ៤២,២ |
| ៦០ - ៦៤,៩ | ២.២៣៤ | ១,១% | ២៤,៤ | ៦០ - ៦៤,៩ | ១.៩៣៨ | ១,៣% | ២៦,១ |
| ៦៥ - ៦៩,៩ | ២.២៤១ | ០,៧% | ១៥,៦ | ៦៥ - ៦៩,៩ | ១.៩៤២ | ០,៩% | ១៨,១ |
| ៧០+ | ២.២៤១ | ១,១% | ២៥,៥ | ៧០+ | ១.៩៤២ | ១,៧% | ៣២,៦ |
| | | ៤៨,៦% | **១.១៧៦,១៤** | | | ៥១,៤% | **១.០១៨,៦១** |

មធ្យមទម្ងន់ = ផលបូក (កាឡូរី/ថ្ងៃ* %ប្រជាជន) = ១.១៧៦,១៤ + ១.០១៨,៦១ = ២.១៩៤,៧៥ បូកនឹង ចំណាយលែលកសម្រាប់ពេលមានផ្ទៃពោះ ៖ អត្រាកំណើតនៃ ០,០២៥ * តម្រូវការកាឡូរីបន្ថែមចំនួន ២១០ = ៥,២៥។ សរុប = ២.១៩៤,៧៥ + ៥,២៥ = **២.២០០,០០**។

**តារាង ៣៦៖** បញ្ជីម្ហូបអាហារ មាតិកាកាឡូរី តម្លៃ និងថ្លៃដើមកាត់បន្ថយក្នុងកន្ត្រកម្ហូបអាហារ ឆ្នាំ២០០៩

| | គីឡូកាឡូរី ក្នុង ១០០ក្រាម | មិនត្រូវការ | ក្រាម/ថ្ងៃ | គីឡូកាឡូរី/ថ្ងៃ | តម្លៃក្នុងមួយគីឡូក្រាម | | | តម្លៃគិតជាប្រាក់រៀល/ថ្ងៃ | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | ភ្នំពេញ | ទីប្រជុំជន | ទីជនបទ | ភ្នំពេញ | ទីប្រជុំជន | ទីជនបទ |
| អង្ករលេខ ១ | ៣៩៣.៥ | 0% | ៥៤.៥ | ១៩៧.៦០ | ២,000 | ២,000 | ២,000 | ១០៨.៩៩ | ១០៨.៩៩ | ១០៨.៩៩ |
| អង្ករលេខ ២ | ៣៥៦.៣ | 0% | ៤២៨.៥ | ១៥២៦.៦០ | ២,000 | ១,៨០០ | ១,៥០០ | ៨៥៦.៩១ | ៧៧១.២២ | ៦៤២.៦៩ |
| អង្ករប្រភេទដទៃទៀត | ៣៥៣.៥ | 0% | ៣.៨ | ១៣.៦០ | ២,២០០ | ២,២០០ | ២,១១៧ | ៨.៤៥ | ៨.៤៥ | ៨.១៣ |
| ផ្លែពោត | ១៥៩.៩ | ៦0% | ២.១ | ១.៣០ | ៣,៣៣៣ | ២,៥០០ | ១,៥០០ | ៦.៩១ | ៥.១៨ | ៣.១១ |
| នំប៉័ង | ២៦៣.៨ | 0% | ០.៤ | ១.១០ | ៧,៥០០ | ៧,៥០០ | ៦,០០០ | ៣.០២ | ៣.០២ | ២.៤២ |
| មីកញ្ចប់ថៃ | ៣៧៣.៧ | 0% | ០.៥ | ១.៧០ | ១០,០០០ | ៧,៦៩២ | ៧,៦៩២ | ៤.៤៩ | ៣.៤៥ | ៣.៤៥ |
| មីប្រភេទដទៃទៀត | ៣៤៣.៦ | 0% | ១.៣ | ៤.៥០ | ៨,០០០ | ៦,៦៦៧ | ៦,៦៦៧ | ១០.៥៩ | ៨.៨២ | ៨.៨២ |
| នំ | ៣៧០.២ | 0% | ០.៤ | ១.៦០ | ១០,០០០ | ៨,៣៣៣ | ១០,០០០ | ៤.១៩ | ៣.៤៩ | ៤.១៩ |
| នំបឺស្គីតប្រភេទដទៃទៀត | ៤៦០.២ | 0% | ៩.៥ | ៤៣.៨០ | ៥,០០០ | ៣,៣៣៣ | ៣,៥០០ | ៤៧.៥៨ | ៣១.៧២ | ៣៣.៣០ |
| នំអង្ករអាកោ | ២៣៤.១ | 0% | ០.៨ | ១.៨០ | ២,៦៣៣ | ៣,០០០ | ២,៥០០ | ២.០៦ | ២.៣៤ | ១.៩៥ |
| នំក្នុងស្រុកប្រភេទដទៃទៀត | ៣៧៦.៧ | 0% | ១.៨ | ៦.៦០ | ៣,៣៣៣ | ៣,៣៣៣ | ៣,០០០ | ៥.៨២ | ៥.៨២ | ៥.២៤ |
| ធញ្ញជាតិបានកែច្នៃ | ៣៦២.៨ | 0% | ០.៤ | ១.៦០ | ៥,០០០ | ៣,៣៣៣ | ៣,១៦៧ | ២.១៧ | ១.៤៤ | ១.៣៧ |
| សាច់ជ្រូកសុទ្ធ | ៣៧៤.៩ | ១៨% | ៥.៥ | ១៧.០០ | ១៥,០០០ | ១៤,០០០ | ១៥,០០០ | ៨៣.០០ | ៧៧.៤៦ | ៨៣.០០ |
| សាច់ជ្រូកមានខ្លាញ់ | ៤៥៦.៨ | ១២% | ១៣.០ | ៥២.៤០ | ១៥,០០០ | ១២,០០០ | ១២,០០០ | ១៩៥.៣៨ | ១៥៦.៣០ | ១៥៦.៣០ |
| ឆ្អឹងជ្រូក | ០.០ | ៨៥% | ៤.៦ | ០.០០ | ១៤,០០០ | ១០,០០០ | ១០,០០០ | ៦៣.៧៤ | ៤៥.៥៣ | ៤៥.៥៣ |
| សាច់គោ | ១៣២.៤ | ២០% | ៤.៣ | ៤.៥០ | ២០,០០០ | ១៥,០០០ | ១៥,០០០ | ៨៥.២៥ | ៦៣.៩៤ | ៦៣.៩៤ |
| ឆ្អឹងគោ | ០.០ | ៨៥% | ១.៦ | ០.០០ | ១២,០០០ | ៧,០០០ | ៧,១៤៣ | ១៩.៥៤ | ១១.៤០ | ១១.៦៣ |
| សាច់មាន់ | ១៥២.៦ | ៤៥% | ៥.៩ | ៤.៩០ | ១៦,០០០ | ១០,០០០ | ១២,០០០ | ៩៣.៩០ | ៥៨.៦៩ | ៧០.៤៣ |
| សាច់ទា | ២៣៣.៤ | 0% | ០.៩ | ២.១០ | ១២,០០០ | ៨,៨៣៣ | ៨,០០០ | ១០.៥៧ | ៧.៧៨ | ៧.០៥ |
| សាច់បសុបក្សីប្រភេទដទៃទៀត | ១៧៦.០ | ២៥% | ៦.១ | ៨.០០ | ៧,២០០ | ៦,០០០ | ៥,០០០ | ៤៣.៥៣ | ៣៦.២៧ | ៣០.២៣ |
| សាច់កែច្នៃក្នុងស្រុក | ២០៤.៨ | 0% | ០.៤ | ០.៩០ | ១៦,០០០ | ១២,០០០ | ១២,០០០ | ៦.៨៩ | ៥.១៦ | ៥.១៦ |
| ត្រីរស់ស្រស់ធំ | ៩៩.២ | ៥០% | ២.២ | ១.១០ | ១០,០០០ | ៨,០០០ | ៨,០០០ | ២១.៥៥ | ១៧.២៤ | ១៧.២៤ |
| ត្រីផ្ទក់ស្រស់ | ៩៩.២ | ៥០% | ១៥.៥ | ៧.៧០ | ១០,០០០ | ៨,០០០ | ៨,០០០ | ១៥៤.៤៩ | ១២៣.៥៩ | ១២៣.៥៩ |
| ត្រីឆ្លាញ | ៨៧.៥ | ៤៣% | ០.៧ | ០.៣០ | ៧,០០០ | ៧,០០០ | ៦,៦៦៧ | ៤.៥៦ | ៤.៥៦ | ៤.៣៤ |
| ត្រីអណ្តែង | ៩២.៣ | ៥១% | ៩.៩ | ៤.៥០ | ៩,០០០ | ៧,០០០ | ៧,០០០ | ៨៩.២៥ | ៦៩.៤១ | ៦៩.៤១ |

**តារាង ៣៦៖ បញ្ជីម្ហូបអាហារ មាតិកាកាឡូរី តម្លៃ និងថ្លៃដើមកាត់បន្ថយក្នុងកន្ត្រកម្ហូបអាហារ ឆ្នាំ២០០៩**

| | គីឡូកាឡូរី ក្នុង ១០០ក្រាម | មិនត្រូវការ | ក្រាម/ថ្ងៃ | គីឡូកាឡូរី/ថ្ងៃ | តម្លៃក្នុងមួយគីឡូក្រាម | | | តម្លៃគិតជាប្រាក់រៀល/ថ្ងៃ | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | ភ្នំពេញ | ទីប្រជុំជន | ទីជនបទ | ភ្នំពេញ | ទីប្រជុំជន | ទីជនបទ |
| ត្រីសមុទ្រតូច | ៧៩.៨ | ៦៣% | ២.៦ | ០.៨០ | ៨,០០០ | ៥,០០០ | ៤,៥០០ | ២០.៩៨ | ១៣.១១ | ១១.៨០ |
| ត្រីប្រាចិញ្ចឹម | ១៣៦.៨ | ៣១% | ៥៨.៨ | ៥៥.៥០ | ៨,០០០ | ៦,០០០ | ៥,០០០ | ៤៧០.០២ | ៣៥២.៥១ | ២៩៣.៧៦ |
| ក្តាមសេះកំពត | ១០៤.៤ | ៦២% | ៦.០ | ២.៤០ | ៣,៥០០ | ២,០០០ | ១,៥០០ | ២១.១៣ | ១២.០៨ | ៩.០៦ |
| គ្រឿងសមុទ្រដទៃទៀត | ៩៤.៣ | ៤៥% | ៦.៦ | ៣.៤០ | ៥,០០០ | ៤,០០០ | ៣,០០០ | ៣២.៩៧ | ២៦.៣៨ | ១៩.៧៨ |
| ត្រីឆ្អើត្រីរៀលតូច | ២១២.៣ | ០% | ១.២ | ២.៥០ | ១០,០០០ | ១០,០០០ | ១០,០០០ | ១១.៧៣ | ១១.៧៣ | ១១.៧៣ |
| ប្រហុកត្រីរៀល | ១០២.១ | ០% | ៩.៩ | ១០.១០ | ៧,០០០ | ៦,០០០ | ៦,០០០ | ៦៩.៣៣ | ៥៩.៤២ | ៥៩.៤២ |
| ត្រីងៀត ត្រីឆ្អើរធំ | ១៩២.៨ | ២៤% | ៣.៨ | ៥.៥០ | ១៣,៣៣៣ | ៩,០០០ | ៨,០០០ | ៥០.៣៦ | ៣៣.៩៩ | ៣០.២២ |
| ត្រីខប្រអប់ស្ត្រី ៣ នាក់ ថៃ | ១៣៨.១ | ០% | ១.៩ | ២.៦០ | ៩,២៨៦ | ៦,៦៦៧ | ៨,៥០០ | ១៧.៤២ | ១២.៥១ | ១៥.៩៥ |
| បង្គារក្រៀមធុមមធ្យម | ៣១៦.៤ | ០% | ០.២ | ០.៧០ | ១០,០០០ | ១៥,០០០ | ១៦,៦៦៧ | ២.១៦ | ៣.២៤ | ៣.៦០ |
| ស៊ុតទាស្រស់ | ១៨២.៨ | ១២% | ១០.៦ | ១៧.០០ | ៥,៨៨២ | ៥,៨៨២ | ៥,៨៨២ | ៦២.៣៤ | ៦២.៣៤ | ៦២.៣៤ |
| ស៊ុតស្រស់ | ១២៨.១ | ៩% | ០.២ | ០.២០ | ១០,០០០ | ១០,០០០ | ១០,០០០ | ១.៥៥ | ១.៥៥ | ១.៥៥ |
| ពងទាប្រៃ | ១៨៩.៧ | ១២% | ០.២ | ០.៤០ | ៧,៤០៧ | ៧,៤០៧ | ៧,៤០៧ | ១.៧៨ | ១.៧៨ | ១.៧៨ |
| ប្រេងចំអិន | ៩០០.០ | ០% | ០.៨ | ៧.០០ | ៦,០០០ | ៥,០០០ | ៦,០០០ | ៤.៦៩ | ៣.៩១ | ៤.៦៩ |
| ប្រេងចំអិន ប្រេងរុក្ខជាតិ | ៩០០.០ | ០% | ២.៥ | ២២.៧០ | ៥,៤៩៥ | ៥,៤៩៥ | ៦,០០០ | ១៣.៨៥ | ១៣.៨៥ | ១៥.១២ |
| ខ្លាញ់ជ្រូក | ៤២៧.៥ | ០% | ០.៩ | ៤.០០ | ៦,០០០ | ៦,០០០ | ៦,០០០ | ៥.៦០ | ៥.៦០ | ៥.៦០ |
| ចេកណាំវ៉ាទំហំមធ្យម | ៩៣.៦ | ៣៤% | ៩.៦ | ៥.៩០ | ១,៦០០ | ១,៥០០ | ១,០០០ | ១៥.២៨ | ១៤.៣២ | ៩.៥៥ |
| ម្នាស់ទុំវៀតណាម | ៤៨.១ | ៤៥% | ១.៤ | ០.៤០ | ២,០០០ | ១,៤២៩ | ១,៦០០ | ២.៨៣ | ២.០២ | ២.២៧ |
| ស្វាយ | ៧៩.២ | ២៨% | ៥.០ | ២.៨០ | ២,០០០ | ២,០០០ | ១,៥០០ | ៩.៩២ | ៩.៩២ | ៧.៤៤ |
| ក្រូចឆ្មា ទំហំមធ្យម | ៤៦.៨ | ២៣% | ០.៧ | ០.៣០ | ៣,០០០ | ៥,០០០ | ២,៥០០ | ២.២១ | ៣.៦៨ | ១.៨៤ |
| សារម៉ាវ វៀតណាម | ៦៨.៥ | ៥៦% | ១.៨ | ០.៥០ | ២,៥០០ | ២,៥០០ | ១,៥០០ | ៤.៥៣ | ៤.៥៣ | ២.៧២ |
| មៀន | ៧០.៨ | ៥០% | ១.១ | ០.៤០ | ៤,៥០០ | ៤,០០០ | ៤,០០០ | ៥.០៨ | ៤.៥២ | ៤.៥២ |
| ល្ហុងទុំ ទំហំមធ្យម | ៣៩.៥ | ២៨% | ៨.៩ | ២.៥០ | ១,៥០០ | ១,០០០ | ១,០០០ | ១៣.៤១ | ៨.៩៤ | ៨.៩៤ |
| ឪឡឹក ទំហំមធ្យម | ២៤.៣ | ៣៧% | ៥.៨ | ០.៩០ | ១,៥០០ | ១,០០០ | ១,០០០ | ៨.៧៣ | ៥.៨២ | ៥.៨២ |
| ត្រសក់ផ្អែម | ៣៥.៩ | ៤៩% | ១.១ | ០.២០ | ១,០០០ | ១,០០០ | ១,០០០ | ១.១៤ | ១.១៤ | ១.១៤ |
| ក្រូចទៀបបាង | ៤៧.៨ | ៦២% | ០.៨ | ០.២០ | ៣,០០០ | ៣,០០០ | ៣,០០០ | ២.៥៣ | ២.៥៣ | ២.៥៣ |

## តារាង ៣៦៖ បញ្ជីម្ហូបអាហារ មាតិកាកាឡូរី តម្លៃ និងថ្លៃដើមកាត់បន្ថយក្នុងកន្ត្រកម្ហូបអាហារ ឆ្នាំ២០០៩

